ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ [illegible] ការផ្សះផ្សា និងខ្មែរក្រហម

◆ [illegible] ខ្មែរក្រហម

[illegible]

លេខ[illegible] ខែសីហា ឆ្នាំ[illegible]

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២០ ខែសីហា ឆ្នាំ២០០១

## មាតិកា

◆ សំបុត្រៈ អត្ថន័យជាប្រវត្តិសាស្ត្រនៃច្បាប់..........១

**ផ្នែកឯកសារ**

◆ ប្រជុំអចិន្ត្រៃយ៍ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥..........២

◆ សម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជា..........៦

◆ សេចក្ដីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជា..........៨

◆ ៥ឆ្នាំនៃការធ្វើផែនទីរណ្ដៅសាកសព គុក និងបូជនីយដ្ឋាន..........១៣

◆ ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍..........១៤

◆ ហួត សម្បត្តិ..........១៦

◆ ៣០ ថ្មេរឡាមប្ដូរនិងមនោសញ្ចេតនាគ្រួសារ..........២២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ សម្លេងពីមន្ទីរស-២១..........២៤

◆ ការគុំកួន ការផ្សះផ្សា និងខ្មែរក្រហម..........៣០

**ផ្នែកច្បាប់**

◆ ឧក្រិដ្ឋកម្មសំខាន់ៗក្រោមច្បាប់កម្ពុជាមុនឆ្នាំ១៩៧៥..........៣៨

◆ តម្លៃនៃភ័ស្តុតាង..........៤១

**វេទិកាពិភាក្សាសាធារណៈ**

◆ ជនកុម្មុយនិស្តខ្មែរក្រហម និងវៀតណាម..........៤៤

◆ របាយការណ៍ៈខ្មែរក្រហម៧រូបប្រឈមមុខនឹងការកាត់ទោស..........៤៨

◆ រឿងរ៉ាវនៃការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស..........៤៩

◆ ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា..........៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ សុបិនឬការពិត?..........៥៨

**សិល្បៈខ្មែរក្រហម**

◆ **កំណាព្យៈ** ប្ដេជ្ញាប្រែក្លាយមាតុភូមិកម្ពុជាដ៏ឧត្តម..........ក្របក្រោយ



កូនអង្គការ

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***វាគ្មិនលេខនេះ:*** ដេវីត ឆេនដល័រ, ចាសិន អាប្រាម, ស៊ីវ រ៉ាតន័រ, ចន ឆរឆីអារី, ប៉ែន យៀរនិន, ថូម៉ាស់ ហាម៉ាប៊ឹក, មិទ្រី មូសយ៉ាកូវ, អាឡិច ហ៊ីនតុន, វ៉ាន់ថាន់ ពៅដារ៉ា, លាង ស៊ីដនី, ផេង ពង្សរ៉ាស៊ី ***អ្នកនិពន្ធនិងស្រាវជ្រាវ:*** សាន់ កល្យាណ, លី សុផល, ដួង សុភារិទ្ធ ***ជំនួយការនិពន្ធនាយក:*** អែម សុខឃីម ***និពន្ធនាយករងទី១:*** ផាត កុសល ***និពន្ធនាយករងទី២:*** សឹម សុរិយ៉ា ***អ្នកបកប្រែ:*** សួ ប៊ុនស៊ូ ***និពន្ធនាយកទូទៅ:*** ឆាំង យុ ***ក្រាហ្វិកកុំព្យូទ័រ:*** ស៊ីម សុភ័ក្ត្រ ***គ្រប់គ្រងការចែកផ្សាយ:*** ទ្រី សុភក្តិ

*សំបុត្រ:*

# អត្ថន័យជាប្រវត្តិសាស្ត្រនៃច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម

នៅថ្ងៃសុក្រ ទី១០ ខែសីហា ឆ្នាំ២០០១ ព្រះមហាក្សត្រកម្ពុជាព្រះបាទសម្តេចនរោត្តម សីហនុ បានឡាយព្រះហស្តលេខាលើច្បាប់ដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

ការឡាយព្រះហស្តលេខាលើច្បាប់នេះមានអត្ថន័យសំខាន់៣ជាប្រវត្តិសាស្ត្រគឺ ១) នេះគឺជាលើកដំបូងបង្អស់នៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាដែលមានច្បាប់បង្កើតឲ្យមាននូវអង្គតុលាការមួយដើម្បីធ្វើការវិនិច្ឆ័យទោសអ្នកដឹកនាំថ្នាក់ជាតិ ។ អង្គតុលាការនេះអាចជាគំរូដើម្បីដោះស្រាយរាល់វិបត្តិនានាដែលបង្ក និងប្រព្រឹត្តឡើងដោយអ្នកដឹកនាំជាតិនៅថ្ងៃអនាគត ២) សិទ្ធរស់រានមានជីវិតដែលបានរំលោភនៅក្នុងអតីតកាលត្រូវបានលើកកម្ពស់និងការពារ ហើយដែលនឹងជះឥទ្ធិពលដល់ភាពរួចទោស ហើយនិងស្តារឡើងវិញនូវតម្លៃនៃជីវិតមនុស្សនាបច្ចុប្បន្នកាលនិងទៅថ្ងៃអនាគត និង ទី៣) ដំណើរការនៃអង្គតុលាការនេះនឹងជួយដល់ការអភិវឌ្ឍកម្ពុជាឲ្យក្លាយទៅជាសង្គមប្រជាធិបតេយ្យមួយ ដែលច្បាប់គឺជាអ្នកធ្វើអន្តរាគមន៍ទៅលើការរំលោភនានានៅក្នុងអតីតកាល នាពេលបច្ចុប្បន្ន និងទៅក្នុងគ្រាអនាគត ។

ដំណើរការនៃការវិនិច្ឆ័យទោសនេះក៏ដូចជាដំណើរការនៃការកសាងសង្គមនៅគ្រប់វិស័យនានាដោយរាប់បញ្ចូលទាំងការលើកម្ពស់និងការពារសិទ្ធិមនុស្ស នាពេលបច្ចុប្បន្នដែលថានឹងមានបញ្ហាជាច្រើនត្រូវប្រឈមមុខនិងដោះស្រាយ ។ នេះគឺពុំមែនជាភាពអវិជ្ជមាន ប៉ុន្តែគឺជាដំណើរការនៃលទ្ធិប្រជាធិបតេយ្យ ដែលតម្រូវឲ្យប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ចូលរួមដើម្បីធានាឲ្យបាននូវភាពត្រឹមត្រូវនិងយុត្តិធម៌មួយដែលអាចទទួលយកបាន ។

នៅក្នុងមាត្រាទី១នៃច្បាប់នេះចែងថាៈ "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជាការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩" ។ នៅក្នុងមាត្រាទី៣បានចែងអំពីទោសបញ្ញត្តិថាៈ "ទោសបញ្ញត្តិចែងក្នុង មាត្រា២០៩, ៥០០, ៥០៦ និងមាត្រា៥០៧នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវកំណត់ជាអតិបរមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិត អនុលោមតាមមាត្រា៣២នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងបញ្ជាក់បន្ថែមដោយមាត្រា៣៨និងមាត្រា៣៩នៃច្បាប់នេះ ។"

**ឆាំង យុ**

# ប្រជុំអចិន្ត្រៃយ៍ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥

នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាខ្មែរក្រហមបានបើកកិច្ចប្រជុំមួយដែលហៅថា«ការប្រជុំអចិន្ត្រៃយ៍» ។ របៀបវារៈនៃការប្រជុំនេះរួមមានៈ ១)ការបែកការងារនិងកិច្ចដំណើរការ ២)ការរៀបចំឲ្យរស់នៅរួម(សមូហភាព) និង៣)ការចាត់ចែងការងារជាក់ស្តែងមួយចំនួនខាងផ្នែកពាណិជ្ជកម្មនិងយោធា ។

### ១)ការបែកការងារ និងកិច្ចដំណើរការ

ក្នុងការបែកការងារនិងកិច្ចដំណើរការនេះ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាបានបែងចែកការងារទៅឲ្យសមាសភាពទទួលខុសត្រូវគឺ ១) សមមិត្តលេខា (ប៉ុល ពត) ជាលេខាគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាទទួលខុសត្រូវរួមខាងយោធានិងសេដ្ឋកិច្ច ២)សមមិត្តអនុលេខា (នួន ជា) ជាអនុលេខាគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាទទួលខុសត្រូវខាងការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការនិងសិក្សាធិការ ៣)សមមិត្ត វ៉ាន់ (អៀង សារី) ជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យទទួលខុសត្រូវខាងការងារបរទេសទាំងបក្សទាំងរដ្ឋ ៤)សមមិត្ត ហែម (ខៀវ សំផន) ជាគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យទទួលខុសត្រូវខាងរណសិរ្សនិងរដ្ឋាភិបាល ពាណិជ្ជកម្ម ខាងបញ្ជីនិងតម្លៃ ៥)សមមិត្ត ធុច (កុយ ធួន) ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យទទួលខុសត្រូវខាងពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ៦)សមមិត្ត ខៀវ (សុន សេន) ជារដ្ឋមន្ត្រីក្រសួងការពារប្រទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ទទួលខុសត្រូវខាងផ្នែកសេនាធិការនិងសន្តិសុខ ៧)សមមិត្ត វន ( វន វេត) ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងនេសាទ ទទួលខុសត្រូវខាងផ្នែកឧស្សាហកម្មនិងនេសាទ ៨) សមមិត្ត ឌឿន ប្រធានមន្ទីរនយោបាយរបស់អង្គភាព៨៧០ ៩)សមមិត្ត ភា (អៀង ធីរិទ្ធ) ទទួលខុសត្រូវខាងផ្នែកវប្បធម៌សង្គមកិច្ចនិងការងារបរទេស ១០)សមមិត្ត អាត (យុន យ៉ាត) ទទួលខុសត្រូវខាងផ្នែកឃោសនាអប់រំ ទាំងផ្ទៃក្នុង ទាំងខាងក្រៅ ១១)សមមិត្ត ជ័យ ទទួលខុសត្រូវខាងផ្នែកកសិកម្ម ១២) សមមិត្ត យ៉ែម ទទួលខុសត្រូវខាងផ្នែកការិយាល័យរបស់អង្គភាព៨៧០ និង ១៣)សមមិត្ត ប៉ាំង ទទួលខុសត្រូវខាងផ្នែកមន្ទីររដ្ឋាភិបាល ។


អៀង សារី

គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាយល់ឃើញថានៅមានភាពខ្វះខាតច្រើន ហើយមានការងារច្រើន

ប្រមូលផ្តុំមកលើតែការិយាល័យអគ្គភាព៨៧០ (អគ្គភាពនយោបាយមជ្ឈិម) ទាំងការងារក្នុងប្រទេស ក្រៅប្រទេសនិងការពារប្រទេសដែលចាត់ចែងតាមមជ្ឈិម ។ កម្មាភិបាលធ្វើកិច្ចការមានចំនួនតិច ។ វិធានការដែលគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាត្រូវដោះស្រាយមានពីរយ៉ាងៈ ទី១) ខំធ្វើឲ្យមានប្រសិទ្ធភាពខាងវិទ្យាសាស្ត្របែងចែកការងារឲ្យល្អ និងទី២) ជ្រើសរើសកម្មាភិបាលបន្ថែមទៀតជាបណ្តើរៗ ។

ចំពោះវិធានការទាំងពីរខាងលើនេះ អង្គប្រជុំបានកំណត់ថាផ្នែកនីមួយៗត្រូវម្ចាស់ការសព្វគ្រប់ទាំងអស់ក្នុងការអនុវត្តមាគ៌ានិងសេចក្តីសម្រេចរបស់បក្ស ដោយគំនិតផ្តើមវាយសម្រុកចាត់ចែងឲ្យហ្មត់ចត់ឲ្យបានរហ័ស ហើយជាបន្តបន្ទាប់ដោយយកមាគ៌ា សេចក្តីសម្រេចចិត្តរបស់បក្សលៃលកច្នៃប្រឌិត ។ ប៉ុន្តែត្រូវមានគណៈកម្មាធិការមួយផ្សព្វផ្សាយឲ្យសមាជិកជ្រួតជ្រាបនិងរួមគ្នាផ្តើមគំនិត ។ ក្នុងការលើកគម្រោងត្រូវសួរយោបល់អចិន្ត្រៃយ៍ដើម្បីសម្រេចនិងអនុម័ត ។ រីឯនិន្នាការពីរចំណុចដែលគណៈកម្មាធិការអចិន្ត្រៃយ៍កំណត់ឲ្យចៀសវាងគឺៈ ១) សួរតែអចិន្ត្រៃយ៍ បើធ្វើយ៉ាងនេះមិនមានប្រជាធិបតេយ្យប្រមូលផ្តុំទេ ។ អចិន្ត្រៃយ៍ទៅមិនរួចទេ បើមកទាំងដុល(មានន័យថាការងារទាំងអស់ប្រមូលមកលើតែអចិន្ត្រៃយ៍) ២) ធ្វើតែតាមផ្នែកនីមួយៗមិនសួរអចិន្ត្រៃយ៍ ។ នេះក៏ជាការខុសឆ្គងដែរ ។

ដើម្បីសម្គាល់ថាអនុវត្តបានល្អឬមិនបានល្អនូវសេចក្តីសម្រេចរបស់បក្ស គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយ-និស្តកម្ពុជាសន្មតថា គឺនៅត្រង់មហាជនទទួលបានឬមិនបាន ។ កម្មាភិបាលមិនគ្រាន់តែជាអ្នកប្រមូលឯកសារទេ ថែមទាំងជាអ្នកគិតគូរថ្មីថ្មោងទៀតផង ។ ប៉ុន្តែអង្គប្រជុំតម្រូវឲ្យធ្វើតាមបែបវិទ្យាសាស្ត្រដើម្បីបង្កើនគុណភាពដឹកនាំរបស់កម្មាភិបាលក្នុងឋានៈជាអ្នកម្ចាស់ការ ។

សំណូមពររបស់អង្គប្រជុំ គឺកំណត់ហេតុត្រូវធ្វើឲ្យច្បាស់ សួរអ្វីគឺត្រូវដឹងហ្នឹង លើការសម្រេចរបស់មជ្ឈិម របស់អចិន្ត្រៃយ៍ឯកសារប្រជុំមជ្ឈិម ថ្ងៃណា ខែណា ត្រូវធ្វើយ៉ាងណាឲ្យច្បាស់ ។ បើកំណត់ហេតុមិនច្បាស់នាំឲ្យពិបាកមើលសាជាថ្មី ។ វិធីធ្វើការងាររបស់គណៈកម្មាធិការអចិន្ត្រៃយ៍នេះមានពីរបែប គឺធ្វើការរួមនិងធ្វើការដោយឡែក ។ នៅពេលប្រជុំអចិន្ត្រៃយ៍ គណៈ-កម្មាធិការអចិន្ត្រៃយ៍បានកំណត់ថាកម្មាភិបាលម្នាក់ៗត្រូវធ្វើសេចក្តីរាយការណ៍ ពីព្រោះការងារកន្លងមកប្រមូលផ្តុំតែទៅលើសមមិត្ត ខៀវ ទាំងអស់ ។ ថ្ងៃក្រោយត្រូវឲ្យតាមផ្នែកនីមួយៗគិតគូរដោយខ្លួនឯង ។ ធ្វើបានដូច្នេះគឺត្រូវមានដម្រើសកម្មាភិបាលជាជំនួយដែលសកម្ម ។ ដំណើរការនេះនឹងចាប់ផ្តើមបន្ទាប់ពីប្រជុំអចិន្ត្រៃយ៍នេះចប់កិច្ចពិភាក្សា ។

## ២) ការរៀបចំឲ្យរស់នៅជាសមូហភាព

ការរៀបចំឲ្យរស់នៅរួមគ្នាជាសមូហភាពនេះ អង្គប្រជុំបានកំណត់ធ្វើចាប់ពីថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៥តទៅ ។ ផ្នែកនីមួយៗដែលបានបែងចែកនៅក្នុងចំណុចទី១នៃការប្រជុំអចិន្ត្រៃយ៍នេះអាចចេញទៅធ្វើការតាមផ្នែកនីមួយៗដែលខ្លួនទទួលខុសត្រូវ ។ ចំណែកបាយទឹកត្រូវចាត់ចែងនៅតាមកន្លែងរៀងៗខ្លួនដែលត្រូវទទួលខុសត្រូវដែរ ។

## ៣) ការចាត់ចែងការងារដាក់ស្តែងមួយចំនួន

ក្នុងការចាត់ចែងការងារដាក់ស្តែងមួយចំនួនដែលមានដូចជាផ្នែកខាងពាណិជ្ជកម្មនិងខាងផ្នែកយោធា គណៈកម្មាធិការអចិន្ត្រៃយ៍បានកំណត់អាទិភាពទៅលើផ្នែកយោធា ។ ចំពោះផ្នែកខាងពាណិជ្ជកម្ម គណៈកម្មាធិការអចិន្ត្រៃយ៍បានកំណត់ថានឹងលើកទៅពិភាក្សានៅពេលក្រោយទៀត ។

ក្នុងផ្នែកយោធាដែលជាអាទិភាព អង្គប្រជុំបានកំណត់ចែកចេញជា៣ផ្នែកធំៗ ទី១) ការរៀបចំសេនាធិការ ទី២) ការរៀបចំកម្លាំងទៅរតនគិរីនិងមណ្ឌលគិរី និងទី៣) ការរៀបចំកងពលឲ្យឯកភាពគ្នា ។

ក) ការរៀបចំសេនាធិការ

ការរៀបចំសេនាធិការនេះត្រូវបានអង្គប្រជុំអចិន្ត្រៃយ៍កំណត់បែងចែកទៅតាមភារកិច្ចនិងទិសដៅផ្សេងពីគ្នា ។ ភារកិច្ចនៅក្នុងការរៀបចំសេនាធិការមានបីផ្នែក គឺនយោបាយ យោធា និងភ័ស្តុភារ ។ ភារកិច្ចខាងផ្នែកនយោបាយមានសមមិត្តខៀវ ជាអ្នកទទួលខុសត្រូវ ។ ភារកិច្ចខាងផ្នែកយោធា គឺត្រូវក្តាប់កម្លាំងរៀបចំកងពល ចាត់ចែងកងទ័ពថ្មី ជើងទឹក ជើងអាកាស រៀបចំទីតាំងកងទ័ពនិងមាគ៌ាប្រយុទ្ធ ។ ភារកិច្ចខាង

ផ្នែកភ័ស្តុភារគឺតម្រូវមានអាវុធ គ្រាប់រំសេវ ស្បៀងអាហារ សម្លៀកបំពាក់ សម្ភារដឹកជញ្ជូន និងថ្នាំពេទ្យ ។

រីឯទិសដៅការងារសេនាធិការគឺត្រូវបើកវគ្គរៀនសូត្រដល់កម្មាភិបាលកងទ័ពដែលនៅសេសសល់ ក្តាប់ប្រវត្តិរូបកងទ័ព សម្រិតសម្រាំងកងទ័ព ចាត់តាំងគណៈកម្មាធិការបក្ស និងរៀបចំសន្និបាតកងទ័ព ។

ខ) ការរៀបចំកម្លាំងទៅរតនគិរី និងមណ្ឌលគិរី

ការរៀបចំកម្លាំងទ័ពទៅឈរជើងនៅខេត្តមួយចំនួននៅភូមិភាគឦសាន អង្គប្រជុំបានកំណត់ឲ្យមានកម្លាំងទ័ពចំនួន១កងពលឈរជើងនៅខេត្តស្ទឹងត្រែងនិងរតនគិរី ហើយនិង១កងពលទៀតឲ្យឈរជើងនៅខេត្តមណ្ឌលគិរី ។ ខេត្តក្រចេះក៏ត្រូវការកម្លាំងកងទ័ពចំនួន១កងពលដែរ ។

ការបោះទីតាំងទ័ពនៅខេត្តមណ្ឌលគិរីបានកំណត់យកទីតាំងនៅម្រើច កោះមៀល អូររាំង និងឡាប៉ាលខេ ។ ប្រសិនណាមានការសម្រេចពីអង្គការនៅរដូវប្រាំង កម្លាំងទ័ពនឹងត្រូវបាននាំយកទៅឈរជើងនៅតាមទីតាំងទាំងប៉ុន្មានដែលបានកំណត់មករួចមកហើយ ។

គ) ការរៀបចំកងពលឲ្យឯកភាពគ្នា

ដើម្បីឲ្យមានការឯកភាពគ្នាក្នុងជួរកងទ័ព គណៈកម្មាធិការអចិន្ត្រៃយ៍បានកំណត់ត្រូវឲ្យមាន៣វរសេនាធំ កាំភ្លើង១០៥ចំនួន៣ដើម កាំភ្លើង១២,៧ម.មចំនួន៣ដើម និងត្រូវមានកម្លាំងកងទ័ពទាំងយុទ្ធជន និងយុទ្ធនារីចំនួន៤០០នាក់ ។ ជាគោលដៅអង្គប្រជុំបានកំណត់ថានឹងចុះទៅពិនិត្យទីតាំងនៅចុងខែតុលា (១៩៧៥) ប្រហែលជា១សប្តាហ៍ទៀតបន្ទាប់ពីការប្រជុំអចិន្ត្រៃយ៍នេះ ។ បន្ទាប់មកកសាងកម្លាំងកងទ័ពថ្មីខាងជើងទឹក ជើងអាកាស កាំភ្លើងធំ និងខាងវិទ្យុទាក់ទងក្នុងគោលបំណងរៀបចំឲ្យបានរហ័សតាមដែលអាចធ្វើទៅបាននិងរំសាយកងពលលេខ១១ ដើម្បីបញ្ចូលទៅក្នុងកងពលផ្សេង បន្ថែមកម្លាំងភ័ស្តុភាររៀបចំទុកដាក់គ្រាប់អាស្លាបកាត់ គ្រាប់ណាប៉ាល់ ។ល ។ ម្យ៉ាងទៀតត្រៀមរៀបចំគ្រាប់កាំភ្លើងតូចៗទុកដាក់នៅទីក្រុងភ្នំពេញ ត្រៀមអង្ករឲ្យម្ចាស់ការ ត្រៀមធ្វើរោងចក្រអាវុធនៅគិរីរម្យនិងត្រៀមធ្វើរោងជាងសម្រាប់កែច្នៃអាវុធ ។

នៅក្នុងផ្នែករៀបចំសេនាធិការនេះ អង្គប្រជុំអចិន្ត្រៃយ៍ក៏បាននិយាយទាក់ទងនឹងជំនួយពីប្រទេសចិនដែរ ជាពិសេសផ្នែកទ័ពខាងជើងទឹក ជើងអាកាស និងខាងវិទ្យុទាក់ទង ។ ខាងជើងទឹកចិនបានចុះទៅពិនិត្យនៅទីតាំងផ្តែព្រុសដែលជាកន្លែងធ្វើកំពង់ផែ ។ ចិនបានរកឃើញនូវចំណុចល្អ គឺមានប្រជាជនល្អ មានទឹកសាប មានភ្នំ មានផ្លូវជាតិលេខ៤ និងមិនសូវមានព្យុះ ។ ចំណុចមិនល្អ គឺមានព្រែកចូលវៀច មានដីខ្សាច់ដុះ នៅឆ្ងាយពីសមរភូមិ និងអស់សោហ៊ុយច្រើន ។ កន្លែងត្រូវដាក់រ៉ាដាដែលអង្គប្រជុំបានកំណត់មាននៅបូកគោ កោះរុងសន្លឹម និងនៅកោះកុង ។

ផ្នែកជើងអាកាសកម្ពុជាប្រជាធិបតេយ្យបានចែកជាពីរផ្នែក គឺផ្នែករ៉ាដានិងផ្នែកយន្តហោះ ។ ផ្នែករ៉ាដាសម្រាប់តាមដានសភាពការណ៍និងរាយការណ៍ ។ ទីតាំងរ៉ាដាកម្ពុជាប្រជាធិបតេយ្យបានកំណត់ មាននៅត្នោតពង បាត់ដំបង និងភ្នំក្រោម ។ ប៉ុន្តែខាងផ្នែករ៉ាដា ចិនបានស្នើឲ្យដាក់នៅទីតាំងនៅក្រុងខេមរភូមិន្ទ អណ្តូងទឹក បូកគោ និងត្រពាំងរូង ។ ខាងផ្នែកយន្តហោះ ចិនបានចុះទៅពិនិត្យនៅខេត្តកំពង់ចាម បាត់ដំបងនិងឧត្តរមានជ័យ ។ តាមការពិនិត្យរបស់ចិនឃើញថាយន្តហោះចំនួន១០០គ្រឿង មានតេ-២៨នៅបើកបាន សេ-៤១អាចបញ្ចេះបាន និងសេ-៤៧នៅឧត្តរមានជ័យមាន៣គ្រឿង ។ សំណើរបស់ចិនបានស្នើឲ្យដោះស្រាយសម្ភារ ប្រេងគ្រប់មុខ ស្នើឯកសារទៅ១២៣ រៀបចំអ្នកបើកបរដោយឲ្យពេទ្យពិនិត្យសុខភាព និងស្នើឲ្យសាងសង់ព្រលានយន្តហោះនៅពោធិចិនតុងដោយពង្រីកផ្លូវមួយទៀតនៅសៀមរាបនិងនៅឧត្តរមានជ័យ ។

ខាងវិទ្យុទាក់ទងមានភារកិច្ចបម្រើការចំពោះមុខ បម្រើការងារក្នុងពេលសង្គ្រាមនិងស៊ើបការណ៍ពីខ្មាំង ។ កម្លាំងកងទ័ពដែលត្រូវប្រើប្រាស់ក្នុងផ្នែកវិទ្យុទាក់ទងនេះគឺត្រូវឲ្យមានចំនួន១៥០០នាក់ ។ សំណើរបស់ចិនក្នុងផ្នែកវិទ្យុទាក់ទងគឺរៀបចំនៅក្រុងព្រះសីហនុជាមុន ដាក់ទូរស័ព្ទនៅតាមផ្លូវជាតិលេខ៣ និងតម្រូវឲ្យមានទូរលេខនិងទូរស័ព្ទទាំងអត់ខ្សែនិងមានខ្សែ ។ ប៉ុន្តែទិសដៅសំខាន់របស់អង្គការគឺដាក់នៅខាងសមុទ្រនិងខេត្តរតនគិរី ។

បន្ថែមពីលើចំណុចទី៣នៃការរៀបចំសេនាធិការ សមមិត្ត

លេខាបានលើកឡើងថា «និយាយរួមស្របតាមការស្នើ ។ នៅតែចាត់ចែងដំណើរការដឹកនាំ គឺត្រូវដំណើរការតាមសមូហភាពព្រោះការងារថ្មីទាមទារការដឹកនាំជាសមូហភាព» ។ សមមិត្តលេខាយល់ឃើញថា ផ្នែកបច្ចេកទេសយោធាមានការលំបាកយ៉ាងធ្ងន់ធ្ងរដែលតម្រូវឲ្យមានគណៈជំនួយការងារខាងនយោបាយយោធា និងភ័ស្តុភារ ។

សំណូមពររបស់មមិត្តលេខាលើបញ្ហាគណៈជំនួយនេះ ទី១គឺគ្រាន់តែមានកម្មាភិបាលទុកដាក់ជីវទស្សនបដិវត្តនិងប្រវត្តិរូបជាការស្រេច ទី២ខាងការអប់រំ គឺសមមិត្ត ខៀវ អាចអប់រំបាន ទី៣តាមក្រុម ពួក និងយុទ្ធជន លេខាកងពលក៏អាចអប់រំនយោបាយបានដែរ ។ សំណូមពរបន្ថែមរបស់សមមិត្តលេខា គឺថា «ការរៀនសូត្រនៅសាលាបក្សគ្រាន់ឲ្យតែក្តាប់ទស្សនៈរួមប៉ុណ្ណោះ ។ ដូច្នេះយើងជ្រើសរើសកម្មាភិបាលត្រឹមវរសេនាតូច វរសេនាធំក៏បាន ឲ្យតែមានប្រវត្តិរូបត្រឹមត្រូវ ។ អ្នកនេះអាចចូលក្នុងមន្ទីរដឹកនាំបាន» ។ ក្នុងផ្នែកយោធានិងភ័ស្តុភារ សមមិត្តលេខាតម្រូវឲ្យមានប្រវត្តិរូបច្បាស់លាស់ដើម្បីចូលក្នុងគណៈ ។ រីឯជំនួយការអាចជ្រើសរើសអ្នកថ្មីក៏បាន ។

ក្នុងការប្រជុំអចិន្ត្រៃយ៍ សមមិត្តលេខាបានពន្យល់ដោយលើកឧទាហរណ៍ពីចំណុចល្អនិងកង្វះខាតនៅក្នុងអគ្គភាពមួយចំនួន ដូចជាអគ្គភាពរបស់សមមិត្ត មាន សមមិត្ត ផាន និងសមមិត្ត អឿន ។ សមមិត្តលេខាបានសន្និដ្ឋានថា «និយាយរួមយើងតាមដានឲ្យជាប់ទាំងនយោបាយទាំងសតិអារម្មណ៍ទាំងការចាត់តាំងដើម្បីក្តាប់ជាប់ការងារនយោបាយសតិអារម្មណ៍ការចាត់តាំងឲ្យបានហ្មត់ចត់ដោយវៃឈ្លាស» ។

សមមិត្តអគ្គលេខា បានលើកឧទាហរណ៍អំពីសមមិត្ត មាន ដោយនិយាយថា «កងសមមិត្ត មាន និយាយរួមល្អ តែការអប់រំមិនបានជ្រៅជ្រះប៉ុន្មាន ហើយសមមិត្ត មាន ក៏ថ្មី ហើយការចាត់តាំងពីមុនយកលំនាំតាមវៀតណាម ។...ប្រវត្តិពីមុនអាចមានគំនិតថា ទ្រាំទ្រមិនបានក៏គេច តែមិនចូលខ្មាំង ចូលអគ្គការ ហើយអគ្គការបញ្ជូនទៅមូលដ្ឋាន» ។

សមមិត្តអគ្គលេខា ក៏បានលើកឧទាហរណ៍អំពីសមមិត្ត ផាន ដែរថា «រឿងសមមិត្ត ផាន ត្រូវស្ទាត់មែនទែន បញ្ហារាយការណ៍អីត្រូវវិភាគ ព្រោះគិញវាឆ្លើយបត់បែន ។ រកប្រវត្តិតាមខ្សែយើងគ្រាន់បើដាន ជឿតាមខ្សែខ្មាំងមិនបាន ។ ការវិនិច្ឆ័យពិតប្រាកដមិនពិតគឺតាមខ្សែយើង ។...បើពិនិត្យមើលក៏មានលក្ខណៈល្អក្នុងពេលប្រយុទ្ធ តែយើងត្រូវតាមដានទៅទៀត» ។

ចំពោះសមមិត្ត អឿន ត្រូវបានសមមិត្តលេខា ផ្តល់យោបល់ថា «កងមិត្ត អឿន ទុកឲ្យនៅកន្លែងហ្នឹងសិន ហើយជ្រើសរើសឲ្យទៅកន្លែងផ្សេងៗ» ។

តាមពិសោធន៍ សមមិត្តលេខាយល់ឃើញថា «ការខ្វះខាតគឺជាការធម្មតា បើមើលលទ្ធភាពរៀនសូត្រ ខ្លះក៏ឃើញចម្រើនដែរដោយកែប្រែបានច្រើន ។ ដូច្នេះមានលទ្ធភាពកសាងបានទៅថ្ងៃមុខទៀតបានច្រើន» ។ តាមសំណូមពររបស់អគ្គលេខា គឺឲ្យក្តាប់កងពលផ្សេងៗទៀត ។ បើក្តាប់មិនបាន ឲ្យមកធ្វើការនៅក្នុងសេនាធិការ ។

ឈរលើជំហរឯករាជ្យម្ចាស់ការ សមមិត្តលេខាយល់ថា ជំនួយក៏យក តែក្នុងគោលជំហរឯករាជ្យម្ចាស់ការដែរ ។ បើយកមកប៉ះពាល់ដល់គោលជំហរនេះ គឺមិនបានទេ ។ សម្បូរបែបក៏វាយ មិនសម្បូរក៏វាយ ។ ជំនួយពីប្រទេសចិនដែលនឹងទទួលបានគឺត្រូវបានកំណត់ឲ្យបែងចែកដោយអនុលោមទៅតាមសភាពការណ៍ដែលវិវត្ត ជាពិសេសខាងវិទ្យុទាក់ទងដែលត្រូវដាក់នៅតាមព្រំដែនសមុទ្រ ខាងព្រំប្រទល់ជើងគោក និងខាងកងទ័ពជើងអាកាសដែលអាចនឹងជួបនូវការខ្វះខាតច្រើន ។

ការប្រជុំអចិន្ត្រៃយ៍នេះ អង្គប្រជុំបានផ្តោតជាសំខាន់លើ៣ចំណុចដូចដែលបាននិយាយរួចហើយពីខាងដើម ។ ប៉ុន្តែចំណុចដែលសំខាន់បំផុត គឺចំណុចទី៣ ព្រោះគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាយល់ថា មាគ៌ារួមគឺកសាងនិងការពារប្រទេស ។ កសាងនិងការពារប្រទេសផ្អែកលើកម្លាំងមហាជន ហើយមាគ៌ាសំខាន់បំផុតក្នុងការការពារប្រទេសគឺសំដៅទៅលើកងទ័ពថ្មើរជើងដែលចាំបាច់តម្រូវឲ្យធ្វើរោងចក្រផលិតកាំភ្លើងគ្រាប់បែកនិងគ្រាប់មីន ។ ហេតុដូច្នេះទើបសេនាធិការសម្រេចយកក្រសួងការពារប្រទេសជាបញ្ហាសំខាន់និងចំពោះមុខក្នុងការកសាងនិងការពារប្រទេស ។

**ខ្ញូង សុភារិទ្ធ**

# សម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជា ជាដៃស្តាំរបស់បក្ស

(យុវជននិងយុវនារីបដិវត្ត លេខពិសេស សីហា-កញ្ញា ១៩៧៤)

ដើម្បីបំផុសនិងជំរុញចលនាយុវជន-យុវនារី យើងឲ្យកាន់តែខ្លាំងក្លាថែមទៀត សមស្របតាមសភាពការណ៍ជាក់ស្តែងនៃចលនាតស៊ូបដិវត្តន៍ដែលកាន់តែឆាបឆេះសន្ធោសន្ធៅខ្លាំងឡើងៗ និងសមស្របនឹងគោលជំហរប្រយុទ្ធរបស់យុវជនយុវនារីយើងផងដែលកាន់តែអង់អាចឈានមុខនិងកាន់តែរឹងប៉ឹងឡើងជាលំដាប់ នៅក្នុងឆ្នាំ១៩៦០ បក្សក៏បានសម្រេចបង្កើតអង្គការយុវជន-យុវនារីកម្ពុជាមួយដែលនៅពេលនោះមានឈ្មោះថា «សម្ព័ន្ធយុវជនកម្ពុជាប្រជាធិបតេយ្យ» ឬហៅកាត់ថា «សម្ព័ន្ធយុវកប»សម្រាប់ដឹកនាំនិងបំផុសចលនាយុវជន-យុវនារីកម្ពុជាក្នុងការតស៊ូបដិវត្តន៍ប្រឆាំងនឹងការជ្រៀតជ្រែកឈ្លានពានរបស់ចក្រពត្តិអាមេរិកនិងបរិវារនៅពេលនោះផង និងតស៊ូវាយប្រហារនិងវាយកម្ទេចរបបជិះជាន់ផ្តាច់ការហ្វាស៊ីសរបស់ពួកសក្តិភូមិនាយទុនប្រតិកិរិយានៅជំនាន់នោះផង ។ ចាប់តាំងពីពេលមានកំណើតឡើងកាលណា សម្ព័ន្ធយុវកបបានពុះពារគ្រប់ឧបសគ្គនិងឆ្លងកាត់គ្រោះថ្នាក់គ្រប់បែបយ៉ាង ប្រយុទ្ធធ្វើសកម្មភាពយ៉ាងក្លៀវក្លាក្នុងមជ្ឈដ្ឋានយុវជន-យុវនារីកម្ពុជា ពិសេសក្នុងមជ្ឈដ្ឋានយុវជន-យុវនារីកម្មករ ពលករ កសិករ និងយុវនារីសិក្សា ។ ក្រោមការដឹកនាំដ៏ភ្លឺស្វាងនៃបក្សកុម្មុយនិស្តកម្ពុជា សម្ព័ន្ធយុវកបយើងបានធ្វើការឃោសនាអប់រំយ៉ាងសកម្មដោយដឹកនាំពាំយួរនូវមាគ៌ានយោបាយ គោលនយោបាយ និងសេចក្តីសម្រេចចិត្តផ្សេងៗរបស់បក្ស យកទៅផ្សព្វផ្សាយក្នុងយុវជនយុវនារីកម្ពុជាដ៏កុះករនិងក្នុងប្រជាជនកម្ពុជាទូទៅ ធ្វើឲ្យកម្លាំងទាំងនេះមានការភ្ញាក់រឭកជាតិនិងភ្ញាក់រឭកវណ្ណៈកាន់តែខ្ពស់ឡើងៗ ហើយប្រែក្លាយទៅជាកម្លាំងបដិវត្តន៍មួយដ៏ខ្លាំងក្លាវាយកម្ចាត់នូវឧបាយកលពិសពុលខ្មៅងងឹតរបស់ចក្រពត្តិអាមេរិកនិងបរិវារបានជាបន្តបន្ទាប់ រហូតដល់វាយបណ្តេញចក្រពត្តិអាមេរិកអស់ពីកម្ពុជានៅពាក់កណ្តាលឆ្នាំ១៩៦៥ ព្រមទាំងវាយប្រហារវែកញែក បកអាក្រាតអំពើរំលោភជាន់ ឆក់ប្លន់ អយុត្តិធម៌ និងបង្ក្រាបរាគត្បាត ចាប់ចងកាប់សម្លាប់យ៉ាងឃោរឃៅហ្វាស៊ីសរបស់ពួកវណ្ណៈកាន់អំណាចជំនាន់នោះដែលតំណាងផលប្រយោជន៍ឲ្យសក្តិភូមិ នាយទុនប្រតិកិរិយាផង ។ ក្រៅពីនេះ សម្ព័ន្ធយុវកកយើងនៅបានចាត់តាំងចលនាតស៊ូដឹកនាំចលនាតស៊ូរួមប្រឡូកផ្ទាល់ក្នុងគ្រប់ចលនាបដិវត្តន៍ដ៏សន្ធោសន្ធៅរបស់យុវជនយុវនារីកម្ពុជាប្រឆាំងចក្រពត្តិអាមេរិកបរិវារ និងពួកវណ្ណៈកាន់អំណាចឃោរឃៅប្រតិកិរិយាជំនាន់នោះយ៉ាងផុលផុស គគ្រឹកគគ្រេងទាំងនៅទីក្រុង ទាំងនៅជនបទ ។

ដូច្នេះសម្ព័ន្ធយុវកបបានទៅជាអ្នកផ្សព្វផ្សាយនិងជាអ្នកអនុវត្តនូវមាគ៌ានយោបាយ គោលនយោបាយ និងសេចក្តីសម្រេចចិត្តផ្សេងៗរបស់បក្សយ៉ាងសកម្មប្រយុទ្ធនិងអង់អាចឈានមុខបំផុតក្នុងមជ្ឈដ្ឋានយុវជនកម្ពុជា ពិសេសយុវជនកម្មករ ពលករ កសិករ និងយុវជនសិក្សា ក៏ដូចក្នុងចំណោមប្រជាជនកម្ពុជាទូទៅ ។ ដូច្នោះ សម្ព័ន្ធយុវកបបានក្លាយទៅជាដៃស្តាំរបស់បក្សយ៉ាងពិតប្រាកដ ។ ក្រោមការដឹកនាំអប់រំថែបំប៉នអំពីបក្សទាំងខាងគោលជំហរនយោបាយ សតិអារម្មណ៍ និងការចាត់តាំងទាំងខាងការសាកល្បងហ៊ឹកហ៊ឺនលត់ដំខ្លួនក្នុងចលនាតស៊ូបដិវត្តន៍ក្តៅជាបន្តបន្ទាប់ សម្ព័ន្ធយុវកបយើងមានធាតុជាអង្គការយុវជនបដិវត្តន៍កម្ពុជាដ៏រឹងប៉ឹងមួយ ហើយបានក្លាយទៅជាកម្លាំងជំនួយដ៏សំខាន់ចំពោះគ្រប់កិច្ចការទាំងអស់របស់បក្សកុម្មុយនិស្តកម្ពុជា ។ ដូច្នេះហើយបានជានៅខែមករាឆ្នាំ១៩៧១ បក្សបានប្រែឈ្មោះអង្គការបដិវត្តន៍យុវជនកម្ពុជានេះទៅជា«សម្ព័ន្ធយុវជន

កុម្មុយនិស្តកម្ពុជា»ដែលហៅកាត់ថា«សម្ព័ន្ធយុវកក»ដើម្បីឲ្យសមស្របទៅនឹងសកម្មភាព ធាតុពិត និងតួនាទីរបស់យុវជនយុវនារីបដិវត្តន៍កម្ពុជាយើងនៅក្នុងចលនាតស៊ូធ្វើសង្គ្រាមប្រជាជនប្រឆាំងនឹងសង្គ្រាមឈ្លានពានដ៏កាចសាហាវរបស់សហរដ្ឋអាមេរិកនិងបរិវារសព្វថ្ងៃនេះ ។ តាំងពីពេលនោះរហូតមកដល់ពេលបច្ចុប្បន្ននេះ សម្ព័ន្ធយុវកកបានប្រកាន់នាទីជាកម្លាំងស្នូលដឹកនាំចលនាបំផុសយុវជន-យុវនារីកម្ពុជាទូទាំងប្រទេស ទាំងសមរភូមិមុខ ទាំងសមរភូមិក្រោយ ទាំងនៅតាមមន្ទីរ ក្រសួងនិងការដ្ឋានផ្សេងៗ ។ សម្ព័ន្ធយុវកកយើងបានធ្វើជាគំរូល្អនិងគំរូឈានមុខគេអង់អាចក្លាហាននិងសកម្មប្រយុទ្ធក្នុងគ្រប់ទេសៈកាលៈ ក្នុងគ្រប់កិច្ចការបដិវត្តន៍តូច-ធំ ធ្ងន់-ស្រាលលំបាក-ស្រួលទាំងអស់ដែលបក្សត្រូវការ ទោះក្នុងភារកិច្ចវាយកម្ទេចខ្មាំងនៅតាមសមរភូមិមុខក្តី ទោះក្នុងភារកិច្ចដឹកជញ្ជូនលីសែង ហាលភ្លៀង ហាលថ្ងៃ ក្រោមគ្រាប់បែកគ្រាប់កាំភ្លើងច្រើនដូចគ្រាប់ភ្លៀងយ៉ាងណាក្តី ទោះក្នុងភារកិច្ចធ្វើពលកម្មលើកទំនប់ ជីកស្រះ ជីកប្រឡាយដោះស្រាយបញ្ហាទឹកជូនប្រជាជនបង្កបង្កើនផលក្តីឬក្នុងចលនាបង្កបង្កើនផលកែប្រែជីវភាពប្រជាជនមូលដ្ឋានឬក្នុងចលនាចាត់តាំង ពង្រឹងពង្រីកសហករណ៍នៅសមរភូមិក្រោយក្តី ទោះនៅក្នុងភារកិច្ចបដិវត្តន៍ផ្សេងៗទៀតនៅតាមមន្ទីរ ការដ្ឋាន និងក្រសួងនានាក្តី ។ ដូច្នោះយើងឃើញតាំងពីដើមរៀងរហូតមកដល់សព្វថ្ងៃនេះ សម្ព័ន្ធយុវកកយើងបានរួមចំណែកយ៉ាងសកម្មនិងយ៉ាងសំខាន់បំផុតជាមួយបក្សនិងប្រជាជនកម្ពុជាយើងទាំងមូល ក្នុងការដណ្តើមយកជ័យជំនះយ៉ាងធំទំហំអស្ចារ្យលើគ្រប់វិស័យលើខ្មាំងសត្រូវគ្រប់ប្រភេទនាបច្ចុប្បន្ននេះ ។ នេះគឺជាការសប្បាយរីករាយនិងជាមោទនភាពបដិវត្តន៍ដ៏ខ្ពង់ខ្ពស់របស់យុវជនយុវនារីបដិវត្តន៍យើង ក៏ដូចជារបស់បក្សបដិវត្តន៍ និងប្រជាជនយើងទាំងមូលដែរ ។ ការរីកចម្រើនដុះដាលនិងធាតុរឹងប៉ឹងរបស់អង្គការបដិវត្តកម្ពុជាយើងនេះ គឺពិតជាបេះមិនដាច់អំពីសកម្មភាពនិងគោលជំហររបស់បក្សកុម្មុយនិស្តកម្ពុជាឡើយ ។ បក្សកុម្មុយនិស្តកម្ពុជានេះហើយដែលជាអ្នកចាត់តាំងកសាង បង្កើតអង្គការបដិវត្តន៍យុវជនកម្ពុជានេះឡើងឲ្យមានទាំងរូបរាងមានទាំងសកម្មភាពជាក់ស្តែង បំពាក់បំប៉ន ពង្រឹងទាំងទស្សនៈគោលជំហរនិងមនោសញ្ចេតនាបដិវត្តន៍ថ្មី ។ ដូច្នោះបក្សកុម្មុយនិស្តកម្ពុជាបានរំដោះយុវជន-យុវនារីកម្ពុជាយើង ទាំងផ្លូវកាយទាំងផ្លូវចិត្ត ទាំងស្មារតី ទាំងខាងទស្សនៈគោលជំហរនិងមនោគមវិជ្ជា ឲ្យរួចចាកផុតពីរណ្តៅងងឹតសូន្យសុងនៃទស្សនៈគោលជំហរ មនោគមវិជ្ជា ពុករលួយ ឱនថយ ជិះជាន់ របស់ចក្រពត្តិសក្តិភូមិនាយទុន ឲ្យឃើញឲ្យស្គាល់នូវពន្លឺរស្មីអនាគតដ៏រុងរឿងមួយ ពោលគឺឧត្តមគតិកុម្មុយនិស្តដ៏ត្រចះត្រចង់ ។

ថ្ងៃ៣០ ខែកញ្ញា ឆ្នាំ១៩៧៤នេះជាថ្ងៃខួបលើកទី២៣នៃកំណើតបក្សកុម្មុយនិស្តកម្ពុជាដ៏រុងរឿង ។ ដើម្បីជាកិច្ចតបស្នងសងគុណដល់បក្សផងនិងដើម្បីឲ្យស្រមទៅតាមសេចក្តីសង្ឃឹមនិងសេចក្តីជឿទុកចិត្តរបស់បក្ស បដិវត្តន៍ និងប្រជាជនកម្ពុជាទាំងមូលមកលើខ្លួនផង យុវជន-យុវនារីបដិវត្តន៍កម្ពុជាប្តេជ្ញាកសាងខ្លួនឲ្យទៅជាដៃស្តាំរបស់បក្សយ៉ាងពិតប្រាកដ ដោយប្តេជ្ញាខិតខំកសាងបំពាក់ឲ្យខ្លួននូវធាតុពិតរបស់សម្ព័ន្ធយុវកកឲ្យបានកាន់តែរឹងប៉ឹងនិងល្អបរិសុទ្ធឡើង ។ ជាក់ស្តែង÷ ១) ត្រូវខិតខំកសាងនិងបំពាក់ឲ្យខ្លួននូវធាតុវណ្ណៈកម្មកររបស់បក្ស ហើយកម្ចាត់នូវវណ្ណៈផ្សេងៗដែលមិនបដិវត្តដែលមាននៅសេសសល់នៅក្នុងខ្លួន ឬក្នុងជួរនៅឡើយ ឲ្យបានដាច់ខាតនិងជ្រះស្រឡះ ។ ២) ត្រូវខិតខំកសាងនិងបំពាក់នូវធាតុឈានមុខរបស់បក្សអង់អាចក្លាហាន មោះមុត ស្ទុះស្ទាញ សកម្មប្រយុទ្ធបំផុតក្នុងការអនុវត្តមាគ៌ានយោបាយ គោលនយោបាយនិងសេចក្តីសម្រេចផ្សេងៗរបស់បក្សក្នុងគ្រប់ការតស៊ូបដិវត្តន៍ យោធា នយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច ការពារ និរសា ដឹកជញ្ជូន បច្ចេកទេសផ្សេងៗ ។ល។ នៅគ្រប់សមរភូមិខាងមុខក្តី ខាងក្រោយក្តី ក្នុងគ្រាស្រួលក្តី ក្នុងគ្រាលំបាកក្តី គ្មានរាថយ តាមគោលជំហររវីរភាពបដិវត្តន៍និងស្មារតីគោរពវិន័យអង្គការដោយភ្ញាក់រឭកខ្ពស់បំផុត ។

បើយុវជន-យុវនារីបដិវត្តយើងមានធាតុទាំងពីរនេះរឹងមាំ យុវជន-យុវនារីយើងនឹងក្លាយទៅជាកម្លាំងជំរុញចលនាតស៊ូបដិវត្តយ៉ាងខ្លាំងក្លានាបច្ចុប្បន្ន ជាអ្នកបន្តវេនកាន់កាប់វាសនាបដិវត្តន៍យ៉ាងរឹងមាំទៅអនាគត ។ ដូច្នេះអនាគតបដិវត្តន៍កម្ពុជានឹងនៅតែមានពណ៌ក្រហមឆ្អិនឆ្អៅជារៀងរហូត ។

# សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជាចំពោះបក្សពលករដាណឺម៉ាក

## *ខែកក្កដា ឆ្នាំ១៩៧៨*

**(តចប់)**

***សំណួរៈ តើនេះជាការសហការគ្នារវាង សេ.អ៊ី.អា និង កា.ហ្សេ.បេ ឬមួយក៏ជាការប្រកួតប្រជែងគ្នាក្នុងការដណ្តើមកម្ពុជាមកកាន់កាប់រៀងៗខ្លួន?***

ទាំងពីរយ៉ាង។ ម្យ៉ាងសេ.អ៊ី.អានិងកា.ហ្សេ.បេ សហការគ្នា ហើយម្យ៉ាងវិញទៀតទាំងពីរក្រុមគឺជាគូប្រកួត។ ឧទាហរណ៍ វៀតណាមបានវាយប្រហារយើង កាលពីចុងខែតុលា ដល់ខែធ្នូ ចំណែកឯអាមេរិកវិញបើកប្រតិបត្តិការនៅជិតកោះមួយចំនួននៅតាមឆ្នេរនិងតាមព្រំដែនជាប់ប្រទេសថៃជាមួយភ្នាក់ងារ សេ.អ៊ី.អា។ ពួកនេះប្រកួតប្រជែងគ្នាដណ្តើមការកាន់កាប់ព្រមៗគ្នា។ នេះជាកិច្ចសហការចំហ។ ចំណែកឯការងារសម្ងាត់វិញមានភ្នាក់ងារសម្ងាត់សេ.អ៊ី.អាមួយចំនួនបានចូលខាងវៀតណាមដើម្បីឆ្លងមកកាន់កម្ពុជា។ ដោយសារអាមេរិកមិនអាចឆ្លងមកកាន់កម្ពុជា អាមេរិកត្រូវតែពឹងពាក់វៀតណាម។ វៀតណាមមិនប្រកាន់ថាភ្នាក់ងារណាជាភ្នាក់ងារណាទេ។ គេទទួលយកទាំងអស់អ្នកដែលវាយប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជា។ សូម្បីតែភ្នាក់ងារសេ.អ៊ី.អាក៏មិនជំទាស់ដែរ!។

ត្រូវតែការពារក្បាលម៉ាស៊ីនដឹកនាំដាច់ខាត។ ប្រសិនបើយើងបាត់បង់សមាជិក ប៉ុន្តែនៅរក្សាបានមេដឹកនាំ យើងអាចបន្តយកជ័យជម្នះបាន។ ជាយុទ្ធសាស្ត្រគឺការពារថ្នាក់ដឹកនាំរបស់បក្សឲ្យបាន។ ដរាបណាមានមេដឹកនាំ បក្សពិតជាមិនស្លាប់ទេ។ បាត់បង់សមាជិក ២០០ទៅ៣០០នាក់ មិនស្មើនឹងបាត់បង់កម្មាភិបាលដឹកនាំ២ទៅ៣នាក់ផង។ ស៊ូបាត់បង់សមាជិក កុំឲ្យតែបាត់បង់ថ្នាក់ដឹកនាំ។ បើមិនដូច្នេះទេ បក្សគ្មានក្បាល និងមិនអាចដឹកនាំការតស៊ូបានទេ។ ឧទាហរណ៍ជាក់ស្តែងគឺបក្សកុម្មុយ-និស្តឥណ្ឌូនេស៊ី។ មេដឹកនាំរបស់បក្សកុម្មុយនិស្តឥណ្ឌូនេស៊ីចំនួន៩០ភាគរយត្រូវបានកម្ទេច។ វាស៊ីពេលអស់មិនតិចទេក្នុងការកសាងកម្លាំងថ្នាក់ដឹកនាំឡើងវិញ។ ៣០ឆ្នាំកន្លងផុតទៅចាប់តាំងពីឆ្នាំ១៩៦៥មកម៉្លេះ មកដល់ពេលនេះបក្សមិនទាន់កសាងបានផង។ យើងមិនដឹងថាតើពេលណាទើបបក្សនេះមានកម្លាំងប្រយុទ្ធដូចកាលពីមុនវិញទេ។ ជាយុទ្ធសាស្ត្រគឺកសាងថ្នាក់ដឹកនាំឲ្យបានល្អ។ វាស៊ីពេលប្រហែលពី១០ទៅ២០ឆ្នាំក្នុងការកសាងជនកុម្មុយនិស្តដឹកនាំ។ ប្រសិនបើអ្នកឯងបាត់បង់ម្នាក់ អ្នកឯងបាត់បង់ច្រើនណាស់។ យើងមិនត្រូវឲ្យការណ៍សម្ងាត់របស់បក្សបែកធ្លាយទេ។

### VI. ការកសាងនិងដឹកនាំចលនាបដិវត្តន៍

ដូចយើងបាននិយាយរួចមកហើយថាចាប់តាំងពីឆ្នាំ១៩៦០មក យើងចាត់ទុកកម្មករ កសិករ និងអនុធន ព្រមទាំងអ្នកចម្រើន ជាកម្លាំងយុទ្ធសាស្ត្រ។ វណ្ណៈកម្មករគឺជាវណ្ណៈចម្រើន ចំណែកឯវណ្ណៈធំជាងគេគឺវណ្ណៈកសិករ។ ចំណែកកម្លាំងផ្សេងៗទៀតគឺជាកម្លាំងសំខាន់បន្ទាប់ ពោលគឺកម្លាំងសម្ព័ន្ធមិត្ត។ មូលធនចម្រើនជាតិគឺជាកម្លាំងកលយុទ្ធទីពីរ។ ជំហានបន្ទាប់ទៀត គឺបង្កើតមាគ៌ាយុទ្ធសាស្ត្រ។ ការតស៊ូនៅតាមជនបទ គឺជាការតស៊ូដ៏សំខាន់។ យើងបែងចែកកម្មាភិបាលយើងទៅតាមទីក្រុងនិងជនបទទៅតាមសមត្ថភាពផ្ទាល់ខ្លួន។ មុនឆ្នាំ១៩៦០ មានការច្របូកច្របល់អំពីបញ្ហានេះ។ យើងមិនមានមាគ៌ាបក្សច្បាស់លាស់ទេ។ យើងបានវិវឌ្ឍមូលដ្ឋាននានានៅតាមជនបទ ប៉ុន្តែខ្មាំងបានបំផ្លាញអស់រហូតដល់៩០ភាគរយ។ ហើយម្យ៉ាងទៀតនៅទីក្រុងយើងមិនខ្លាំងទេ។ នៅឆ្នាំ១៩៥៩ យើងដឹងថាយើងខ្វះកម្លាំងយុទ្ធសាស្ត្រដែលចាំបាច់សម្រាប់ជំរុញដំណើរការបដិវត្តន៍ទៅមុខ។

ទើបតែមកដល់ឆ្នាំ១៩៦០ ទើបយើងចាត់តាំងកម្លាំងបានត្រឹមត្រូវ។ កម្លាំងភាគច្រើនចុះទៅធ្វើការជាមួយកសិករ។ មួយចំនួនតូចធ្វើការជាមួយអនុធនសិស្ស និស្សិត។ ចំណែកឯមួយភាគតូចជាងនេះទៀតគឺធ្វើការជាមួយមូលធនជាតិនិងបុគ្គលិកធ្វើការធំៗខាងរដ្ឋបាល។ នៅពេលយើងមានមាគ៌ានេះ

យើងអាចកសាងកម្លាំងយើងបានយ៉ាងឆាប់រហ័ស ។ ជាពិសេស យើងបានកសាងមូលដ្ឋាននៅជនបទ ។ នៅពេលដែលចលនាមហាជនកាន់តែមានកម្លាំងខ្លាំងឡើងៗ យើងអាចបង្កើតការងារស្របច្បាប់និងមិនស្របច្បាប់ ហើយថែមទាំងអាចបង្កើនបាតុកម្មមហាជនថែមទៀតផង ។ ជាពិសេសចាប់ពីឆ្នាំ១៩៦២ដល់ ១៩៦៣ កម្លាំងរបស់យើងកាន់តែខ្លាំងទៅៗ ។

កម្មាភិបាលភាគច្រើនធ្វើការជាមួយប្រជាកសិករដែលកសាងមូលដ្ឋាននៅតាមតំបន់ដាច់ស្រយាលបំផុត ។ កម្មាភិបាលទាំងនោះត្រូវតែសម្របខ្លួនដើម្បីធ្វើការជាមួយប្រជាកសិករ ។ ដំបូងមានបញ្ហាច្រើនណាស់ ។ ចំណែកឯនៅតាមក្រុងវិញ កម្មាភិបាលត្រូវក្លាយជាកម្មករលីសែង ។ លក្ខខណ្ឌការងារនៅទីក្រុងនិងជនបទមានភាពខុសប្លែកពីគ្នាយ៉ាងច្រើន ។ នៅតាមជនបទ ជីវភាពរស់នៅមានលក្ខណៈមិនសូវអំណោយផល ប៉ុន្តែក៏មិនសូវមានខ្មាំងច្រើនដែរ ចំណែកឯនៅទីក្រុង ជីវភាពរស់នៅមានលក្ខណៈប្រសើរជាង ប៉ុន្តែខ្មាំងក៏មានច្រើនដែរ ។ កន្លែងទាំងពីរនេះមានគុណសម្បត្តិនិងគុណវិបត្តិ ។ កម្មាភិបាលត្រូវតែបានជ្រើសរើសទៅតាមនោះ ។ នៅតាមជនបទមានជំងឺគ្រុនចាញ់ច្រើនណាស់ ។ មានកម្មាភិបាលខ្លះមិនព្រមទៅធ្វើការនៅកន្លែងនោះ ប៉ុន្តែនៅទីនោះយើងមានការងារដែលត្រូវធ្វើ ហើយយើងត្រូវតែពង្រឹងជំហរសតិអារម្មណ៍ ។

នៅពេលយើងក្រឡេកមើលថយក្រោយដល់សម័យនោះ យើងមើលទៅមិនគួរបានទទួលជ័យជម្នះដ៏ធំធេងរបៀបនេះទេ បើសិនជាយើងមិនពុះពារឧបសគ្គទាំងនេះ ។ យើងឃើញចំណុចរបត់ពីរៈ ប្រសិនបើយើងមិនបានរៀបចំជាថ្មីម្តងទៀត នៅឆ្នាំ ១៩៦០ ម៉្លេះប្រហែលជាយើងមិនអាចធ្វើការតស៊ូប្រដាប់អាវុធនៅក្នុងឆ្នាំ១៩៦៨បានទេ ។ ហើយប្រសិនបើយើងមិនបានធ្វើការតស៊ូប្រដាប់អាវុធនៅឆ្នាំ១៩៦៨ ក៏យើងមិនអាចម្ចាស់ការលើសភាពការណ៍នៅពេលរដ្ឋប្រហារឆ្នាំ១៩៧០ដែរ ។ បើមិនអនុវត្តដូច្នេះទេ ម៉្លេះខ្មាំងកម្ទេចកម្លាំងយើងអស់បាត់ទៅហើយ ។ ពាក្យថាម្ចាស់ការលើសភាពការណ៍ពឹងផ្អែកលើកម្លាំងយើងផ្ទាល់មានអធិបតេយ្យភាព គឺមានន័យបាន លុះត្រាណាតែយើងមានកម្លាំងប្រជាជននៅក្នុងដៃ ។ បើមិនមានទេ គឺវានឹងធ្លាក់ក្នុងដៃខ្មាំងជាមិនខាន ។ បញ្ហាសំខាន់គឺត្រូវក្តាប់កម្លាំងជាតិនៅក្នុងប្រទេសរបស់យើង ។ នេះគឺជាមេរៀនដ៏សំខាន់សម្រាប់យើង ។

យើងខំសង្កត់ធ្ងន់លើចំណុចត្រឹមត្រូវក្នុងការប្រមូលកងទ័ព ។ ការណ៍នេះសំខាន់ណាស់នៅគ្រប់ដំណាក់កាលបដិវត្ត ។ សព្វថ្ងៃនេះ នៅក្នុងដំណាក់កាលបដិវត្តសង្គមនិយមកម្លាំងយើងខ្លាំងជាងកាលពីសម័យបដិវត្តប្រជាជាតិប្រជាធិបតេយ្យ ។ មុនដំបូង កម្មាភិបាលមានការពិបាកក្នុងការរស់នៅតាមជនបទ ប៉ុន្តែយូរៗទៅគេមានមោទនភាពចំពោះបដិវត្តន៍ ។ គេឃើញអនាគតកូនដោយសារតែបដិវត្តន៍យើងស្អាតស្អំ និងយើងមានឯករាជ្យនិងអធិបតេយ្យភាព ។ កម្មាភិបាលដឹងថាយើងអាចការពារខ្លួនគេឲ្យផុតពីដៃវៀតណាម ហើយគេមានការជឿទុកចិត្តមកលើយើង ។ ចំណែកឯនិស្សិតដែលនៅរៀននៅបរទេសនៅឡើយ មានអ្នកខ្លះគាំទ្រយើង ។ នៅប្រទេសបារាំង សមាគមមួយបានសម្តែងនូវសាមគ្គីភាពជាមួយយើង ហើយប្រឆាំងនឹងវៀតណាម ។ ឥឡូវនេះ យើងខ្លាំងជាងកាលពីការធ្វើបដិវត្តន៍ដំបូង ព្រោះប្រជាជន៨៥ភាគរយជារបស់បដិវត្តន៍ធ្វើជាកម្មករកសិករ ហើយនិស្សិត៨០-៩០ភាគរយក៏ជារបស់បដិវត្តន៍ ។ មានតែ១០ភាគរយទេដែលមិនមែនជារបស់បដិវត្តន៍ ។ យើងព្យាយាមអប់រំប្រជាជនទាំងនេះឲ្យយល់ថាបដិវត្តន៍ល្អសម្រាប់គេនិងកូនចៅរបស់គេ ។ ដូច្នេះយើងកាន់តែខ្លាំងឡើងៗ ។

យើងបានប្រមូលកម្លាំងមកពីគ្រប់ជាន់ថ្នាក់និងគ្រប់សម័យ ពីព្រោះម្នាក់ៗទទួលស្គាល់ស្មារតីស្នេហាជាតិរបស់ជនកុម្មុយនិស្ត ។ ពួកសក្តិភូមិបានតែនិយាយរឿងអាក្រក់ពីវៀតណាមនិងអាមេរិក តែមិនធ្វើអ្វីទាំងអស់ ។ ពួកនេះពុករលួយ និងឲ្យវៀតណាមចូលមក១០០គីឡូម៉ែត្រ ២០០គីឡូម៉ែត្រ កន្លះគីឡូម៉ែត្រចូលមកតាមព្រំប្រទល់ ដោយធ្វើឲ្យនគរបាលកម្ពុជាចេះប្រព្រឹត្តអំពើពុករលួយ ។ វៀតណាមបានវាតចូលមកទឹកដីយើងតាមអ្វីដែលហៅថា «ស្របច្បាប់» ជាពិសេសចូលក្នុងខេត្តតាកែវនិងខេត្តស្វាយរៀង ។ ប៉ុន្តែនៅពេលអំណាចចូលមកក្នុងដៃរបស់បក្ស ម្នាក់ៗឃើញថាយើងអាចលើកទង់ឯករាជ្យបាន ។ អ្នកទាំងនោះដឹងថាជនកុម្មុយនិស្តស្អាតស្អំ រស់នៅជាប្រជាជនសាមញ្ញ ។ កាលពីមុននៅពេលប្រជាជនរស់តាមរបៀបមូលធន សង្គម

មានការបែងចែក ។ នៅពេលប្រជាជនយល់ គេក៏បានដើរតាមផ្លូវកុម្មុយនិស្ត ហើយយើងអាចប្រមូលផ្តុំកម្លាំងដោយស្រួល ។

## VII. ការបង្កើតរណសិរ្សរួបរួមជាតិ

តើយើងធ្វើឲ្យសីហនុចូលជាមួយយើងដោយរបៀបណា? យើងអាចប្រមូលកម្លាំងបានក្រោយរដ្ឋប្រហារពីព្រោះយើងបានរៀបចំទុកជាយូរមកហើយ ។ យើងម្ចាស់ការលើសភាពការណ៍ យើងមានកងទ័ព យើងមានអាវុធមួយចំនួន ។ ហេតុដូចនេះហើយយើងអាចបង្កើតរណសិរ្សរួបរួមជាតិបាន ។ យើងថែមទាំងបានដាក់ឲ្យសម្តេចសីហនុធ្វើជាប្រធានរណសិរ្សនេះទៀតផង ។ វាគ្មានន័យអ្វីទាំងអស់ ពីព្រោះយើងម្ចាស់ការលើសភាពការណ៍ ។ ក្រោយពីមានរដ្ឋប្រហារមក សម្តេចសីហនុ ត្រូវបានដកចេញនូវអ្វីៗគ្រប់យ៉ាងដែលទ្រង់ធ្លាប់មានចំណែក យើងមានអ្វីៗគ្រប់យ៉ាងនៅទីក្រុងក៏ដូចជានៅតាមជនបទដែរ ។ កម្លាំងមកពីមូលដ្ឋានសំខាន់ណាស់សម្រាប់ឲ្យថ្នាក់លើចូលរួមជាមួយយើង ។ នេះជាមេរៀនទីមួយ ។

មេរៀនទីពីរនិងបទពិសោធន៍គឺទាក់ទងជាមួយសកម្មភាពនៅសមរភូមិមុខ យើងនៅមិនបានស្រណុកឡើយ ។ ខ្មាំងបានព្យាយាមធ្វើឲ្យ សម្តេចសីហនុ ពុករលួយ មានដូចជាអាមេរិកបារាំង និងពួកសេរីនិយមសូវៀត ហើយព្យាយាមបំបែកទ្រង់ចេញពីរណសិរ្សនេះ ។ សម្តេច សីហនុ មិនព្រមចេញទេ ពីព្រោះយើងទទួលបានជ័យជម្នះជាបន្តបន្ទាប់ នៅថ្នាក់មូលដ្ឋាន ។ បើមិនទទួលបានជ័យជម្នះដូច្នេះទេ ម៉្លេះសម្តេច សីហនុ ចាកចេញចោលយើងបាត់ទៅហើយ ជាពិសេសនៅឆ្នាំ១៩៧៣ នៅពេលវៀតណាមចូលអង្គុយនៅតុចរចាជាមួយអាមេរិក ។ សីហនុ ខ្លាចណាស់មិនហ៊ាននៅម្នាក់ឯងទេ ។ សម្តេចសួរយើងម្តងហើយម្តងទៀត ថាតើយើងអាចបន្តការតស៊ូទៅមុខទៀតបានទេ ។ សម្តេចចង់ចរចា ប៉ុន្តែយើងបានទូលព្រះអង្គថាយើងអាចបន្តការតស៊ូលុះដល់ទីបញ្ចប់ ។

ទីបីយើងយល់ថាយើងត្រូវតែតស៊ូនៅផ្ទៃក្នុងរណសិរ្សជាមួយសីហនុនៅទន្ទឹមពេលដែលយើងរួបរួមជាមួយទ្រង់ផ្នែកខាងក្រៅ ។ សម្តេចសុំអ្វីយើងឲ្យហ្នឹង ឲ្យតែមិនជ្រុយទៅនឹងទិសនយោបាយយុទ្ធសាស្ត្ររបស់យើង ។ យើងត្រូវតែបត់បែនទៅតាមកាលៈទេសៈ ។ ទិសស្លោករបស់បក្សគឺ «កុំរុញមនុស្សឲ្យចូលខ្មាំង» ។

## VIII. ការតស៊ូនៅទីក្រុង ឆ្នាំ១៩៦០-១៩៧៣

ការតស៊ូរបស់យើងនៅតាមទីក្រុងចែកចេញជាពីរៈ ទីមួយការតស៊ូតាមផ្លូវច្បាប់ ទីពីរការតស៊ូសម្ងាត់ ។ ការតស៊ូនៅតាមទីក្រុងមានសារសំខាន់ដូចគ្នាទៅនិងការតស៊ូនៅតាមជនបទដែរ ។ ប៉ុន្តែឥទ្ធិពលនៃការតស៊ូនេះត្រូវបានចាប់អារម្មណ៍ពេញផ្ទៃប្រទេសនិងលើឆាកអន្តរជាតិ ។ ជាងនេះទៅទៀត ការតស៊ូមានឥទ្ធិពលទៅលើថ្នាក់ដឹកនាំថ្នាក់កណ្តាល ទោះបីជាទីក្រុងជាទីស្នាក់ការនិងក្បាលម៉ាស៊ីនបង្ក្រាបរបស់វណ្ណៈកាន់អំណាចក៏ដោយ ។

កិច្ចការច្បាប់ខ្លះត្រូវបានធ្វើឡើងនៅក្នុងសភាជាតិ ។ យើងមិនចង់បានកៅអីអង្គុយទេ ។ យើងប្រើបុគ្គលស្នេហាជាតិមួយចំនួនដើម្បីបម្រើឲ្យការឃោសនារបស់យើង ។ បុគ្គលថ្នាក់ខ្ពស់ៗទាំងអស់នេះមិនប្រព្រឹត្តក្នុងនាមបក្សទេ ប៉ុន្តែតាមខ្លឹមសារ គឺបក្សនៅពីក្រោយខ្នងការឃោសនានេះ ។ ការងារនេះមានកម្រិតត្រឹមត្រូវ ។ យើងគ្រាន់តែឲ្យប្រជាជនយើងប្រើទិសស្លោកយុទ្ធសាស្ត្រដើម្បីធ្វើឲ្យប្រជាជនភ្ញាក់រឭក ។ នៅទន្ទឹមពេលនេះដែរយើងបានប្រើប្រាស់កាសែតដើរឃោសនា និងសុំឲ្យប្រជាជនដើរតាមតំណាងរាស្ត្រដែលបានចូលមកក្នុងសភាជាតិ ។ នៅក្នុងផ្លូវនេះ យើងធ្វើការនៅខាងលើដោយធ្វើឲ្យប្រជាជនដើរតាមយើង ចំណែកឯយើងវិញធ្វើការនៅតាមមូលដ្ឋាន ។

យើងអាចធ្វើការដោយស្របច្បាប់នៅក្នុងសភាជាតិយ៉ាងនេះក៏ពិតមែន ប៉ុន្តែមានពេលខ្លះតំណាងប្រជាជនរបស់យើងក៏ទទួលរងនូវការបង្ក្រាបដែរ ។ ពេលនោះយើងព្យាយាមធ្វើឲ្យគំនិតយើងជ្រៀតចូលទៅក្នុងតំណាងរាស្ត្រផ្សេងៗទៀតដោយប្រាប់ថា «ប្រសិនបើអ្នកឯងនិយាយអីនេះមួយអីចុះពីរនោះ ប្រជាជននឹងដើរតាម ហើយបោះឆ្នោតឲ្យអ្នកឯងម្តងទៀត» ។ ហើយជួនកាលមានគេសាកល្បងធ្វើតាមយើងដែរ ។ នៅពេលប្រើទិសស្លោករបស់យើងនៅចំពោះមុខប្រជាជន ប្រជាជនទះដៃសាទរ ។ តំណាងរាស្ត្រក៏សប្បាយចិត្តទៅតាមហ្នឹងដែរ ។ ក្រោយមកទៀត តំណាងរាស្ត្រនោះសួរយើងតើ

ត្រូវនិយាយអ្វីទៀតយើងក៏ឆ្លៀតបញ្ចូលទិសស្លោករបស់យើងថែមទៀត ។ សមមិត្តយើងខ្លះយល់មិនដល់ ហើយគិតថាធ្វើយ៉ាងនេះគឺមានន័យថាយើងពង្រីងឥទ្ធិពលរបស់វណ្ណៈកាន់អំណាច ។ ប៉ុន្តែចំពោះយើងវិញ គិតថាទង្វើនេះនឹងមិនមានផលប៉ះពាល់អ្វីឡើយ ។ បើយើងអាចបញ្ចូលខ្លឹមសារនេះដល់ប្រជាជននោះ យើងនឹងបានប្រជាជនមកតាមយើងមិនខាន ។ ការតស៊ូជាមួយកាសែតយើងមានការលំបាកដែរ ។

នៅពេលដែលវណ្ណៈកាន់អំណាចដឹងថាកាសែតមួយចំនួនត្រូវបានបោះផ្សាយជាសម្ងាត់ដោយបក្ស កាសែតនេះនឹងត្រូវបិទទ្វារមិនហួសពីបីខែទេ ។ ហេតុនេះយើងក៏ឲ្យមិត្តយើងសរសេរជាលក្ខណៈអនាមិកចុះក្នុងកាសែតដែលមានចរិតអព្យាក្រឹត ។ ជួនកាលយើងកាត់ចោលកន្លែងខ្លះដើម្បីដកចេញគំនិតមួយចំនួន ។ យើងក៏បានឲ្យប្រជាជនយើងមានប្រតិកម្មតបនឹងអត្ថបទកាសែតប្រតិកិរិយា ដោយសរសេរជាលិខិតសុំឲ្យនិពន្ធនាយកបញ្ឈប់ការចេញផ្សាយទស្សនៈប្រតិកិរិយា ។ ចំពោះកាសែតប្រតិកិរិយាមួយចំនួនដែលមិនមានការបង្ក្រាប យើងបានឲ្យមហាជនធ្វើបាតុកម្មនៅការិយាល័យតែម្តង ។ ក្នុងករណីកាសែតភ្នំពេញប្រេស ដែលជាកាសែតរបស់សេ.អ៊ី.អានិងជាកាសែតប្រតិកិរិយាបំផុតក្នុងចំណោមកាសែតផ្សេងៗទៀតនោះ យើងបានឲ្យប្រជាជនទៅដេញកន្លែងនោះចេញតែម្តង ។ ក្នុងសកម្មភាពនៅទីក្រុងដូចគ្នានេះដែរ យើងបានបង្កើនការសម្តែងសិល្បៈផ្សេងៗឲ្យប្រជាជនមើលនិងរៀបចំដំណើរកម្សាន្តនៅតាមជនបទ មើលពិធីនិងបុណ្យប្រពៃណីផ្សេងៗជាដើម ។ ដោយធ្វើយ៉ាងនេះយើងអាចធ្វើឲ្យកម្លាំងយើងកាន់តែខ្លាំងឡើងៗគ្រប់ជាន់ថ្នាក់នៅក្នុងសង្គម ។

ការជ្រើសរើសទិសស្លោកត្រឹមត្រូវដែលត្រូវតាមសភាព-ការណ៍ជាក់ស្តែងគឺសំខាន់ណាស់ក្នុងការធ្វើការនៅតាមទីក្រុង ។ កុំសួរច្រើនពេក ហើយក៏កុំសួរតិចពេកដែរ ។ ឧទាហរណ៍យើងមិនប្រើពាក្យ«បដិវត្តន៍» «កុម្មុយនិស្ត» ឬ«ក្រហម» ទេ ។ ប៉ុន្តែយើងត្រូវប្រើពាក្យអ្វីដែលគ្រប់ៗគ្នាអាចទទួលយកបានដូចជា«វាយចក្រពត្តិអាមេរិក» «វាយដើម្បីអធិបតេយ្យភាព» ជាដើម ។ ប្រជាជនឮតែពាក្យ«បដិវត្តន៍» និង«កុម្មុយនិស្ត» គឺខ្លាចបាត់ទៅហើយ ។ ប៉ុន្តែយើងធ្វើឲ្យគេសម្របតាមមាគ៌ារបស់បក្សយើងដោយដាក់ចេញនូវមាគ៌ាបក្សតាមខ្លឹមសារជាក់ស្តែង ។ បើធ្វើតាមផ្លូវនេះ យើងអាចឲ្យប្រជាជនដើរតាមមាគ៌ានេះ ពោលគឺប្រជាជនដែលខ្លាច «បដិវត្តន៍» និង «កុម្មុយនិស្ត» ពេលនោះអ្នកទាំងនោះ ទោះបីជាមានការភ័យខ្លាចយ៉ាងណាក៏ដោយក៏អាចជ្រោងទង់បក្សយើងបានដែរ ។

យើងថែមទាំងធ្វើការជាមួយចលនាព្រះសង្ឃទៀតផងដោយធ្វើឲ្យព្រះសង្ឃទាំងនោះដើរតាមយើង តាមរយៈពាក្យថាយើងការពារប្រទេសនិងសាសនា ។ ប្រសិនបើព្រះសង្ឃស្ថិតក្រោមឥទ្ធិពលបរទេសនោះ សាសនាក៏លែងមានទៀតដែរ ។ ដូច្នេះព្រះសង្ឃក៏យ៉ាងដូច្នេះដែរ គឺអាចជ្រោងទង់បក្សទោះបីជាខ្លួនមិនចូលចិត្តកុម្មុយនិស្តក៏ដោយ ។ យើងធ្វើការមិនត្រឹមតែជាមួយព្រះសង្ឃតូចតាចដែលមិនសូវជាប្រតិកិរិយានោះទេ ប៉ុន្តែថែមទាំងជាមួយសម្តេចសង្ឃរាជនានាដែលគ្រប់គ្រងតំបន់ភាគច្រើននៃផ្ទៃប្រទេស ។ យើងប្រើទិសស្លោកដែលប្រឆាំងនឹងការគាបសង្កត់របស់បរទេសមកលើវប្បធម៌កម្ពុជា ។ ពេលនោះព្រះសង្ឃក៏ប្រែជាមានចិត្តស្នេហាជាតិដោយគាំទ្រយើងទាំងមិនដឹងខ្លួន ។

យើងក៏បានធ្វើការជាមួយបុគ្គលធ្វើការខ្ពស់ៗមួយចំនួនដូចជា ប៉ែន នុត ជាដើម ។ យើងត្រូវយកគំនិតរបស់គាត់មិនស្មើ ហើយក៏មិនផ្សព្វផ្សាយដែរ ។ អ្នកស្នេហាជាតិមានឋានៈខ្ពង់ខ្ពស់បែបនេះមិនមែនជាកម្លាំងសំខាន់ទេ ប៉ុន្តែយើងព្យាយាមប្រមូលកម្លាំងឲ្យគាំទ្រការតស៊ូ ជាពិសេសនៅតាមទីក្រុង ។ ឧទាហរណ៍យើងសួរថា «តើឯកឧត្តមមានយោបល់បែបណាប្រសិនបើអាមេរិកវាយកម្ពុជា?» ។ យើងត្រូវគិតអំពីរឿងនេះហើយលួចយកគំនិតរបស់គាត់តើត្រូវធ្វើយ៉ាងម៉េចនោះ ។ នៅពេលនោះ អ្នកថ្នាក់ខ្ពស់ៗស្តាប់យើង ហើយនិយាយទៅកាន់អ្នកផ្សេងទៀតក្រោមឥទ្ធិពលរបស់ខ្លួន ។ ដូច្នេះយើងឃើញថា ប៉ែន នុត មិនដឹងថាយើងឃោសនាឲ្យជនកុម្មុយនិស្តទេ ។

ទាំងនេះគឺជារូបភាពតស៊ូផ្លូវច្បាប់នៅតាមទីក្រុង ។ ប៉ុន្តែយើងផ្តោតសំខាន់សង្កត់ធ្ងន់បំផុតទៅលើការតស៊ូសម្ងាត់ ។ បើគ្មានការតស៊ូសម្ងាត់ការតស៊ូតាមផ្លូវច្បាប់ ក៏មិនទទួលជ័យជម្នះ

ដែរ ។ ការតស៊ូតាមទម្រង់ទាំងពីរនេះមានការទាក់ទងគ្នានិងពឹងពាក់គ្នាទៅវិញទៅមក ប៉ុន្តែការងារសម្ងាត់ គឺមានសារសំខាន់បំផុត ។

យើងត្រូវតែអប់រំកម្មាភិបាលរបស់យើងគ្រប់ពេលវេលាអំពីការងារសម្ងាត់ក៏ដូចជាការងារផ្លូវច្បាប់ ។ ពេលដែលសភាពការណ៍មានភាពងាយស្រួលកម្មាភិបាលចង់ធ្វើការតាមផ្លូវច្បាប់ដើម្បីមានឱកាសបានយសស័ក្តិនិងមាសប្រាក់ ។ ហើយនៅពេលសភាពការណ៍មើលទៅមិនស្រួល កម្មាភិបាលចូលចិត្តធ្វើការសម្ងាត់វិញ ។ ប៉ុន្តែទោះជាតាមផ្លូវមួយណាក៏ដោយ កម្មាភិបាលត្រូវអប់រំខ្លួនបន្តបន្ទាប់ដើម្បីអាចមានលទ្ធភាពរក្សាមុខតំណែងរបស់ខ្លួន ទោះជាមានគ្រោះថ្នាក់ដល់ជីវិតក៏ដោយ ។ កម្មាភិបាលមិនអាចចូលកាន់មុខតំណែងថ្មីផ្សេងទៀតតាមចិត្តខ្លួនចង់ទេ លុះត្រាណាតែមានការអនុញ្ញាតពីបក្សជាមុនសិនទើបទៅរួច ។ នេះគឺជាការងារសតិអារម្មណ៍ ។

ដោយដឹងថាមានការលំបាក យើងក៏មានការប្រុងជើងការជាមុន ។ យើងបានបង្កើតមូលដ្ឋាននៅតាមជនបទដែលអាចទាក់ទាញឲ្យប្រជាជនឲ្យចូលរួមក្នុងការងារសម្ងាត់នៅតាមទីក្រុង ។ ប៉ុន្តែនៅពេលបែកការណ៍សម្ងាត់ កម្មាភិបាលទាំងនោះមិនត្រូវបានឲ្យធ្វើការសម្ងាត់នៅតាមជនបទឡើយ ។ ពេលបែកការណ៍សម្ងាត់ហើយ គឺធ្វើការបេញចំហធម្មតា? ។ យើងត្រូវប្រុងប្រយ័ត្នអំពីកន្លែងដែលប្រជាជនទៅ ដើម្បីឲ្យដឹងជាមុន ។ ប្រសិនបើប្រជាជនទៅមែន ខ្មាំងនឹងដឹងមិនខានឡើយ ។ នៅពេលកម្មាភិបាលមានបញ្ហា កម្មាភិបាលតែងតែសុំឲ្យបញ្ជូនខ្លួនទៅជនបទ ទោះបីជាការសម្ងាត់មិនទាន់បែកខ្ទេចខ្ទាយក៏ដោយ ។ ដោយសារតែយ៉ាងដូច្នេះហើយបានជាយើងត្រូវធ្វើការមួយជំហានម្តងៗ ជាមួយគោលជំហរសតិអារម្មណ៍ ហើយយើងត្រូវយកចិត្តទុកដាក់ទៅលើអ្នកដែលធ្វើការនៅតាមទីក្រុង ទោះជាសម្ងាត់ឬតាមផ្លូវច្បាប់ក៏ដោយ ដោយសង្កេតជាពិសេសលើជីវភាពរស់នៅនិងស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកទាំងនោះ ។ អ្នកដែលធ្វើការជាសម្ងាត់មិនអាចរកការងារធ្វើបានដូចប្រជាជនធម្មតាបានទេ ដូច្នេះយើងត្រូវជួយគេឲ្យរកការងារបានធ្វើខ្លះផង ។

ផ្អែកលើមាគ៌ាត្រឹមត្រូវរបស់បក្ស យើងអាចកសាងនិងការពារកម្លាំងរបស់យើងបាន ។ កម្លាំងមួយចំនួនត្រូវខ្មាំងកម្ទេច ប៉ុន្តែភាគច្រើនយើងការពារបានជាពិសេសនៅក្រោយរដ្ឋប្រហារនៅឆ្នាំ១៩៧០ នៅពេលដែលយើងមានតំបន់រំដោះយ៉ាងធំ ។ ទីតាំងមូលដ្ឋានដ៏សំខាន់បំផុតរបស់យើង គឺស្ថិតក្នុងភាពសម្ងាត់ សូម្បីតែគ្រឿងអេឡិចត្រូនិករបស់អាមេរិកក៏មិនអាចរកឃើញដែរ ។ ទោះបីជាការទម្លាក់គ្រាប់បែករបស់អាមេរិកធ្វើឲ្យមានភាពខូចខាំយ៉ាងច្រើនក៏ដោយ ក៏ការទម្លាក់នេះមិនសូវជាមានប្រសិទ្ធភាពប៉ុន្មានឡើយ ដោយសារយើងនៅស្អិតជាប់ជាមួយមាគ៌ាតស៊ូសម្ងាត់របស់យើង ។ កងកម្លាំងវៀតណាមនៅក្នុងប្រទេសវៀតណាមមិនសូវលាក់ ជិតនិងសម្ងាត់ដូចយើងទេ ដូច្នេះហើយបានជាត្រូវកម្ទេចអស់ច្រើនជាងយើង ។ សូម្បីតែវៀតណាមនៅទីនេះក៏ទទួលរងការវាយប្រហារញឹកជាងយើងដែរ ។ ប្រជាជននិងកងទ័ពយើងហៅបេ-៥២ថា «ខ្វាក់ភ្នែក» ។ ពេលវាមក វាទម្លាក់គ្រាប់បែកមិនចេះមើលចេះតែទម្លាក់ ។ វាមិនដែលខ្វល់ថាតើទម្លាក់ហ្នឹងត្រូវគោលដៅ ឬក៏អត់ទេ ។ ប្រជាជនយើងមិនខ្លាចបេ-៥២ ណាស់ណាទេ ។

យើងដឹងថាយើងរក្សាបាននូវការសម្ងាត់ ការតស៊ូរបស់យើងអាចបន្តទៅមុខតាមតែការចាំបាច់ ។ សូម្បីតែកាំភ្លើងការណុងធំធ្វើនៅអាមេរិកក៏មិនមានប្រសិទ្ធភាពដែរ ព្រោះវាមិនដឹងថាយើងជានរណា ហើយនៅកន្លែងណា ។ មានគ្នាយើងមួយចំនួនត្រូវគ្រាប់ដែរ តែមួយចំនួនតូចប៉ុណ្ណោះ ។ តែយើងបានប្រាប់កម្មាភិបាលយើងថាកុំឲ្យភ័យពេកនិងឲ្យលាក់ខ្លួនពេលនោះយើងអាចបណ្តេញចក្រពត្តិអាមេរិក ។

## ពន្យល់ពាក្យខ្មែរក្រហម

◆ **យោធាបដិវត្តល្អៈ** យោធាដែលបំពេញភារកិច្ចគ្រប់មុខបានល្អដោយគ្មានលក្ខខណ្ឌ ពេលមានពេលក្រ ពេលអត់ពេលស្រួល ពេលលំបាក ពេលឈ្នះពេលចាញ់ជាបណ្តោះអាសន្ន ពេលឈ្នះទាំងស្រុង ចូលទីក្រុងក៏គ្មានលក្ខខណ្ឌ ។

(កំណត់ហេតុលេខ១០៨ កណាហ១៨៥)

# ៥ឆ្នាំនៃការធ្វើផែនទីរណ្តៅសាកសពគុក និងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម

ក្នុងរយៈកាល៥ឆ្នាំកន្លងមកនេះក្រោមកិច្ចគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជានិងការធានាសន្តិសុខដោយក្រសួងមហាផ្ទៃព្រមជាមួយនឹងកិច្ចសហប្រតិបត្តិការ ជាពិសេសពីសំណាក់អភិបាលខេត្ត មន្ត្រីដឹកនាំស្រុក ឃុំ ភូមិ និងអ្នកស្រុក មជ្ឈមណ្ឌលឯកសារកម្ពុជាមានលទ្ធភាពចងក្រងបានឯកសារជាលក្ខណៈវិទ្យាសាស្ត្រតាមប្រពន្ធ័ផ្កាយរណបនូវទីតាំងគុកនៃរបបខ្មែរក្រហមបានចំនួន **១៥៨(មួយរយហាសិបប្រាំបី)** កន្លែង ។ រណ្តៅសាកសពរួមចំនួន**១៨៩៧៥ (មួយម៉ឺនប្រាំបីពាន់ប្រាំបួនរយចិតសិបប្រាំ)** កន្លែងដែលមានផ្នុកអ្នកស្លាប់ប្រមាណ **១ ២០៥ ៦៦២ (មួយលានពីរសែន សូន្យម៉ឺនប្រាំពាន់ប្រាំមួយរយហុកសិបពីរ)** នាក់ ។ ចំនួនជនរងគ្រោះនេះគឺរាប់តែនៅជុំវិញបរិវេណគុក និងរណ្តៅសាកសពតែប៉ុណ្ណោះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានកត់ត្រាទុកនូវទីតាំងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះដែលសាងសង់ឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាចំនួន**៧៦ (ចិតសិបប្រាំមួយ)** កន្លែងដែរ ។

ការស្រាវជ្រាវផែនទីរណ្តៅសាកសពធ្វើឡើងនៅក្នុងស្រុកចំនួន **១២៩ (មួយរយម្ភៃប្រាំបួន)** នៃខេត្តចំនួន **២៣(ម្ភៃបី)** (រាប់បញ្ចូលទាំងក្រុងកែបផង) ។ ទិន្នន័យជាប្រវត្តិសាស្ត្រនេះមិនទាន់ប្រមូលបានមួយរយភាគរយនៅឡើយទេ ប៉ុន្តែមានលក្ខណៈគ្រប់គ្រាន់ក្នុងការចង្អុលបង្ហាញឲ្យឃើញអំពី “រង្វាស់នៃការសម្លាប់រង្គាល” ដែលប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ផែនទីដែលបោះពុម្ពផ្សាយភ្ជាប់មកជាមួយនេះត្រូវបានរៀបចំបញ្ចូលធ្វើឡើងនៅក្នុងប្រពន្ធ័កុំព្យូទ័រដោយសកលវិទ្យាល័យយ៉េលសហរដ្ឋអាមេរិកសហការជាមួយសកលវិទ្យាល័យ នៅប្រទេសអូស្ត្រាលី ហើយដែលអាចសិក្សាស្រាវជ្រាវបានតាមរយៈប្រពន្ធ័អ៊ីនធ័រណែត ។ ផែនទីរណ្តៅសាកសពតាមបណ្តាខេត្តនីមួយៗក៏បានបោះពុម្ពរួចជាស្រេចហើយ សម្រាប់បម្រើការសិក្សាស្រាវជ្រាវជាប្រវត្តិសាស្ត្រអំពីការប្រល័យពូជសាសន៍នៅកម្ពុជា ។ នៅលើចំណុចនីមួយៗដែលដៅនៅលើផែនទីនេះមានផ្ទុកនូវពត៌មានដើម រួមមានឯកសារ រូបថត កសិណសាក្សីរបស់ជនរងគ្រោះនិងកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមជាដើម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងសហការជាមួយសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងដើម្បីយកផែនទីនេះទៅជំនួសផែនទីលលាដ៏ក្បាលសាកសពជនរងគ្រោះដែលកំពុងដាក់តាំងនៅក្នុងសារមន្ទីរទួលស្លែង ។ **ផេង ពង្សរ៉ាស៊ី**



ក្រុមអ្នកស្រាវជ្រាវនិងសាក្សី (ស្រុកថ្ពង ខេត្តកំពង់ស្ពឺ)

# ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍

## ការធ្វើផែនទីវាលពិឃាតនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥-២០០០

| ល.រ | លេខកូដទីតាំង | ឈ្មោះទីតាំង | ទិន្នន័យរណ្ដៅនិងជនរងគ្រោះ តាមជាក់ស្តែង | | ទិន្នន័យរណ្ដៅនិងជនរងគ្រោះ តាមរបាយការណ៍ | | របាយការណ៍ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ប៉ាន់ស្មានរណ្ដៅ | ប៉ាន់ស្មានជនរងគ្រោះ | ប៉ាន់ស្មានរណ្ដៅ | ប៉ាន់ស្មានជនរងគ្រោះ | |
| ១ | ០៣០៣០១ | វត្តស្គន់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ២ | ០៣០៣០២ | វត្តស្គន់ | ៤០០ | ជាង៥០០០ | ជាង៤០០ | ជាង៥០០០ | ១៩៩៥/៩៦ |
| ៣ | ០៣០៣០៣ | ដីតាប្រាង | ជាង១០០ | ជាង២០០០ | ជាង១០០ | ជាង២០០០ | ១៩៩៥/៩៦ |
| ៤ | ០៣០៣០៤ | ឡធ្យូង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៥ | ០៣០៣០៥ | ឡធ្យូង | ជាង២០០ | គ្មាន | ជាង៤០០ | គ្មាន | ១៩៩៥/៩៦ |
| ៦ | ០៣០៦០១ | វត្តនគរ | គ្មាន | ជាង១០០០ | គ្មាន | ជាង១០០០ | ១៩៩៥/៩៦ |
| ៧ | ០៣០៦០២ | វត្តភ្នំប្រុស | ៤៧ | ជាង១០០០០ | ៤៧ | ជាង១០០០០ | ១៩៩៥/៩៦ |
| ៨ | ០៣០៧០១ | វត្តអូរត្រកួន | ៤៦៧ | ៣២៦៩០ | ៤៦៧ | ៣២៦៩០ | ១៩៩៥/៩៦ |
| ៩ | ០៣០៧០២ | វត្តអូរត្រកួន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ១០ | ០៣០៧០៣ | វត្តអូរត្រកួន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ១១ | ០៣០៧០៤ | វត្តនិគ្រោធ | ១៨៦ | ១១១៦០ | ១៨៦ | ១១១៦០ | ១៩៩៥/៩៦ |
| ១២ | ០៣០៧០៥ | វត្តនិគ្រោធ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ១៣ | ០៣០៩០១ | ទ្រា ២ | គ្មាន | ១០០០ | ៨ | គ្មាន | ១៩៩៥/៩៦ |
| ១៤ | ០៣០៩០២ | កោះផល | ៤៩ | ៥១០០០០ | ៤៩ | ៥០០០-១០០០០ | ១៩៩៥/៩៦ |
| ១៥ | ០៣១៥០១ | វត្តស្ទឹងត្រង់ | ២៧ | ៥០០០ | ២៧ឬលើស | ជាង១០០ | ១៩៩៥/៩៦ |
| ១៦ | ០៣១៦០១ | ចម្ការស្វាយ | ១៧ | ជាង១០០០ | ១៧ | គ្មាន | ១៩៩៥/៩៦ |
| ១៧ | ០៣១៦០២ | ចម្ការស្វាយ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ១៨ | ០៣១៦០៣ | វត្តវិហារទន្ទឹង | គ្មាន | ជាង១០០ | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ១៩ | ០៣១៦០៤ | សាលាស្ងួន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ២០ | ០៣១៦០៥ | ចម្ការម្នាស់ | ២ | ជាង១០០០ | ២ | គ្មាន | ១៩៩៥/៩៦ |
| ២១ | ០៣១៦០៦ | ក្បាលជ្រោយ | ជាង៥០ | ជាង៥០០០ | គ្មាន | ជាង១០០ | ១៩៩៥/៩៦ |
| ២២ | ០៧០១០១ | មន្ទីរតាម៉ឺន | ១៣៦(១៨២) | ៣០៤៧ | ១៣៦ | គ្មាន | ១៩៩៥/៩៦ |
| ២៣ | ០៧០៣០១ | វត្តស្ទឹង | គ្មាន | ៣២៥ | ៣២៥ | គ្មាន | ១៩៩៥/៩៦ |
| ២៤ | ០៧០៥០១ | ភ្នំល្អាង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ២៥ | ០៧០៥០២ | ភូមិល្អាង | ជាង១០០ | ១០០០០ | ជាង១០០ | គ្មាន | ១៩៩៥/៩៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៦ | ០៧០៧០១ | វត្តដុំក្រៀល | គ្មាន | ១០០ | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ២៧ | ០៧០៧០២ | វត្តកំពង់ត្រឡាច | ២ | ៧៥០ | ២ | ៧៥០ | ១៩៩៥/៩៦ |
| ២៨ | ០៧០៧០៣ | ព្រៃត្រពាំងស្ពោ | ១១ | ៥៨១ | ១១ | ៥០៨ | ១៩៩៥/៩៦ |
| ២៩ | ០៧០៧០៤ | ស្ថានីយ៍ប្រេងសែស្រូល | គ្មាន | គ្មាន | គ្មាន | ប្រហែល៤០ | ១៩៩៥/៩៦ |
| ៣០ | ០៨០១០១ | សាលាត្រពាំងស្វា | គ្មាន | ជាង៣០០០ | ៩៥ឬលើស | ៧០០០-១០០០០ | ១៩៩៥/៩៦ |
| ៣១ | ០៨០១០២ | ទួលយាយបូ | ជាង១០០ | ៧០០០-១០០០០ | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៣២ | ០៨០១០៣ | ទន្លេបាទី | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៣៣ | ០៨០២០១ | វត្តចំពុះក្អែក | ៨៥ | ១៨៦៦៤ | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៣៤ | ០៨០២០២ | វត្តចំពុះក្អែក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៣៥ | ០៨០២០៣ | វត្តចំពុះក្អែក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៣៦ | ០៨០៤០១ | ពោធិ៍ទន្លេ | ៥៥ | ៣៥០២៧ | ៥៥ | ៣៥០២៧ | ១៩៩៥/៩៦ |
| ៣៧ | ០៨០៤០២ | ពោធិ៍ទន្លេ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៣៨ | ០៨០៤០៣ | ពោធិ៍ទន្លេ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៣៩ | ០៨០៥០១ | វត្តព្រែកដាច់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៤០ | ០៨០៥០២ | កោះកន្ធាយ | ២០០ | ៤៥០០ | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៤១ | ០៨០៥០៣ | កោះកន្ធាយ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៤២ | ០៨១០០១ | កោះគរ | (?)៥ | (?)៧០០០ | ៥ | ៥០០០-៧០០០ | ១៩៩៥/៩៦ |
| ៤៣ | ០៨១០០២ | កោះគរ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៤៤ | ០៨១០០៣ | កោះគរ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៤៥ | ០៨១០០៤ | កោះថ្មី | ជាង២០០ | ជាង២០០០ | ប្រហែល២០០ | ប្រហែល៥-៧០០០ | ១៩៩៥/៩៦ |
| ៤៦ | ០៨១០០៥ | កោះថ្មី | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៤៧ | ១៤០១០១ | ភ្នំកំដុក | ជាង២៥០ | ជាង១៧២០០ | ជាង២៥០ | គ្មាន | ១៩៩៥/៩៦ |
| ៤៨ | ១៤០២០១ | តាសំ | ២ | គ្មាន | ២ | គ្មាន | ១៩៩៥/៩៦ |
| ៤៩ | ១៤០២០២ | តាសំ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៥០ | ១៤០២០៣ | ព្រៃបឹងព្រួស | ៦២ | ៥០០០ | ៦២ | ជាង៥០០០ | ១៩៩៥/៩៦ |
| ៥១ | ១៤០២០៤ | ព្រៃបឹងព្រួស | គ្មាន | ២០០០ | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៥២ | ១៤០២០៥ | វត្តតាកេង | ១៥-២០ | គ្មាន | ១៦ឬលើស | គ្មាន | ១៩៩៥/៩៦ |
| ៥៣ | ១៤០៧០១ | វត្តពាម | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៥៤ | ១៤០៧០២ | វត្តជ្រោយ | ១៥ | គ្មាន | ១៥ | គ្មាន | ១៩៩៥/៩៦ |
| ៥៥ | ១៤០៨០១ | ទួលស្វាង | ៨៦ | ១៥០០០ | ៨៣ | ១៥០០០ | ១៩៩៥/៩៦ |
| ៥៦ | ១៤០៨០២ | វត្តស្វា | ៨៦ | ៥២៥០ | ៨៦ | ៥២៥០ | ១៩៩៥/៩៦ |

◆ តួលេខនេះសម្រាប់ខេត្តដែលចុះស្រាវជ្រាវរួចមកហើយ គឺខេត្តកំពង់ចាម កំពត កណ្តាល និងព្រៃវែង ។ **(នៅមានត)**

# ហួត សម្បត្តិ

*រយៈកាលនៃសង្គ្រាម៥ឆ្នាំ១ខែ(ចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥) ត្រូវបានខ្មែរក្រហមចាត់ទុកថាជាដំណាក់កាលនៃសង្គ្រាមរំដោះជាតិនិងរំដោះប្រជាជន ។ ការតស៊ូនេះបានទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាពេលដែលខ្មែរក្រហមឬរបបកម្ពុជាប្រជាធិបតេយ្យឡើងកាន់អំណាច ។ មុនពេលដែលទទួលបានជ័យជម្នះ និស្សិត បញ្ញវ័ន្ត មន្ត្រីរាជការ ឬអង្គទូតមួយចំនួនក្នុងរបបមុនៗបានចេញទៅបរទេសដើម្បីសិក្សាឬបំពេញភារកិច្ចរៀងៗខ្លួន ។ ក្នុងចំណោមអ្នកទាំងនោះ ភាគច្រើនពុំបានដឹងច្បាស់ថាតើស្ថានការណ៍នយោបាយដែលកំពុងតែបានកើតឡើងក្នុងស្រុកខ្មែរយ៉ាងណាឡើយ បន្ទាប់ពីថ្ងៃរំដោះ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ហួត សម្បត្តិ គឺជាអតីតអង្គទូតរណសិរ្សរួបរួមជាតិកម្ពុជា ប្រចាំនៅប្រទេសយូហ្គោស្លាវី ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ និងក្រោយពីរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជាត្រូវបានបង្កើតឡើង ។ ហួត សម្បត្តិ បានត្រឡប់ចូលស្រុកខ្មែរវិញ ហើយត្រូវបានអង្គការចាប់ឃុំខ្លួននិងសួរចម្លើយនៅមន្ទីរស-២១(ឬគុកទួលស្លែង) នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ និងត្រូវបានកម្ទេចចោល ដោយចោទថាក្បត់បដិវត្តន៍នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ។*

*ក្នុងចម្លើយសារភាពរបស់ ហួត សម្បត្តិ បានឲ្យដឹងថា «ជាធម្មតា អ្នកណាចូលរណសិរ្សត្រូវមកប៉េកាំងសិន ដើម្បីទទួលការអប់រំរួចបានចេញទៅបរទេស...មន្ទីរបេសកកម្មរណសិរ្សរួបរួមជាតិនៅប៉ារីស» ។ រដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជាបានតែងតាំង គិម ស្រុន ជាឯកអគ្គរដ្ឋទូតប្រចាំប្រទេសតង់សានីនៅឆ្នាំ១៩៧២ ។ ង៉ួន ពីទូរ៉េត ត្រូវបានតែងតាំងឲ្យធ្វើជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសម៉ូរីតានី ។ ហោ ណាំហុងត្រូវបានតែងតាំងឲ្យធ្វើជាអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសគុយបា ។ នូ ពេច ត្រូវបានតែងតាំងឲ្យធ្វើជាអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសឈីលីនៅឆ្នាំ១៩៧៣ ។ ហួត សម្បត្តិ បានឲ្យដឹងទៀតថា «ក្នុងរយៈកាលនៃសង្គ្រាម៥ឆ្នាំ១ខែកន្លងទៅនេះ ខ្ញុំបានមកប៉េកាំងតែបីដងប៉ុណ្ណោះ គឺឆ្នាំ១៩៧១ មករៀនសូត្រក្រោមការដឹកនាំរបស់បងអៀង សារី ។ ឆ្នាំ១៩៧៣ ដោយសីហនុ ហៅមកជាមួយនិងមិត្ត ជា សាន ។ ឆ្នាំ១៩៧៥ ព្រោះម្តាយរបស់ សីហនុ បានស្លាប់» ។*

*នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៥ ហួត សម្បត្តិ បានវិលត្រឡប់មកដល់ភ្នំពេញ ។ នៅខែសីហា ឆ្នាំ១៩៧៥ មុនមកដល់ភ្នំពេញ ដួន អេន បានប្រាប់ ហួត សម្បត្តិ ថា «ក្រសួងការបរទេសបានអញ្ជើញមេដឹកនាំបេសកកម្មទូតនិងនយោបាយទាំងអស់ឲ្យមកប្រជុំរៀនសូត្រនៅភ្នំពេញក្នុងរយៈពេល១០ថ្ងៃ» ។ ដួន អេន បានបន្តថា «សេ.អ៊ី.អា បានចាត់តាំងក្រុមមួយដែលមានមនុស្សប្រាំមួយនាក់ដើម្បីមកកម្ពុជាប្រមូលពត៌មានពីកម្ពុជា រួចយកទៅបរទេស» ។*

*អ្នកដែលបានវិលចូលមកក្នុងប្រទេសវិញនៅពេលសង្គ្រាម ឬអ្នកដែលចូលមកក្រោយថ្ងៃរំដោះ១៧ ខែមេសា ឆ្នាំ១៩៧៥ កម្រនឹងមានឱកាសចេញទៅក្រៅប្រទេសវិញណាស់ ។ ព្រោះក្រោយពីរៀនសូត្រចប់ ហើយបានឆ្លងប្រវត្តិរូបនិងជីវទស្សន៍រួចមកអ្នកទាំងអស់នោះត្រូវបានអង្គការបាត់បែងជាពីរក្រុមឲ្យចុះទៅជនបទ ។ ការចេញទៅរស់នៅឯជនបទក៏ពុំមានកំណត់ពេលវេលាច្បាស់លាស់ដែរ ។*

*ខាងក្រោមនេះជាប្រវត្តិនិងសកម្មភាពរបស់ ហួត សម្បត្តិ ដែលត្រូវបានសួរចម្លើយចំនួន១២លើកចាប់ពីថ្ងៃទី១០ខែកញ្ញា ឆ្នាំ១៩៧៦រហូតដល់ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦ ។ ប៉ុន្តែសុំបញ្ជាក់ថាឯកសារដែលផ្ញើនៅពីមន្ទីរស-២១(ឬគុកទួលស្លែង) ពុំឃើញមានចម្លើយសារភាពលើកទី៣ ទី៤ ទី៨ និងលើកទី៩ ឡើយ ។*

## *ប្រវត្តិសង្ខេបមុនរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០*

*នៅឆ្នាំ១៩៤៩ ហួត សម្បត្តិ បានចេញទៅរៀននៅប្រទេសបារាំង បន្ទាប់ពីបងប្រុសរបស់ខ្លួនឈ្មោះ ហួត សុវណ្ណ*

ស្លាប់ដោយស្នាដៃអាណានិគមនិយមបារាំងក្នុងឆ្នាំ១៩៤៩ ។ នៅខែវិច្ឆិកា ហួត សម្បត្តិ បានទៅដល់ប្រទេសបារាំង ហើយបានទៅរក ឌុក រ៉ាស៊ី ដែលធ្លាប់រៀនសូត្រជាមួយបងប្រុសរបស់ខ្លួន ។ បន្ទាប់មក ឌុក រ៉ាស៊ី ក៏បាននាំ ហួត សម្បត្តិ ទៅជួប សម សារី និង ម៉ៅ សាយ(ដែលពីមុនមកពុំធ្លាប់ស្គាល់គ្នាសោះ) ។ គោលបំណងរបស់ ហួត សម្បត្តិ ដែលទៅស្រុកបារាំងនោះ គឺចង់ធ្វើចលនាបណ្តេញអាណានិគមនិយមបារាំងចេញឲ្យអស់ពីកម្ពុជា ដើម្បីបន្តបេសកកម្មបងប្រុសរបស់ខ្លួនដែលបានស្លាប់ដោយសារស្នាដៃ អាណានិគមបារាំង ។ ហួត សម្បត្តិ បានទៅជួប ហើយទាក់ទងជាមួយ សាក់ដុយក្លូ និងអង់ដ្រេ ម៉ាទី ដែលជាសមាជិកគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តបារាំង (កាលឆ្នាំ១៩៥០ អង់ដ្រេ ម៉ាទី មិនទាន់ត្រូវបានគណៈកម្មាធិការមជ្ឈិមបណ្តេញចេញពីបក្សនៅឡើយទេ) ។ ជនជាតិបារាំងទាំងពីររូបនេះបានឲ្យ ហួត សម្បត្តិ ទៅជួបនឹងបក្សកុម្មុយនិស្តឥណ្ឌូចិន (ដែលមានវៀតណាមជាអ្នកដឹកនាំ) ។ បារាំងចង់ឲ្យកម្ពុជាធ្វើជារណបវៀតណាម ហើយពេលនោះ សម សារី និង ម៉ៅ សាយ បានប្រាប់ ហួត សម្បត្តិ ថា «មានតែផ្លូវមួយគត់ គឺចូលដៃជាមួយចក្រពត្តិអាមេរិក ពីព្រោះមានតែចក្រពត្តិអាមេរិកទេដែលអាចបង្ខំឲ្យបារាំងផ្តល់ឯករាជ្យដល់កម្ពុជា ។ ចំណែកពួកកុម្មុយនិស្តគ្មានលទ្ធភាពនឹងបណ្តេញបារាំងបានទេ» ។ សម សារី ម៉ៅ សាយ និង ឌុក រ៉ាស៊ី គឺជាអ្នកប្រឆាំងមិនឲ្យពួកកុម្មុយនិស្តចូលស្រុកខ្មែរ ។ ហួត សម្បត្តិ បានដឹងថា សម សារី ជាភ្នាក់ងារសេ.អ៊ី.អានៅឆ្នាំ១៩៥៨ (ពេលក្បត់ជាមួយ ដាប ឈួន) ។ រីឯ ម៉ៅ សាយ និង ឌុក រ៉ាស៊ី គឺជាភ្នាក់ងារសេ.អ៊ី.អាក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។



ហួត សម្បត្តិ មុនពេលចាប់ខ្លួន



ហួត សម្បត្តិ ពេលចាប់ខ្លួននៅមន្ទីរស-២១

ក្នុងចម្លើយសារភាពរបស់ ហួត សម្បត្តិ លើកទី១ បានបញ្ជាក់ជូនអង្គការថា «នៅប្រទេសបារាំង កាលខ្ញុំបាទនៅរៀន ខ្ញុំបាទគ្មានការទាក់ទងផ្ទាល់នឹងអាពួកភ្នាក់ងារអាសេ.អ៊ី.អាសញ្ជាតិអាមេរិកទេ តែមានការទាក់ទងយូរៗម្តងជាមួយនឹងអាបីនាក់ខាងលើនេះ» ។

នៅឆ្នាំ១៩៥០ ហួត សម្បត្តិ បានផ្ញើសំបុត្រមួយផ្ញើតាមរយៈ បែនសាមាំង កូហែន (អគ្គលេខាធិការនៃអង្គការសហប្រជាជាតិដែលមកប្រជុំធំនៅទីក្រុងប៉ារីស) ទៅឲ្យរដ្ឋមន្ត្រីការបរទេសអាមេរិកឈ្មោះ អែនជីសុន និយាយអំពីស្រុកខ្មែរពេលនោះថា ប្រជាជនទូទៅចង់បានឯករាជ្យ បណ្តេញអាណានិគមនិយមបារាំងចេញពីប្រទេសកម្ពុជា ប៉ុន្តែរដ្ឋមន្ត្រីអាមេរិករូបនោះមិនបានឆ្លើយតបមក ហួត សម្បត្តិ វិញទេ ។

ចាប់តាំងពីឆ្នាំ១៩៥២ ហួត សម្បត្តិ ធ្វើការឲ្យសម្តេច ប៉ែន នុត ដែលជានាយករដ្ឋមន្ត្រីទី១នៃរបបសង្គមរាស្ត្រនិយម ដោយធ្វើសេចក្តីរាយការណ៍តាមរយៈការកាត់កាសែតផ្ញើមកភ្នំពេញក្នុងមួយសប្តាហ៍ម្តង ។ ហួត សម្បត្តិ ត្រូវទិញនិងអានកាសែតទាំងអស់ដែលមាននៅក្រុងប៉ារីស ។ សម្តេច ប៉ែន នុត បានផ្ញើប្រាក់ជារៀងរាល់ខែសម្រាប់ទិញកាសែតនិងសម្រាប់ថ្លៃផ្ញើតាមប្រអប់សំបុត្រ ។ យូរៗម្តង សម្តេច ប៉ែន នុត បានផ្ញើប្រាក់ឲ្យ ហួត សម្បត្តិ ចំនួន៥០០០ ឬ១០០០០ហ្វ្រង់សម្រាប់ចំណាយផ្ទាល់ខ្លួន ។

នៅឆ្នាំ១៩៥៣ ហួត សម្បត្តិ បានដកខ្លួនចេញពីសមាគមខ្មែរនៅស្រុកបារាំងដោយយល់ឃើញថា សកម្មភាពបំបែកបំបាក់និស្សិតនិងកម្មករខ្មែរនៅស្រុកបារាំងកាន់តែខ្លាំងឡើងៗ ។ ហួត សម្បត្តិ ត្រូវបានសម្តេច ប៉ែន នុត ឲ្យបន្តធ្វើសេចក្តីរាយការណ៍តាមរយៈកាសែតដើម្បីតាមដានសន្និសីទហ្សឺណែវ(១៩៥៤) ។ នៅពេលមានសន្និសីទសេដ្ឋកិច្ចមួយនៅទីក្រុងប៉ារីស ប្រទេសបារាំង(១៩៥៤-៥៥) ដែលមានប្រទេសចំនួន៤ចូលរួម ក្នុងនោះមានខ្មែរ វៀតណាមខាងត្បូង

ឡាវ និងបារាំង សម្តេច ប៉ែន នុត បានតែងតាំង ហួត សម្បត្តិ ឲ្យធ្វើជាសមាជិកនៃគណៈប្រតិភូខ្មែរទទួលភារកិច្ចទាក់ទងនឹងអ្នកកាសែត ។

រហូតមកដល់ខែមីនា ឆ្នាំ១៩៥៥ ហួត សម្បត្តិ បានត្រឡប់មកស្រុកខ្មែរ ហើយបានសង្កេតឃើញថា អ្នកធ្វើការឲ្យក្រសួងសម្ងាត់បរទេសមានច្រើនណាស់នៅភ្នំពេញ ។ ចក្រពត្តិអាមេរិកកំពុងតែធ្វើសកម្មភាពទាក់ទាញកម្ពុជាឲ្យចូលក្នុងអង្គការអូតាស (OTASE គឺជាពាក្យកាត់នៃភាសាបារាំងស្មើនឹងពាក្យកាត់ជាភាសាអង់គ្លេសថា SEATO មានន័យជាភាសាខ្មែរថា “អង្គការសន្ធិសញ្ញាអាស៊ី-អគ្នេយ៍” ដែលស្រដៀងគ្នាទៅនឹងអង្គការ NATO ដែរ ។ អង្គការនេះត្រូវបានរលាយបាត់ទៅវិញនៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ហើយប្រហែលជាត្រូវបានជំនួសដោយពាក្យថា ASEAN ។ ភាពខុសគ្នាត្រង់ថា SEATO ជាអង្គការបម្រើឲ្យផ្នែកសន្តិសុខ ឬយោធាដែលបង្កើតឡើងដើម្បីទប់ទល់ឥទ្ធិពលរបស់ចិនកុម្មុយនិស្ត ។ ចំណែកឯ ASEAN ផ្តោតជាសំខាន់ទៅលើផ្នែកសេដ្ឋកិច្ច) ។ ក្នុងអំឡុងខែតុលា វិច្ឆិកា និងខែធ្នូ ឆ្នាំ១៩៥៥ ហួត សម្បត្តិ ត្រូវបាន សម្តេច សីហនុ តែងតាំងជារដ្ឋលេខាធិការក្រសួងសិក្សាធិការនិងក្រសួងកិច្ចការបរទេស ។ ពេលនោះ សម សារី ជារដ្ឋមន្ត្រីក្រសួងសិក្សាធិការ ។ ទីប្រឹក្សាស្ថានទូតអាមេរិកម្នាក់ឈ្មោះ ម៉ាទីន ហេត្ស ច្រើនមកទាក់ទងជាមួយ ហួត សម្បតិ សួរនាំអំពីស្ថានការណ៍នយោបាយក្នុងស្រុកខ្មែរ ។ ប៉ុន្តែក្រោយពីទីប្រឹក្សាស្ថានទូតអាមេរិកចាកចេញពីភ្នំពេញទៅ លោក ម៉ាទីន ហេត្ស បានសរសេរសៀវភៅមួយរិះគន់អំពីសម្តេច សីហនុ ធ្វើឲ្យទ្រង់មានព្រះពិរោធយ៉ាងខ្លាំង ។ ពីឆ្នាំ១៩៥៥-៥៦ នៅភ្នំពេញមានភាពច្របូលច្របល់ ។ ភ្នាក់ងារសម្ងាត់ប្រចាំស្ថានទូតបរទេសកើតមានច្រើន ភ្នាក់ងារបារាំងនិងអាមេរិកក៏មានច្រើន ។ ក្នុងពេលនោះ ហួត សម្បត្តិ មិនបានចូលជាភ្នាក់ងារក្រសួងសម្ងាត់ណាមួយទេ ។ នៅឆ្នាំ១៩៥៦ ហួត សម្បត្តិ បានត្រឡប់មកស្រុកខ្មែរវិញ ហើយក៏ជាពេលដែលលមានការបាក់បែកគ្នារវាង ហួត សម្បត្តិ និង សម សារី និង ម៉ៅ សាយ ដែរ ពីព្រោះអ្នកទាំងពីរនេះត្រូវ ហួត សម្បត្តិ ចាត់ទុកថាជាជនពុករលួយ ។ បន្ទាប់មក សម សារី ក៏ចេញទៅធ្វើទូតនៅប្រទេសអង់គ្លេស ចំណែក ម៉ៅ សាយ ត្រូវបាន ហួត សម្បត្តិ រួមចំណែកទម្លាក់ចេញពីតំណែងរដ្ឋមន្ត្រីក្រសួងផែនការ ។

ចាប់ពីឆ្នាំ១៩៥៧-៦២ ហួត សម្បត្តិ បានឈប់ធ្វើការនៅក្នុងតំណែងរដ្ឋាភិបាល ហើយមកធ្វើជាតំណាងរាស្ត្រប្រចាំមណ្ឌលស្វាយរៀងវិញ ។ ប៉ុន្តែពីឆ្នាំ១៩៦២-៦៤ ហួត សម្បត្តិ បានមកធ្វើជារដ្ឋមន្ត្រីកិច្ចការបរទេស ក្នុងពេលដែលកម្ពុជានិងអាមេរិកមានទំនាស់នឹងគ្នាកាន់តែខ្លាំង ។ រដ្ឋាភិបាលកម្ពុជាពេលនោះក៏បានសម្រេចប្តឹងទៅអង្គការសហប្រជាជាតិចំពោះអាមេរិកនិងវៀតណាម ព្រៃនគរ ។ ហួត សម្បត្តិ ត្រូវបានបញ្ជូនទៅធ្វើជាតំណាងរដ្ឋាភិបាលខ្មែរនៅឯអង្គការសហប្រជាជាតិដើម្បីប្តឹងបកអាក្រាតយ៉ាងខ្លាំងអំពីអាមេរិក និងបានស្នើសុំឲ្យអង្គការសហប្រជាជាតិ(ក្រុមប្រឹក្សាសន្តិសុខ) ផ្តន្ទាទោសដល់អាមេរិក ។ ក្នុងពេលជាមួយគ្នានោះ ហួត សម្បត្តិ បានទាក់ទងជាមួយអគ្គលេខាធិការនៃបក្សកុម្មុយនិស្តឥណ្ឌូនេស៊ី ឈ្មោះ អាដិត ។ នៅឆ្នាំ១៩៦៣ ហួត សម្បត្តិ បានទៅជួបជាមួយនឹងហូជីមិញ និង ដាម វ៉ាន់ដុង នៅទីក្រុងហាណូយ ។ លុះដល់ឆ្នាំ១៩៦៥ ហួត សម្បត្តិ ត្រូវបានតែងតាំងជាតំណាងកម្ពុជានៅអង្គការសហប្រជាជាតិរហូតដល់រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ ពេលនោះក៏ជាពេលដែលប្រទេសកម្ពុជាបានផ្តាច់ទំនាក់ទំនងការទូតជាមួយនឹងសហរដ្ឋអាមេរិកដែរ ។ ប៉ុន្តែមុននឹងផ្តាច់ទំនាក់ទំនងការទូតនេះ តំណាងរាស្ត្រអាមេរិកម្នាក់ឈ្មោះ ម៉ឹក មេនហ្វេល បានមកជួបជាមួយ ហួត សម្បត្តិ ដើម្បីដោះស្រាយទំនាស់នេះ ។ ប៉ុន្តែ ហួត សម្បត្តិ មិនព្រមដោះស្រាយ ។ ក្រោយពីកម្ពុជាផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិកមក ហួត សម្បត្តិ បានទទួលបញ្ជាពីរដ្ឋាភិបាលភ្នំពេញដើម្បីបំផុសមហាជនអាមេរិកឲ្យជួយគាំទ្រដល់កម្ពុជា ហើយប្រឆាំងនឹងការឈ្លានពានរបស់សហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៦៩ ទំនាក់ទំនងការទូតរវាងកម្ពុជានិងសហរដ្ឋអាមេរិកក៏ចាប់ផ្តើមមានជាថ្មីឡើងវិញ ។ នេះជារឿងមួយដែលធ្វើឲ្យ ហួត សម្បត្តិ ពិបាកធ្វើការនៅឯអង្គការសហប្រជាជាតិដោយមូលហេតុត្រូវបញ្ឈប់ការបកអាក្រាតចំពោះសហរដ្ឋអាមេរិក ។

## សកម្មភាពក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ពីរ-បីថ្ងៃមុនរដ្ឋប្រហារ ព្រះមាតារបស់សម្តេច សីហនុ បានបញ្ជូនសារតាមរយៈ កែ មាស យកទៅថ្វាយសម្តេច សីហនុ នៅប៉េកាំង ។ ហួត សម្បត្តិ បានបញ្ជាក់ថា ខ្លួនមិនបានដឹងក្នុងសារនោះនិយាយអំពីអ្វីឡើយ ។ ខែឧសភា ឆ្នាំ១៩៧០ ក្រោយពីរណសិរ្សរួបរួមជាតិកម្ពុជានិងរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមួយត្រូវបានបង្កើតឡើង ហួត សម្បត្តិ បានដឹងថាសម្តេច សីហនុ បានតែងតាំង កែ មាស ឲ្យធ្វើជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសចិនប្រជាមានិត (ពីដើមមក កែ មាស ធ្វើជាមន្ត្រីបម្រើព្រះមាតារបស់សម្តេច សីហនុ) ។

ក្រោយរដ្ឋប្រហារភ្លាម ហួត សម្បត្តិ គ្មានប្រាក់ដើម្បីធ្វើដំណើរមកកាន់ទីក្រុងប៉េកាំងទេ ។ ប្រពន្ធរបស់ ហួត សម្បត្តិ ក៏បានយកទ្រព្យសម្បត្តិរបស់ខ្លួនទៅលក់ ។ ប៉ុន្តែប្រាក់ដែលបានមកពីការលក់ទ្រព្យសម្បត្តិនេះនៅតែមិនល្មមនឹងតម្លៃសំបុត្រយន្តហោះសម្រាប់សមាជិកគ្រួសាររបស់ ហួត សម្បត្តិ ចំនួន១២នាក់ឡើយ ។ ហួត សម្បត្តិ ទៅខ្ចីប្រាក់ពី អ៊ូ ថាន់ អគ្គលេខានៃអង្គការសហប្រជាជាតិ ។ ប៉ុន្តែខ្ចីមិនបាន ដោយសារលោកអគ្គលេខាមិនហ៊ានយកប្រាក់របស់អង្គការសហប្រជាជាតិឲ្យ ហួត សម្បត្តិ ខ្ចី ។ ហួត សម្បត្តិ ក៏បានទៅខ្ចីប្រាក់ពីលោកសង្ឃជាតិបារាំងមួយអង្គព្រះនាម ប៉ែ ហ៊ូតាំង បានចំនួន៤ពាន់ដុល្លារសហរដ្ឋអាមេរិក ដើម្បីបង្គ្រប់ថ្លៃសំបុត្រយន្តហោះធ្វើដំណើរពីទីក្រុងញូវយ៉កមកទីក្រុងមូស្គូតាមជើងយន្តហោះឈ្មោះអេរ៉ូហ្វ្លុត របស់សហភាពសូវៀត ។ ប៉ុន្តែថ្លៃបាយទឹក ស្នាក់នៅនិងធ្វើដំណើរពីទីក្រុងម៉ូស្គូមកទីក្រុងប៉េកាំង គឺបានរដ្ឋាភិបាលចិនជាអ្នកចំណាយឲ្យទាំងអស់ ។

នៅខែសីហា ឆ្នាំ១៩៧០ ស៊ាន អាន តំណាងទូតកម្ពុជានៅហាណូយ បានទូរស័ព្ទមករដ្ឋាភិបាលនៅប៉េកាំងថា ឯកអគ្គរដ្ឋទូតប្រទេសប៉ូឡូញប្រចាំកម្ពុជាឈ្មោះ បាវ សូវស្គី សូមមកជួបសម្តេច សីហនុ នៅប្រទេសចិនប្រជាមានិត ។ សម្តេច សីហនុ ក៏ព្រមឲ្យជួប ។ បីថ្ងៃក្រោយមកពេលដែលឯកអគ្គរដ្ឋទូតប្រទេសប៉ូឡូញមកដល់ប៉េកាំង សម្តេច ប៉ែន នុត បានឲ្យ ហួត សម្បត្តិ ទៅទទួល ហើយជូនទៅជួបសម្តេច សីហនុ នៅមាត់សមុទ្រភាគខាងជើងប្រទេសចិនឈ្មោះ«ពេតាហេ»ដែលនៅទីនោះសម្តេចសីហនុ និងគ្រួសារទៅសម្រាកលំហែកាយ ។ ពេលធ្វើដំណើរមកជួបសម្តេច សីហនុ នៅសមុទ្រ«ពេតាហេ» បាវ សូវស្គី បានប្រាប់ ហួត សម្បត្តិ តាមផ្លូវធ្វើដំណើរថា នៅភ្នំពេញមានក្រុមមួយបម្រុងនឹងបង្កើត«កម្លាំងទី៣»មួយដែលមិនចូលរួមនឹង លន់ ណុល ហើយក៏មិនចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជាដែរ ។ អ្នកបង្កើត«កម្លាំងទី៣»មានសម្តេចសង្ឃគណៈមហានិកាយ ហួត តាត, សឺន សាន, ចេង ហេង, នរោត្តម កន្តុល, អ៊ុង ហុងសាធ ជាដើម និងបញ្ញាជនប្រហែល៣០០នាក់ទៀត ក្នុងទិសដៅចង់បញ្ឈប់សង្គ្រាមបង្ហូរឈាម... 

ទិសដៅចង់បញ្ឈប់សង្គ្រាមបង្រួបបង្រួមគ្នាឡើងវិញ ។ ដើម្បីអនុវត្តគោលបំណងនេះ តម្រូវឲ្យសម្តេច សីហនុ និង លន់ ណុល ដើរចេញពីកម្ពុជាសិន ហើយ«កម្លាំងទី៣»រៀបចំធ្វើជាប្រជាមតិនៅក្រោមការមើលខុសត្រូវនៃអង្គការអន្តរជាតិមួយ ដោយសួរប្រជាជនឲ្យជ្រើសរើសសម្តេច សីហនុ ឬ លន់ ណុល ។ ប្រសិនបើប្រជាជនរើសសម្តេច សីហនុ ធ្វើជាប្រមុខរដ្ឋ លន់ ណុល ត្រូវដើរចេញពីកម្ពុជា ឬផ្ទុយទៅវិញ ។ ប៉ុន្តែក្រោយពីបានស្តាប់ហើយ ហួត សម្បត្តិ មិនបានឆ្លើយតបវិញឡើយ ។ បាវ សូវស្គី ក៏បាននិយាយបន្តអំពីការអនុវត្តលទ្ធិកុម្មុយនិស្តនៅប្រទេសប៉ូឡូញនិងនៅកម្ពុជា ។ ទោះជាយ៉ាងណាក្តី ហួត សម្បត្តិ នៅតែមិនព្រមឆ្លើយតប ប៉ុន្តែបែរជាសួរសំណួរទៅ បាវ សូវស្គី ថាតើពេលណាទើបទទួលស្គាល់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយបិទស្ថានទូតរបស់លោកនៅភ្នំពេញ? ភ្លាមនោះ បាវ សូវស្គី បានឆ្លើយថា គាត់ឈប់ត្រឡប់មកភ្នំពេញទៀតហើយ ។ ចំណែកឯការទទួលស្គាល់ គាត់នឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋាភិបាលគាត់ ។

ពេលទៅដល់មាត់សមុទ្រ ហួត សម្បត្តិ បានទៅជួបសម្តេច សីហនុ ហើយបានធ្វើសេចក្តីរាយការណ៍ទាំងអស់អំពីអ្វីដែលបាននិយាយជាមួយឯកអគ្គរដ្ឋទូតនៃប្រទេសប៉ូឡូញ ។ ការបង្កើត«កម្លាំងទី៣»នេះ សម្តេច សីហនុ មិនយល់ស្របទេ ទោះជាការជួបគ្នារវាង បាវ សូវស្គី និងសម្តេច សីហនុ មិនបានពិភាក្សាគ្នាលើបញ្ហានេះក៏ដោយ ។ នៅពេលត្រឡប់មកប៉េកាំងវិញ ហួត

សម្បត្តិ បានយករឿងនេះទៅប្រាប់សម្តេច ប៉ែន នុត បន្តទៀត ។

ក្នុងឆ្នាំ១៩៧១ ក្រោយពេលដែល ហួត សម្បត្តិ បាន មកធ្វើការនៅប្រទេសយូហ្គោស្លាវី អូវ៉ាលិច អនុរដ្ឋមន្ត្រីក្រសួងការបរទេសយូហ្គោស្លាវីបានប្រាប់ ហួត សម្បត្តិ ថា តាមសេចក្តីរាយការណ៍ដែលគាត់បានទទួលអំពីស្ថានទូតនៅយូហ្គោស្លាវីថា បារាំងបានចូលដៃជួយនៅក្នុងរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៧០ដែរ ។ ក្នុងឆ្នាំនោះដែរសម្តេច ប៉ែន នុត បានឲ្យ សារិន ឆាក និង ចាន់ យូរ៉ាន់ ទៅជួបជាមួយ សឺន សាន នៅក្រុងប៉ារីស ហួត សម្បត្តិ មិនបានដឹងថាតើសម្តេច ប៉ែន នុត បញ្ជូនអ្នកទាំងពីរដែលម្នាក់ជារដ្ឋមន្ត្រីនិងម្នាក់ទៀតជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជាក្នុងគោលដៅអ្វីឡើយ ។ ប៉ុន្តែបន្ទាប់មកទៀត ហួត សម្បត្តិ បានដឹងថា សឺន សាន ចង់បំបែកសម្តេច ប៉ែន នុត ចេញពីរណសិរ្សរួបរួមជាតិ កម្ពុជា ហើយនេះក៏ជាគំនិត និងទិសដៅរបស់រដ្ឋាភិបាលបារាំង និងសហភាពសូវៀតដែរ ។ ទោះជាយ៉ាងណាក្តី ដោយមានការលើកទឹកចិត្តពី ជូ អេនឡាយ សម្តេច ប៉ែន នុត ក៏នៅជាមួយរណសិរ្សរួបរួមជាតិកម្ពុជារហូតមក ។

«កម្លាំងទី៣» ជាគ្រោងការរបស់បារាំងនិងសហភាពសូវៀត ។ ប្រទេសទាំងពីរនេះភ័យខ្លាចក្តាប់បដិវត្តន៍កម្ពុជាមិនបាន ហើយដឹងថា ១) សម្តេច សីហនុ លែងមកកាន់អំណាចទៀតហើយនោះ ២) រដ្ឋអំណាចត្រូវធ្លាក់ទៅលើដៃអ្នកបដិវត្តកម្ពុជាដែលពលីជីវិតច្រើនជាងគេ ។ «កម្លាំងទី៣» នេះបានឃោសនាឲ្យមានការចរចាគ្នារវាងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាល លន់ ណុល រហូតដល់ឆ្នាំ១៩៧៤ ។ ប៉ុន្តែនៅពេលដែលរបប លន់ ណុល ហៀបនឹងដួលរលំក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ ញ៉ឹក ជូឡុង បាន សរសេរក្នុងកាសែតអាមេរិកមួយនៅទីក្រុងប៉ារីសដើម្បីគាំទ្រ



ហួត សម្បត្តិ

នយោបាយអាមេរិកនិងបារាំងអំពីការឈប់បាញ់នៅកម្ពុជា ។

ក្នុងចម្លើយសារភាពលើកទី១០របស់ ហ៊ូត សម្បត្តិ បាន បញ្ជាក់ថា «នៅឆ្នាំ១៩៧១ មិត្តយើងនៅក្នុងប្រទេសបានផ្ញើរូបថតពីដែនដីរំដោះមកមានរូបថតមិត្តយើងបីនាក់ ខៀវ សំផន ហ៊ូ នឹម និងហ៊ូ យន់។ ស្ថានទូតកម្ពុជាទាំងអស់ទទួលភារកិច្ចផ្សព្វផ្សាយរូបថតនោះ ហើយធ្វើការឃោសនាបង្ហាញឲ្យឃើញថា ការតស៊ូរបស់ប្រជាជនកម្ពុជាមានការចម្រើនច្រើនថា កងទ័ពអង្គការបដិវត្តន៍កម្ពុជាពិតៗបានធ្វើសង្គ្រាមមិនមែនវៀតកុងដូចការឃោសនារបស់បនអាក្បត់លន់ ណុលទេ» ។

នៅឆ្នាំ១៩៧១ បរិយាកាសនយោបាយនៅស្រុកខ្មែរក៏អាក្រក់ណាស់ដែរក្នុងចំណោមខ្មែរនៅប៉េកាំង ព្រោះមានការបាក់បែកគ្នាក្នុងរណសិរ្សរួបរួមជាតិកម្ពុជានិងមានការសង្ស័យគ្នា ចោទប្រកាន់គ្នា ។ រដ្ឋាភិបាលកម្ពុជាគ្មាននរណាមួយស្តាប់ទេ ។ ចម្លើយរបស់ ហ៊ូត សម្បត្តិ បានឲ្យដឹងថា «ដោយសារតែបានបងអៀង សារី គាត់ចេញពីកម្ពុជាមក ក៏គាត់បានរៀបចំអប់រំបានស្រួលមានរបៀបរៀបរយឡើងវិញបរិយាកាសក៏បានធូរក្លៀវក្លាង ការងារក៏ចម្រើនដើរទៅមុខ» ។

នៅឆ្នាំ១៩៧២ក្រោយពីបានធ្វើទស្សនកិច្ចជាលើដំបូងទៅប្រទេសមួយចំនួនជាមិត្តនៅអឺរ៉ុប អាស៊ី និងអាហ្វ្រិក សម្តេចសីហនុ បានប្រជុំខ្មែរទាំងអស់នៅប៉េកាំង ហើយបានប្រកាសសុំលាលែងពីតំណែងជាប្រមុខរដ្ឋដោយសារតែរដ្ឋាភិបាលនេះបេះតែជំទាស់នឹងនយោបាយរបស់ព្រះអង្គ ។ ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧២ ហ៊ូត សម្បត្តិ បានរៀបចំធ្វើពិធីតាំងរូបថតដែលទទួលបានមកពីស្រុកខ្មែរ ។ ក្នុងពេលជាមួយគ្នានោះ អ៊ីតហ៊ុំរ កូទីយេ ជាគ្រូបង្រៀនជាតិអាមេរិកកាំងម្នាក់ធ្លាប់នៅសៀមរាប ហើយដែលធ្លាប់ទាក់ទងគ្នាជាមួយ ហ៊ូត សម្បត្តិ (ក្នុងឆ្នាំ១៩៦៨នៅអង្គការសហប្រជាជាតិ) បានទៅលេងនៅប្រទេសយូហ្គោស្លាវី ។ ហ៊ូត សម្បត្តិ ក៏បានហៅ អ៊ីតហ៊ុំរ កូទីយេ ឲ្យមកមើលរូបថតតាំងពិពណ៌នេះ ។ ហ៊ូត សម្បត្តិ ក៏បានស្នើឲ្យ អ៊ីតហ៊ុំរ កូទីយេ ទាក់ទងនឹងអ្នកស្នេហាសន្តិភាព ក្រុមសង្គមស្នេហាសន្តិភាពឲ្យជួយផ្សាយពិព័រណ៍រូបថតកម្ពុជានៅពេលណាដែលត្រឡប់ទៅអាមេរិកវិញ ។ ឆ្លៀតពេលដែល អ៊ីតហ៊ុំរ កូទីយេ ត្រឡប់ទៅសហរដ្ឋអាមេរិកវិញ ហ៊ូត សម្បត្តិ ក៏បានផ្ញើតាមរយៈ អ៊ីតហ៊ុំរ កូទីយេ នូវទឹកប្រាក់ចំនួន៤០០០ ដុល្លារអាមេរិក ដើម្បីសងទៅព្រះសង្ឃជាតិបារាំងមួយអង្គនៅសហរដ្ឋអាមេរិក ដែលខ្លួនបានខ្ចីកាលពីក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ក្នុងពេលដែលខ្លួននិងគ្រួសារធ្វើដំណើរទៅទីក្រុងប៉េកាំងប្រទេសចិន ។ ការនិយាយរបស់ខ្លួនជាមួយ អ៊ីតហ៊ុំរ កូទីយេ និងការទាក់ទងជាមួយអ្នកកាសែត ឬជាមួយតំណាងរាស្ត្រអាមេរិកត្រូវបាន ហ៊ូត សម្បត្តិ ធ្វើសេចក្តីរាយការណ៍ទៅសម្តេច ប៉ែន នុត ដែលជាប្រធានការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជានាពេលនោះ ។

ក្នុងឆ្នាំ១៩៧៣ មតិសកលលោកបានគ្របដណ្តប់មកលើប្រទេសកម្ពុជា ក្នុងការចង់ឲ្យកម្ពុជាចរចាជាមួយរបប លន់ ណុល (ដែលមានអាមេរិកជាអ្នកគាំទ្រ) ។ ពេលនោះ ប្រធានាធិបតីនៃប្រទេសជាមិត្តដូចជាប្រទេសម៉ូរីតានី អាល់សេរី រ៉ូម៉ានី បានសុំសម្តេច សីហនុ ចរចាជាមួយរបប លន់ ណុល ។ ចំណែកឯសម្តេច សីហនុ ក៏ចង់ជួបជាមួយ គីសស៊ីងហ្គើរ រដ្ឋមន្ត្រីការបរទេសអាមេរិកដែរ ។ ពេលឃើញសភាពមិនសូវល្អយ៉ាងដូច្នេះ ហ៊ូត សម្បត្តិ បានស្នើសុំលាឈប់ពីតំណែងនៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយបានស្នើឲ្យប្រគល់អំណាចរដ្ឋាភិបាលទាំងស្រុងទៅឲ្យអ្នកដែលនៅក្នុងស្រុក ពីព្រោះ ហ៊ូត សម្បត្តិ ដឹងថាអ្នកនៅក្នុងស្រុកពិតជាមិនព្រមចរចាដាច់ខាត ដែលគំនិតនេះស្របនឹងគោលជំហររបស់ ហ៊ូត សម្បត្តិ ដែរ ។

**(នៅមានត)**

**ឃួន សុភារិទ្ធ**

## ពន្យល់ពាក្យខ្មែរក្រហម

◆ **បដិសង្គមនិយមៈ** គឺវាយកម្មសិទ្ធ កសាងសង្គមនិយមសហករ គឺចិញ្ចឹមគោឲ្យធាត់ រកដី លើកភ្លឺប្រឡាយ ដោះស្រាយជីវភាពប្រជាជន ដោះស្រាយទឹក បំផុសពីដាំដុះ កសាងប្រជាជនពិបាកគឺប្រវត្តិរូប ។

(កំណត់ហេតុ គណហ ២០៩)

# ៣០ថ្នេរឡាមប្តូរនិងមនោសញ្ចេតនាគ្រួសារ

នៅភូមិស្រែ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ សឿន បានធ្វើអត្តឃាតដោយវះពោះខ្លួនឯងនឹងឡាមកោរពុកមាត់មូលហេតុដោយសារខឹងសម្បានិងខកបំណងយ៉ាងខ្លាំងចំពោះប្រធានសហករណ៍ដែលមិនអនុញ្ញាតឲ្យខ្លួនបានទៅជួបបងប្រុសដែលទើបនឹងមកពីភ្នំពេញ ហើយដែលគាត់បានសន្យឹមទុកជាមុនថានឹងបាននាំបងប្រុសទៅលេងនឹងឪពុក ។ ខ្ញុំមានការរន្ធត់ក្នុងចិត្តជាខ្លាំងនៅពេលដែលបានឮ ពូផែម ដែលជាឪពុកជនរងគ្រោះ រៀបរាប់ប្រាប់អំពីរឿងនេះ ។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០១ វេលាម៉ោងប្រហែល ១០កន្លះព្រឹក ពូផែម បាននិយាយប្រាប់ខ្ញុំថា “កូនវាថាសុំ ប្រធានគេ ចាំគេ(វ៉ាត់)មកពី(ខេត្ត)ព្រះវិហារ គេ(វ៉ាត់) ចូលយកទៅលេងឪពុក ។ ឪពុក(ខ្ញុំ) នៅព្រែកស្បូវកំពង់គរ ។ ម៉ោដល់សុំប្រធានគេមិនបាន សុំប្រធានមិនបាន ក៏អាកូន(វ៉ាត់) អត់បានចូលលេងនឹងខ្ញុំព្រោះមិនស្គាល់កន្លែង ។ ក៏មីនោះឯង (សឿន) វាខឹងនឹងប្រធាននោះវាមិនឲ្យទៅវះពោះខ្លួនឯងសម្លាប់...ថាខឹងនឹងប្រធានសហករណ៍ គេមិនឲ្យទៅ...” ។



ពូផែម

ដំណើររឿងគឺដូចតទៅនេះ៖ ឈ្មោះ វ៉ាត់ ត្រូវជាបងប្រុសរបស់សឿន ហើយអ្នកទាំងពីរត្រូវជាកូនបង្កើតរបស់លោកពូផែម ។ វ៉ាត់ បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាំងពីនៅក្មេងៗម្ល៉េះក្នុងអាយុប្រហែល១៧ឆ្នាំ ។ កាលណោះ វ៉ាត់ ធ្វើជាអ្នកបើកបរឡានដឹកជញ្ជូនសម្ភារមកពីប្រទេសចិន ។ ចាប់តាំងពីចូលបម្រើបដិវត្តន៍មក វ៉ាត់ បានឆៀងចូលលេងភូមិកំណើតបានតែម្តងគត់ទាំងប្រញិតប្រញើយ ព្រោះចំពេលដែលខ្លួនត្រូវបើកឡានដឹកសម្ភារទៅខេត្តព្រះវិហារ ហើយកាត់មុខផ្ទះផង ។ វ៉ាត់ មិនដែលបានមកលេងស្រុកកំណើតដោយទទួលបានការអនុញ្ញាតត្រឹមត្រូវឡើយ ។ នៅពេលដែលបើកឡានមកដល់ភូមិស្រែ វ៉ាត់ បានជួបនឹងប្អូនស្រីរបស់ខ្លួន (សឿន) ហើយថែមទាំងបានឲ្យរបស់របរខ្លះៗដល់ប្អូនរួមមានសារុងនិងឡាមកោរពុកមាត់មួយប្រអប់ផង ។ មុននឹងបន្តដំណើររបស់ខ្លួនឆ្ពោះទៅខេត្តព្រះវិហារ វ៉ាត់ បានប្រាប់ប្អូនស្រីថា នៅពេលត្រឡប់ពីខេត្តវិញនឹងចូលមកយកប្អូនដើម្បីទៅលេងនឹងឪពុកទាំងអស់គ្នា ។ មុនពេលដែលឈ្មោះ វ៉ាត់ មកដល់ភូមិកំណើត វ៉ាត់ មិនបានដឹងថា ពូផែម ដែលជាឪពុកត្រូវបានជម្លៀសចេញពីភូមិកំណើតទៅរស់នៅឯភូមិផ្សេងទៀតឡើយ ។ ពូផែម ត្រូវបានជម្លៀសឲ្យទៅនៅភូមិព្រែកស្បូវឯណោះ ដែលឆ្ងាយពីភូមិកំណើត ។ ពូផែម បានបញ្ជាក់រឿងរ៉ាវសម្លាប់ខ្លួនរបស់កូនស្រីរបស់គាត់ដោយនិយាយថា “ចង់ទៅលេងចង់ឲ្យបងនោះទៅលេងនឹងខ្ញុំ ។ ខ្ញុំនៅព្រែកស្បូវឯណោះ ឲ្យប្អូននោះសុំប្រធានសហករណ៍គេទៅលេងនឹងខ្ញុំ នាំទៅចូលលេងគេ(វ៉ាត់) ឈប់ឡានមួយភ្លែត អានោះគេបើកឡាន...សុំអត់បាន ក៏អាបងទៅផុតឯនោះខឹងម៉េចទេ វះពោះខ្លួនឯងសម្លាប់...ដល់ដឹកទៅពេទ្យវាថាអត់ចង់រស់ទេ សុខចិត្តស្លាប់ល្អជាង មិនបានជួបនឹងបងហើយមិនបានម៉ោលេងនឹងពុក បងចង់ម៉ោលេងនឹងពុក...” ។ ពូផែម មិនបានជួបនឹងកូនប្រុសរបស់គាត់ទេដោយសារតែកូនរបស់គាត់មិនស្គាល់កន្លែង ហើយបើកឡានបន្តសមកភ្នំពេញតែម្តង ។ ចំណែកឯ វ៉ាត់ ក៏មិនបានដឹងរឿងរ៉ាវប្អូនស្រីរបស់ខ្លួនធ្វើអត្តឃាតដោយវះពោះនឹងឡាមនេះដែរ ។

ទំហំនៃការនឹករឭកបងប្អូន ក្រុមគ្រួសារក្នុងរបបខ្មែរក្រហមអាចឈានដល់មានការសម្លាប់ខ្លួនឯង ។ តើខ្មែរក្រហមធ្វើការឃាត់ឃាំងយ៉ាងតឹងរ៉ឹងបែបនេះ គឺគិតថាខ្លួននឹងទទួលបានជោគជ័យ ឬក៏យ៉ាងណា? ការបំបាត់មនោសញ្ចេតនាក្នុងគ្រួសារបៀបដូចនេះគឺជាមធ្យោបាយមួយដែលរបបខ្មែរក្រហមបានប្រើប្រាស់ក្នុងការកសាងសង្គមនិយមរបស់ខ្លួន ។ សឿន សុខចិត្តស្លាប់ខ្លួន ប្រសើរជាងរស់នៅមិនបានជួបបងប្អូនឪពុកម្តាយ ។ បន្ទាប់ពីមានហេតុការណ៍នេះ ទាហានក្នុងសហករណ៍បានយករទេះគោដឹក សឿន ទៅមន្ទីរពេទ្យនៅឃុំសាលាវិស័យ

ដោយរុំនឹងក្រមា ហើយបានទៅហៅឪពុករបស់គាត់ទាំងកណ្ដាលអធ្រាត្រ ។ នៅពេលដែលពូ ឆែម ទៅដល់មន្ទីរពេទ្យ កូនស្រីរបស់គាត់មិនទាន់ស្លាប់ភ្លាមៗទេ ។ ពូឆែម បានរំឭកសម្ដីចុងក្រោយរបស់កូនស្រីប្រាប់ខ្ញុំថា “ដល់ដឹកទៅពេទ្យ វា(សឿន)ថា អត់ចង់រស់ទេ សុខចិត្តស្លាប់ ល្អជាង មិនបានជួបនឹងបង ហើយមិនបានម៉ោលេងនឹងពុកទៀត ។ បងចង់ម៉ោលេងនឹងពុក” ។ កាលណោះ នៅឯមន្ទីរពេទ្យ មានការបញ្ឆេះម៉ាស៊ីនភ្លើងដើម្បីធ្វើការវះកាត់តពោះវៀនដែរ ក៏ប៉ុន្តែដោយសារពោះវៀនដាច់ដល់ទៅសាមសិបថ្នេរទៅហើយ ពេទ្យមិនអាចជួយសង្គ្រោះបានទេ ។ រំលងពេលអស់មួយថ្ងៃមួយយប់ សឿន ក៏បានស្លាប់នៅក្នុងមន្ទីរពេទ្យទៅ ។

**ម៉ាន់ថាន់ ពៅដារ៉ា**

# ទួលស្លែង ស-២១

*វិចិត្រករៈ វ៉ាន់ ណាត*
*អតីតអ្នកទោសមន្ទីរស-២១*



អ្នកទោសនៅមន្ទីរស-២១



ដឹកអ្នកទោសចេញពីមន្ទីរស-២១

***(តពីលេខមុន)*** *នៅក្នុងអំឡុងពេលនេះ ទំនាក់ទំនងរវាងអ្នកសួរចម្លើយនិងអ្នកទោសទៅនឹងទម្រង់នៃការសួរចម្លើយត្រូវតែកើនឡើងដូចដែលចម្លើយសារភាពសំខាន់ៗមួយចំនួនដូចជារបស់ ណៃ សារ៉ន បញ្ជាក់ស្រាប់ ប៉ុន្តែទំនាក់ទំនងទាំងនេះមិនមាននៅបណ្ណសារឡើយ ។ ករណីលើកលែងមួយដែលបញ្ជាក់ពីវិន័យក្នុងការសួរចម្លើយ គឺចម្លើយសារភាពរបស់ឈ្មោះ ជុង វ៉ាន់ ជាសមាជិកបក្ស ដែលត្រូវបានចាប់ខ្លួននៅខែកញ្ញា ឆ្នាំ ១៩៧៧ ។ ជុង បាននិយាយអំពីការសួរចម្លើយចំពោះខ្លួនថា៖*



**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី៤៖ បង្កើតសំណួរសម្រាប់ទម្លាក់កំហុស**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

*«ពេលដែលខ្ញុំមកដល់មន្ទីរស-២១ ដំបូងមានតំណាងម្នាក់ធ្វើការមន្ទីរសន្តិសុខបានមកសួរខ្ញុំ ។ ម្នាក់នោះបានចោទប្រកាន់ខ្ញុំថាជាសេ.អ៊ី.អា តាមការឆ្លើយដាក់ពីអ្នកដទៃ ។ នៅចំណុចនោះខ្ញុំគ្រប់គ្រងខ្លួនឯងលែងបាន ហើយនិយាយថាមិនពិតទេ ។ វាបន្តទៀតថា បើឯងថាទេ វ៉ៃទាល់តែចេញហ្នឹង! ។ ក្នុងការចាប់ផ្តើមខ្ញុំបានសរសេរលម្អិតអំពីសកម្មភាពក្បត់បដិវត្តតាំងតែពីមុនមកដល់បច្ចុប្បន្ន ។ ពេលដែលខ្ញុំសរសេរហើយ តំណាងមន្ទីរសន្តិសុខនិយាយថា ម៉េចបានអញមិនឃើញប្រវត្តិក្បត់បន្តិចសោះអីចឹង? ខ្ញុំក៏ឆ្លើយតបវិញថា ពីព្រោះខ្ញុំមិនបានធ្វើអ្វីខុសទេ ។ ពេលនោះតំណាងនោះនិយាយថា បើឯងនិយាយថាទេនឹងត្រូវព្រនង់មិនខាន ។ ខ្ញុំក៏សួរទៅវិញថាតើខ្ញុំអាចសរសេរតាមការពិតបានទេ ។ តំណាងតបវិញថា បើឯងសរសេរពីសកម្មភាពក្បត់ជាការល្អ ។ ខ្ញុំដឹងថាពេលនេះខ្ញុំពិតជាទទួលទារុណកម្មជាមិនខានឡើយ ដូច្នេះខ្ញុំសម្រេចចិត្តសរសេររឿងប្រឌិតអំពីសកម្មភាពក្បត់របស់ខ្ញុំ ។ ខ្ញុំសរសេរថា ខ្ញុំក្បត់តាំងពីឆ្នាំ១៩៧០មកម្ល៉េះ ហើយសរសេរអំពីការពាក់ព័ន្ធរបស់ខ្ញុំជាមួយនឹង នង សួន នៅពេលដែលយើងនៅជាមួយគ្នានៅ...ឱរ៉ាល់ ។ ខ្ញុំបានរៀបរាប់ឈ្មោះសមមិត្តមួយចំនួនដែលធ្វើសកម្មភាពបដិវត្តជាមួយខ្ញុំនៅឆ្នាំ១៩៧៦ ។ បន្ទាប់មក តំណាងមន្ទីរសន្តិសុខឲ្យខ្ញុំបញ្ជាក់អំពីដំណើររឿងរបស់ខ្ញុំផ្ទាល់ដោយនិយាយថា តើសកម្មភាពក្បត់ពេលដែលឯងនៅទីក្រុងមានអ្វីខ្លះ? ។ ខ្ញុំក៏ឆ្លើយថាអត់មានទេ ។ តំណាងមន្ទីរសន្តិសុខនិយាយថា បើឯងមិនឆ្លើយទេចាំទទួលរំពាត់ខ្សែភ្លើងទៅ! នៅពេលឮថាទារុណកម្ម ខ្លួនខ្ញុំចាប់ផ្តើមញ័រចំប្រប់ ។ ពេលនោះខ្ញុំក៏ចាប់ផ្តើមសរសេររឿងប្រឌិតតែម្តងទៅ» ។*

*ប៉ុន្មានខែមុននេះ ស៊ាត ឆែ (ហៅទុំ) បានសរសេរកំណត់សម្គាល់មួយច្បាប់ទៅកាន់សន្តិបាលដែលជាការផ្តល់នូវចិត្តសាស្ត្រមួយទៀតរបស់អ្នកទោសនៅដំណាក់កាលមុនពេលសួរចម្លើយនិងទារុណកម្ម(មើលវគ្គទី៣) ។ ស៊ាត ឆែ ជឿជាក់ថា ខ្លួនត្រូវបានចោទប្រកាន់ខុសទំនង ហើយថា ឌុច នឹងអនុញ្ញាតឲ្យធ្វើការទាក់ទងដោយផ្ទាល់ជាមួយនឹង«បង១ថ្នាក់លើ»ជាសំណើដែល ឌុច បានដុសខាត់ម្តងហើយម្តងទៀត ។ កំណត់សម្គាល់ចុះថ្ងៃទី៨ ខែឧសភា បានលាតត្រដាងអំពីសភាពរេរាមិននឹងនរនៅក្នុងចិត្តរបស់ ឆែ៖ នៅល្ងាចថ្ងៃទី៧-៨ ខែឧសភា ឆ្នាំ១៩៧៧ ចិត្តខ្ញុំស្ថិតនៅក្នុងសភាពមួយមិននឹងនររហូតមិនដឹងថាត្រូវនិយាយយ៉ាងម៉េចដងទេ ។ ខ្ញុំមើលមិនឃើញផ្លូវសម្រាប់អនាគតសោះឡើយ ។ ខ្ញុំបានអង្វរបក្សថា នៅពេលនេះសូមក្តីអាណិតកូនរបស់ខ្លួនផង ។ [ទាំងនេះជា] វិវឌ្ឍន៍នៃចិត្តគំនិតរបស់ខ្ញុំ ។ ដំណាក់កាលទី១៖ នៅក្នុងអំឡុងពេលក្រោយពីបក្សបានចាប់ខ្ញុំរហូតមកដល់ខែឧសភា ឆ្នាំ[១៩]៧៧ គឺជាពេលសរសេររបាយការណ៍ទៅលើចំណុចដែលអង្គការចង់ឲ្យពន្យល់ ។ ដោយប្រើរបាយការណ៍ទាំងនោះ ខ្ញុំសង្ឃឹមថាអង្គការនឹងសាកសួរនិងស៊ើបអង្កេតនៅតាមមូលដ្ឋានដែលខ្ញុំធ្លាប់ប្រឡូកនិងធ្វើការស្រាយបំភ្លឺសម្តីរបស់*

ខ្ញុំ ។ ខ្ញុំសង្ឃឹមថាក្រសួងសន្តិបាលដែលជាក្រសួងទទួលខុសត្រូវតាមដាននិងបញ្ចោកផ្ទៀងផ្ទាត់ឯកសារទាំងនេះ នឹងយកសេចក្តីសង្ខេបនេះដាក់ជូនអង្គការមិនខាន ។ បង្កើតមូលដ្ឋានកំហុសធំតូចរបស់ខ្ញុំ ហើយយកចិត្តទុកដាក់ចំពោះខ្ញុំផង ។ ដំណាក់កាលទី២ៈ ចាប់ពីល្ងាចថ្ងៃទី៤ ខែឧសភា មក[ដល់ថ្ងៃនេះ] ខ្ញុំបានទទួលរងទារុណកម្មគ្រប់បែបយ៉ាងតាមការប្រព្រឹត្តរបស់សន្តិបាល ។ គំនិតរបស់សន្តិបាលគឺគ្មានមធ្យោបាយណាដែលថាខ្ញុំមិនមែនជាជនក្បត់នោះទេ ។ ដូច្នេះដោយដឹងនូវជំហរនេះ កម្រិតនៃការធ្វើទារុណកម្មកាន់តែកើនឡើងជាលំដាប់ ធ្វើឲ្យអារម្មណ៍ខ្ញុំប្រែប្រួលចុះឡើងយ៉ាងខ្លាំង ។ ខ្ញុំគ្មានផ្លូវត្រូវចេញរួចទេ [រាត្រីនោះ] ខ្ញុំមានអារម្មណ៍ដូចខាងក្រោមនេះ÷ ១) ប្រសិនបើខ្ញុំសារភាពថាក្បត់មិនដឹងជាត្រូវសរសេរអំពីសកម្មភាពក្បត់ជាមួយបក្ខពួកប្រកបដោយហេតុផលនិងតាមលំដាប់លំដោយយ៉ាងម៉េចទេបើខ្ញុំមិនបានក្បត់ផងនោះ ។ នេះជារឿងមួយ ។ រឿងមួយទៀតបើខ្ញុំសរសេររបៀបនេះដោយគិតអំពីជំហរខ្ញុំចំពោះបក្សចាប់តាំងពីថ្ងៃ២៦ ខែឧសភា [១៩]៥៩ និងចំពោះបងទីមួយ [ប៉ុលពត] ដែលខំចិញ្ចឹមបីបាច់ខ្ញុំតាំងពីតូចរហូតមក ហើយសរសេរតាមការធ្វើទារុណកម្មនោះ ខ្ញុំធ្វើទៅមិនរួចទេ! ។ ២) គិតចុះគិតឡើង ខ្ញុំឃើញផ្លូវដ៏ល្អមួយគឺសេចក្តីស្លាប់...ការស្លាប់មួយពព្រិចភ្នែកដែលអាចចាកផុតពីការឈឺចាប់...ហើយនៅជាមួយបក្សលុះដល់ទីបញ្ចប់ ។ ប៉ុន្តែមើលទៅគ្មានផ្លូវស្លាប់មួយពព្រិចភ្នែកទេ ។ ហើយគ្មានផ្លូវចេញទេ...ខ្ញុំខ្លាចការធ្វើទារុណកម្មនិងសេចក្តីស្លាប់ណាស់ ។ បើខ្ញុំពាក់ព័ន្ធជាមួយជនក្បត់មែន ខ្ញុំនឹងប្រាប់អង្គការភ្លាម ហើយរួចចាកផុតពីការធ្វើទារុណកម្មភ្លាម ។ ៣) ក្រោយពីគិតសាចុះសាឡើងហើយគ្មានផ្លូវចេញ ព្រឹកនេះខ្ញុំតស៊ូសរសេរឲ្យអង្គការដឹងអំពីការវិវត្តរបស់អារម្មណ៍ខ្ញុំនិងអាណិតខ្ញុំ ។ សំណូមពរចុងក្រោយនេះគឺដើម្បីសុំឲ្យអង្គការពន្យារពេលធ្វើទារុណកម្មនិងពិចារណាម្តងទៀតនូវសក្ខីកម្មរបស់ជនក្បត់បីនាក់ដែលចោទប្រកាន់មកលើខ្ញុំ ។ អ្នកទាំងបីនាក់នេះចេះតែប្រឌិតទេ ។ ខ្ញុំដឹងថាច្បាស់ជាមានមតិផ្ទុយគ្នានៅក្នុងបញ្ហាសំខាន់មួយចំនួនមិនខាន ។

អ្នកធ្វើការនៅមន្ទីរ ស-២១ម្នាក់ៗត្រូវបានជំរុញឲ្យមានការសង្ស័យគ្នាទៅវិញទៅមកដូចដែល ហ៊ុម ហ៊ុយ បាននិយាយទៅកាន់ ភីតធើ ម៉ាឃៀរ ថា «យើងទាំងអស់គ្នាគិតតែពីតាមដានគ្នាទៅវិញទៅមក» ។ ម្នាក់ៗគិតតែពីមើលបំណាំគ្នាទៅវិញទៅមក គ្រប់ជ្រុងជ្រោយ ។ គ្រួសារទុកមុំ មិត្តភាពផ្តល់សន្តិសុខតិចតួចណាស់ឬគ្មានផង ហើយសិទ្ធិអាចត្រូវដកយកនៅពេលណាក៏បាន ។ គ្រប់សកម្មភាពទាំងអស់សុទ្ធតែជារឿងនយោបាយ ។ ប្រទេសជាតិកំពុងតែមានសង្គ្រាមជាមួយខ្មាំងខាងក្រៅ ចំណែកឯសង្គមជាតិកំពុងតែមានសង្គ្រាមជាមួយខ្លួនឯង ហើយបក្សកំពុងមានសង្គ្រាមជាមួយនឹង «ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង» រីឯប្រជាជនកំពុងធ្វើសង្គ្រាមជាមួយនឹងកំហុសរបស់ខ្លួន ។ រដ្ឋអំណាចនិងភាពស្របច្បាប់របស់អង្គការមិនមានអ្វីគួរឲ្យសង្ស័យ ប៉ុន្តែតាមគោលការណ៍របស់អង្គការគឺថា មានមនុស្សបង្កប់ក្នុងអង្គការដែលខិតខំរិះរកមធ្យោបាយកម្ទេចរដ្ឋអំណាចនេះ ។ បើគិតតាមន័យខ្មាំងគឺមានទាំងមិនស្គាល់ឈ្មោះ ទាំងស្គាល់ឈ្មោះ មើលឃើញនិងមើលមិនឃើញនៅខាងក្នុងនិងខាងក្រៅមន្ទីរស-២១ ។ អតីតកម្មាភិបាលរបស់កម្ពុជាប្រជាធិប-តេយ្យម្នាក់បាននិយាយប្រាប់ ស៊ើវ ហេដឌ័រ កាលពីឆ្នាំ១៩៨០ ដោយនិយាយថា«[នៅក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យ] មនុស្សមានសតិអារម្មណ៍មិនស្រួលទេ ។ ម្នាក់ៗខ្លាចធ្វើខុសដោយមិនដឹងខ្លួនឬត្រូវអ្នកដទៃចង្អុលមុខ ។ [យើង]ចេះតែញញឹមៗទៅ តែតាមពិតតឹងចិត្តណាស់» ។

ចម្លើយសារភាពដែលនៅសេសសល់ពីមន្ទីរស-២១ មានលក្ខណៈផ្សេងៗគ្នាទាំងប្រវែង ទាំងភាពពេញលេញ និងប្រយោជន៍ ។ តាមការប៉ាន់ស្មានគ្រួសៗឃើញថា មានបួនភាគរយនៃចម្លើយសារភាពដែលបានថតចម្លងចូលម៉ាស៊ីនម៉ាយក្រូហ្វីលនិងមួយភាគតូចដែលតម្កល់ទុកនៅបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺមួយច្បាប់មានមិនលើសពីបីទំព័រឡើយ ។ ចម្លើយទាំងនេះភាគច្រើនត្រូវបានសរសេរឡើងក្រោយពេលដែលអ្នកទោសត្រូវបានបញ្ជូនមកដល់មន្ទីរស-២១ភ្លាម មុនពេលយកទៅសួរចម្លើយ ។ ជាទូទៅ ចម្លើយសារភាពមានទិន្នន័យប្រវត្តិរូបតាមលំដាប់លំដោយពីដើមដល់ចប់និងមិនមាននិយាយអំពីទោសកំហុសឡើយ ។ នៅក្នុងករណីខ្លះ

ក្រដាសទិន្នន័យត្រូវបានពិនិត្យនិងចារថា "គ្មានប្រយោជន៍ទេ បោះវាចោលទៅ" ។ តាមរយៈឯកសារដែលសេសសល់ ការបញ្ជាឲ្យ"បោះចោល"អាចនិយាយយោងដល់អ្នកទោសផ្ទាល់តែម្តង ។ "បោះចោល" គឺជាពាក្យសម្រាប់សម្រាលន័យដែលប្រើនៅមន្ទីរស-២១ជំនួសឲ្យពាក្យ"សម្លាប់" ។ ចម្លើយសារភាពចំនួន២០១៣ច្បាប់ក្នុងចំណោមចម្លើយសារភាពដែលថតចម្លងចូលម៉ាស៊ីនម៉ាយក្រូហ្វីលឬស្មើនឹងពាក់កណ្តាលឯកសារបណ្ណសារដែលថតចម្លងរួច ហើយដែលបានមកក្រោយពីការសួរចម្លើយមួយដង និងឯកសារចម្លើយសារភាពដែលនៅសល់ក្រៅពីនោះត្រូវបានសរសេរចេញដោយកម្មាភិបាលជាលក្ខណៈកែសម្រួលបន្តបន្ទាប់ដែលជួនកាលមានសរសេររហូតរាប់សប្តាហ៍ឬរាប់ខែទម្រាំតែរួចរាល់ ។ ចម្លើយសារភាពភាគច្រើនរបស់បណ្ណសារដែលធ្វើការថតចម្លងរួចហើយនិងដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានកម្រាស់ពី១០ទៅ៤០សន្លឹក ។ អ្នកទោសដែលខ្ញុំហៅថា "កម្មាភិបាល" ដែលមានអាយុលើសពី៣០ឆ្នាំ និងមាននាមក្លែងច្រើនតែសរសេរចម្លើយសារភាពរបស់ខ្លួនរាប់រយសន្លឹកឯណោះ ។

ដោយពេលវេលាចេះតែរំកិលទៅមុខ ទ្រង់ទ្រាយនិងសភាពដើមរបស់ឯកសារចម្លើយសារភាពក៏បានផ្លាស់ប្តូរទៅតាមនោះដែរ ។ ឯកសារមួយចំនួនត្រូវបានសរសេរឡើងដោយអ្នកគុក ហើយឯកសារដែលសរសេរឡើងនៅមុននេះបន្តិចគឺជារបស់អ្នកទោសផងនិងអ្នកសួរចម្លើយផង ប៉ុន្តែចម្លើយសារភាពដែលសរសេរដោយដៃភាគច្រើនត្រូវបានចម្លងចេញពីខ្សែអាត់ថតសម្លេងឬកំណត់ហេតុផ្សេងៗដោយអ្នកសួរចម្លើយនិងអ្នកធ្វើការនៅក្នុងគុក ។ គ្មានខ្សែអាត់ថតសម្លេងណាមួយដែលប្រហែលជាមានទាំងសំណួរផងនៅសេសសល់ឡើយ ។ ចម្លើយសារភាពមួយចំនួនគឺជាសេចក្តីព្រាងលើកទីមួយដែលមានការថែមថយកែសម្រួលដោយអ្នកទោស អ្នកធ្វើឯកសារ ឬកម្មាភិបាលជាន់ខ្ពស់ ។ ជួនកាលសេចក្តីព្រាងមួយចំនួននៅមានសល់ដោយវាយជាអង្គុលីលេខរួចជាស្រេច ចំណែកមួយចំនួនទៀតមានចំណារថា "កុំប្រើ" ឬ "កុំសង្ខេប" ដែលប្រហែលជាមិនដែលត្រូវបានយកចេញពីគុកឡើយ ។ អត្ថបទចម្លើយសារភាពពីឆ្នាំ១៩៧៦ រួមមានសំណួរដែលសរសេរឡើងដោយដៃអ្នកសួរចម្លើយផ្ទាល់ ដូចជា ឌុច បានសរសេរពីរលើកសួរទៅអ្នកទោស ។ ប៉ុន្តែស្ទើរតែគ្រប់សំណួរនិងការឲ្យជាយោបល់ទាំងអស់ មិនមាននៅសេសសល់ទាល់តែសោះ ។

នៅត្រឹមឆ្នាំ១៩៧៨ ចម្លើយសារភាពភាគច្រើនត្រូវបានវាយអង្គុលីលេខទាំងអស់ ។ ចម្លើយសារភាពជាច្រើនត្រូវបានធ្វើជាច្រើនច្បាប់ហើយកិបចូលគ្នាជាសៀវភៅស្តើង ។ យើងដឹងតាមរយៈសៀវភៅសរសេររបស់ ទុយ ប៉ុន ថា នៅត្រឹមឆ្នាំ១៩៧៨ ចម្លើយសារភាពសំខាន់ៗចំនួន៦ច្បាប់ត្រូវបានរៀបចំជាធម្មតា ។ មានពីរច្បាប់ត្រូវបានផ្ញើទៅកាន់"អង្គការ" ហើយនៅសល់ពីនោះត្រូវបានផ្ញើទៅឲ្យអតីតអង្គភាពការងាររបស់គុកឲ្យមន្ទីរសន្តិសុខគុកនិងដៃគូដែលជាមន្ទីរពាក់ព័ន្ធនៅតាមភូមិភាគ ។ ឯកសារទាំង៦ច្បាប់នេះត្រូវបានថែរក្សាទុកនៅបណ្ណសារនៃមន្ទីរស-២១ ។

ចម្លើយសារភាពមុនៗជាច្រើននៅមន្ទីរស-២១គឺជាបណ្តុំរបាយការណ៍នគរបាលកម្ពុជាមុនបដិវត្តន៍ ។ ដោយប្រើប្រាស់ប្រព័ន្ធនៃការសួរសំណួរផ្ទាល់មាត់របស់បារាំង ឯកសារទាំងនេះមានកត់ត្រាការផ្តើមគំនិតរបស់អ្នកទោសដែលជាទូទៅជាការប្រកាសចោទប្រកាន់ខ្លួនឯង ។ ចម្លើយសារភាពជាច្រើនទៀតបានធ្វើឡើងទៅតាមលក្ខណៈពិសេសនៃសម័យអាណានិគមបារាំង ដូចជាសរសេរកាលបរិច្ឆេទដោយអក្សរមិនមែនដោយលេខជាដើម ។ល ។ ចម្លើយសារភាពភាគច្រើននៅមន្ទីរស-២១ត្រូវបានបញ្ជាក់ដោយការចុះហត្ថលេខាឬផ្តិតមេដៃនិងមានចុះថ្ងៃខែដោយអ្នកទោសនៅលើសន្លឹកនីមួយៗ ។ នៅពេលដែលអ្នកសួរចម្លើយសរសេរចេញជាចម្លើយសារភាព តែងតែមានការបញ្ជាក់ដោយអ្នកទោសនិងចុះហត្ថលេខាបញ្ជាក់មួយទៀតដោយបុគ្គលិកឯកសារដែលមានវត្តមាននៅពេលសួរចម្លើយ ។ ទម្រង់លម្អិតរបស់ចម្លើយសារភាពនិងឯកសារផ្សេងៗបង្ហាញថា ឌុច និងសហការីមានមោទកភាពចំពោះភាពហ្មត់ចត់ភាពទំនើបនិងប៉ិនប្រសប់របស់ខ្លួន ។ បុគ្គលិកនៅមន្ទីរស-២១ចង់ឲ្យមន្ទីរនេះក្លាយទៅជាកន្លែងសួរចម្លើយគំរូនិងចាត់ទុកខ្លួនឯងជាអ្នកជំនាញការសន្តិសុខពិតៗ ។

យើងដឹងតិចតួចណាស់អំពីដំណើរការសួរចម្លើយទៅលើអ្នកទោសនៅពេលមកដល់ ឬអំពីរបៀបដែលអ្នកសួរចម្លើយត្រូវនិយាយប្រាប់សង្ខេបៗពីមួយថ្ងៃទៅមួយថ្ងៃ ប៉ុន្តែទម្រង់ផ្សេងៗដែលទាក់ទងទៅនឹងអ្នកទោស១៩នាក់ក្រោមការសួរចម្លើយនៅក្នុងខែសីហា កញ្ញា និងខែធ្នូ ឆ្នាំ១៩៧៦ ដែលទម្រង់មួយផ្នែកត្រូវបានរកឃើញ បង្ហាញឲ្យដឹងអំពីដំណើរការទាំងអស់នេះ ។ សំណួរជាគោលគឺសួររកឈ្មោះពិតរបស់អ្នកទោស ឈ្មោះក្លែង អង្គភាពធ្វើការ និងខ្សែបណ្តាញ ។ ក្រោយមកក៏ចេញជាសេចក្តីសង្ខេបសរសេរដោយដៃដាក់សំណួរដែលត្រូវបានសួររួចហើយនៅថ្ងៃនោះ ហើយដាក់សំណួរមួយចំនួនទៀតសម្រាប់សួរនៅពេលក្រោយមកទៀត ។ ចំពោះអ្នកទោសជាច្រើននាក់ ទម្រង់បែបបទនៃការសួរចម្លើយលើអ្នកទោសម្នាក់ៗដែលនៅសល់គឺមានរហូតទៅដល់៦ដងជាប់ៗគ្នា ។ កំណត់ត្រារបស់អ្នកសួរចម្លើយអំពីសុខភាពរបស់អ្នកទោស(មានប្រាំនាក់ “ខ្សោយ”ហើយបីនាក់ទៀត “ធម្មតា”) គឺបង្ហាញថាអាចមាន ឬគ្មានការធ្វើទារុណកម្ម(នៅក្នុងករណីនេះគ្មានទេ) ហើយកត់សម្គាល់អំពីសភាពខ្វះឃ្លាងអ្នកទោស និងសោសម្រាប់ចាក់ចេញ ។ មានករណីមួយអ្នកសួរចម្លើយសង្កេតឃើញថា អ្នកទោសបានសរសេរចម្លើយសារភាពរបស់ខ្លួនរហូតទៅដល់១០ទំព័រមុនថ្ងៃសួរចម្លើយទៅទៀត ។



ទិដ្ឋភាពរៀបចំសារមន្ទីរគុកទួលស្លែងឆ្នាំ១៩៧៩

នៅចុងឆ្នាំ១៩៧៦ ឯកសារចម្លើយសារភាពភាគច្រើននៅមន្ទីរស-២១មានបួនផ្នែកផ្សេងគ្នាដែលនៅសល់រហូតមកដល់ការដួលរលំនៃរបបនេះ តែមានការកែប្រែខ្លះៗ ។ នៅក្នុងផ្នែកទីមួយ អ្នកទោសបានរៀបរាប់ពី“រឿងរ៉ាវជីវិត”ប្រាប់ឈ្មោះញាតិសន្តាននិងបក្ខពួក ហើយរាយឈ្មោះអង្គភាពដែលខ្លួនបានធ្វើការ ។ ប្រវត្តិរូបផ្ទាល់ខ្លួនទាំងនេះជាទូទៅមានរៀបរាប់ពីក្រោមនូវផ្នែកមួយដែលដាក់ថា “ប្រវត្តិសកម្មភាពក្បត់ ឬ “ប្រវត្តិនយោបាយ”[របស់ខ្ញុំ] ដែលមានរៀបរាប់តាមលំដាប់លំដោយ ។ ផ្នែកទីបីដែលដាក់ថា “ផែនការ” បានរៀបរាប់អំពីអ្វីដែលអ្នកទោសអាចធ្វើបានប្រសិនបើមិនត្រូវបានចាប់ខ្លួន ។ ចម្លើយសារភាពភាគច្រើនបញ្ចប់ទៅដោយតារាងរាយឈ្មោះបក្ខពួក ឬ“ខ្សែ”ក្បត់របស់អ្នកទោស ដែលមានបញ្ជាក់ប្រាប់ពីកន្លែងលាក់ខ្លួនទៀតផង ។ នៅក្នុងករណីខ្លះ “ខ្សែ” រួមមានឈ្មោះអ្នកដែលត្រូវបានរៀបរាប់នៅក្នុងចម្លើយសារភាព ទោះជាអ្នកនោះបានស្លាប់ហើយក៏ដោយ ។

ប្រវត្តិរូបផ្ទាល់ខ្លួនត្រូវបានរៀបចំឲ្យសរសេរតាមរបៀបកុម្មុយនិស្តពិសេស ។ មុនឆ្នាំ១៩៧៥ ការរៀបរាប់ដំណើរដើមទងអំពីប្រវត្តិផ្ទាល់ខ្លួនកម្រមានណាស់នៅក្នុងប្រទេសកម្ពុជា ហើយរបៀបសរសេរក៏មិនមានលក្ខណៈពិសេសដែរ ។ ប៉ុន្តែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដូចនៅក្នុងប្រទេសកុម្មុយនិស្តផ្សេងៗទៀត ការរៀបរាប់ប្រវត្តិរូបផ្ទាល់ខ្លួនដែលមានទាំងស្វ័យទិតៀនដងរបស់សមាជិកបក្ស ត្រូវបានរើសយកមកម្តងហើយម្តងទៀត ផ្ទៀងផ្ទាត់ និងទុកជាឯកសារ ។ ការសរសេរប្រវត្តិរូបនិងការយកមកប្រើប្រាស់យូរៗម្តងជាឯកសារបង្ហាញផ្លូវហាក់ដូចជាមានសារសំខាន់ណាស់នៅក្នុងបក្ស

កុម្មុយនិស្តចិននិងវៀតណាមជាងនៅកន្លែងផ្សេងៗទៀត ។ ការអនុវត្តរបៀបនេះត្រូវបានយកមកប្រើប្រាស់យ៉ាងទូលំទូលាយនៅប្រទេសចិនក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៤០ ។ នៅប្រទេសកម្ពុជា ប្រវត្តិស្វ័យទិតៀនត្រូវបានលើកឡើងនៅក្នុងការ "ប្រជុំជីវភាព"ធម្មតា ។ អ្នកមិនមែនកុម្មុយនិស្តជាច្រើនបានជួបប្រទះបែបបទនេះជាលើកដំបូងពេលដែលខ្លួនត្រូវបានជម្លៀសចេញពីទីរួមខេត្តនិងទីក្រុងនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ហើយឲ្យសរសេរនៅតាមចំណុចត្រួតពិនិត្យតាមផ្លូវធ្វើដំណើរ ។ នៅពេលដែលដំណើរការនេះបានក្លាយទៅជាទម្លាប់ទូទាំងប្រទេសនៅឆ្នាំ១៩៧៦ ប្រជាជនត្រូវបានឲ្យដាក់ឈ្មោះសមាជិកគ្រួសារ និងអ្នកធ្វើការជាមួយរៀបរាប់ពីធាតុវណ្ណៈដើម សកម្មភាពនយោបាយ និងកត់សម្គាល់ពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ខ្លួន ។ ចុងក្រោយ អ្នកចូលរួមប្រជុំជីវភាពទាំងអស់ត្រូវបានឲ្យបញ្ចេញយោបល់ដើម្បីកែប្រែខ្លួននិងអាកប្បកិរិយាតាមវិធីផ្សេងៗ ។

ការបើកកកាយរឿងខ្លួនឯងនេះដែលមានបញ្ជាក់នៅក្នុងសង្គមសម្ងាត់ជាច្រើន គឺក្នុងគោលបំណងធ្វើវិសុទ្ធកម្មអ្នកចូលរួមក្រុម ពង្រឹងសាមគ្គីភាពនៅក្នុងក្រុម និងបង្ហាញពីការកត់សម្គាល់និងប្រុងប្រយត្ន័របស់អង្គការ ។ ចំពោះសមាជិកបក្សវិញ បក្សបានជំនួសអង្គការ ។ ដេវីដ អាប់ធ័រ និង ជូនី សៃ បានរៀបរាប់អំពីបទពិសោធន៍នៃស្វ័យទិតៀននៅក្នុងប្រទេសចិនលែងកាន់លទ្ធិម៉ៅថា "បុគ្គលម្នាក់ៗចាប់ផ្តើមនិយាយឡើងគឺអំពីកំហុសនិងភាពសៅហ្មងរបស់ខ្លួន ហើយការលើកលែង មិនបោសសម្អាតចំពោះអំពើទាំងនេះជាការសំខាន់ណាស់ដែលនាំទៅដល់ការភ្ញាក់រឭកមិនត្រឹមតែសម្រាប់អ្នកឡើងនិយាយនេះទេ តែសំខាន់សម្រាប់សមូហភាពទាំងមូលតែម្តង ក្រែងលោថ្ងៃក្រោយទៅមានភាពល្អក់កករ ។ គំនិតមិនល្អនាំឲ្យល្អក់កករនិងវិសុទ្ធកម្មត្រូវបានកែតម្រង់តាមកន្លែងខ្វះប៉ុណ្ណោះគឺមិនធ្វើជាទូទៅទេ" ។

ដូច្នេះ ប្រវត្តិរូបទាំងនេះដែលត្រូវបានចម្រាញ់ចេញមកក៏អាចយកទៅប្រើប្រាស់ជាភស្តុតាងពាក់ព័ន្ធកំហុសឬសម្រាប់តម្លើងឋានៈដែរ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមនុស្សម្នាក់ៗសុទ្ធតែត្រូវបានជម្រះទោសឥតឈប់ឈរ ។ ភាពគួរឲ្យទុកចិត្តអាចចុះថយប្រសិនបើជាពត៌មាននៅក្នុងប្រវត្តិរូបត្រូវបានរកឃើញថា មិនពេញលេញ ខុស"ស្មុគស្មាញ" ឬមិនត្រឹមត្រូវ ។ ផ្ទុយមកវិញ ប្រវត្តិរូបដែល"ល្អ"ដែលមានធាតុវណ្ណៈដើម"ល្អ" និងសកម្មភាពគួរឲ្យសរសើរអាចនាំដល់ការបញ្ចូលជាសមាជិកភាពរបស់បក្សចាត់តាំងការងារប្រសើរជាងមុននិងពង្រឹងសន្តិសុខផ្ទាល់ខ្លួន ។ គក ស្រស់ បាននិយាយថា គាត់បានឡើងឋានៈនៅក្នុងជួរបក្ស(គាត់បានក្លាយជាសមាជិកបក្សពេញសិទ្ធិនៅឆ្នាំ១៩៧៨) ដោយសារគាត់ធ្វើការងារសកម្មនិងមាន"ប្រវត្តិរូបល្អ" ។ ញ៉ែម អេន អ្នកថតរូបនៅមន្ទីរស-២១ ក៏បានអះអាងប្រហាក់ប្រហែលគ្នានេះដែរ ។

នៅដំណាក់កាលនោះ ប្រវត្តិរូបត្រូវបានសរសេរឲ្យស្របតាមតម្រូវការរបស់បក្ស គឺសរសេរដោយផ្ទៀងផ្ទាត់ជាមួយនឹងប្រវត្តិបក្សចាប់ពីពេលផ្តើមសរសេរ និងផ្ទៀងផ្ទាត់ជាមួយនឹងតម្រូវការជាយុទ្ធសាស្ត្រដែលចេះតែផ្លាស់ប្តូរឥតឈប់ឈរ ។ វគ្គសិក្សានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ជាក់អំពីសារសំខាន់នៃការរៀបចំប្រវត្តិរូបឲ្យបាន "ស្អាត" ហើយអ្នកអានទស្សនាវដ្តី "ទង់បដិវត្តន៍" ត្រូវបានព្រមានថាកុំឲ្យទាក់ទងជាមួយនឹងមនុស្សដែលមានប្រវត្តិរូបស្មុគស្មាញ ។ មួយរយៈក្រោយមកនៅឆ្នាំដដែល នៅពេលនិយាយថាខ្មាំងនៅក្នុងជួរបក្ស គឺជា "មេរោគ" ប៉ុល ពត បានប្រាប់ទៅកូនចៅរបស់ខ្លួនថា "ប្រវត្តិរូបជីវិតត្រូវតែល្អនិងសមស្របតាមតម្រូវការរបស់យើង" ។ កម្មាភិបាលជាន់ខ្ពស់បានជ្រើសរើសយកប្រវត្តិរូបមួយចំនួនរបស់កូនចៅនៅក្រោមបញ្ជាមកមើល ។ នួន ជា បានសម្តែងនូវការសោកស្តាយរបស់ខ្លួនដែលមិនសូវបានយកចិត្តទុកដាក់ក្នុងរឿងនេះថា÷ "ចំណុចខ្វះខាតរបស់ខ្ញុំគឺថាខ្ញុំមិនបានតាមដានឯកសារប្រវត្តិរូបរបស់បក្សនិងសមាជិកស្នូលឲ្យបានលម្អិតហើយចាត់វិធានការបោសសម្អាតនៅក្នុងជួរបក្សទេ ។ ខ្ញុំមើលតែសកម្មភាពទូទៅរបស់គេប៉ុណ្ណោះ ខ្ញុំមិនអាចក្តាប់ធាតុដើមដែលមានសារ-សំខាន់របស់គេទេ ខ្ញុំមិនបានជីកឫសជីកគល់រឿងគ្រួសារគេ ។ នេះធ្វើឲ្យខ្មាំងមានឱកាសយ៉ាងងាយក្នុងការជ្រៀតចូលស៊ីរូងផ្ទៃក្នុងបក្ស" ។

នៅឆ្នាំ១៩៧៧ ប្រជាជនកម្ពុជារាប់សែននាក់ក៏ដូចជាសមាជិកបក្ស បានសរសេរប្រវត្តិរូបផ្ទាល់ខ្លួន ។ មានរាប់ពាន់

នាក់បានសរសេរប្រវត្តិរូបលើសពីមួយ ។ មានប្រវត្តិរូបចំនួនជាងពីររយច្បាប់ដែលរៀបចំដោយបុគ្គលិកមន្ទីរស-២១ នៅសេសសល់ក្នុងទម្រង់ជាសៀវភៅស្តើងដែលត្រូវបានយកមកប្រើប្រាស់នៅទូទាំងប្រទេស ។ សៀវភៅប្រវត្តិរូបស្តើងទាំងនេះមានបញ្ជីសំណួរដែលដូចគ្នាទៅនឹងផ្នែកប្រវត្តិរូបនៅក្នុងចម្លើយសារភាព ហើយទម្រង់សំណួរនៅក្នុងសៀវភៅនេះបង្កើតបានជាមូលដ្ឋានសម្រាប់ការសួរចម្លើយជាច្រើន ។

បញ្ជីសំណួរបើកចំហដោយសួរអំពីឈ្មោះសាមីជន ឈ្មោះបដិវត្តប្រសិនបើមាន ថ្ងៃ-ខែ-ឆ្នាំកំណើតនិងទីកន្លែងកំណើត ភេទ ជនជាតិ ឬជាតិពន្ធ និងរៀបការឬនៅលីវ ។ ចំណុចបន្ទាប់ទៀតដែលនិយាយពី«របររកស៊ីនិងវណ្ណៈភាពដើមមុនពេលចូលបដិវត្តន៍» ត្រូវបានយកមកប្រើដើម្បីកំណត់វណ្ណៈភាព ។ ប្រជាជនរស់នៅទីក្រុងមុនបដិវត្តន៍ដែលស្គាល់ថាជា «ប្រជាជនថ្មី» ក្រោយឆ្នាំ១៩៧៥ត្រូវបានចាត់ចូលប្រភេទជា «អ្នករាជានិយម» «មូលធននិយម» ឬ«អនុធន» ។ ប៉ុន្តែចំណាត់ថ្នាក់វណ្ណៈសម្រាប់ប្រជាជនជនបទវិញគឺនិយាយអំពីទ្រព្យសម្បត្តិជាសម្ភារដែលត្រូវបានគិតតាមមូលដ្ឋានដីធ្លីដែលមានសម្ភារសម្រាប់សង់ផ្ទះ ចំនួនសមាជិកក្នុងបន្ទុក និងចំនួនបសុសត្វដូចជា គោ ក្របី និងសម្ភារធ្វើស្រែចម្ការដែលគ្រួសារនេះមាន ។ ជាក់ស្តែង សួស ធី ប្រធានក្រុមធ្វើឯកសារនៅមន្ទីរស-២១ សរសេរនៅក្នុងប្រវត្តិរូបខ្លួនថា «កសិករថ្នាក់កណ្តាល» ចំណែកឯ ហ៊ឹម ហ៊ុយ ដាក់ថា «កសិករកណ្តាលថ្នាក់ក្រោម» ។ នៅក្នុងចម្លើយសារភាពតែងតែភ្លេចនិយាយអំពីវណ្ណៈភាព ប្រហែលដោយសារធាតុវណ្ណៈ«ល្អ» ត្រូវបានលុបបំបាត់ ឬធាតុវណ្ណៈ«អាក្រក់» លេចឡើងតាមរយៈសកម្មភាពក្បត់របស់អ្នកទោស ។

មុនឆ្នាំ១៩៧៥ មានប្រជាជនមួយចំនួនតូចដែលស្ថិតនៅក្រោមចលនាកុម្មុយនិស្តសម្ងាត់ បានធ្វើការវិភាគធាតុវណ្ណៈ ។ ប៉ុន្តែភាគច្រើននៃអ្នកទាំងនេះបានធ្វើការបែងចែកជាទូទៅថាអ្នកណាខ្លះត្រូវស្ថិតនៅក្នុងក្រុម«អ្នកមាន» «អ្នកមធ្យម»និង«អ្នកក្រ» ទៅតាមក្រុមមនុស្សដែល«ប្រើ» «អ្នកជា» និង «អ្នកបម្រើ» ។

សក្តានុពលបដិវត្តនិងតម្លៃខាងក្នុងរបស់ជនជាតិកម្ពុជាត្រូវបានគិតថាជាការបង្ហាញឲ្យឃើញពីធាតុវណ្ណៈ ។ អ្នកដែលមានធនធានតិចតួចមាន«ដំណើររឿងជីវិត» យ៉ាងល្អបំផុត ហើយប្រហែលជាមានឋានៈខ្ពស់ទៀតផង ។ ផ្ទុយទៅវិញ អ្នកដែលមានទំនាក់ទំនងឬកម្មសិទ្ធិច្រើន គឺមានប្រវត្តិរូប«ស្មុគ្រស្មាញ» ហើយក្លាយជាសត្រូវដ៏ធំ ។ ធាតុវណ្ណៈរបស់«បង១ថ្នាក់លើ» ត្រូវបានលាក់យ៉ាងជិតមិនឲ្យអ្នកណាដឹងឡើយ ។ ភាគច្រើននៃអ្នកទាំងនោះ លើកលែងតាម៉ុកចេញដែលជាករណីពិសេស សុទ្ធតែមានប្រភពចេញមកពីស្រទាប់អនុធន ។ បង១ថ្នាក់លើបានរៀបចំប្រវត្តិរូបស្វ័យទិតៀនដោយខ្លួនឯង ប៉ុន្តែដោយសារខ្លួនបានដឹកនាំប្រទេសសម្រេចបានជ័យជម្នះនៅឆ្នាំ១៩៧៥ ជាការច្បាស់ណាស់អ្នកទាំងនោះក៏លុបបំបាត់ចោលនូវស្នាមទុយ៌សរបស់ខ្លួនកាលពីអតីត ។ នៅក្នុងការស្វែងរកការត្រាស់ដឹងដែលមានរយៈពេលមួយជីវិត តាមជាក់ស្តែង បង១ថ្នាក់លើបានទៅដល់ក្បែរ១នៃព្រះនិព្វានដែលជាកន្លែងត្រាស់ដឹងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះពុទ្ធ(ដែលខ្លួនឯងបានមើលងាយមើលថោកនោះ) ។ មិនខុសពីសាវ័ករបស់ព្រះពុទ្ធទេ បង១ថ្នាក់លើត្រូវបានផ្តល់គ្រឿងបរិក្ខារសម្រាប់ជួយអ្នកដទៃឲ្យឈានដល់ព្រះនិព្វាន ។ នៅក្នុងន័យនេះ វាជាការចាប់អារម្មណ៍ដែរដែលហ៊ូជីមិញជ្រើសរើសរហស្សនាមខ្លួនឯងថា ព្រះហូជាម្ចាស់នៅឆ្នាំ១៩៤៣ មុនពេលចូលបញ្ជា«រំដោះ»ប្រទេសវៀតណាម ។

សំណួរបន្ទាប់មកទៀតនោះគឺសួរឲ្យអ្នកទោសឆ្លើយរាយឈ្មោះសមាជិកនៅក្នុងជួរ «អង្គការនយោបាយមិនបដិវត្តន៍» ។ បុគ្គលិកមន្ទីរស-២១ដែលខ្ញុំបានមើលបញ្ជីសំណួរនោះសរសេរថា «គ្មាន» ។ ប៉ុន្តែអ្នកទោសត្រូវបានជំរុញឲ្យឆ្លើយនៅត្រង់ចំណុចនេះដើម្បីសារភាពថាមានទំនាក់ទំនងជាមួយនឹងរបប លន់ ណុល ជាមួយគណបក្សដែលប្រឌិតឡើងឬដែលបាត់ស្រមោលទៅហើយ និងជាមួយភ្នាក់ងារសម្ងាត់បរទេសផ្សេង១ទៀត ។

សំណួរបន្ទាប់មកទៀតគឺថា តើចូលបដិវត្តន៍នៅពេលណា? ។ ដំណើរការនេះ តាមការស្មានប្រហែលមានពិធីសច្ចាប្រណិធានចំពោះមុខអង្គការនិងសម្តែងពីបំណងចង់កាន់អាវុធផង ។ នៅក្នុងសំណួរស្ទើរតែទាំងអស់និងចម្លើយសារភាពភាគច្រើន ពាក្យថា ចូលបដិវត្តន៍ គឺដូចគ្នាទៅនឹងចូលធ្វើកងទ័ពខ្មែរក្រហមក្នុងចន្លោះឆ្នាំ១៩៧០-១៩៧៥ដែរ ។ **(នៅមានត)**



# ការគុំកួន ការផ្សះផ្សា និង ខ្មែរក្រហម

នៅពេលកំហឹងគ្របដណ្តប់យើង វាធ្វើឲ្យប៉ះពាល់ដល់ខ្លួនយើងផ្ទាល់និងអ្នកដែលនៅជុំវិញយើង ។ កំហឹងដុតរោលចិត្តនិងខ្លួនប្រាណ ។ មុខឡើងក្រហម ចិត្តចាប់ផ្តើមចុះខ្សោយ ដៃចាប់ផ្តើមញ័រ ។ **មហាឃោសានន្ទ** ។

ចំពោះអ្នកក្រៅ ហើយជារឿយៗខ្លួនយើងផ្ទាល់តែម្តងតែងប្រមើលមើលថា ប្រទេសកម្ពុជាមើលទៅហាក់ដូចជាមានសន្តិភាពគ្រប់គ្រាន់ ។ ប្រជាកសិករក៏ចេះតែខំប្រឹងបង្កបង្កើនផលខ្លួបប្រាំងខ្លួបវស្សា ។ អ្នកនេសាទត្រីរស់នៅលើទូក ។ វិថីដ៏ធំទូលាយនៅរដ្ឋធានីភ្នំពេញមានដើមឈើបញ្ចេញផ្កាស្រស់បំព្រង ។ សម្រស់និងភាពស្អាតស្អំបែបនេះយើងអាចមើលឃើញតាមរយៈចក្ខុវិស័យ ។ ប៉ុន្តែអ្វីដែលនៅខាងក្នុង ហើយដែលមិនអាចមើលឃើញ និងបានលាក់ទុកមកជាយូរនោះគឺ «គុំ» ។ «គុំ» គឺជាពាក្យខ្មែរសំដៅដល់គំនិតចង់សងសឹក ។ បើនិយាយឲ្យច្បាស់ជាងនេះទៅទៀត «គុំ» គឺជាកំហឹងដ៏យូរអង្វែងដែលនាំទៅដល់ការសងសឹកលើសពីអ្វីដែលជាការខូចខាតពីដើមដំបូងទៅទៀត ។ ប្រសិនបើខ្ញុំវាយអ្នកឯងមួយដៃ អ្នកឯងរង់ចាំប្រាំឆ្នាំទើបវាយខ្ញុំសងវិញពីក្រោយខ្នងក្នុងទីងងឹតសូន្យឈឹង ។ របៀបនេះខ្មែរហៅថា «គុំ» ប្រជាជនកម្ពុជាយល់ច្បាស់ណាស់អំពីពាក្យថា«គុំ» នេះ ។ “នេះជា



*ជង់ឆ្អឹងដែលចេះតែរាលដាលឥតឈប់ឈរនៅក្នុងព្រលឹងជាតិយើង ។»* **នេះជាសម្តីរបស់លោក ហាំង ឆៅ ។**

ទស្សនាវដ្តីទង់បដិវត្តន៍លេខពិសេស(នៃរបបកម្ពុជាប្រជាធិបតេយ្យ) ចេញផ្សាយសម្រាប់ខែកញ្ញា-តុលា ឆ្នាំ១៩៧៦ បានព្រមានថា «អំណាចវណ្ណៈកម្មករ-កសិករនេះ យើងដណ្តើមបានតាមការបង្ហូរឈាមយូរលង់ ។ វណ្ណៈជិះជាន់ទាំងក្នុងប្រទេសទាំងក្រៅប្រទេស វាចងកំហឹងខ្លាំងនឹងយើង ហើយវាមានគំនុំនឹងមកដណ្តើមអំណាចមកវិញ» ។ ពីរបីប្រយោគមកក្រោមទៀតមានសរសេរថា «ទន្ទឹមនេះត្រូវមានវិធានការបោសសម្អាតសម្រិតសម្រាំងរដ្ឋអំណាចយើងឲ្យបានស្អាត ឲ្យរឹង ឲ្យខ្លាំង ។»

ជាការច្បាស់ណាស់ ខ្មែរក្រហមដឹងថាដោយសារនយោបាយប្រល័យពូជសាសន៍មកលើក្រុមមួយចំនួនចាប់ពី «ប្រជាជនថ្មី»រហូតដល់ប្រជាជនចាមដែល«ត្រូវសម្រិតសម្រាំង» ជនរងគ្រោះដែលជាមុខសញ្ញាទាំងនេះក៏មានកំហឹងនឹងនយោបាយរបស់ខ្មែរក្រហម ។ នេះសបញ្ជាក់ថា ប្រជាជនជាច្រើនរួមទាំង«ប្រជាជនចាស់»ទាំង«ប្រជាជនថ្មី» ក្រោយពីខ្មែរក្រហមធ្លាក់ពីអំណាចភ្លាម ក៏ចាប់ផ្តើមសងសឹកចំពោះកម្មាភិបាលខ្មែរក្រហមនៅទូទាំងប្រទេសកម្ពុជា ជួនកាលរហូតដល់កាត់ក្បាលកម្មាភិបាលដែលបានប្រព្រឹត្តអំពើឃោរឃៅទៀតផង ។

ប្រជាជនកម្ពុជាជាច្រើនដែលទទួលរងនូវការឈឺចាប់យ៉ាងខ្លាំង និងបាត់បង់សាច់សាលោហិតក្នុងក្រុមគ្រួសារជាច្រើននៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏បន្តចងគំនុំជាមួយខ្មែរក្រហម ។ អារម្មណ៍នេះដុតរោលកាន់តែខ្លាំងថែមទៀតតាមរយៈសង្គ្រាមស៊ីវិល អត្ថបទអប់រំឃោសនា បូជនីយដ្ឋាន និងការប្រារព្ធពិធី«ថ្ងៃចងកំហឹង» ។ ដោយមានការចុះចូលពីសំណាក់ខ្មែរក្រហមនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០បញ្ហា «ចងកំហឹង» នឹងខ្មែរក្រហម កាន់តែមានភាពស្មុគស្មាញថែមទៀត ។ ម្យ៉ាងវិញនោះ កម្មាភិបាលមួយចំនួនដែលធ្លាប់បានធ្វើការបំភិតបំភ័យក្នុងភូមិស្រុក ក៏លេចមុខសាជាថ្មីនៅកន្លែងដែលខ្លួនធ្លាប់ធ្វើសកម្មភាពពីមុន(ឬនៅក្បែរៗនោះ) ហើយមករស់ជាមួយអ្នកស្រុកអ្នកភូមិដែលខ្លួនបានរំលោភបំពាន ។ រីឯតុលាការចាប់ផ្តើមលេចស្រមោលស្លុងៗនៅពេលអនាគតដ៏ខ្លីខាងមុខនេះ ដើម្បីជម្រះទោសមេដឹកនាំខ្មែរក្រហមដែលបានអនុវត្តនយោបាយប្រល័យពូជសាសន៍ ។ ដោយសារព្រឹត្តិការណ៍ទាំងនេះ ធ្វើឲ្យប្រជាជនកម្ពុជាជាច្រើនមានអារម្មណ៍កាន់តែខ្លាំងឡើង ជាពិសេសការគុំកួននិងចង់សងសឹក វាល្មមដល់ពេលផ្អាកត្រឹមនេះសិន ហើយបង្ហាញថាអ្វីទៅជាគំនុំ ហើយថាតើប្រជាជនកម្ពុជាដែលនៅតែបន្តចងកំហឹងនឹងខ្មែរក្រហមអាចសម្របសម្រួលផ្សះផ្សាជាមួយអតីតសត្រូវរបស់ខ្លួនបានដែរឬយ៉ាងណា ។

អ្វីទៅជាការគុំកួនដូចដែលលោក ហាំង ឆៅ លើកឡើងនៅកថាខណ្ឌខាងលើ ដែលនោះគឺប្រភពនៃហិង្សាដែលមិនចេះចប់

ចេះហើយ នៅក្នុងសង្គមកម្ពុជាគឺ«គុំគួន»ដែលនាំទៅដល់«ការសងសឹក» ។ វចនានុក្រមរបស់ពុទ្ធសាសនបណ្ឌិត(ទំព័រ១៧០,១៧១ បោះពុម្ពផ្សាយនៅឆ្នាំ១៩៦៧)ពន្យល់ពាក្យ «គុំ» ថាៈ ប៉ងដោយអាក្រក់, ប៉ងធ្វើការបៀតបៀនគេ ចងចិត្តព្យាបាទគេ ចងគំនុំគុំវាយ គុំបម្រុងនឹងសងសឹកវិញ ។ វចនានុក្រមនេះ បន្តពន្យល់ទៀតថា គុំគួនគឺ គុំយ៉ាងខ្លាំងខ្ជាប់ខ្ជួនមិនបណ្ដោយឲ្យភ្លេច ។ ឧទាហរណ៍ៈ វាគុំគួនយូរហើយ បម្រុងនឹងលបវាយមិត្តចាស់របស់វា ។

ស្ត្រីខ្មែរម្នាក់ធ្វើការនៅខាងសិទ្ធិមនុស្សបានធ្វើការពន្យល់ខ្លីហើយច្បាស់ៗថា «មនុស្សម្នាក់នឹងចងកំហឹងនៅពេលដែលគាត់ដឹងថាមនុស្សម្នាក់ទៀតបានធ្វើអំពើអាក្រក់មកលើគាត់ ។ បុគ្គលម្នាក់នោះនឹងរក្សាគំនិតនេះនៅក្នុងចិត្ត» ។ នៅពេលមនុស្សម្នាក់ធ្វើឲ្យបុគ្គលដែលនិយាយខាងលើនេះ ឬក្រុមរបស់គាត់ទទួលរងនូវការឈឺចាប់(ដូចជាសម្លាប់ក្រុមគ្រួសារ) បាត់បង់អំណាច(ដូចជាបណ្ដេញចេញពីកន្លែងធ្វើការ) ឬបាក់មុខបាក់មាត់(ដូចជាធ្វើឲ្យខូចកិត្តិយសតែបន្តិចបន្តួច) ជាទូទៅវាស្ទើរតែនាំដល់កំហឹងនិងការអៀនខ្មាសយ៉ាងខ្លាំង ហើយមានបំណងចង់«ឈ្នះ» សត្រូវរបស់ខ្លួនជាក់ជាមិនខាន ។

ចំណែកឫសគល់នៃការសងសឹកវិញគឺថា «សង» មានន័យថាឲ្យតម្លៃរបស់ដែលទិញ ឬដែលខ្ចីគេមក ឬចេញថ្លៃឲ្យគេជាជំនួសរបស់ដែលខូចដែលវិនាសព្រោះខ្លួន ដូចជាសងបំណុលសងថ្លៃស្រូវគេ ។ ខ្លឹមសារស៊ីជម្រៅបំផុតនៅក្នុងសង្គមកម្ពុជាគឺពាក្យថា«សងគុណអ្នកដទៃ» ។ ដូច្នេះតាមក្រមសីលធម៌ប្រជាជនទូទៅត្រូវ «សងគុណ»ឪពុកម្ដាយ សាច់ញាតិបងប្អូន គ្រូបាធ្យាយនិងអាណាព្យាបាលដែលបានធ្វើល្អចំពោះខ្លួន ។ ជាទូទៅមនុស្សរមិលគុណត្រូវទទួលនូវការស្អប់ខ្ពើមយ៉ាងខ្លាំង ។ ការដឹងគុណបែបនេះតែងតែបង្កើតឡើងនូវទំនាក់ទំនងផ្ទាល់ខ្លួនរវាងភាគីពីរខាង ។ អ្នកដែលទទួលអំពើល្អនឹងទទួលស្គាល់ការដឹងគុណរបស់ខ្លួន ដោយស្ដែងចេញការគោរពយ៉ាងខ្លាំង ភក្ដីភាព និងសេចក្ដីស្រលាញ់ចំពោះឧបការីជនរបស់ខ្លួន ទោះជាកម្រិតនៃការសងគុណមានកម្រិតពុំស្មើនឹងគុណដែលខ្លួនបានទទួលក៏ដោយ ។ ការគោរពកាន់តែខ្លាំងឡើងៗរបស់អ្នកដែលដឹងគុណ ធ្វើឲ្យបុគ្គលដែលធ្វើអំពើល្អនោះមានមុខមាត់កាន់ខ្ពស់ទៅតាមនោះដែរ ។

ជាងនេះទៅទៀតយើងឃើញថា ការសងសឹកគឺជាការសងប្រាសមកវិញ ។ បើធ្វើល្អនឹងបានទទួលផលល្អ បើធ្វើអាក្រក់នឹងទទួលបានផលអាក្រក់ ។ ពាក្យថា សងសឹកមានន័យត្រង់ថា«សងសឹកនឹងសត្រូវ» ។ មិនតែប៉ុណ្ណោះសោត ការសងសឹករបស់ភាគីរងរបួសស្នាមជាមួយសត្រូវរបស់ខ្លួនបង្កើតបានជាចំណងមួយ ។ ជនជាតិខ្មែរមួយរូបដែលមានចិត្តព្យាបាទគេតែងតែថា«ចងកំហឹងជាមួយសត្រូវ» ។ ឧទាហរណ៍នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ឬរដ្ឋកម្ពុជា រដ្ឋាភិបាលបានរៀបចំប្រារព្ធទិវាចងកំហឹង ។ នៅស្រុកនីមួយៗប្រជាជនតែងតែនាំគ្នានៅតាមវាលពិឃាតឬបូជនីយដ្ឋានតំកល់អដ្ឋិធាតុប្រចាំស្រុករបស់ខ្លួន ដើម្បីស្ដាប់រដ្ឋអំណាចមូលដ្ឋាននិងជនរងគ្រោះធ្វើវិយោគកថាទាក់ទងនឹងអំពើឃោរឃៅដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកស្រុកអ្នកភូមិកាន់កាំបិត ពូថៅ ដំបងព្រនង់ក្នុងដៃហើយស្រែកថា«វាយឲ្យបរាជ័យបន ប៉ុល ពត អៀង សារី ខៀវ សំផន» ឬថា «ចងចាំជានិច្ចនូវជីវិតវេទនាក្រោមរបប ប៉ុល ពត ដែលចង់បំបាត់ពូជសាសន៍ខ្មែរ» ។ ពិធីបុណ្យនេះគឺជាមធ្យោបាយដ៏ស័ក្តិសិទ្ធិក្នុងការធ្វើឲ្យប្រជាជន«មានកំហឹងជាប់ជានិច្ច»ចំពោះខ្មែរក្រហមដែលនៅតែធ្វើសង្គ្រាមឈ្លបប្រឆាំងនឹងរដ្ឋាភិបាលនៅពេលនោះ ។ ពិធីចងកំហឹងនេះ ទោះបីជាមានរូបភាពមិនសូវផុសផុលក៏ដោយ ប៉ុន្តែវាបានបន្តមកដល់សព្វថ្ងៃនេះ ។

ការចងគំនុំអាចបណ្ដាលមកពីព្រឹត្តិការណ៍ឬហេតុការណ៍តូចៗដែលផ្សំផ្គុំច្រើនៗ ហើយក្លាយទៅជាបញ្ហា ។ បុគ្គលម្នាក់តែងតែចង់សងសឹកនៅពេលបុគ្គលម្នាក់ទៀត«ធ្វើអំពើអាក្រក់»មកលើខ្លួន ។ ឧទារហណ៍ដូចជានៅក្នុងរឿងទុំទាវ ទុំខឹងនឹងអរជូនដែលចង់រៀបការនាងទាវជាមួយកូនប្រុសរបស់ខ្លួន ។ ប្រជាជនខ្មែរជាច្រើនបន្តចងកំហឹងព្យាបាទជាមួយខ្មែរក្រហមដែលទទួលខុសត្រូវចំពោះការឈឺចាប់ទុក្ខវេទនានិងការសម្លាប់របស់ក្រុមគ្រួសារខ្លួន ។ ស្រដៀងគ្នានេះដែរ នៅខែវិច្ឆិកា ឆ្នាំ១៩៩៤ នៅពេលអ្នកផ្សព្វផ្សាយសាសនាយេស៊ូឈ្មោះ ម៉ៃ អេវ៉ាន មកដល់កម្ពុជាហើយសន្យាព្យាបាលមនុស្សខ្វាក់ឲ្យមើលឃើញនិងអ្នកខ្វិនជើងឲ្យដើររួច ប្រជាជននៅទូទាំងប្រទេសបានមានក្តីរីករាយផង

រំភើបផង នាំគ្នាលក់របស់របរដើម្បីយកធ្វើជាសោហ៊ុយធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញដើម្បីមកព្យាបាលជំងឺនិងពិធីញ៉ាំងឲ្យប្តូរសាសនាដែលរៀបចំដោយ ម៉ៃ អេវ៉ាន ។ ក្រោយពីផ្តល់គម្ពីរសាសនាគ្រិស្តហើយ អេវ៉ាន មិនបានព្យាបាលជំងឺជូនប្រជាជនទាំងអស់នោះឡើយ ។ នៅយប់ទីបី អ្នកមកចូលរួមទាំងអស់ដឹងថាខ្លួនត្រូវចាញ់បោកជនបរទេសនេះ ហើយក៏ចាប់ផ្តើមធ្វើកុបកម្មតែម្តង ។ អេវ៉ាន បានរត់គេចពីកម្ពុជាដោយខ្លួនទទេ ហើយបន្តមានសត្រូវដែលចង់សងសឹកចំពោះអំពើដែលគាត់បានប្រព្រឹត្តរហូតមកដល់សព្វថ្ងៃនេះ ។ (នៅពេលត្រឡប់មកដល់សហរដ្ឋអាមេរិកវិញ អេវ៉ាន បាននិយាយទៅកាន់បរិស័ទដែលកំពុងធ្វើសក្ការៈថា ដំណើររបស់គាត់ទៅកាន់ប្រទេសកម្ពុជាបានទទួលជោគជ័យល្អណាស់) ។

ម្យ៉ាងវិញទៀត ការចងកំហឹងអាចកាន់តែមានកម្រិតខ្លាំងឡើងៗនៅពេលបុគ្គលម្នាក់ទទួលនូវកំហឹងបន្ថែមទៀតដែលមានរូបភាពជាកំហឹងនៅស្រាលតែអាចចងបាន ពោលគឺ«ហេតុការណ៍» ។ បុគ្គលដែលមានកំហឹងនៅក្នុងខ្លួនអាចទប់ចិត្តមិនឲ្យមានជម្លោះផ្ទុះចេញមកបាន ប៉ុន្តែមិនភ្លេចកំហឹងងាយៗបានទេ ។ ដូចដែលឈ្មោះ លីម បានប្រាប់ខ្ញុំថា «ប្រជាជនខ្មែរចងចាំមិនភ្លេចទេ ។ គេចងចាំរឿងរ៉ាវគ្រប់បែបយ៉ាង ។ នៅពេលមានហេតុការណ៍បន្តិចបន្តួចដែលមានចរិតបង្កឲ្យមានកំហឹង គេក៏ចាប់ផ្តើមចងគំនុំភ្លាម» ។ ការមិនសប្បាយចិត្តដែលកប់ទុកក្នុងចិត្តយ៉ាងស្ងៀមស្ងាត់អាចជាគំរូដល់ក្មេងៗនៅពេលវាឈ្លោះប្រកែកគ្នា ។ ឪពុកម្តាយបំបែកកូនរបស់ខ្លួនដែលកំពុងឈ្លោះគ្នាដោយឃាត់កូនឲ្យឈប់ឈ្លោះគ្នា ប៉ុន្តែភាគច្រើនមិនបានប្រាប់កូនឲ្យសុំទោសឬសម្រួលគ្នាជាមួយក្មេងនៅម្ខាងទៀតទេ ។ បើសុំទោសនឹងធ្វើឲ្យអាប់មុខអាប់មាត់ទាំងកូននិងទាំងឪពុកម្តាយ ។ ជនជាតិខ្មែរម្នាក់បានពន្យល់ថា «និយាយថា«សុំទោស» មួយមាត់ធ្វើឲ្យខ្លួនថោកទាបខ្លាំងណាស់ ។ ពាក្យនេះដូចជា មានន័យថា«សូមឲ្យខ្ញុំចាញ់» យ៉ាងដូច្នេះដែរ ។ ជួនកាលឪពុកម្តាយរបស់ក្មេងម្នាក់ដែលវ៉ៃចាញ់គេ ខឹងខ្លាំងណាស់» ។ ជាលទ្ធផលគឺថា កូនចៅ«មិនដឹងថាតើត្រូវបំភ្លេចកំហឹងយ៉ាងដូចម្តេចទេ» ជួនកាលក៏ចងជាគំនុំតូចមួយក្នុងចិត្ត ហើយអាចឈប់និយាយរកគ្នាពីរបីថ្ងៃ ពីរបីខែ ឬឈប់និយាយរហូតតែម្តង ។

ក្នុងភាសាខ្មែរមានឃ្លាជាច្រើននិយាយពីគំនិតសន្សំរឿង ។ ជនជាតិខ្មែរមួយចំនួននិយាយថា បុគ្គលម្នាក់ទទួលយកកំហឹងយកមកទុកក្នុងខ្លួន ឬលាក់ទុកក្នុងចិត្ត ជួនកាលលាក់ទុកក្នុងក្បាល ។ ជាក់ស្តែង យុវជនម្នាក់ឈ្មោះ គិច ដែលរស់ក្នុងត្រកូលអ្នកក្រក្សត់មួយ បានទទួលការអញ្ជើញទៅចូលរួមពិធីការញាតិមិត្តនៅក្រុងកំពង់ចាមដែលជាត្រកូលអ្នកខ្ពង់ខ្ពស់គ្រាន់បើ ។ ប៉ុន្តែនៅពេលដែល គិច ទៅដល់កន្លែងពិធីមង្គលការ ម្ចាស់ដើមការមិនញញឹមដាក់ឬស្វាគមន៍គាត់ត្រឹមត្រូវទេ ។ គិច និយាយថា «ខ្ញុំបាក់មុខនិងតូចចិត្តយ៉ាងខ្លាំង ។ អ្នកមានទាំងនេះមិនបានគោរពខ្ញុំឲ្យបានសមរម្យទេ ពីព្រោះខ្ញុំជាអ្នកក្រ ។ ខ្ញុំបានដឹកស្រវឹងហើយលាក់ទុកកំហឹងនេះនៅក្នុងចិត្តមិនបញ្ចេញឲ្យអ្នកណាដឹងទេ» ។ គិច និយាយថា គាត់មិនសម្តែងកំហឹងដោយផ្ទាល់ដាក់គ្រួសារនេះទេ តែគាត់កំពុងតែ«លាក់ទុកក្នុងចិត្ត» ។ ហេតុការណ៍កំប៉ិកកំប៉ុកបែបនេះអាចធ្វើឲ្យបុគ្គលម្នាក់មានការអន់ចិត្តនិងមានកំហឹងដែលជួនកាលខ្មែរហៅថា«ឈឺចាប់» ។ ដូចដែលខ្ញុំបានលើកមកពិភាក្សាតាមរយៈអត្ថបទរបស់ខ្ញុំនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត(លេខ១៧)ថាៈ ការអន់ចិត្តដែលចេះតែកើនឡើងបន្តិចម្តងៗ ក្លាយជាកត្តាសំខាន់ស្ទាប់រស់ក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យ ។ ពេលនោះ មនោគមវិជ្ជាខ្មែរក្រហមជំរុញ ឬញុះញង់ឲ្យអ្នកក្រខ្សត់ធ្វើការសងសឹកទៅលើអ្នកមានចំពោះការរំលោភដែលកើតឡើងកាលពីអតីតកាល ។

គំរូព្យាបាទដែលលើកមកនិយាយខាងលើនេះគឺជាសញ្ញាណបង្ហាញថាហេតុការណ៍កំប៉ិកកំប៉ុកផ្សំគ្នាច្រើនទៅបង្កឲ្យទៅជាការឈឺចាប់ឬខ្មាសអៀន ហើយការឈឺចាប់ឬការខ្មាសអៀននេះនាំដល់កំហឹង ការអន់ចិត្ត និងដំណាក់កាលចុងក្រោយនិងខ្លាំងក្លាគឺការចង់សងសឹក ។ អ្នកដែលមានកំហឹងខ្លាំងជួនកាលរហូតដល់ចង់ស៊ីសាច់ហុតឈាមសត្រូវរបស់ខ្លួនទៀតផង ។ ប៉ុន្តែទោះជាមានបំណងចង់សងសឹកមានខ្លាំងយ៉ាងនេះក្តី ក៏មនុស្សទូទៅដឹងថាការសងសឹកវិញភ្លាមៗមិនសមរម្យទេ ។ ដូច្នេះកំហឹងមានធាតុផ្សំមួយដែលលាក់មិនឲ្យនរណាដឹងនិងមានរយៈពេលយូរអង្វែងទៀតផង ។ អាចារ្យម្នាក់បានធ្វើការពន្យល់ថា«គំនុំគឺជាបណ្តុំនៃកំហឹង

ដែលមិនទាន់ផុះចេញមក ។ វានៅខាងក្នុងខ្លួនក្តៅធំ ប៉ុន្តែមិនចេញទៅណាទេ ។ វានៅតែចាំរហូតដល់ដំណាក់កាលមួយថា ថ្ងៃណាមួយអញនឹងរើតែម្តង» ។ ជនជាតិខ្មែរជាច្រើននិយាយថា ទោះជារបបកម្ពុជាប្រជាធិបតេយ្យកន្លងផុតទៅ២០ឆ្នាំហើយក៏ដោយ ក៏ខ្លួននៅតែមានកំហឹងនឹងពួកខ្មែរក្រហម ហើយថា «ថ្ងៃចងកំហឹង» គឺជាបំណងរបស់រដ្ឋាភិបាលសាធារណរដ្ឋកម្ពុជា ឬរដ្ឋកម្ពុជាពិតៗក្នុងការធ្វើឲ្យប្រជាជនរក្សានូវ«កំហឹង...ក្តៅគគុក» និងត្រៀមខ្លួនជាស្រេចក្នុងការ«សងសឹកវិញ» ។

ដើម្បីរក្សាបាននូវធាតុនាំឲ្យភ្ញាក់ផ្អើល និងដើម្បីការពារកុំឲ្យគូបដិបក្ខម្ខាងទៀតដែលកំពុងតែមានអំណាចដឹងខ្លួននិងចង់ចាត់ការមកលើខ្លួនបានមុន ប្រជាជនកម្ពុជាដែលមានគំនុំព្យាបាទ និងខំលាក់ទុកគំនុំក្នុងចិត្តមិនឲ្យសត្រូវរបស់ខ្លួនដឹងឡើយ ។ ដូចជាកំហឹងដែរ ជាទូទៅគំនុំត្រូវបានលាក់ទុកមិនឲ្យអ្នកដទៃដឹង ។ នៅពេលប្រាស្រ័យទាក់ទងជាមួយគ្នា បុគ្គលដែលមានកំហឹងឬគំនុំក្នុងចិត្តតែងតែញញឹមនិងទាក់ទងធម្មតាជាមួយសត្រូវរបស់ខ្លួន ។ នៅពេលមានឱកាសហុចឲ្យ បុគ្គលនោះនឹងចាត់ការភ្លាម ។ អ្នកដែលមិនអាចសងសឹកដោយដៃខ្លួនឯងផ្ទាល់អាចធ្វើការសម្រេចចិត្តជួលឃាតករឬកូនចៅរបស់ខ្លួនឲ្យទៅសងសឹកទៅលើអ្នកដែលខ្លួនគុំនោះ ។ អ្នកកាសែតកម្ពុជាមួយចំនួនត្រូវបានលួចធ្វើឃាតប៉ុន្មានសប្តាហ៍ឬប៉ុន្មានខែក្រោយពីខ្លួនបានសរសេរអត្ថបទទាក់ទងដល់មន្ត្រីរដ្ឋាភិបាលនិងអ្នកជំនួញ ។ ឧទាហរណ៍ដ៏គួរឲ្យរន្ធត់មួយទៀត គឺស្ត្រីខ្មែរត្រូវវាយប្រហារដោយទឹកអាស៊ីដ ។ ការវាយប្រហារនេះត្រូវបានគេចោទប្រកាន់ទៅលើភរិយារបស់បុគ្គលមានអំណាចខ្មែរដែលសង្ស័យថាមានសហាយស្មន់ជាមួយស្រីវ័យក្មេងរូបស្រស់ ។

មានករណីផ្សេងទៀត ជួនកាលមានការជួលធ្មប់ឲ្យធ្វើមន្តអាគមអូមអាមទៅលើគូសត្រូវរបស់ខ្លួន ។ ក្រោយពេល ម៉ែអេវ៉ាន ចាកចេញពីកម្ពុជា មានសេចក្តីរាយការណ៍ថាប្រជាជនកម្ពុជាបានយាយីនិងវាយប្រហារមកលើគ្រិស្តសាសនិករបស់អេវ៉ាន តាមរយៈអំពើអាបធ្មប់នេះ ។ ប្រជាជនកម្ពុជាជាច្រើនមានការភ័យខ្លាចនឹងអំពើអាបធ្មប់ណាស់ ដែលអំពើនេះប្រជាជនជឿថាអាចបណ្តាលឲ្យមានជំងឺ មើលមិនជាទាល់តែស្លាប់ ។ ដើម្បីការពារគ្រោះចង្រៃនេះ ប្រជាជនកម្ពុជាពាក់គ្រឿងដែលមានបញ្ចូលមន្តអាគម ដូចជា ចែកាច់ជ្រូកព្រៃ ភ្លុកដំរី បញ្ចុះមាសសន្ទឹក ពាក់ខ្សែកាថា ប្រើយ័ន្តកាថាព្រះពុទ្ធរូប ឬផ្សំរបស់ស័ក្តិសិទ្ធិទាំងអស់នេះបូលគ្នាតែម្តង ។

ហេតុអ្វីបានជាគំនុំខ្មែរជួនកាលនាំដល់ការសងសឹកដែល «ធ្វើឲ្យគ្រោះថ្នាក់លើសពីកម្រិតនៃការរងរបួសមុនដំបូងទៅទៀត?» ។ នៅវគ្គខាងដើម ខ្ញុំបានគូសបញ្ជាក់ថា ឧបការី(អ្នកមានគុណ) ទទួលបាននូវការគោរពលើកឋានៈរបស់ខ្លួននិងបង្កើតបំណុលផ្នែកសីលធម៌តាមរយៈអំពើល្អរបស់បុគ្គលនោះ ។ តែផ្ទុយមកវិញ ជនដៃដល់ដែលបានប្រព្រឹត្តអំពើអាក្រក់បង្ហាញពីការមិនគោរព បន្ទាបមុខមាត់និង«យកឈ្នះ»អ្នកដែលទទួលរងអំពើរបស់ខ្លួន ។ ក្រោយមក អ្នកដែលទទួលអំពើអាក្រក់នោះក៏សងទៅតាមកម្រិតនៃអំពើអាក្រក់របស់ជនដៃដល់វិញ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ការសងបំណុលទៅតាមអំពើដែលបានប្រព្រឹត្តមុនដំបូង នឹងធ្វើឲ្យភាគីទាំងសងខាងមានភាពស្មើគ្នា ។ ជារឿយៗ ដោយសារតែមនុស្សតែងតែចង់«ខ្ពស់ជាង»អ្នកដទៃ បុគ្គលទាំងនេះតស៊ូយកឈ្នះនិងធ្វើឲ្យខ្លួនខ្ពស់ជាងគូបដិ-បក្ខរបស់ខ្លួនដោយធ្វើអ្វីដែលអាក្រក់ជាងមុន ។

ហាំង ង៉ៅ ពន្យល់ថា «ប្រសិនបើខ្ញុំវាយអ្នកឯងមួយដៃ អ្នកឯងរង់ចាំប្រាំឆ្នាំទើបវាយខ្ញុំសងវិញពីក្រោយខ្នងក្នុងទីងងឹតសូន្យឈឹង ។ របៀបនេះហៅថាគុំ...» ។ អំពើនេះយ៉ាងហោចណាស់អាច«ស្តារកិត្តិយស»និងបំផ្លាញកេរ្តិ៍ឈ្មោះរបស់សត្រូវ ។ ប្រធានសមាគមសង្គមព្រះពុទ្ធសាសនាខ្មែរបានរៀបរាប់ថា ប្រជាជនខ្មែរដែលចងគំនុំ«ចង់សងសឹកឲ្យលើសពីអ្វីដែលខ្លួនបានទទួលរងនោះ ពីព្រោះគាត់ចង់យកឈ្នះនិងមិនចង់អាម៉ាស់មុខនៅចំពោះភ្នែកអ្នកដទៃ ។ នៅពេលគាត់ឈ្នះ គាត់មានកិត្តិយស ហើយអ្នកផងទាំងពួងនឹងមើលមកហើយមិនគិតថាគាត់អន់ទេ» ។

ឧទាហរណ៍ មានយប់មួយប៉ូលិសខេត្តម្នាក់ឈ្មោះ ហុង បានផឹកស្រាស្រវឹង ហើយក៏ចាប់ផ្តើមឈ្លោះប្រកែកគ្នាជាមួយអ្នកផ្សេង ។ នៅពេលជម្លោះកាន់តែក្តៅទៅៗ ហុង ក៏ចាប់ផ្តើមបាញ់កាំភ្លើងអាកា៤៧ឡើងលើ ហើយស្រែកឡូឡាខ្លាំងៗ ។ មានប៉ូលិសម្នាក់ទៀតឈ្មោះ ម៉ូលី ក៏បានចូលទៅសុំទោសជំនួស ។

ពេលនោះ ហុង បានភ្ជង់កាំភ្លើងដាក់ ម៉ូលី ហើយស្រែកគំរាមថា«បើឯងហ៊ានចូលបន្តិចទៀតអញនឹងបាញ់ឯងចោល»។ ម៉ូលី ខឹងខ្លាំងណាស់ នៅពេលទៅដល់ស្ថានីយ៍ប៉ូលិសវិញ ម៉ូលី និយាយថា«អាហុងឯងកុំចង់ខ្លាំងជាមួយអញ។ អញក៏ខ្លាំងដែរ ហើយអញនឹងយកឈ្នះឯងឲ្យបាន»។ ម៉ូលី បានទៅហៅសាច់ញាតិរបស់ខ្លួនដែលជាមេរបស់ ហុង ហើយនិយាយរៀបរាប់ដំណើរដើមទងចប់សព្វគ្រប់។ ប្រមាណជា២០នាទីក្រោយមក មេប៉ូលិសនិងកូនចៅជាច្រើននាក់បានមកដល់កន្លែងកើតហេតុ មកចាប់ ហុង ដាក់គុក។ តាមរយៈឧទាហរណ៍មួយនេះ យើងឃើញថា ហុង បាន«ធ្វើអំពើអាក្រក់»ទៅលើ ម៉ូលី ដែលធ្វើឲ្យ ម៉ូលី ខ្មាសគេនិងមានអារម្មណ៍ថា«នៅក្រោមគេ»។ ការអៀនខ្មាសនិងកំហឹងរបស់ ម៉ូលី ក៏ក្លាយទៅជាគំនុំក្លាម។ ម៉ូលី បានសងសឹកវិញលើសពីអ្វីដែល ហុង បានធ្វើមកលើខ្លួនទៅទៀត ពោលគឺរហូតទៅដល់ជាប់គុកឯណោះ។ ធ្វើយ៉ាងនេះ ម៉ូលី បានស្តារកិត្តិយសរបស់ខ្លួន«យកឈ្នះ»លើ ហុង ហើយបង្ហាញថាខ្លួនពិតជាមនុស្សគ្រាន់បើមែន។

តើគំនុំអាចទាយទុកមុនបានទេ? ប្រសិនបើគំនុំតែងតែនាំដល់អំពើឃោរឃៅ នោះលទ្ធផលនៃគំនុំមិនអាចទាយទុកមុនបានទេ។ មានជម្រើសច្រើនណាស់ក្នុងការទប់ទល់នឹងកំហឹងរបស់បុគ្គលម្នាក់។ ផ្លូវដែលល្អបំផុត បើតាមព្រះពុទ្ធសាសនា គឺត្រូវគ្រប់គ្រងនិងពន្លត់កំហឹងដែលចេញមកដោយអវិជ្ជានិងកាមកិលេស។ អវិជ្ជានិងកាមកិលេសនាំដល់មានទុក្ខ។ ទាំងនៅផ្ទះនិងនៅវត្តអារាម កុមារកុមារីរៀនសូត្រគោលការណ៍ព្រះពុទ្ធសាសនា អំពើអហិង្សា និងវិធីរំលត់កំហឹង។ មេរៀនទាំងនេះត្រូវបានបញ្ចូលនៅក្នុងរឿងព្រេងមានដូចជារឿងគតិលោកនិងរឿងទុំទាវដែលសុទ្ធតែបង្ហាញពីសំណាងអាក្រក់ដែលអ្នកឆាប់ខឹងទទួលរង។ នៅក្នុងព្រះពុទ្ធសាសនា ការទប់កំហឹងដោយគិតគូរត្រឹមត្រូវគឺការស្គាល់នូវប្រភពរបស់កំហឹងនិងធ្វើឲ្យកំហឹងរំសាយទៅ ពីព្រោះកំហឹងដូចរឿងផ្សេងៗទៀតនៅលើពិភពលោកយើងនេះគ្មានអ្វីទៀងទាត់ឡើយ។ ខ្លឹមសារដែលប្រជាជនកម្ពុជាប្រើសម្រាប់ទប់កំហឹងគឺស្តែងចេញតាមរយៈពាក្យពេចន៍ច្បាស់លាស់ដែលមានដូចជា«ទប់ចិត្ត រំងាប់ចិត្ត រំសាយកំហឹង ឬរំសាយចិត្ត ពត់ចិត្ត រំលាយកំហឹង សង្កត់ចិត្ត ណាយចិត្ត រំលត់កំហឹង តម្កល់ចិត្ត និងរំសាយកំហឹង»។ ដូចគ្នានេះដែរ មនុស្សដែលមិនងាយខឹងផ្តាស ខ្មែរហៅថាមនុស្សចិត្តធ្ងន់។

ក៏ប៉ុន្តែមនុស្សភាគច្រើនមិនមានគតិបណ្ឌិតនិងសមត្ថភាពក្នុងការរំលាយកំហឹងរបស់ខ្លួនឡើយ ជាពិសេសនៅពេលទទួលរងនូវការឈឺចាប់ខ្លាំង។ នៅពេលមានកំហឹង មនុស្សតែងតែមានផ្លូវដោះស្រាយដោយមិនទុកក្នុងចិត្តឡើយ។ ឧទាហរណ៍ ជួនកាលទម្លាប់ឆេវឆាវដោយមិនដឹងខ្លួន ឃើញក្លាមថាក្លាម។ បុគ្គលដែលមិនអាចបញ្ចេញអារម្មណ៍ខឹងក្រេវក្រោធក្លាមៗអាចបញ្ចេញជាអាការៈដោយប្រយោលដូចជាឈឺក្បាល មិនសូវឃ្លានអាហារ ធុញថប់ក្នុងចិត្ត ដេកមិនលក់ ពិបាកដកដង្ហើម ឈឺខ្នង ឈឺ(ក) ឬឈឺក្រពះ។ នៅពេលមានអាការៈទាំងអស់នេះ ប្រជាជនកម្ពុជាតែងតែនិយាយថា «ឈឺ» ហើយក៏រកវិធីព្យាបាលផ្សេងៗដូចជាកោសខ្យល់ ចាប់ខ្យល់ និងជប់ខ្យល់។ បុរសម្នាក់បាននិយាយប្រាប់ខ្ញុំថា ក្រោយពេលគាត់ខឹង ជាពិសេសនៅពេលចៅហ្វាយឬប្រពន្ធស្តីបន្ទោស គាត់តែងតែមានអាការៈឈឺក្បាលនិងមានអាការៈផ្សេងៗទៀតដែលត្រូវតែកោសខ្យល់ទើបបានស្វាង។ «ជារឿយៗ នៅមុនពេលកោសខ្យល់ខ្ញុំខឹងមែនទែន ហើយពិបាកដកដង្ហើមទៀតផង ប៉ុន្តែនៅពេលខ្ញុំកោសខ្យល់រួចហើយ ខ្ញុំដកដង្ហើមស្រួលដូចធម្មតា។ ខ្លួនខ្ញុំក្តៅគគុក ហើយបែកញើសនៅកន្លែងស្នាមកោសខ្យល់...ហើយចិត្តខ្ញុំក៏ស្រួលវិញមិនសូវខឹង»។

ក្រៅពីមានអាការៈទាំងនេះ ជួនកាលបុគ្គលក៏ខឹងឡើងវិញ។ នៅពេលខឹង ជួនកាលបុគ្គលម្នាក់អាចវាយនេះ វាយនោះ ឬជេរប្រទេចដោយសម្តីអសុរសមកលើខ្លួនឯង។ មានយាយម្នាក់មានវ័យចាស់ដែរហើយៗ មានកូនស្រីម្នាក់ដែលមិនគោរពគាត់។ គាត់ក៏ចាប់ផ្តើមគក់ទ្រូងហើយស្រែកខ្លាំងៗថា «អញមានកម្មអីក៏អាក្រក់ម្ល៉េះ អញនិយាយទៅវាផងមិនស្តាប់អញទាល់តែសោះ។ អញមិនដែលខ្មាសគេដូចពេលនេះទេ។ ចិត្តវាផងអីក៏អាក្រក់ម្ល៉េះៗ» ផ្លូវមួយទៀតនៅពេលដែលកំហឹងខ្លាំងហួសកម្រិតគឺការធ្វើអត្តឃាត។ អត្តឃាតជួនកាលកើតឡើងនៅពេលបុគ្គលមានកំហឹងនិងភាពអាម៉ាស់ហួសនិស្ស័យដូចជាការ

ប្រលងសញ្ញាប័ត្រធ្លាក់ជាដើម ។

ប៉ុន្តែវិធីមួយទៀតក្នុងការដោះស្រាយជាមួយកំហឹងគឺធ្វើការបង្វែរអារម្មណ៍ប្រឆាំងនឹងសង្គម ដោយខ្លួនរកទៅរកអ្វីដែលគេទទួលស្គាល់ជាទូទៅ ។ តាមលោកទស្សនៈ បុគ្គលប្រភេទនេះតែងតែមានអារម្មណ៍បែបនេះឯង ដែលជាអារម្មណ៍មួយមិនអាចសម្តែងចេញឲ្យឃើញដោយសារការប្រាស្រ័យទាក់ទងគ្នារាល់ថ្ងៃវាមានលក្ខណៈអរូប ។ ការមានអារម្មណ៍បែបនេះជាមុខសញ្ញាបញ្ចេញនូវភាពប្រទូសរ៉ាយ ប៉ុន្តែមិនសូវជាញឹកញាប់ទេ ។ អ្នកដែលមានអារម្មណ៍បែបនេះមិនត្រូវបានចាត់ទុកថាជាអ្នកទទួលខុសត្រូវចំពោះកាយវិការប្រឆាំងនឹងសង្គមរបស់ខ្លួនឡើយ ។ ប្រជាជនកម្ពុជាដែលសម្តែងនូវកាយវិការប្រឡោងខាមនិងមិនធម្មតាបែបនេះយូរៗទៅហៅថាមនុស្សឆ្កួត និងត្រូវដាក់ឲ្យរស់នៅក្រៅសង្គម ។

ការបញ្ចេញអារម្មណ៍មួយទៀតដែលមានលក្ខណៈទូទៅគឺការវាយសត្វធាតុ ។ ឧទាហរណ៍ ប្រជាជនជាច្រើនចាត់ទុកឆ្កែថាជាសត្វដែលមានឋានៈថោកទាបជាងគេបំផុត ហើយវាយឆ្កែនៅពេលវាធ្វើឲ្យខ្លួនខឹង ។ ប៉ុន្តែគួរឲ្យសោកស្តាយ កាយវិការប្រទូសរ៉ាយបែបនេះជួនកាលក៏ជាចរិតរបស់មនុស្សទូទៅដែរ ។ ជួនកាលឪពុកម្តាយវាយកូននៅពេលដែលខ្លួនមិនសូវសប្បាយចិត្តពីរឿងអ្វីមួយ ។ មិត្តភក្តិរបស់ខ្ញុំម្នាក់បានឃើញម្តាយដែលកំពុងតែខឹងវាយកូនរបស់គាត់ ហើយកូនស្រីនោះក៏បន្តទាត់មាន់ដែលដើរកាត់មុខ ។ ប្រជាជនកម្ពុជាជាច្រើនចូលចិត្តល្បែងជល់មាន់ដែលហាក់ដូចជាកន្លែងបញ្ចេញភាពប្រទូសរ៉ាយ ។ មានពេលខ្លះម្ចាស់មាន់ថ្នាក់ថ្នមនិងធ្វើសរសៃឬលុញសាច់ដុំមាន់ជល់របស់ដងខ្លួន ហើយរហូតដល់បឺតក្បាលមាន់ដើម្បីឲ្យទឹកឆ្អាលនឹងមានកម្លាំងចូលប្រកួតជាមួយគូបដិបក្ខសាជាថ្មីទៀត ។

ក្រៅពីយុទ្ធសាស្ត្រដោះស្រាយកំហឹងសំខាន់ៗដែលរៀបរាប់ខាងលើនេះ នៅមានរបៀបបន្ទាប់បន្សំមួយចំនួនទៀត ។ ជួនកាលបុគ្គលម្នាក់ចង់សម្តែងចេញនូវកំហឹងទៅមនុស្សម្នាក់ទៀតដោយប្រយោលនិងមិនសូវខ្លាំងក្លា ។ ទី១ ប្រជាជនកម្ពុជាអាចបញ្ចេញកំហឹងដោយធ្វើជាមិនមាត់មិន(ក) ដែលជាទូទៅមានដូចជា មិនញញឹម សម្លឹងសម្លក់ ចងចញ្ចើម ដើរចេញ និងជ្រួលប្រាលរកនិយាយបន្តិច មិននិយាយបន្តិច ។ ទី២ ប្រជាជនកម្ពុជាបញ្ចេញកំហឹងដោយនិយាយប្រយោល ។ ដូចដែលនរវិទូ ម៉េយ៍ អេបីហារា បានកត់សម្គាល់ថា នៅពេលមានជម្លោះ អ្នកស្រុកភូមិតែងស្រែកជេរទាលខ្លាំងៗតែម្នាក់ឯង មិនសំដៅទៅអ្នកណាម្នាក់ឡើយ ប៉ុន្តែការបញ្ចេញសំឡេងក្តែងៗបែបនេះធ្វើឲ្យឮខ្ទរមួយភូមិតែម្តង(រួមទាំងគូបដិបក្ខរបស់ខ្លួនដែរ) ។ បុគ្គលបែបនេះបញ្ចេញកំហឹងរបស់ខ្លួនដោយនិយាយរិះគន់ដោយប្រយោល ដែលភាសាខ្មែរហៅថានិយាយបញ្ឆិតបញ្ឆៀង ។

មានពេលខ្លះទៀត ប្រជាជនកម្ពុជាបញ្ចេញកំហឹងដោយនិយាយឡើងតឹងសសៃក ។ បុគ្គលដែលប្រើពាក្យគួរសមជ្រុលពេក អាចធ្វើឲ្យបុគ្គលម្នាក់ទៀតកាន់តែមិនសូវស្និទ្ធស្នាល ហើយការនិយាយបែបនេះជាសញ្ញាបង្ហាញថា បុគ្គលទីមួយមិនសូវពេញចិត្តនឹងបុគ្គលម្នាក់ទៀត ។ ផ្លូវមួយទៀតក្នុងការបញ្ចេញភាពប្រទូសរ៉ាយតាមរយៈសម្តីប្រយោលគឺការឌឺដងផ្លែផ្កា ប៉ុន្តែនៅប្រទេសកម្ពុជា វិធីទូទៅបំផុតក្នុងការបញ្ចេញកំហឹងគឺប្រហែលជានិយាយដើមគ្នា ។ ចំណុចចុងក្រោយមួយទៀតគឺថាប្រជាជនកម្ពុជាតែងតែបញ្ចេញកំហឹងតាមរយៈទន់ភ្លន់ ពោលគឺការគេចមុខឲ្យផុត ដូចជាមិនមើលមុខ មិននិយាយរក ឬដើរចេញពីអ្នកដែលខ្លួនខឹងរហូតដល់ឈប់ខឹង ។ នៅពេលខ្លាំងមែនទែន បុគ្គលពីរនាក់នេះអាចឈប់ទាក់ទងនិងឈប់និយាយរកគ្នារហូតអស់មួយជីវិតតែម្តង ។

បងប្រុសម្នាក់ឈ្មោះ វ៉ែល បានឲ្យឧទាហរណ៍មួយទៀតទាក់ទងនឹងការគេចមុខពីគ្នានេះ ។ បុរសម្នាក់ក្នុងចំណោមអ្នកជួលបន្ទប់នៅជាមួយគ្នា៣នាក់ ឈ្មោះ ឡាត់ បានខឹងយ៉ាងខ្លាំងក្រោយពេលគ្នីគ្នា២នាក់ទៀតបានយកចង្កៀងប្រេងកាតក្នុងខណៈដែលគាត់កំពុងតែអានសៀវភៅមកបង្កាត់ភ្លើងដាំបាយពេលល្ងាច ។ ឡាត់ មិននិយាយអ្វីសូម្បីតែមួយមាត់ ហើយក៏ចេញពីបន្ទប់បាត់ទៅ ។ ក្រោយមក វ៉ែល មកនិយាយសម្រុះសម្រួលជាមួយ ឡាត់ ។ ឡាត់ ក៏ខឹង វ៉ែល ដោយនិយាយសើកសៀតដាក់ វ៉ែល ។ វ៉ែល រៀបរាប់ថា "ខ្ញុំមិនចង់ឈ្លោះជាមួយ ឡាត់ ទេ ខ្ញុំបានព្យាយាមទប់ចិត្ត ហើយមិនខឹងវិញទេ ។ ក្នុងអំឡុងពីរ-បីថ្ងៃនោះ ខ្ញុំបានព្យាយាមនិយាយរក ឡាត់ ប៉ុន្តែ

ឡាត់ មិនសូវនិយាយតបតវិញទេ និយាយតែមួយមាត់ៗ ប៉ុណ្ណោះ ។ ហើយក្រោយមកអត់និយាយសោះតែម្តង ។ មានថ្ងៃមួយពេលខ្ញុំត្រឡប់មកវិញស្រាប់តែមិនឃើញ ឡាត់ ហើយបង្អួចរបស់គាត់ក៏មិនឃើញ» ។ វ៉ែល បានព្យាយាមទប់កំហឹងបានយ៉ាងជោគជ័យ ចំណែកឯ ឡាត់ វិញជ្រើសរើសផ្លូវបញ្ចេញកំហឹងដោយសភាពស្ងប់ស្ងាត់តាមរយៈពាក្យបញ្ចិតបញ្ចៀង ការគេចមុខចេញ និងស្ងៀមស្ងាត់ ។

**ការគុំកួន ការផ្សះផ្សា និង ខ្មែរក្រហមៈ** នៅក្នុងសង្គមកម្ពុជាក៏ដូចជាសង្គមផ្សេងៗទៀតនៅក្នុងពិភពលោកដែរ មនុស្សតែងតែងមានការយល់ដឹងខុសប្លែកពីគ្នាទៅលើជម្រើសក្នុងការដោះស្រាយកំហឹងរបស់ផងខ្លួន ។ បុគ្គលម្នាក់ៗខិតទៅរកជម្រើសទាំងនេះ ទោះទាំងដឹងខ្លួនឬមិនដឹងខ្លួនក្តី នៅពេលសម្រេចចិត្តទប់ទល់ជាមួយកំហឹងរបស់ខ្លួន ។

ការប្រាប់មនុស្សម្នាក់ដែលទើបរកឃើញឃាតករសម្លាប់ក្រុមគ្រួសារនិងមិត្តភក្តិរបស់ខ្លួនថាឲ្យខំរំងាប់កំហឹង នោះមិនមែនជាការងាយទេ ។ ដូចគ្នានេះដែរ ប្រជាជនកម្ពុជាជាច្រើនចងគំនុំក្នុងចិត្តជាមួយ ប៉ុល ពត, អៀង សារី, ខៀវ សំផន, សុន សេន ព្រមទាំងថ្នាក់ដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យដទៃៗទៀត ។ តើយើងអាចប្រាប់គាត់ឲ្យ "អភ័យទោសឬបំភ្លេច" បានទេ? ។ ព្រះពុទ្ធសាសនាបានប្រៀនប្រដៅថាៈ បុគ្គលគ្រប់រូបត្រូវតែស្វែងរកផ្លូវទៅកាន់ព្រះនិព្វាន ។ ដូច្នេះប្រជាជនកម្ពុជាម្នាក់ៗត្រូវសម្រេចចិត្តដោយខ្លួនឯង ថាតើត្រូវធ្វើអ្វីខ្លះ ប្រសិនបើ"ចំណង"នៃគំនុំនៅតែចងជាប់ជាមួយនឹងមេដឹកនាំខាងលើនេះ ។ ទោះបីជាប្រជាជនកម្ពុជាសម្រេចយ៉ាងដូចម្តេចក៏ដោយ តុលាការជំនុំជម្រះក្តីនិងការកាត់ទោសជនដែលប្រល័យពូជសាសន៍ នឹងមានដំណើរព្រមជាមួយគ្នាឆ្ពោះទៅរកការរំលត់កំហឹងរបស់ប្រជាជនកម្ពុជា ។

ក៏ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ការផ្សះផ្សាពាក់ព័ន្ធរឿងច្រើនជាងការជម្រះក្តី ។ វាតម្រូវឲ្យផ្លាស់ប្តូរឥរិយាបទតែម្តង ។ ដើម្បីផ្លាស់ប្តូរឥរិយាបទតម្រូវឲ្យមានការគិតគូរឲ្យបានជិតដល់មែនទែន ។ ដើម្បីគិតឲ្យបានជិតដល់ត្រូវពង្រីកការយល់ដឹងដោយផ្ទាល់និងដោយប្រយោលទៅលើគំនិតនានាដែលមានលក្ខណៈបង្ហាញផ្លូវដល់យើង ។ អត្ថបទនិពន្ធនេះបានព្យាយាមជួយឲ្យយល់ដឹងនូវដំណើរការនេះតាមរយៈការស្វែងយល់អំពីបញ្ហាគន្លឹះជាលក្ខណៈវប្បធម៌នៃកំហឹង គំនុំ និងការសងសឹកដែលអាចនាំទៅដល់ទាំងអំពើឃោរឃៅ ទាំងដំហរផ្សះផ្សា ។ ដូចព្រះមហាឃោសានន្ទទ្រង់មានពុទ្ធដីកាយ៉ាងដូច្នេះថា មាគ៌ាទៅកាន់ការផ្សះផ្សាសម្របសម្រួលជាមួយខ្មែរក្រហមគឺជារឿងដ៏លំបាកមួយ ប៉ុន្តែប្រសិនបើធ្វើទៅតាមគំនិតពិចារណាត្រឹមត្រូវហ្មត់ចត់ អាចនឹងនាំទៅរកចំណាត់ការដ៏សមរម្យមួយ ។ ខ្ញុំសូមទុកឲ្យមិត្តអ្នកអានពិនិត្យត្រិះរិះនូវសេចក្តីណែនាំរបស់ព្រះអង្គផ្ទាល់÷

អាត្មាយល់ស្របថា ការស្រឡាញ់អ្នកដែលសង្កត់សង្កិនខ្លួន(ប្រជាជនកម្ពុជាស្រឡាញ់ខ្មែរក្រហម) គឺជារឿងមួយពិបាកធ្វើបំផុត ។ ប៉ុន្តែនេះជាច្បាប់មនុស្សលោក ដែលការចងពៀរ អាឃាត សងសឹក កើតឡើងមិនចេះចប់មិនចេះហើយ ។ ការផ្សះផ្សាមិនមានន័យថា យើងបោះបង់ចោលនូវសិទ្ធិនិងកាយលក្ខណៈនោះទេ តែផ្ទុយមកវិញយើងប្រើការស្រឡាញ់នៅគ្រប់ការចរចាទាំងអស់ ។ មានន័យថាយើងមើលខ្លួនយើងនៅក្នុងចិត្តសត្រូវ ។ យើងត្រូវមើលចិត្តសត្រូវថាអ្នកនោះគិតចំពោះខ្លួនយើងយ៉ាងម៉េច ហេតុអ្វីបានជាយល់ថាយើងជាសត្រូវជាមួយគេ ។ ដូច្នេះមានតែស្រឡាញ់ការអនុគ្រោះ អត់ឱន និងគិតពិចារណាត្រឹមត្រូវ ទើបអាចរំដោះយើងឲ្យផុតពីអវិជ្ជាបាន ។

**អាឡិច ហ៊ីនតុន**

## ពាក្យស្លោកខ្មែរក្រហម

- **ការងារនយោបាយសតិអារម្មណ៍ ជាកត្តាកំណត់មូលដ្ឋាន ការងារចាត់តាំងជាកត្តាគន្លឹះសម្រេច ត្រូវប្រយុទ្ធគស៊ូខណ្ឌៈ ទាំងនយោបាយ ទាំងសតិអារម្មណ៍ ទាំងខាងចាត់តាំងជាប់ជានិច្ចក្នុងសហករណ៍ រោងចក្រ ការដ្ឋាន ក្រសួងមន្ទីរទាំងអស់។**
- **បំផុសចលនាមហាអនាម័យឲ្យទៅតាមសហករណ៍ រោងចក្រ ការដ្ឋាន ក្រសួងមន្ទីរ ទីក្រុងភ្នំពេញ និងទូទាំងប្រទេស។**

*(ដកស្រង់ចេញពីសៀវភៅ០៧៦ គណហ)*

# ឧក្រិដ្ឋកម្មសំខាន់ៗក្រោមច្បាប់កម្ពុជាមុនឆ្នាំ១៩៧៥

ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦បានបង្ហាញនូវឧក្រិដ្ឋកម្មសំខាន់ៗដែលទទួលស្គាល់ដោយប្រទេសនានាស្ទើតែទាំងអស់ ។ យោងទៅលើការអនុវត្តរបស់បារាំង ក្រមព្រហ្មទណ្ឌនេះចែកបទល្មើសតាមកម្រិតធ្ងន់ធ្ងរជាឧក្រិដ្ឋកម្ម បទឧក្រិដ្ឋ បទល្មើសមជ្ឈិម និងការរំលោភបំពានរបស់នគរបាល ។ បទឧក្រិដ្ឋនិងបទល្មើសមជ្ឈិមត្រូវបានចែកជាកម្រិតទី១ ទី២ ឬទី៣ តាមលំដាប់នៃភាពធ្ងន់ធ្ងរ និងតាមលំដាប់ទណ្ឌកម្មរបស់វា ។

បទឧក្រិដ្ឋអាចទទួលដាក់ទណ្ឌកម្មដោយទណ្ឌកម្មបទឧក្រិដ្ឋទាំងឡាយណាដែលជាប់បទឧក្រិដ្ឋកម្រិតទី៣ត្រូវទទួលទោសប្រហារជីវិត ។ បទល្មើសមជ្ឈិមកម្រិតទី២ត្រូវទទួលទោសជាប់ពន្ធនាគារអស់មួយជីវិត ហើយបង្ខំឲ្យធ្វើពលកម្មផង ។ បទឧក្រិដ្ឋកម្រិតទី១ត្រូវទទួលទោសដោយបង្ខំឲ្យធ្វើពលកម្មសម្រាប់រយៈពេលកំណត់ណាមួយ ។ នៅក្នុងជំពូកទី XII នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានលុបចោលនូវទោសប្រហារជីវិត ។ បទល្មើសមជ្ឈិមត្រូវទទួលទោសដោយ «ទណ្ឌកម្មយុត្តាធិការ» ពោលគឺជាប់ពន្ធនាគារ ដាក់ពិន័យ ឬក៏ទាំងជាប់ពន្ធនាគារនិងដាក់ពិន័យ ហើយចំពោះករណីនីមួយៗគឺឈរលើកម្រិតនៃបទល្មើសមជ្ឈិម ។ ការប្រព្រឹត្តបទល្មើសរបស់នគរបាលត្រូវទទួលទោស«ទណ្ឌកម្មរបស់នគរបាល»តែប៉ុណ្ណោះ ពោលគឺការឃុំខ្លួននគរបាល ការដាក់ពិន័យនគរបាល ឬក៏ទាំងការឃុំខ្លួននិងដាក់ពិន័យនគរបាល ។ ក្រមព្រហ្មទណ្ឌនេះក៏បានអនុញ្ញាតឲ្យមានស្ថានការណ៍មួយចំនួនដែលតុលាការអាចបន្ថយឬបង្កើននូវទោសបញ្ញត្តិអាស្រ័យទៅលើកាលៈទេសៈធូរស្រាលឬក៏ធ្ងន់ធ្ងរ ។ កាលៈទេសៈធ្ងន់ធ្ងររួមមានករណីទាំងឡាយណាដែលចេញមកពីវិធីនៃឧក្រិដ្ឋកម្មស្ថានភាពជនរងគ្រោះ ហើយនិងប្រវត្តិឧក្រិដ្ឋកម្មរបស់ជនល្មើស ។ ឧក្រិដ្ឋកម្មសំខាន់ៗនិងការដាក់ទណ្ឌកម្មស្របទៅតាមទោសឧក្រិដ្ឋកម្មនេះអាចត្រូវបានសង្ខេបដូចតទៅនេះ:

**មនុស្សឃាត (មាត្រា៥០១-៥០៨):** មនុស្សឃាតដោយចេតនាប្រព្រឹត្តឡើងក្នុងគោលបំណងបង្កដល់ការបាត់បង់ជីវិត ពោលគឺឃាតកម្ម ។ មនុស្សឃាតដោយចេតនារួមមានមនុស្សឃាតដោយមកពីការធ្វេសប្រហែស មិនប្រយ័ត្នប្រយែង និងប្រភេទដទៃទៀត ។ ការសម្លាប់ដោយមានរៀបចំគម្រោងជាមុនត្រូវបានចាត់ទុកថាជាអំពើឃាតកម្ម ។ មាត្រា៥០៥ បានចែងថា «បំណងបង្កឲ្យមានការបាត់បង់ជីវិតអាចបញ្ជាក់បានតាមរយៈការប្រើអាវុធដែលអាចមានគ្រោះថ្នាក់ដល់ស្លាប់ ហើយក៏អាចតាមរយៈភាពធ្ងន់ធ្ងរ ឬអាស្រ័យដោយទីតាំងនៃការវាយសំពងទៅលើជនរងគ្រោះ» ។ ការសម្លាប់និងការលបធ្វើឃាតគឺជាឧក្រិដ្ឋកម្មកម្រិតទី២និងទី៣រៀងគ្នា ។ មនុស្សឃាតដោយអចេតនាត្រូវទទួលទោសតាមកម្រិតនៃសភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តបទល្មើស ។


រូបថតអ្នកទោសបានស្លាប់នៅមន្ទីរស-២១

**ការធ្វើទារុណកម្ម (មាត្រា៥០០):** ការធ្វើទារុណកម្មគឺជាបទឧក្រិដ្ឋកម្រិតទី៣ ។ និយមន័យនេះតំណាងឲ្យនិយមន័យទារុណកម្មដែលត្រូវបានយល់ព្រមទទួលយកជាអន្តរជាតិគ្រង់

ការធ្វើឲ្យមានភាពឈឺចុកចាប់ក្នុងគោលបំណងដើម្បីទាញយកព័ត៌មាន វាត្រូវបានកម្រិតថាព័ត៌មានប្រាកដជាមានសារសំខាន់ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋឬបទឧក្រិដ្ឋជាមជ្ឈិម ។

**ការចាប់រំលោភ (មាត្រា៨៨៣-៨៦):** មាត្រា៨៨៣ បានឲ្យនិយមន័យនៃការចាប់រំលោភថាជាការចាប់ផ្ដើមឬការប៉ុនប៉ងចាប់ផ្ដើមដាក់ប្រដាប់បន្តពូជរបស់បុគ្គលម្នាក់ទៅក្នុងប្រដាប់បន្តពូជរបស់បុគ្គលម្នាក់ទៀតដោយប្រើកម្លាំងឬដោយគំរាមកំហែងដោយគ្មានការយល់ព្រមពីភាគីម្ខាងទៀត ។ ចំពោះជនរងគ្រោះអាយុ១៣ឆ្នាំនិងអាយុលើសនេះ ការរំលោភគឺជាបទឧក្រិដ្ឋកម្រិតទី៣ ។ ចំពោះបុគ្គលដែលនៅក្រោមអាយុ១៣ឆ្នាំ ការរំលោភគឺជាបទឧក្រិដ្ឋកម្រិតទី១ ។ ច្បាប់នេះក៏បានទទួលស្គាល់នូវការចាប់រំលោភចំពោះជនទាំងពីរភេទណាដែលមានអាយុក្រោម១៣ឆ្នាំដែរ ។

**អំពីការរំលោភលើរូបកាយផ្សេងៗទៀត (មាត្រា៨៩៥-៩៩):** អំពើហិង្សាដោយចេតនាដែលបន្សល់ទុកនូវស្លាកស្នាមលើជនរងគ្រោះ ជាបទឧក្រិដ្ឋមជ្ឈិមកម្រិតទី២ នេះប្រសិនបើមិនប្រើអាវុធយុទ្ធភណ្ឌ ហើយជាបទឧក្រិដ្ឋកម្រិតទី៣ នេះប្រសិនបើប្រើអាវុធយុទ្ធភណ្ឌ ។ ក្នុងករណីដែលដែលប្រើអំពើហិង្សាបណ្ដាលឲ្យមានពិការភាពជាអចិន្ត្រៃយ៍ ការធ្វើឲ្យមានវិកលកម្ម ការបាត់បង់នូវអវៈយវៈឬវិញ្ញាណណាមួយខាងបញ្ហាផ្លូវចិត្ត ឬការរំលូតកូន វាគឺជាបទឧក្រិដ្ឋកម្រិតទី១ ។ កំណត់ថាមានបទល្មើសកើតឡើង ហើយបើភាគីម្ខាងមានអាវុធយុទ្ធភណ្ឌប្រើដើម្បីវាយប្រហារទៅលើជនរងគ្រោះ ហើយបទឧក្រិដ្ឋរបស់វាក៏កើតឡើងដែរ ទោះបីជាប្រព្រឹត្តដោយគ្មានបំណងមនុស្សឃាតដោយមធ្យោបាយណាផ្សេងក៏ដោយ ។

**ការឃុំឬឃាត់ខ្លួនតាមអំពើចិត្ត (មាត្រា៨៨២-៨៦):** ជនណាដែលឃាត់ខ្លួនឬឃុំខ្លួនជនដទៃទៀតលើកលែងតែមានការអនុញ្ញាតស្របច្បាប់ឬក្នុងករណីឧក្រិដ្ឋកម្ម ត្រូវទទួលទោសពីបទមជ្ឈិមកម្រិតទី២ ប្រសិនបើការឃុំខ្លួនមានរយៈពេល១០ថ្ងៃឬតិចជាង ។ បើមិនដូច្នោះទេ ត្រូវទទួលទោសបទមជ្ឈិមកម្រិតទី៣ ។ ការដាក់ទោសបញ្ញត្តិជាអតិបរមាត្រូវបានអនុវត្តប្រសិនបើជនរងគ្រោះទទួលរងនូវអំពើហិង្សា ធ្វើទុក្ខទោស បង្អត់អាហារ ឬថែរក្សាគាំពារមិនគ្រប់គ្រាន់ ។ ជាងនេះទៅទៀត ជនល្មើសអាចត្រូវបានដាក់ទណ្ឌកម្មចំពោះការរំលោភនូវសិទ្ធិ ស៊ីវិល ដូចជាសេរីភាពក្នុងការធ្វើដំណើរ ។ លើសពីនេះទៅទៀត មាត្រា២៨៩-៥១ ក៏បានចាត់ទុកការឃុំឃាំងខុសច្បាប់ដែលធ្វើឡើងដោយមន្ត្រីរាជការ ទោះជានគរបាល ឆ្មាំគុក ឬតុលាការក៏ដោយ ហើយអំពើនេះត្រូវចាត់ចូលជាបទមជ្ឈិមកម្រិតទី២ ។

**ការវាយប្រហារលើសាសនា (មាត្រា២០៩-១៨):**

ការវាយប្រហារទៅលើអាយុជីវិតរបស់ព្រះសង្ឃដែលកំពុងធ្វើប្រណិប័តន៍ព្រះពុទ្ធសាសនាដែលទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជាក្នុងពេលកំពុងអនុវត្តព្រះបរមកិច្ចរបស់ព្រះសង្ឃគឺជាបទឧក្រិដ្ឋកម្រិតទី៣ ។ ការវាយប្រហារដទៃទៀតទៅលើពុទ្ធបរិស័ទរបស់ព្រះសង្ឃ គឺជាឧក្រិដ្ឋកម្មកម្រិតទី២ ។ បទឧក្រិដ្ឋកម្រិតទី២ដទៃទៀតរួមមានការទប់ស្កាត់ឬបញ្ឈប់នូវការបូជាសាសនា និងការប្រមាថមើលងាយនូវទីកន្លែងសាសនាឬវត្ថុពិសិដ្ឋរបស់សាសនា ។

**ការរំលោភដទៃទៀតរបស់អាជ្ញាធររដ្ឋាភិបាល (មាត្រា២៤០-៤៤):** ច្បាប់ព្រហ្មទណ្ឌបានដាក់ទណ្ឌកម្មដល់ការប្រើអំណាចតាមអំពើចិត្តដោយរដ្ឋាភិបាលឬអាជ្ញាធររាជការ ដោយឲ្យទទួលទោសតាមបទមជ្ឈិមកម្រិតទី២ ។ អំពើរំលោភបំពានតាមអំពើចិត្តត្រូវបានឲ្យនិយមន័យរួមថាជាការបិទមិនឲ្យសិទ្ធិឬសេរីភាពរបស់ប្រជាពលរដ្ឋខាងនយោបាយស៊ីវិលឬគ្រួសារដោយគ្មានយុត្តាធិការស្របច្បាប់ ។ ការខកខានរបស់មន្ត្រីរដ្ឋាភិបាលក្នុងការរាយការណ៍នូវអំពើបែបនេះ ក៏ជាបទមជ្ឈិមកម្រិតទី២ដែរ ។

**ឧក្រិដ្ឋកម្មពាក់ព័ន្ធនានាមួយចំនួន (មាត្រា៧៧-៨៨):** មាត្រា៧៧បានទាក់ទណ្ឌកម្មដល់ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋដូចជាបទឧក្រិដ្ឋដែរ ក្នុងករណីការប៉ុនប៉ងទាំងនេះខកខានមិនសម្រេចតាមបំណងរបស់ខ្លួនដោយសារតែមានអំពើណាផ្សេងមិនបណ្ដាលមកពីជនប្រព្រឹត្តបទល្មើសនោះ ។ ការប៉ុនប៉ងចំពោះបទមជ្ឈិម គឺត្រូវទទួលទោស ប្រសិនបើមានចែងច្បាស់លាស់ ។ ការប៉ុនប៉ងរំលោភបំពាន(របស់នគរបាល)មិនត្រូវទទួលទោសទេ ។ ចំពោះករណីឃុបឃិត មាត្រា៨២បានចែងថា បុគ្គលទាំងអស់ដែលបាន

ចូលរួមដោយស្មគ្រចិត្ត ទោះជាដោយផ្ទាល់ឬដោយប្រយោល ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម គឺទទួលការដាក់ទណ្ឌកម្មដូចគ្នា ។ ការចូលរួមដោយប្រយោលគឺត្រូវបានកំណត់ដោយមាត្រា៨៣ រាប់បញ្ចូលទាំងការញុះញង់ ការបណ្តុះបណ្តាល ការផ្តល់មធ្យោបាយ និងការឧបត្ថម្ភ ។ បន្ថែមលើបទល្មើសដូចដែលបានរៀបរាប់ខាងលើ ច្បាប់តុលាការយោធាដែលបានបោះពុម្ពផ្សាយជាមួយច្បាប់ព្រហ្មទណ្ឌនេះដែរ ផ្តល់នូវការពណ៌នាបទឧក្រិដ្ឋកម្មបន្ថែមមួយចំនួនទៀតដែលប្រព្រឹត្តដោយមន្ត្រីបុគ្គលិកយោធា ។ ឧក្រិដ្ឋកម្មនិងការដាក់ទណ្ឌកម្មជាទូទៅត្រូវបានឲ្យនិយមន័យដូចគ្នានៅក្នុងច្បាប់ព្រហ្មទណ្ឌដែរ ។ ភាគច្រើនដែលបានចែងក្នុងច្បាប់នេះពាក់ព័ន្ធនឹងបទរំលោភបែបយោធា ដូចជាការមិនគោរពវិន័យថ្នាក់លើ រត់ចោលជួរ និងអំពើក្បត់ជាតិ ។ ប៉ុន្តែច្បាប់នេះដាក់ជាបទឧក្រិដ្ឋមជ្ឈិមកម្រិតទី២ ចំពោះការលួចឆក់ប្លន់ដោយមន្ត្រីបុគ្គលិកយោធាដែលប្រព្រឹត្តដោយមានអាវុធប្រើកម្លាំងឬអំពើហិង្សា ។ ប្រសិនបើសមាជិកមួយចំនួននៅក្នុងក្រុមគឺជាអ្នកបង្កឡើងនូវបទល្មើស សមាជិកទាំងនោះ និងជនដែលមានឋានន្តរសក្តិយោធាខ្ពស់បំផុតត្រូវទទួលទោសនូវបទឧក្រិដ្ឋកម្រិតទី២ ហើយអ្នកដទៃទៀតគឺជាអ្នកញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ កម្រិតទី១ ។



ទាហានខ្មែរក្រហមត្រៀមចេញប្រយុទ្ធ

ចុងក្រោយបង្អស់ ច្បាប់ឆ្នាំ១៩៥៦មិនបានចែងឲ្យច្បាស់នូវឧក្រិដ្ឋកម្មអន្តរជាតិ ដូចជាអំពីប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬក៏ឧក្រិដ្ឋកម្មសង្គ្រាមទេ ។ ប៉ុន្តែច្បាប់នេះផ្តោតការយកចិត្តទុកដាក់ច្រើនទៅលើតែឧក្រិដ្ឋកម្មក្នុងប្រទេសតែប៉ុណ្ណោះ ។ ប្រការដែលថាតើច្បាប់កម្ពុជាអនុញ្ញាតឲ្យយកមកកាត់ទោសដោយផ្ទាល់នូវបុគ្គលដែលប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិដោយចាំបាច់បញ្ចូលឧក្រិដ្ឋកម្មទាំងអស់នោះនៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា គឺមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ ។

ច្បាប់រដ្ឋធម្មនុញ្ញបារាំងអាចអនុញ្ញាតឲ្យមានការយកមកកាត់ទោសយ៉ាងហោចណាស់តាមច្បាប់អន្តរជាតិដែលឈរលើសន្ធិសញ្ញា ពីព្រោះថាសន្ធិសញ្ញានានាអាចអនុវត្តនៅក្នុងប្រទេសបាន តែតាមការបោះពុម្ពផ្សាយជាផ្លូវការមួយចំនួន ។ ប្រសិនបើប្រទេសកម្ពុជាដើរតាមវិធីសាស្ត្របារាំង ប្រទេសកម្ពុជាអាចបញ្ចូលនូវច្បាប់អន្តរជាតិក្នុងប្រទេសរបស់ខ្លួនតាមរយៈក្រឹត្យបែបនោះ ប៉ុន្តែការអនុវត្តប្រតិសកម្មបែបនេះអាចបង្កនូវការលំបាកដូចគ្នាទៅនឹងប្រតិសកម្មអនុវត្តលើឧក្រិដ្ឋកម្មដែរ ។ ប្រសិនបើប្រទេសកម្ពុជាបានចេញក្រឹត្យឲ្យអនុវត្តបាននូវកតិកាសញ្ញាប្រល័យពូជសាសន៍ឬក៏កតិកាសញ្ញានៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិដទៃផ្សេងទៀតក្នុងប្រទេសបញ្ហាប្រតិសកម្មនឹងមិនកើតជាឧបសគ្គចំពោះឧក្រិដ្ឋកម្មទាំងនោះឡើយ ។

**ចាសិន អាប្រាម និង ស្ទីវ រ៉ាតន័រ**

# តម្លៃនៃភស្តុតាង

**(តពីលេខមុន)** ដើម្បីបង្កើតរូបភាពខ្សែសង្វាក់ឲ្យបានកាន់តែច្បាស់ពេញលេញថែមទៀត គឺត្រូវយកឯកសារទាំងអស់មកផ្ដុំបញ្ចូលជាឯកសារតែមួយ ។ សំបុត្រឆ្លងឆ្លើយតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាផ្ដល់ជាពត៌មានមួយចំនួន ។ រីឯឯកសារមួយចំនួនទៀតក៏ផ្ដល់ជាពត៌មានដែរ ដូចជាកំណត់ហេតុប្រជុំគណៈកម្មាធិការ ឯកសារផ្លូវការរបស់អង្គការបក្សកុម្មុយ-និស្តកម្ពុជា ច្បាប់និងបទបញ្ជាផ្សេងៗ ។ សំបុត្រឆ្លងឆ្លើយច្រើនតែនិយាយយោងដល់សមាជិកមួយចំនួននៃបក្សកុម្មុយនិស្តកម្ពុជា ព្រមទាំងមុខងាររបស់គេផង ។ មិនតែប៉ុណ្ណោះសំបុត្រឆ្លងឆ្លើយក៏នៅមាននិយាយអំពីកងនយោបាយនិងកងយោធាដែលជាការបញ្ជាក់អំពីរចនាសម្ព័ន្ធបញ្ជា ។ កំណត់ហេតុប្រជុំរបស់គណៈកម្មាធិការផ្ដល់នូវពត៌មានប្រហាក់ប្រហែលគ្នានេះ ហើយមានបន្ថែមចំនួនឈ្មោះដែលមានវត្តមាន ឬក៏ការបញ្ជាក់ពីសមាជិកភាពនៃគណៈកម្មាធិការដែលរៀបចំការប្រជុំ ។ ចំណុចចុងក្រោយមួយទៀត គឺការផ្សព្វផ្សាយជាផ្លូវការរបស់បក្សកុម្មុយនិស្តកម្ពុជាដែលថែងច្បាស់អំពីតួនាទីយ៉ាងលម្អិតរបស់មន្ត្រីរដ្ឋាភិបាលមួយចំនួន ។ ជាទូទៅ អ្នកដែលមានតំណែងខ្ពស់បំផុតនៅក្នុងរចនាសម្ព័ន្ធរបស់បក្ស នឹងមានបញ្ជាក់អំពីក្បួនច្បាប់មួយចំនួនរបស់អង្គការចាត់តាំងបក្សកុម្មុយនិស្តកម្ពុជា ។ បើយកមកប្រើផ្គុំគ្នាឯកសារទាំងអស់នេះផ្ដល់នូវរូបភាពពេញលេញមានហេតុផលគ្រប់គ្រាន់អំពីខ្សែសង្វាក់បញ្ជារបស់យោធានិងនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ឯកសារនេះថែមទាំងអាចផ្ដល់រូបភាពច្បាស់លាស់នៃរចនាសម្ព័ន្ធទូទៅនៃអង្គការចាត់តាំងនយោបាយភូមិសាស្ត្រនិងយោធាដែលមានប្រយោជន៍សំខាន់រហូតដល់អាចយកមកប្រើប្រាស់បានជាភស្តុតាងប្រយោល ។

កំណត់ហេតុកត់ត្រាកិច្ចសម្ភាសន៍និងចម្លើយសារភាពក៏រួមចំណែកក្នុងការផ្ដល់ពត៌មានដែរ ទោះបីជាមានទម្ងន់ស្រាលបន្តិចក៏ដោយ ។ វានៅតែមិនច្បាស់លាស់ដដែលថាតើតុលាការនឹងវាយតម្លៃឯកសារជាពាក្យចចាមអារ៉ាម ឬចម្លើយសារភាពស្ដីអំពីទំនាក់ទំនង ឬរចនាសម្ព័ន្ធនៃការបញ្ជាតាមបែបណា ។

### ៣) បំណងឧក្រិដ្ឋ

ឯកសារជាច្រើនតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានលក្ខណៈបង្ហាញផ្លូវដែលអាចចូលទៅក្នុងធាតុផ្សំរបស់ចេតនាឧក្រិដ្ឋក្នុងការទទួលខុសត្រូវលើការបញ្ជាដែរ ។ ឯកសារដែលមានសារសំខាន់បំផុតរបៀបនេះចែកចេញជាបួនជំពូក÷ ក) ឯកសារឆ្លងឆ្លើយ ខ) កំណត់ហេតុប្រជុំគណៈកម្មាធិការបក្សកុម្មុយនិស្តកម្ពុជា គ) របាយការណ៍ដែនទី និងឃ) ការផ្សព្វផ្សាយជាផ្លូវការរបស់បក្សកុម្មុយនិស្តកម្ពុជាដែលមានទម្ងន់ស្រាលបំផុត ។ ឯកសារឆ្លងឆ្លើយបង្ហាញអំពីការដឹងឮសកម្មភាពឧក្រិដ្ឋរបស់កូនចៅក្រោមបញ្ជានៅពេលដែលថ្នាក់លើជាអ្នកទទួលរបាយការណ៍នៃសកម្មភាពនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានតម្កល់ឯកសារបក្សកុម្មុយនិស្តកម្ពុជាយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលសរសេរនិងចម្លងជូនមន្ត្រីថ្នាក់លើរបស់ខ្លួន ។ ឯកសារទាំងនេះនិយាយអំពីសកម្មភាព ដូចជាការធ្វើទារុណកម្ម ការកាប់សម្លាប់ ឬសកម្មភាពពិរុទ្ធផ្សេងៗទៀតដែលត្រូវបានប្រព្រឹត្តឡើងដោយកូនចៅដែលនៅក្រោមបញ្ជា ។ របាយការណ៍ខ្លះមានចំណារដែលសរសេរយ៉ាងច្បាស់ដោយមន្ត្រីថ្នាក់កំពូល បញ្ជាក់ច្បាស់ថាខ្លួនបានទទួលរបាយការណ៍ទាំងនោះហើយ ។ ដោយមានសក្ខីកម្មពីអ្នកជំនាញវិភាគអក្សរដៃ ឯកសារមួយចំនួនទៀតដែលមានចំណាររបស់មន្ត្រីថ្នាក់កំពូល អាចជាភស្តុតាងដ៏មានទម្ងន់ថារបាយការណ៍ពិតជាត្រូវបានទទួលហើយ ។ មិនតែប៉ុណ្ណោះ ចំនួនរបាយការណ៍ដ៏ច្បាស់ផ្ញើទៅកាន់មន្ត្រីថ្នាក់លើដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានបន្ថែមជាភស្តុតាងប្រយោលថាមានឯកសារមួយចំនួន ទោះបីមិនទាំងអស់ក៏ដោយ ពិតជាត្រូវបានទទួល ។

គួររំឭកដែរថា ឯកសារឆ្លងឆ្លើយភាគច្រើនដែលមានការ

ពាក់ព័ន្ធ គឺរបាយការណ៍ចម្លើយសារភាព ។ ទោះបីជាតម្លៃភ័ស្តុតាងនៃចម្លើយសារភាពខ្លួនឯងមានកម្រិតយ៉ាងណាក៏ដោយ ក៏ការរៀបរាប់ជាការផ្ដើមសរសេរដោយអ្នកសួរចម្លើយ ផ្ដល់ជាភ័ស្តុតាងបង្ហាញថា ចម្លើយសារភាពត្រូវបានស្រង់យកតាមរយៈការធ្វើទារុណកម្ម ។ មានឯកសារមួយចំនួនបញ្ជាក់យ៉ាងច្បាស់អំពី "ទារុណកម្ម" ដែលត្រូវបានធ្វើឡើងដើម្បីបង្ខំឲ្យបុគ្គលណាមួយឆ្លើយ ។ មិនខុសគ្នាទៅនឹងឯកសារជាច្រើនដែលប្រើពាក្យបង្រ្គួញពិសេសដូចជាពាក្យ"កម្ទេច" ឬ"សម្រិតសម្រាំង" របាយការណ៍មកពីអ្នកសួរចម្លើយមិនមានអ្វីគួរឲ្យសង្ស័យទេថា អ្នកបានទទួលរបាយការណ៍ត្រូវបានប្រាប់ជាដំណឹងស្ដីអំពីការប្រព្រឹត្តបទឧក្រិដ្ឋ ។

កំណត់ហេតុប្រជុំគណៈកម្មាធិការក៏មានលក្ខណៈប្រហាក់ប្រហែលគ្នានេះដែរ គឺផ្ដល់នូវភ័ស្តុតាងបញ្ជាក់ពីតម្រូវការចូលក្នុង "បំណងឧក្រិដ្ឋ" ។ ដោយរួមទាំងការជជែកពិភាក្សាគ្នាអំពីអំពើឧក្រិដ្ឋផង កំណត់ហេតុគណៈកម្មាធិការដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា បង្ហាញពីការដឹងឮអំពីការរំលោភរបៀបនេះក្នុងចំណោមសមាជិកគណៈកម្មាធិការដែលមានវត្តមាន ។ លើសពីនេះទៀត កិច្ចប្រជុំគណៈកម្មាធិការមួយចំនួនមានបញ្ចូលអនុសាសន៍ទៅលើនយោបាយដែលថា "សមាសភាពមិនល្អ" និង "អ្នកប្រឆាំងអង្គការ" ត្រូវតែ "កម្ទេចចោល" ឬ "សម្រិតសម្រាំង" ចេញពីបក្សនិងជួរមហាជន ។ ការពោលរបៀបនេះបង្ហាញយ៉ាងច្បាស់អំពីចេតនារបស់អ្នកនិយាយក្នុងការនាំមកឬបណ្ដោយឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ ។ ខ្ញុំមិនបានឃើញកំណត់ហេតុគណៈកម្មាធិការណាមួយដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានលើកឡើងនូវការជំទាស់ចំពោះនយោបាយនេះឡើយ ។ កង្វះសម្លេងជំទាស់អាចយកមកប្រើជាភ័ស្តុតាងប្រយោលដែលបង្ហាញថា សមាជិកនៅសល់ទាំងប៉ុន្មានដែលមានវត្តមានបានទាំងគាំទ្រនិងអនុលោមជាមួយនឹងនយោបាយ "កម្ទេច" និង "សម្រិតសម្រាំង"ទៅលើខ្មាំងរបស់របបនេះផង ។

ប្រភពសំខាន់ទីបីនៃភ័ស្តុតាងដ៏មានទម្ងន់តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបង្កើតជាធាតុ "បំណងឧក្រិដ្ឋ" គឺរបាយការណ៍ដែនទីដែលធ្វើឡើងដោយបុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ របាយការណ៍នៃការចុះធ្វើដែនទីគឺជាភ័ស្តុតាងបង្ហាញពីចំនួនមនុស្សស្លាប់យ៉ាងច្រើន និងរណ្ដៅសាកសពធំៗដែលមាននៅទូទាំងប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការកើតឡើងនូវការសម្លាប់ក្នុងទ្រង់ទ្រាយធំរបៀបនេះនៅតាមភូមិភាគនីមួយៗរបស់បក្សកុម្មុយនិស្តកម្ពុជាគឺជាភ័ស្តុតាងប្រយោលដ៏មានទម្ងន់ដែលបង្ហាញថាមន្ត្រីថ្នាក់លើរបស់បក្សកុម្មុយនិស្តកម្ពុជាបានដឹងឮយ៉ាងគ្រប់គ្រាន់ចំពោះការសម្លាប់ដែលយ៉ាងហោចណាស់ខ្លួនក៏ត្រូវតែមានកាតព្វកិច្ចធ្វើការស៊ើបអង្កេតដ៏សមហេតុសមផលដែរ ។ កំណត់ហេតុកត់ត្រាកិច្ចសម្ភាសន៍ ញត្តិ និងឯកសារដទៃទៀតដែលបានមកពីអ្នកដែលមានវាសនារួចរស់ជីវិតពីរបបខ្មែរក្រហម ជាការបន្ថែមមួយទៀតទៅលើភ័ស្តុតាងប្រយោលដែលថាមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបានដឹងឮនូវអំពើឃោរឃៅដែលប្រព្រឹត្តឡើងនៅថ្នាក់ក្រោម ។

ការផ្សព្វផ្សាយជាផ្លូវការរបស់បក្សកុម្មុយនិស្តកម្ពុជាកាន់តែមានកម្រិតទៅលើការប្រើប្រាស់ថែមទៀត ។ភាគតិចណាស់ដែលការផ្សព្វផ្សាយនេះបង្ហាញពីចេតនាទូទៅរបស់មជ្ឈិមក្នុងការលុបបំបាត់អ្នកប្រឆាំងផ្នែកនយោបាយ ។ សេចក្ដីថ្លែងការណ៍នេះបន្ថែមទៅលើភ័ស្តុតាងដែលបង្ហាញថា ថ្នាក់ដឹកនាំជាន់ខ្ពស់មានចេតនាចង់ឲ្យមានវិសុទ្ធកម្ម ហើយផ្ដល់នូវការបង្ហាញជាប្រយោលថា ថ្នាក់ដឹកនាំទាំងនេះបានដឹងនិងសហការជាមួយគ្នានៅក្នុងការប្រព្រឹត្តនេះ ។ ក៏ប៉ុន្តែចេតនាដែលស្តែងចេញតាមរយៈការផ្សព្វផ្សាយទាំងនេះគឺការប្រើពាក្យមិនច្បាស់លាស់ដែលបញ្ហានេះនាំឲ្យតម្លៃភ័ស្តុតាងធ្លាក់ចុះមួយកម្រិត ។

## ៤) អំពើពិរុទ្ធ

ឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក៏អាចយកមកប្រើប្រាស់ដើម្បីបង្ហាញពីអំពើពិរុទ្ធ ឬអំពើដែលគួរដាក់ទណ្ឌកម្មរបស់ជនជាប់ចោទថ្នាក់លើដែរ ។ គំនិតដ៏មានប្រសិទ្ធភាពរបស់ព្រះរាជអាជ្ញាគឺត្រូវប្រើភ័ស្តុតាងឯកសារជាលក្ខណៈដុំគ្នា ។ ប្រភពចម្បងទីមួយគឺភ័ស្តុតាងនៅមជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់បង្ហាញពីអំពើពិរុទ្ធ ឬការខកខានមិនបានទប់ស្កាត់របស់មន្ត្រីថ្នាក់លើនៃបក្សកុម្មុយនិស្តកម្ពុជា គឺរបាយការណ៍នៃការចុះធ្វើដែនទី ។ ចំនួនមនុស្សស្លាប់មិនធម្មតានិងរណ្ដៅកប់

ខ្មោចធំៗ នៅទូទាំងប្រទេសកម្ពុជា នៅក្នុងអំឡុងពេលដ៏ខ្លី គឺជាភ័ស្តុតាងប្រយោលដ៏មានទម្ងន់បង្ហាញថាមន្ត្រីជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជាមិនបានចាត់វិធានការទប់ស្កាត់ការកាប់សម្លាប់ ឬដាក់ទណ្ឌកម្មឲ្យសមរម្យតាមទោសកំហុសរបស់កូនចៅដែលនៅក្រោមបញ្ជារបស់ខ្លួនទេ ។ កំណត់ហេតុកិច្ចសម្ភាសន៍ ញត្តិ និង ឯកសារផ្សេងៗ ទៀតដែលប្រមែប្រមូលបានមកពីអ្នកដែលមានវាសនារស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ជាការបន្ថែមទៅលើភ័ស្តុតាងប្រយោលឲ្យកាន់តែមានទម្ងន់ ។

សំបុត្រឆ្លងឆ្លើយគឺជាប្រភពទីពីរនៃភ័ស្តុតាងបញ្ជាក់ពីអំពើពិរុទ្ធ ។ សំបុត្រជាច្រើនច្បាប់បានរាយការណ៍ប្រាប់មន្ត្រីថ្នាក់លើថាកូនចៅនៅក្រោមបញ្ជាបន្ត "សម្រិតសម្រាំងសមាសភាពមិនល្អ" និង "កម្ទេច" អ្នកប្រឆាំងនឹងអង្គការ ។ ការផ្ញើរបាយការណ៍ប្រហាក់ប្រហែលគ្នាទៅថ្នាក់លើ អាចយកមកប្រើប្រាស់ជាភ័ស្តុតាងបង្ហាញថា ថ្នាក់លើមិនបានជំទាស់ឲ្យបានគ្រប់គ្រាន់ចំពោះការប្រព្រឹត្តអំពើនេះ ក្រោយពីបានទទួលរបាយការណ៍ទីមួយហើយ ។ ន័យពិតរបស់សំបុត្រជាច្រើនដែលត្រូវបានយកមកផ្គុំគ្នាជារបាយការណ៍ បញ្ជាក់ពីការរីកចម្រើនក៏គាំទ្រដល់ការវិនិច្ឆ័យថាមន្ត្រីថ្នាក់លើបានបញ្ជាកូនចៅរបស់ខ្លួនឲ្យធ្វើការ "បោសសម្អាត" និង "សម្រិតសម្រាំង"ដែរ ។

ក្នុងន័យចេតនាឧក្រិដ្ឋវិញ ចំណាររបស់អ្នកសួរចម្លើយសរសេរឡើងមុនរបាយការណ៍ចម្លើយសារភាព ផ្តល់នូវភ័ស្តុតាងមានទម្ងន់បញ្ជាក់ពីអំពើពិរុទ្ធ (អំពើដែលគួរតែដាក់ទណ្ឌកម្ម) ឬការធ្វេសប្រហែសរបស់ថ្នាក់លើ ។ របាយការណ៍ដដែលៗ ស្តីអំពីការធ្វើទារុណកម្ម បង្ហាញថាថ្នាក់លើខកខានមិនបានចាត់វិធានការឲ្យបានសមស្រប ដើម្បីទប់ស្កាត់កុំឲ្យអំពើនេះកើតឡើងសាជាថ្មីម្តងទៀត ។ មិនតែប៉ុណ្ណោះសោត ការពិតដែលថាសំបុត្រត្រូវបានព្រាងជារបាយការណ៍បញ្ជាក់ពីការរីកចម្រើន នាំទៅដល់សេចក្តីសន្និដ្ឋានបានថាអំពើនេះត្រូវបានបញ្ជាឬជំរុញ ។



រូបថតអ្នកទោសថតនៅមន្ទីរស-២១

កំណត់ហេតុប្រជុំគណៈកម្មាធិការគឺជាទម្រង់មួយទៀតនៃភ័ស្តុតាងឯកសារ ។ នៅក្នុងការពិភាក្សាទាក់ទងនឹងអំពើដែលធ្វើឡើងដោយកូនចៅនៅក្រោមបញ្ជា អនុសាសន៍ឬទិសដៅបញ្ជារបស់មេដឹកនាំឲ្យមានការ "សម្រិតសម្រាំង" បង្ហាញពីការចូលរួមឬការជំរុញដ៏សកម្មបង្កឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ ។

ចំណុចមួយទៀតគឺថា ការផ្សព្វផ្សាយជាផ្លូវការរបស់បក្សកុម្មុយនិស្តកម្ពុជាក៏បង្ហាញពីអំពើពិរុទ្ធដែរ ដោយបញ្ជាយ៉ាងច្បាស់ៗដល់សមាជិកបក្សឲ្យ "សម្រិតសម្រាំង" សមាសភាពរបស់បក្ស ។ ក៏ប៉ុន្តែដូចដែលបានលើកឡើងពិភាក្សានៅខាងលើរួចមកហើយស្តីអំពីបំណងឧក្រិដ្ឋ ការផ្សព្វផ្សាយជាផ្លូវការរបៀបនេះត្រូវបានប្រើពាក្យពិបាកយល់មិនច្បាស់លាស់ ដូច្នេះវាបានកាត់បន្ថយតម្លៃភ័ស្តុតាងមួយកម្រិតៗ ។ **(នៅមានត)** **ចន ឆរតីអារី**

# ជនកុម្មុយនិស្តខ្មែរក្រហម និង វៀតណាម៖
# ប្រវត្តិទំនាក់ទំនងរវាងខ្មែរក្រហម និង វៀតណាម

**(តពីលេខមុន)** នៅទន្ទឹមពេលគ្នានេះដែរ ព័ត៌មានដែលផ្តល់ដោយទីក្រុងហាណូយដល់ភាគីសូវៀត មានផ្ទុកនូវការភ្លើងឆ្លល់របស់ខ្លួនជាច្រើន ។ នៅក្នុងកិច្ចសន្ទនាមួយជាមួយអគ្គទូតសូវៀតធ្វើឡើងនាខែវិច្ឆិកា ឆ្នាំ១៩៧៣ អនុប្រធាននាយកដ្ឋានទទួលបន្ទុកប្រទេសសង្គមនិយមនៃគណៈកម្មាធិការ មជ្ឈិមបក្សពលករវៀតណាម ង្វៀន ចុង ធួត បាននិយាយថា "ព័ត៌មានចុងក្រោយបង្អស់នេះបញ្ជាក់ច្បាស់ថាដំណើរការរបស់រណសិរ្សរួបរួមជាតិកម្ពុជា ហើយជាពិសេសតួនាទីដឹកនាំរបស់ ខៀវ សំផន ផ្ទាល់ឥឡូវនេះកំពុងតែត្រូវបានពង្រឹងហើយ" ។

នៅខែមករា ឆ្នាំ១៩៧៨ ព័ត៌មាននិយាយអំពី ខៀវ សំផន គឺខុសគ្នាទាំងស្រុង ។ អនុប្រធានទីមួយនៃនាយកដ្ឋានទំនាក់ទំនងខាងក្រៅរបស់គណៈកម្មាធិការបក្សកុម្មុយនិស្តវៀតណាម ង្វៀន ថាញ់ ឡេ បានប្រាប់ឯកអគ្គរដ្ឋទូតសូវៀតថា "នៅឆ្នាំ១៩៧១-១៩៧២ ខៀវ សំផន គឺជាសមាជិកសាមញ្ញរបស់បក្ស ហើយទើបតែនៅឆ្នាំ១៩៧៥ទេ ទើប ខៀវ សំផន ក្លាយជាបក្ខជនត្រៀមនៃគណៈមជ្ឈិម" ។

តាមរយៈនេះ យើងអាចពន្យល់បំភ្លឺភាពខុសគ្នានេះបានពីររបៀបៈ របៀបទីមួយគឺថា ទីក្រុងហាណូយពិតជាមិនដឹងអំពីឋានៈដឹកនាំរបស់ ខៀវ សំផន នៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជាទេ (ខៀវ សំផន តែងតែនៅឆ្ងាយពីការដឹកនាំពិតប្រាកដ) ។ របៀបទីពីរ គឺថាទីក្រុងហាណូយដឹងប៉ុន្តែមិនចង់ប្រាប់ទៅភាគីសូវៀតដែលមានបំណងចង់ធ្វើការទាក់ទងមិនមែនជាមួយមេដឹកនាំពិតប្រាកដ ប៉ុន្តែទាក់ទងជាមួយ ខៀវ សំផន ដែលមិនអាចធ្វើសេចក្តីសម្រេចចិត្ត ។ យ៉ាងហោចណាស់នៅឆ្នាំ១៩៧៣-៧៤ ខៀវ សំផន និង អៀង សារី ក៏ត្រូវបានចាត់ទុកនៅក្នុងមជ្ឈដ្ឋានទីក្រុងមូស្គូថាជាមនុស្សដ៏មានឥទ្ធិពលនៅក្នុងបក្សកុម្មុយនិស្តកម្ពុជាដែរ ។ មន្ត្រីក្រុងមូស្គូបានព្យាយាមជាច្រើនលើកច្រើនសាក្នុងការរៀបចំកិច្ចប្រជុំជាមួយ ខៀវ សំផន តែម្នាក់ឯង ។ នៅក្នុងកិច្ចសន្ទនាមួយនៅក្នុងខែមេសា ឆ្នាំ១៩៧៤ ជាមួយឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ហ័ង វ៉ាន់ទាន ឯកអគ្គរដ្ឋទូតសូវៀត បាន "សួរអំពីពេលវេលានៃការវិលត្រឡប់របស់ ខៀវ សំផន មកកាន់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនៅក្នុងដំណើររបស់ខ្លួនមកកាន់ប្រទេសកម្ពុជា ។ ឯកអគ្គរដ្ឋទូតសូវៀតនិយាយថា ខ្លួនចង់ជួបនិយាយជាមួយ ខៀវ សំផន" ។

ក្នុងការឆ្លើយតបទៅនឹងសំណើនេះ ប្រធាននាយកដ្ឋានទទួលបន្ទុកសហភាពសូវៀតនិងបណ្តាប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើតនៃក្រសួងការបរទេសវៀតណាម ង្វៀន ហ៊ុវ ឆៅ និយាយថា "នៅព្រឹកថ្ងៃទី២៨ ខែឧសភា នាយកដ្ឋានពិធីសារនៃក្រសួងការបរទេសបានលើកឡើងបញ្ហាកិច្ចប្រជុំនេះជាមួយនឹង ខៀវ សំផន តាមសំណើរបស់ឯកអគ្គរដ្ឋទូតសូវៀត ។ នៅថ្ងៃរសៀល នៅក្នុងកិច្ចចរចាជាមួយគណៈប្រតិភូកម្ពុជា នាយក-រដ្ឋមន្ត្រី ផាម វ៉ាន់ដុង បានផ្តាំផ្ញើការស្វាគមន៍ដ៏ភាតរភាពរបស់សមមិត្ត ប្រឺសនីវ ប៉ូហ្គោនី និង កូស៊ីជីន ជូនចំពោះ ខៀវ សំផន និង អៀង សារី ដោយជូនពរឲ្យអ្នកទាំងពីរទទួលបានជ័យជម្នះនៅក្នុងការតស៊ូរបស់ខ្លួន ។ ថ្នាក់ដឹកនាំសូវៀតបានសួរទៅ ផាម វ៉ាន់ដុង អំពីរឿងនេះ នៅក្នុងដំណើរទស្សនកិច្ចថ្មីៗរបស់ខ្លួនទៅកាន់ទីក្រុងមូស្គូ" ។

ឥឡូវនេះជាការច្បាស់ណាស់ថា ទោះបីជា ខៀវ សំផន មានចំណាប់អារម្មណ៍ចូលរួមប្រជុំនេះក៏ដោយ ក៏ ខៀវ សំផន មិនអាចធ្វើទៅរួចដែរបើគ្មានការយល់ព្រមពីសំណាក់ ប៉ុល ពត ឬគណៈកម្មាធិការប្រធានផ្នែកនយោបាយនិងប្រតិបត្តិនៃ

គណៈកម្មាធិការមជ្ឈិមទេនោះ ។ ការពុះពារបង្កើតទំនាក់ទំនងរវាងទីក្រុងមូស្គូនិងខ្មែរក្រហមអាចកើតឡើងទៅបាន លុះត្រាណាមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំខ្មែរក្រហមសំខាន់ៗ ។ ក៏ប៉ុន្តែវៀតណាមបានព្យាយាមអស់ពីសមត្ថភាពក្នុងការរារាំងមិនឲ្យមានការទាក់ទងដោយផ្ទាល់រវាងទីក្រុងមូស្គូជាមួយអាជ្ញាធរបក្សកុម្មុយនិស្តកម្ពុជាទេ ព្រោះវៀតណាមមានបំណងចង់ចៀសវាងមិនឲ្យមានអ្នកណាម្នាក់ដណ្តើមយកទំនាក់ទំនងផ្តាច់មុខជាមួយខ្មែរក្រហម ។ ដោយដឹងថាទីក្រុងមូស្គូអាចសង្ស័យពីរឿងដែលថាទីក្រុងហាណូយមានចេតនាជួយបង្កើតទំនាក់ទំនងរវាងបក្សកុម្មុយនិស្តសូវៀតនិងបក្សកុម្មុយនិស្តកម្ពុជាដែរឬក៏អត់នោះ មន្ត្រីវៀតណាមបានប្រកាសគ្មានឈប់ថា "បក្សពលករវៀតណាមខំប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការជួយបង្កើនទំនាក់ទំនងរវាងមិត្តកម្ពុជានិងមិត្តសូវៀត" ។ មានការជឿជាក់យ៉ាងទូលំទូលាយថា ក្រោយឆ្នាំ១៩៧៣ ទំនាក់ទំនងរវាងជនកុម្មុយនិស្តខ្មែរក្រហមនិងជនកុម្មុយនិស្តវៀតណាមបានថមថយចុះជាបណ្តើរៗ រហូតដល់មានសង្គ្រាមព្រំដែននៅខែមេសា ឆ្នាំ១៩៧៧ ។ ឯកសារបណ្ណសារដែលយើងមានបង្ហាញថាសម្មតិកម្មនេះមិនត្រឹមត្រូវទេ ហើយថាក្រោយពីមានការផ្អាកដើម្បីផ្លាស់ប្តូរគំនិតនៅឆ្នាំ១៩៧៣រួចមក ទំនាក់ទំនងនេះមានការរីកចម្រើននៅឆ្នាំ១៩៧៤រហូតដល់មានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ។

នៅឆ្នាំដដែលនេះ អាជ្ញាធរបក្សកុម្មុយនិស្តកម្ពុជាហាក់ដូចជាបំភ្លេចនូវការចោទប្រកាន់ទាំងឡាយដែលថាវៀតណាម "បានក្បត់នឹងផលប្រយោជន៍របស់ប្រជាជនខ្មែរ" ហើយចាប់ផ្តើមលើកតម្កើងទំនាក់ទំនងយុទ្ធសាមគ្គីភាពនិងចំណងសាមគ្គីភាពសាជាថ្មីរវាងកងកម្លាំងរំដោះវៀតណាមនិងកម្ពុជា ។

តាមការពិត ប៉ុល ពត ត្រូវបានបង្ខំឲ្យទទួលស្គាល់ថាខ្លួនប្រញាប់តែចោទប្រកាន់វៀតណាមពេក ពីព្រោះនៅដើមឆ្នាំ១៩៧៤ វាច្បាស់ណាស់ថា ដោយសារមានការខូចខាតយ៉ាងដំណំនៅក្នុងយុទ្ធនាការយោធាឆ្នាំ១៩៧៣ ខ្មែរក្រហមមិនមានលទ្ធភាពវាយយកភ្នំពេញដោយគ្មានជំនួយយោធានិងបច្ចេកទេសដ៏សន្ធឹកសន្ធាប់របស់វៀណាមបានឡើយ ។



នួន ជា

នៅក្នុងការស្វែងរកជំនួយសម្ភារនិងអាវុធ ប៉ុល ពត បានបែរទៅរកចិន ។ ប៉ុន្តែចិនធ្វើជាមិនដឹងមិនឮចំពោះការសុំជំនួយដោយទទូចអង្វរនេះ ។ ទីក្រុងប៉េកាំងបានលេងល្បែងរបស់ខ្លួន ហើយសង្ឃឹមថានឹងមានការផ្លាស់ប្តូរក្នុងសហសម័ន្ធនៃកងទ័ពក្នុងជួរថ្នាក់ដឹកនាំវៀតណាម និងក្នុងទិសដៅនយោបាយរបស់ខ្លួនដែលអាចធ្វើឲ្យកិច្ចសហប្រតិបត្តិការវៀតណាមជាមួយចិនកាន់តែខ្លាំងឡើងនិងធ្វើឲ្យថមថយចុះនូវឥទ្ធិពលរបស់សូវៀតដែលចេះតែកើនឡើង។ ក្រោយពីទទួលការបដិសេធផ្តល់

ជំនួយពីទីក្រុងប៉េកាំង ប៉ុល ពត ដែលជារឿយៗត្រូវបានហៅថា«បងលេខមួយ» នៅក្នុងឯកសារបក្សកុម្មុយនិស្តកម្ពុជានោះ បានបង្ខំចិត្តបន្ទូរបន្ថយសន្ទ្រាមពាក្យសម្ដីរបស់ខ្លួននិងសុំការជួយជ្រោមជ្រែងពីទីក្រុងហាណូយសាជាថ្មី ។ ឯកសារបណ្ណសារបង្ហាញអំពីការចុះថមថយនៃទំនាក់ទំនងរវាងខ្មែរនិងវៀតណាម ។ របាយការណ៍នយោបាយឆ្នាំ១៩៧៤របស់ស្ថានទូតសូវៀតប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យ វៀតណាមសរសេរថា នៅដើមឆ្នាំនោះ នៅក្នុងកិច្ចសន្ទនាជាមួយអគ្គទូតសូវៀត មិត្តវៀតណាមបាននិយាយយោងដល់ការលំបាកក្នុងកិច្ចសហប្រតិបត្តិការជាមួយជនកុម្មុយនិស្តកម្ពុជា ។ នៅចុងឆ្នាំនោះ មិត្តវៀតណាមនិយាយថា ទំនាក់ទំនងមានភាពល្អជាងមុន ។ នៅខែមីនាក្នុងសំបុត្រមួយច្បាប់ផ្ញើទៅកាន់ ឡេ ឌឹកថូ សមាជិកគណៈកម្មាធិការប្រធានផ្នែកនយោបាយនិងប្រតិបត្តិនៃគណៈកម្មាធិការមជ្ឈិមបក្សពលករវៀតណាម ប៉ុល ពត និយាយថា «ខ្ញុំសូមធានាដោយស្មោះស្ម័គ្រអស់ពីចិត្តពីថ្លើមថាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ខ្ញុំនៅតែមានភក្ដីភាពចំពោះនយោបាយមហាមិត្តភាពនិងភាតរភាពនិងសាមគ្គីបដិវត្តន៍រវាងកម្ពុជានិងវៀតណាមជានិច្ច ទោះជាមានការលំបាកនិងមានឧបសគ្គអ្វីមករារាំងក៏ដោយ» ។

ច្បាស់ណាស់ នៅក្នុងឆ្នាំ១៩៧៤ ប៉ុល ពត កំពុងតែលេងល្បែងយ៉ាងប៉ិនប្រសប់ជាមួយទីក្រុងហាណូយ ដោយមានគោលបំណងដ៏មានឥទ្ធិពល ។ ប៉ុល ពត បានសម្ដែងនូវការដឹងគុណនិងស្បថស្បែ ពីព្រោះខ្លួនមិនមានឱកាសល្អក្នុងការទទួលជំនួយយោធានិងជំនួយផ្សេងៗទៀតពីវៀតណាមឡើយ ។ នៅឆ្នាំ១៩៧៨ ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ង្វៀន កូថាច់ បានប្រាប់ទៅជនកុម្មុយនិស្តអាល្លឺម៉ង់ថា នៅឆ្នាំ១៩៧៤ កម្ពុជាបានសុំជំនួយដើម្បីវាយយកភ្នំពេញ ។ «ប៉ុន្តែចិនមិនផ្ដល់ជំនួយនេះឡើយ ពេលនោះ ប៉ុល ពត បានងាកទៅជិតវៀតណាមវិញ» ។ ការអំពាវនាវសុំជំនួយថ្មីមួយទៀតនៅឆ្នាំ១៩៧០ មិនមែនចេញមកពី ប៉ុល ពត ទេ ប៉ុន្តែមកពីអនុប្រធានបក្សឈ្មោះ នួន ជា (ឯកសារសន្ទនារបស់ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ង្វៀន កូថាច់ ជាមួយសមមិត្តអាល្លឺម៉ង់ក្នុងខណៈកំពុងស្នាក់អាស្រ័យនៅ GDR នៅថ្ងៃទី១-៦ ខែសីហា ឆ្នាំ១៩៧(៨) ។ គ្មានអ្វីគួរឲ្យចម្លែកទេចំពោះការអំពាវនាវដោយបង្ខំចិត្តរបស់ ប៉ុល ពត ដែលសុំជំនួយពីវៀតណាមនោះ ។ រឿងដែលចម្លែកគឺថា ហេតុអ្វីបានជាថ្នាក់ដឹកនាំវៀតណាមដែលដឹងច្បាស់អំពីជំហររបស់មេដឹកនាំខ្មែរក្រហមក្នុងទំនាក់ទំនងជាមួយទីក្រុងហាណូយ មិនចាត់វិធានការទាល់តែសោះក្នុងការផ្លាស់ប្តូររបៀបរបបគ្រប់គ្រងអំណាចនៅក្នុងជួរបក្សកុម្មុយនិស្ត ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។ ជាការច្បាស់ណាស់ ជំហររបស់ នួន ជា ដែលជាមនុស្សសំខាន់ម្នាក់ដែលមេដឹកនាំទីក្រុងហាណូយជ្រោមជ្រែង ពិតជាមានអំណាចសម្រេចនៅក្នុងខណៈនោះ ។ នួន ជា កំពុងតែមានសហប្រតិបត្តិការស្រាប់ហើយជាមួយ ប៉ុល ពត ។ ច្បាស់ណាស់ថា នួន ជា ក្បត់នឹងចៅហ្វាយវៀតណាមដោយមិនរាករេនិងដោយចេតនាទាក់ទងទៅនឹងផែនការដាក់ស្តែងរបស់ថ្នាក់ដឹកនាំខ្មែរក្រហម ដោយសង្កត់ធ្ងន់ទៅលើភាពមិនមានប្រយោជន៍នៃការផ្លាស់ប្តូរមេដឹកនាំខ្មែរ ។ ជាលទ្ធផល នៅឆ្នាំ១៩៧៤ វៀតណាមបានផ្ដល់ជំនួយយោធាដោយឥតលក្ខខណ្ឌ ។ ប៉ុល ពត មិនត្រូវបានផ្តួលរំលំឡើយ ។ ហើយក៏មិនមានការប៉ុនប៉ងកម្ចាត់តួនាទីរបស់ ប៉ុល ពត ឬពង្រីងឥទ្ធិពលរបស់កម្លាំងប្រឆាំងដែរ ។ វាអាចទៅរួចដែលថាទីក្រុងហាណូយមិនចង់ឲ្យមានបញ្ហាដែលមិនមែនជាការប៉ងប្រាថ្នាកើតឡើងនៅក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយទីក្រុងភ្នំពេញនៅក្នុងខណៈពេលរៀបចំខ្លួនវាយប្រហារនៅវៀតណាមខាងត្បូង ។

គ្មានអ្វីគួរឲ្យឆ្ងល់សោះថា បំណងប្រាថ្នាដាក់ច្បាស់របស់ថ្នាក់ដឹកនាំខ្មែរក្រហមភាគច្រើនក្នុងការគ្រប់គ្រងប្រទេសកម្ពុជាដោយឯករាជ្យនិងគ្មានប្រឹក្សាភិបាល គឺត្រូវមើលងាយមើលថោកនៅទីក្រុងហាណូយ ។ ឧទាហរណ៍ក្រោយមកទើបមេដឹកនាំវៀតណាមសារភាពអំពីកំហុសចោលម្សៀតនេះ ។ សមាជិកម្នាក់នៃគណៈកម្មាធិការប្រធានផ្នែកនយោបាយនិងប្រតិបត្តិនៃបក្សពលករវៀតណាមនិងជារដ្ឋមន្ត្រីក្រសួងការបរទេសដ៏យូរអង្វែង ង្វៀន កូថាច់ នៅក្នុងកិច្ចសន្ទនាឆ្នាំ១៩៧៨របស់ខ្លួនជាមួយជនកុម្មុយនិស្តអាល្លឺម៉ង់ បាននិយាយថា «នៅឆ្នាំ១៩៧៥

វៀតណាមវាយតម្លៃខុសចំពោះសភាពការណ៍នៅកម្ពុជា» ។

ការទទួលកំហុសដែលសម្ដែងចេញដោយរដ្ឋមន្ត្រីដើងចាស់រូបនេះគឺគ្មានអ្វីគួរឲ្យងឿងឆ្ងល់ទេ ពោលគឺនៅឆ្នាំ១៩៧៥ ទំនាក់ទំនងរវាងទីក្រុងភ្នំពេញនិងទីក្រុងហាណូយ បានធ្លាក់ចុះ ។ ក្រោយពីមានការកាន់កាប់ទីក្រុងភ្នំពេញដោយខ្មែរក្រហមនិងសៃហ្គនដោយវៀតណាមនោះ សភាពការណ៍នៅឥណ្ឌូចិនបានប្រែប្រួលយ៉ាងគំហុក ។ មេដឹកនាំវៀតណាមខាងជើងបានសម្រេចតាមសំណើមួយក្នុងចំណោមសំណើផ្សេងៗរបស់ទីក្រុងហូជីមិញ ពោលគឺគេបានរួបរួមវៀតណាមឲ្យស្ថិតក្រោមការគ្រប់គ្រងអំណាចរបស់ទីក្រុងហាណូយ ហើយកាន់តែស្គាល់ឆន្ទៈរបស់គ្នាទៅវិញទៅមកៈ ការបង្កើតសហព័ន្ធឥណ្ឌូចិនក្រោមការគ្រប់គ្រងរបស់វៀតណាម ។ ប៉ុន្តែគួរឲ្យភ្ញាក់ផ្អើលណាស់ថា ខុសពី «ផាថេត ឡាវ» និង កាយសុន ភូមវិហាន, ប៉ុល ពត និង ថ្នាក់ដឹកនាំខ្មែរបានបដិសេធការដែលថាមាន«ទំនាក់ទំនងពិសេស» ជាមួយទីក្រុងហាណូយ ។ ដំណើរទស្សនកិច្ចរបស់ ប៉ុល ពត ទៅកាន់ទីក្រុងហាណូយនៅខែមិថុនា ឆ្នាំ១៩៧៥ គឺជាព្រឹត្តិ-ការណ៍ពិធីសារយ៉ាងសំខាន់ ។

ប៉ុល ពត បានលើកឡើងនូវឃ្លាមួយជាទម្លាប់ប្រពៃណីថា «បើគ្មានជំនួយនិងការឧបត្ថម្ភពីសំណាក់បក្សពលករវៀតណាម យើងមិនអាចសម្រេចជ័យជម្នះបានទេ» សម្ដែងការដឹងគុណចំពោះ«បងៗនៅវៀតណាមខាងជើងនិងខាងត្បូង» កត់សម្គាល់ជាពិសេសចំពោះការគាំទ្ររបស់វៀតណាមនៅក្នុង«ការវាយប្រហារចុងក្រោយដ៏ធំនៅរដូវប្រាំងឆ្នាំ១៩៧៥ ពេលនោះយើងជួបការលំបាកខ្លាំងណាស់» ។ មេដឹកនាំរូបនេះមិនបាននិយាយអំពីការបង្កើតទំនាក់ទំនងជាពិសេសជាមួយវៀតណាមដូចដែលវៀតណាមបានសង្ឃឹមទុកនោះទេ ។ មិនតែប៉ុណ្ណោះទៀតសោត ក្រោយពីបានវិលត្រឡប់មកដល់ទីក្រុងភ្នំពេញវិញ ប៉ុល ពត បានប្រកាសថា «យើងឈ្នះទាំងស្រុង ជាស្ថាពរ និងស្អាតបរិសុទ្ធ មានន័យថាយើងឈ្នះដោយគ្មានការពាក់ព័ន្ធជាមួយបរទេសណា ឬការចូលរួមពីបរទេសណាទេ...យើងធ្វើការតស៊ូបដិវត្តន៍ដោយផ្អែកលើគោលការណ៍ឯករាជ្យ អធិបតេយ្យភាព និងស្វ័យម្ចាស់ការខ្លួនទីពឹងខ្លួន» ។ ហេតុដូច្នេះ មេដឹកនាំខ្មែរក្រហមរូបនេះធ្វើមិនដឹងមិនឮ សូម្បីតែសម្ដែងការដឹងគុណជាប្រចាំចំពោះប្រជាជនវៀតណាមដែលខ្លួនបានបន្ទីឡើងនៅអំឡុងពេលដំណើរទៅកាន់ទីក្រុងហាណូយក៏គ្មានដែរ ។ តាមការពិត លទ្ធផលតែមួយបានមកពីដំណើរទស្សនកិច្ចនេះ គឺការព្រមព្រៀងលើការរៀបចំប្រជុំកំពូលមួយនៅខែមីនា ឆ្នាំ១៩៧៦ ។ ក៏ប៉ុន្តែដូចដែលប្រភពវៀតណាមនានាបានបញ្ជាក់យ៉ាងដូច្នេះថា កិច្ចប្រជុំមិនដែលត្រូវបានរៀបចំឡើងទេ ។

តាមពិតទៅ វៀតណាមមិនចង់និយាយការពិតទាំងអស់ទេ ។ កិច្ចប្រជុំបែបនេះត្រូវរៀបចំឡើងនៅឆមាសទីមួយនៃឆ្នាំ១៩៧៦ ។ នៅឆ្នាំ១៩៧៨ ប្រធានគណៈកម្មាធិការរដ្ឋទទួលបន្ទុកផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដិន ឃ្វី អ៊ីញ បាននិយាយទៅកាន់ឯកអគ្គរដ្ឋទូតស៊ូវៀតអំពីពត៌មានលម្អិតនៃកិច្ចប្រជុំនេះ ។ ដិន ឃ្វី អ៊ីញ និយាយថា នៅក្នុងអំឡុងកិច្ចប្រជុំផ្ទាល់ខ្លួនរវាង ឡេ យន់ និង ប៉ុល ពត នៅក្នុងឆ្នាំ១៩៧៦ ប៉ុល ពត និយាយអំពីទំនាក់ទំនងមិត្តភាព ហើយ ឡេ យន់ ហៅរបបនៅក្រោមការដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យថា «កុម្មុយនិស្តបែបទាសភាព» ។ នៅក្នុងកិច្ចសន្ទនាជាមួយ ប៉ុល ពត មេដឹកនាំវៀតណាមហៅបដិវត្តន៍កម្ពុជាថា «កម្រ គឺមានតែមួយ» ឯកសារកិច្ចសន្ទនារបស់ឯកអគ្គរដ្ឋទូតស៊ូវៀតជាមួយសមាជិកគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តវៀតណាម ប្រធានគណៈកម្មាធិការរដ្ឋទទួលបន្ទុកផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។ **(នៅមានត)**

**មិទ្រី ម៉ូសយ៉ាកូវ**

សូមសរសេរលិខិត

ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក

**ទស្សនាវដ្ដី«ស្វែងរកការពិត»**

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ឬតាមទូរសារលេខៈ (៨៥៥)(២៣)២១០៣៥៨

ឬ Email: dccam@bigpond.com.kh

*របាយការណ៍ៈ*

# ខ្មែរក្រហម៧រូបប្រឈមមុខនឹងការកាត់ទោស

២១ឆ្នាំក្រោយពីការដួលរលំនៃរបបខ្មែរក្រហម អ្នកជំនាញការពីររូបដែលជាអ្នកនិពន្ធរួមផ្នែកសិក្សាស្រាវជ្រាវជាន់ខ្ពស់អំពីកម្ពុជាគឺ ស្ទីវ ហេដឌ័រ និងអ្នកជំនាញការច្បាប់សិទ្ធិមនុស្សអន្តរជាតិ ប្រែអ៊ិន ទិតម័រ បានសរសេរនូវរបាយការណ៍មួយដោយធ្វើការវាយតម្លៃជាលើកដំបូងបង្អស់ទៅលើពិរុទ្ធភាពរបស់បុគ្គលមួយចំនួន ។

របាយការណ៍នេះមានចំណងជើងថា "បុគ្គល៧រូបដែលត្រូវកាត់ទោសៈ ការដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម" ។ របាយការណ៍គឺជាឯកសារប្រវត្តិសាស្ត្រមួយដែលមិនត្រឹមតែកត់ត្រានូវអំពើឃោរឃៅដែលប្រព្រឹត្តឡើងនៅក្នុងរបបកាន់អំណាចដ៏ខ្មៅងងឹតរបស់ខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ជាក់អំពីការដឹងឮរបស់មេដឹកនាំ និងអំពីការទទួលខុសត្រូវលើបទព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ។

ដោយផ្អែកលើភ័ស្តុតាងឯកសារដែលទើបតែស្រាវជ្រាវរកឃើញថ្មីៗដែលត្រូវបានពិនិត្យរួចហើយ មានបញ្ជាក់អំពីនយោបាយមហាឃាតកម្មបង្កើតឡើងដោយថ្នាក់លើដែលមានអំណាចបំផុតនិងអនុវត្តតាមរយៈខ្សែសង្វាក់នៃការបញ្ជា ។

ភ័ស្តុតាងទាំងនេះរួមមាន ឯកសារទូរសា កំណត់ហេតុប្រជុំបក្សរបាយការណ៍ពីកន្លែងសម្លាប់និងគុកដែលត្រូវបានផ្ញើឲ្យជនដែលសង្ស័យទាំង៧នាក់ដែលត្រូវកាត់ទោស ថែមទាំងសៀវភៅកំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហមនិងចម្លើយសារភាពរបស់"កម្មាភិបាល"ខ្មែរក្រហមដែលត្រូវបានធ្វើទារុណកម្មនិងសម្លាប់ចោលក្រោយពីត្រូវបានដកចេញពីមុខតំណែង ព្រមទាំងបទសម្ភាសន៍របស់មេដឹកនាំថ្នាក់លើដែលរួមមានកិច្ចសន្ទនារបស់ ស្ទីវ ហេដឌ័រ ផ្ទាល់ ជាមួយ អៀង សារី ទៀតផង ដែលបានបង្ហាញអំពីខ្សែសង្វាក់ដែលមិនមានអ្នកណាស្រាវជ្រាវរកឃើញពីមុនមករវាងអំពើឃោរឃៅនានាដែលប្រព្រឹត្តនៅថ្នាក់ក្រោមជាមួយកម្មាភិបាលដែលមានឈ្មោះនៅក្នុងរបាយការណ៍នេះ ។

របាយការណ៍នេះសង្កត់ធ្ងន់លើការសម្លាប់ជាទ្រង់ទ្រាយធំទៅលើក្រុមដែលជាមុខសញ្ញាចំនួនបីគឺៈ ទីមួយ អ្នកដែលជាប់និន្នាការជាមួយអតីតរបបសាធារណរដ្ឋដែលខ្មែរក្រហមផ្តួលរំលំនៅក្នុងឆ្នាំ១៩៧៥ ។ ទីពីរ បក្ខជនឬ "កម្មាភិបាល" នៅក្នុងជួរខ្មែរក្រហមដែលត្រូវបានសង្ស័យថាជាជនក្បត់ ។ ទីបី សមាជិករបស់ក្រុមមិនមែនកុម្មុយនិស្តជាប្រជាជនទូទៅ ។

បុគ្គលទាំង៧នាក់ដែលមានក្នុងរបាយការណ៍នេះរួមមានថ្នាក់ដឹកនាំនៅកៀកស្និទ្ធនឹង ប៉ុល ពត ដែលនៅរស់រានមានជីវិតសព្វថ្ងៃនេះ រួមមាន ÷

- នួន ជា (បងលេខ២) ជាអនុរបស់ ប៉ុល ពត និងជាសមាជិកបង្គោលគណៈកម្មាធិការមជ្ឈិមដ៏មានអំណាចរបស់ខ្មែរក្រហមដែលបានបង្កើតនិងអនុវត្តនយោបាយសម្លាប់មនុស្ស ។
- អៀង សារី ជារដ្ឋមន្ត្រីក្រសួងការបរទេសដែលបានជំរុញនិងជួយជ្រោមជ្រែងជាសាធារណៈឲ្យមានការចាប់ខ្លួននិងការសម្លាប់កម្មាភិបាលនៅក្នុងជួរក្រសួងរបស់ខ្លួន ។
- ខៀវ សំផន ជាគណៈប្រធានរដ្ឋដែលបានជម្រុញមន្ត្រីបក្សថ្នាក់ក្រោមឲ្យសម្លាប់ជនរងគ្រោះ ។
- ម៉ុក ជាលេខាបក្សភូមិភាគនិរតីដែលជាអ្នកបញ្ជានិង(ឬ) ជួយជ្រោមជ្រែងក្នុងការចាប់ខ្លួនអ្នកនៅថ្នាក់ក្រោមនៅក្នុងភូមិភាគដែលត្រូវបានសង្ស័យថាក្បត់ ហើយមិនបានទប់ស្កាត់ឬដាក់ទណ្ឌកម្មចំពោះអំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយកូនចៅក្រោមបង្គាប់ខ្លួនផ្ទាល់ ។
- កែ ពក លេខាបក្សភូមិភាគឧត្តរ-កណ្តាលដែលបានបញ្ជានិង (ឬ) ជម្រុញឲ្យមានការចាប់ខ្លួនបក្ខពួកក្បត់ដែលជាប់សង្ស័យ នៅភូមិភាគរបស់ខ្លួន និងមិនបានទប់ស្កាត់ឬដាក់ទណ្ឌកម្មដល់អំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយកូនចៅនៅក្រោមបង្គាប់ខ្លួនផ្ទាល់ ។
- ស៊ូ ម៉េត និង មាស មុត ជាប្រធានយោធាដែលមានតួនាទីចុះចាប់និងបញ្ជូនកូនចៅទៅសួរចម្លើយនិងសម្លាប់ចោល ។

របាយការណ៍នេះចងក្រងជាឯកសារយ៉ាងលម្អិតអំពីតួនាទីដែលបុគ្គលខាងលើបានជម្រុញនិងអនុវត្តនូវនយោបាយមនុស្សឃាតមានជាអាទិ៍ដូចជាតាមរយៈការចូលប្រជុំរៀបចំគម្រោងសម្លាប់មនុស្ស ហើយរៀបរាប់អំពីសកម្មភាពរបស់បុគ្គលទាំង៧រូប និងធ្វើការវាយតម្លៃ
















ទៅលើអ្វីដែលបុគ្គលម្នាក់ៗខាងលើបានដឹងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយកូនចៅនៅក្រោមបង្គាប់ខ្លួន ពោលគឺជាការដឹងព្វដែលជនសង្ស័យទាំងនេះមួយចំនួនបានបដិសេធជាយូរណាស់មកហើយ ។

ភស្តុតាងដែលបង្ហាញថាបុគ្គលខាងលើជាអ្នកបានទទួលរបាយ-ការណ៍និងឯកសារផ្សេងៗស្តីអំពីដំណើរការវិវត្តទៅមុខនៃអំពើឃោរឃៅ ហើយមិនបានការពារថា ប៉ុល ពត ដែលបានស្លាប់ហើយនោះមិនទទួលខុសត្រូវក្នុងការរៀបចំនិងអនុវត្តនយោបាយឃោរឃៅរបស់ខ្មែរក្រហមឡើយ ។

ពេលនេះ អ្នកដែលមានការទទួលខុសត្រូវខ្ពស់បំផុតក្នុងការសម្លាប់ប្រជាជនកម្ពុជាជិតមួយភាគបី នៅក្នុងការគ្រប់គ្រងអំណាចរបស់ខ្មែរក្រហម ប្រាកដជាមិនអាចនិយាយថាខ្លួនមិនដឹងតទៅទៀតបានឡើយ ។ ការចេញផ្សាយនូវរបាយការណ៍នេះស្របគ្នាទៅនឹងកិច្ចប្រឹងប្រែងនានាដែលកំពុងបន្តធ្វើដោយអង្គការសហប្រជាជាតិ ប្រទេសដែលពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជានិងគ្រប់ទិសទី ក្នុងការបង្កើតនូវតុលាការឧក្រិដ្ឋកម្មមួយដើម្បីយកអ្នកដែលទទួលខុសត្រូវមកកាត់ទោសចំពោះមុខច្បាប់ ។

របាយការណ៍នេះអាចជាគ្រឹះក្នុងការកសាងសំណុំរឿងព្រហ្មទណ្ឌដូចដែលកំពុងតែធ្វើសព្វថ្ងៃនេះដើម្បីដាក់បន្ទុកចោទប្រកាន់លើបុគ្គលទាំង៧រូបខាងលើ ព្រមទាំងកម្មាភិបាលខ្មែរក្រហមផ្សេងៗទៀតដែលនៅរស់ ដោយយោងទៅតាមភស្តុតាងដែលមានស្រាប់និងរៀបចំឡើង ប្រយោជន៍ដើម្បីជួយផ្តល់ឲ្យប្រជាជនកម្ពុជានូវអ្វីដែលជាឱកាសចុងក្រោយក្នុងការកាត់ទោសក្រុមថ្នាក់ដឹកនាំរបស់ ប៉ុល ពត ដែលនៅរស់រានមានជីវិតនិងមានវ័យកាន់តែចាស់ជរាហើយនោះ ។

**សួ ប៊ុនស៊ូ**

# រឿងរ៉ាវនៃការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស

**(តចប់)** នៅថ្ងៃទី១២ ខែកញ្ញា ខ្ញុំបានអញ្ជើញអ្នកទាំងនោះត្រូវឲ្យវិលត្រឡប់មកវិញនៅខែមករា ក្រោយពីពេលដែលយើងបានបញ្ចប់ការចងក្រងឯកសារខ្មែរក្រហមទាក់ទងនឹងអំពើប្រល័យពូជសាសន៍ជូនដល់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដោយមានការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសំណាក់ ស៊ី.ដី.ភី ពេលនោះមានសេរីភាពក្នុងការបម្រើការចាំបាច់ផ្សេងៗរបស់មន្ទីរបញ្ចកោណ ។ នៅថ្ងៃទី២៣ ខែមករា ចេម ដាប់ប៊ែលយូ វ៉ូល មកពីផ្នែក អឹម.អាយ.អេ របស់ក្រសួងការពារជាតិ បានទទួលយកសំណើរបស់ខ្ញុំ ។ ខ្ញុំបានឆ្លើយតបវិញនៅថ្ងៃទី២៥ ខែតុលា ដោយបញ្ជាក់ជាថ្មីម្តងទៀតចំពោះឧត្តមសេនីយ វ៉ូល ថា អ្នកសិក្សាស្រាវជ្រាវរបស់លោកឈ្មោះ ដេវីត ឆេនដល័រ ត្រូវបានស្វាគមន៍ឲ្យធ្វើការនៅបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងខែមករា-កុម្ភៈឆ្នាំ១៩៩៧ ។ ការិយាល័យរបស់ វ៉ូល បានទូរស័ព្ទនៅពេលរសៀលថ្ងៃនោះមកអរគុណខ្ញុំ ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកក៏អរគុណខ្ញុំដូចជា ឆេនដល័រ ដែរ ។

បីថ្ងៃក្រោយមក នៅថ្ងៃទី២៩ខែតុលា នៅក្នុងទិនានុប្បវត្តិ អេស៊ាន វ៉លស្ទ្រីត ស្ទ៊ីត ចោទប្រកាន់ខ្ញុំខុសថាខ្ញុំមិនព្រមធ្វើកិច្ចសហប្រតិបត្តិការជាមួយអ្នកសិក្សាស្រាវជ្រាវរបស់ក្រសួងការពារប្រទេស ។ ខ្ញុំបានឆ្លើយតបវិញតាមទូរសារនៅថ្ងៃទី៤ ខែវិច្ឆិកា ប៉ុន្តែសារពត៌មានរបស់ ស្ទ៊ីត បដិសេធមិនហ៊ានចេញផ្សាយនូវការឆ្លើយតបរបស់ខ្ញុំនេះ ដោយបន្តផ្ញើទៅឲ្យទិនានុប្បវត្តិ

វីល ស្រ៊ីត នៅទីក្រុងញូវយ៉កវិញ ។ នៅថ្ងៃទី៥ ខែធ្នូ លោក ចច មេឡុន ដែលជានិពន្ធនាយករង បានសុំ «សំបុត្រមួយច្បាប់ដែលលោកបានទទួលពីឧត្តមសេនីយ៍ វ៉ូល» ។ ពេលនោះ ខ្ញុំក៏ផ្ញើតាមទូរសារទៅឲ្យ មេឡុន ភ្លាម ។ សំបុត្រនេះបញ្ជាក់ពីការទទួលយករបស់ខ្ញុំចំពោះមន្ទីរបញ្ចុកោណចុះថ្ងៃ១២ ខែកញ្ញា ។ ក៏ប៉ុន្តែនៅថ្ងៃទី១៩ ទិនានុប្បវត្តិបានចេញផ្សាយពត៌មានរបស់ ស្មិត ចុះខែតុលា ជាមួយនឹងបទវិចារណកថាមួយនិយាយថា «យៀវនិនបានបដិសេធអ្នកសិក្សាស្រាវជ្រាវមិនឲ្យប្រើប្រាស់ឯកសារ ។ គាត់នៅតែបន្តធ្វើយ៉ាងដូច្នេះទៀតសព្វថ្ងៃនេះ ហើយនឹងបន្តទៅទៀតលុះដល់គម្រោងរបស់គាត់ត្រូវចប់សព្វគ្រប់» ។ កាលពី ២សប្តាហ៍មុននេះ មេឡុន បានទទួលភ័ស្តុតាងជាក់ស្តែងមិនអាចប្រកែកបានដែលបង្ហាញថាយើងបានរៀបចំដំណើរទស្សនកិច្ចរបស់ក្រសួងការពារជាតិនៅខែក្រោយនេះ ។ បទវិចារណកថាមិនត្រឹមត្រូវនេះបានលេចឡើងព្រមៗគ្នានៅក្នុងទិនានុប្បវត្តិអេស៊ាន វ៉ុលស្ទ្រីត ។ ចុងក្រោយ សារពត៌មានទាំងពីរនេះក៏បានបោះពុម្ពផ្សាយសំបុត្រខ្ញីរបស់ខ្ញុំចុះថ្ងៃទី៤ ប៉ុន្តែមិនព្រមផ្សាយនូវសេចក្តីកែតម្រូវចំពោះបទវិចារណកថាថ្មីរបស់ខ្លួនឡើយ ។ លោក ធ័រទីល អ៊ីឡូត ដែលជាអនុប្រធានមូលនិធិ ហិនរី លូស បានសរសេរថា ខ្ញុំបានទទួលអំណោយឧបត្ថម្ភជាទឹកប្រាក់ចំនួនពីរសែនប្រាំម៉ឺនដុល្លារពីមូលនិធិរបស់លោក ។ សំណេរនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងសម្តីរបស់ ស្មិត កាលពីខែតុលា ឆ្នាំ១៩៩៦ ដែលថាខ្ញុំ «មិនគួរបានទទួលទឹកប្រាក់ជំនួយក្នុងចំនួនច្រើនបែបនេះឡើយ» ។ ទិនានុប្បវត្តិនេះបានបដិសេធមិនព្រមបោះផ្សាយសំបុត្រនេះដែលជាការឆ្លើយតបរបស់សកលវិទ្យាល័យយែលផ្ទាល់ទេ ហើយសូម្បីតែសំបុត្រមកពីក្រសួងការពារជាតិក៏មិនព្រមដែរ ។ សំបុត្រនេះធ្វើឲ្យអ្នកអានអ្នកផ្តល់មូលនិធិសំខាន់ៗនិងខ្មែរក្រហមយល់ច្រឡំថា ស៊ី.ជី.ភី នឹង«បិទទ្វារ»នៅខែមករា ឆ្នាំ១៩៩៧ ។

ប៉ុន្តែផ្ទុយមកវិញ នៅខែមករា ឆ្នាំ១៩៩៧ ស៊ី.ជី.ភី បានចេញនូវអ៊ីនធ័រណែត រួមទាំងទិន្នន័យធំៗ៤ និងចងក្រងឯកសារទាក់ទងនឹងបទឧក្រិដ្ឋកម្មខ្មែរក្រហម ។ ឆេនដល័រ បានធ្វើការនៅក្នុងបណ្ណសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងខែកុម្ភៈ ឆ្នាំ១៩៩៧ ដូចដែលបានគ្រោងទុក ហើយត្រឡប់ទៅវិញនៅខែឧសភា ។ ទោះបីជាទាំងគាត់និងបុគ្គលិកមន្ទីរបញ្ចុកោណមិនទាន់បានប្រកាសថាខ្លួនបានរកឃើញអ្វីខ្លះទាក់ទងនឹងទាហានបាត់ខ្លួននៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ ឆេនដល័របានអរគុណយើងចំពោះកិច្ចសហការនេះ ។ យើងមិនបានឃើញការទទួលស្គាល់បែបនេះនៅក្នុងទិនានុប្បវត្តិ វ៉ុល ស្ទ្រីត ឡើយ ។ ប៉ុន្តែនិពន្ធនាយកទូទៅនៃទិនានុប្បវត្តិ វ៉ុល ស្ទ្រីត បានធ្វើរបាយការណ៍ពីអត្ថិភាពរបស់យើងថាជា «កិច្ចការស្រាវជ្រាវតែមួយគត់នៅក្នុងពិភពលោកដែលផ្តោតសំខាន់ទៅលើអំពើឃោរ-ឃៅរបស់ខ្មែរក្រហម» ។ នៅពេលទន្ទឹមគ្នានេះដែរ សារពត៌មានវ៉ីដ័រ ដាយចេស៍ បានសរសើរ ស៊ី.ជី.ភី និងមជ្ឈមណ្ឌលឯកសារកម្ពុជាថា «សូម្បីតែសព្វថ្ងៃនេះបុគ្គលិកក្នុងគម្រោងការនេះកំពុងតែរកឃើញឯកសារជាច្រើនបង្ហាញពី «ច្បាប់ទម្លាប់មរណៈ» របស់ ប៉ុល ពត ។ ជាងនេះទៀត ការខិតខំរបស់សាកលវិទ្យាល័យយែល បានឈានដល់កម្រិតមួយរហូតដល់មានការតាំងចិត្តពីសំណាក់រដ្ឋាភិបាលកម្ពុជាថានឹងយល់ព្រមចំពោះការផ្តើមគំនិតក្នុងការនាំយកភ័ស្តុតាងព្រមទាំងមេដឹកនាំខ្មែរក្រហមមកកាន់តុលាការដើម្បីជម្រះក្តី» ។

ក្នុងខណៈនេះដែរ ក្រុមផ្តាច់ខ្លួនដែលមានមួយក្រុមដឹកនាំដោយ អៀង សារី បានបង្កើតការ «ស្រាវជ្រាវនិងប្រមែប្រមូលឯកសារ» ដើម្បីការពារខ្លួន ។ នៅខែមិថុនា ឆ្នាំ១៩៩៧ នាយករដ្ឋមន្ត្រីកម្ពុជាទាំងពីរបានអំពាវនាវសុំឲ្យអង្គការសហប្រជាជាតិបង្កើតនូវតុលាការមួយដើម្បីវិនិច្ឆ័យទោសឧក្រិដ្ឋកម្មកើតឡើងក្នុងអំឡុងដែលខ្មែរក្រហមកាន់កាប់ ។ នៅដើមឆ្នាំ ១៩៩៨ អង្គការសហប្រជាជាតិបានប្រមូលបុគ្គលមួយក្រុមជំនាញខាងច្បាប់មកធ្វើរបាយការណ៍ស្តីពីបញ្ហានេះ ។ អ្នកជំនាញការច្បាប់បានមកមជ្ឈមណ្ឌលឯកសារកម្ពុជានៅខែវិច្ឆិកា ឆ្នាំ១៩៩៨ ហើយបានពិនិត្យភ័ស្តុតាងយ៉ាងលម្អិត ។ របាយការណ៍នេះដែលជូនដល់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៩ បានស្នើឲ្យមានការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិពិសេសមួយដើម្បីវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម និងបង្កើតគណៈកម្មាធិការស្វែងរកការពិត

មួយនៅក្នុងប្រទេសកម្ពុជា ប្រយោជន៍ឲ្យជនរងគ្រោះដែលនៅរស់សម្តែងនូវការសាទុក្ខបុណ្ណិងតវ៉ាពីលក្ខខណ្ឌការងារឲ្យកាន់តែពេញលេញ ។

ប៉ុល ពត បានស្លាប់នៅក្នុងដំណេកនៅក្នុងខែមេសា ឆ្នាំ១៩៩៨ គឺជិតមួយឆ្នាំក្រោយពី ប៉ុល ពត បានសម្លាប់អតីតមេសន្តិសុខរបស់ខ្លួនឈ្មោះ សុន សេន ដែល ប៉ុល ពត សង្ស័យថាបានប៉ុនប៉ងឲ្យ អៀង សារី ចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា ។ ប៉ុន្តែក្តូដកម្មនិងការចុះចូលនៅឆ្នាំ១៩៩៨ នៃមេបញ្ជាការរងខ្មែរក្រហម កែ ពក និងការចុះចូលរបស់ ខៀវ សំផន និង នួន ជា មានន័យថាមេដឹកនាំបីរូបក្នុងចំណោមមេដឹកនាំខ្មែរក្រហមចុងក្រោយនឹងអាចចាប់ខ្លួនបានហើយ ។ មេបញ្ជាការយោធាជើងម្ខាងដែលនៅឯកោឈ្មោះ ឈិត ជឿន ហៅ ម៉ុក មិននៅក្នុងព្រៃបានយូរប៉ុន្មានទៀតឡើយ ។ មកដល់ខែមីនា ឆ្នាំ១៩៩៩ ម៉ុក ត្រូវបានចាប់ខ្លួន ហើយបញ្ជូនមកតុលាការសឹកកម្ពុជា ។ ក្នុងខណៈនោះដែរប្រទេសដែលជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានប្រកាសគាំទ្រយ៉ាងពេញទំហឹងដល់ការបង្កើតតុលាការដែលមានចរិតជាអន្តរជាតិមួយ ។

ក្នុងអំឡុងពេលនេះ មានការប៉ុនប៉ងថ្មីៗក្នុងការរារាំងបន្ទុចបង្អាក់ការងារនៃកម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ នៅក្នុងខែមីនា ឆ្នាំ១៩៩៨ សមាជិកសភាជាន់ទាបឈ្មោះ ខេម ប៊ែល បានសរសេរសំបុត្រមួយច្បាប់ទៀត ជូនទៅរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកដែលគាំទ្រដោយយុទ្ធជនជើងចាស់សម័យសង្គ្រាមវៀតណាម និងជាអតីតអ្នកដែលត្រូវបានតែងតាំងដោយ រីហ្កែន ឈ្មោះ ចន ដាសុន វីលល័រ III ។ លើកនេះ ការចោទប្រកាន់ គឺការចាត់ចែងមិនបានត្រឹមត្រូវនូវជំនួយរបស់ក្រសួងការបរទេសចំពោះស៊ី.ជី.ភី ។ ក្រោយពីការស៊ើបអង្កេតអស់រយៈពេល៦ខែមក ការិយាល័យស៊ើបអង្កេតសហរដ្ឋអាមេរិក«មិនបានរកឃើញភស្តុតាងបង្ហាញពីកំហុសឡើយ» រួចហើយក៏បញ្ឈប់ការស៊ើបអង្កេតត្រឹមនេះ ។ ក្នុងខណៈនោះ សហការីរបស់លោក ខេមប៊ែល ដែលជាសមាជិកសភាឈ្មោះ ដាណា រ៉ូរ៉ាប៊ែកឃ័រ និងសមាជិកព្រឹទ្ធសភា ចេស្សីហែម នៅភាគខាងជើងការ៉ូលីណា បានស្នើដំណោះស្រាយមួយលេខ (H.Res.៥៣៣) កាត់ទោសនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃប្រទេសកម្ពុជាក្នុងបទ «ឧក្រិដ្ឋកម្មសង្គ្រាម» ជាជាងតាមរកអ្វីដែលលោកហៅថា«ការមមៃទៅលើតែមេដឹកនាំមួយក្តាប់តូចដែលស្ថិតក្នុងវ័យចាស់ជរានិងមានជំងឺប្រចាំកាយ» ។

នៅពេលដែលឧក្រិដ្ឋជនប្រល័យពូជសាសន៍ទាំងពីររូបដែលមានវ័យចំណាស់និងមានជំងឺប្រចាំកាយ នួន ជា និង ខៀវ សំផន ចុះចូលជាមួយនឹងរដ្ឋាភិបាលកម្ពុជា ហើយសហរដ្ឋអាមេរិកអំពាវនាវឲ្យបញ្ជូនខ្លួនអ្នកទាំងពីរទៅកាន់តុលាការអន្តរជាតិនោះ ស្ទីហ្វាន ម៉ូរីស បានធ្វើការប៉ុនប៉ងចុងក្រោយដើម្បីការពារមិនឲ្យមានតុលាការប្រល័យពូជសាសន៍កើតឡើង ។ ម៉ូរីស បានសរសេរបទអត្ថាធិប្បាយខ្លីមួយរិះគន់ «មជ្ឈមណ្ឌលព្រមានអំពើប្រល័យពូជសាសន៍» ដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកទើបបានបង្កើតកាលពីខែមុន ។ ឥឡូវនេះ ម៉ូរីស ប្រកាសថា «អំពើប្រល័យពូជសាសន៍កម្រកើតមានណាស់» ហើយថា «ឧទាហរណ៍មួយដែលច្បាស់លាស់ពីអំពើប្រល័យពូជសាសន៍ គឺមានតាំងពីសម័យហាយនភាពណាស៊ីស»មក គឺករណីនៅរ៉ាវ៉ាន់ដាកាលពីឆ្នាំ១៩៩៤ ។ គំនិតរបស់ ម៉ូរីស យល់ថាប្រជាជនកម្ពុជាមិនបានទទួលរងនូវអំពើប្រល័យពូជសាសន៍ទេ ពីព្រោះ«ការធ្វើទុក្ខបុកម្នេញជនជាតិភាគតិចគឺគ្រាន់តែជាទិដ្ឋភាពនយោបាយតូចមួយប៉ុណ្ណោះ»ដែលត្រូវបានដាក់ចេញក្នុងសម័យខ្មែរក្រហម ។ សហការីម្នាក់របស់ ម៉ូរីស ឈ្មោះ អាដាម ហ្កាហ៊ីងហ្កល បានប្រកាន់ជំហរមិនឲ្យមានតុលាការអន្តរជាតិចំពោះបញ្ហាកម្ពុជា តាមរយៈសារពត៌មានឡូសអេនជីឡេសថែម ។ ទី១ ហ្កាហ៊ីង ហ្កល បានទាញហេតុផលថា «អំពើឃោរឃៅនៅក្នុងប្រទេសកម្ពុជាស្ទើរតែបង្ហាញពីគំនិតឆ្គួតលេលាផ្នែកនយោបាយនិងសតិអារម្មណ៍ ពោលគឺមិនមែនជារឿងជនជាតិឬសាសនាអ្វីឡើយ ។ ដោយសារមូលហេតុនេះហើយ ការប្រើពាក្យប្រល័យពូជសាសន៍ចំពោះអ្វីដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៤-១៩៧៩ មិនត្រឹមត្រូវទេ» ។ ទី២ ហ្កាហ៊ីង ហ្កល បន្ថែមថា «តើរដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងមានរឿងអ្វីខ្លះទាក់ទងនឹងឃាតករពីរនាក់នេះ (ខៀវ សំផន និង នួន ជា) ?

តើមានជនជាតិអាមេរិកស្លាប់ក្នុងដៃឧក្រិដ្ឋជនដែលបង្កការប្រល័យពូជសាសន៍ ប្រប្រលទាំងនេះឬទេ? ហើយចំណុចទាំង៣ ហ្កាហ៊ីង ហ្គល ទាញសេចក្តីសន្និដ្ឋានថា «តុលាការនឹងអាចបង្ហាញនូវភាពអាម៉ាស់មិនតិចឡើយស្តីពីតួនាទីរបស់អាមេរិកាំងនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្ន...។ [យើង]ពិតជានៅទីនោះនៅពេលមានការបង្កើតបញ្ហាកម្ពុជា ។ អ៊ីចឹងទេ ទោះជាគាស់ខ្មោចជីដូនជីតាផ្នែកនយោបាយមកនិយាយ ក៏មិនអាចទៅរួចដែរ» ។

ការមើលទៅលើកិច្ចខិតខំព្យាយាមមិនបានសម្រេចក្នុងការបន្ទុចបន្ទាក់ការងាររបស់ស៊ី.ដី.ភី អាចធ្វើឲ្យយើងឃើញផ្ទាល់អំពីដំណើរការបដិសេធថាមិនមានអំពើប្រល័យពូជសាសន៍ និងការគាបសង្កត់ផ្នែកពត៌មាន ។ ទាំងការបង្កើតការចងចាំ ការចងក្រងប្រវត្តិសាស្ត្រ និងការលុបផ្នែកប្រវត្តិសាស្ត្រ គឺអាស្រ័យទៅលើនយោបាយជាក់ស្តែង ។ ថាច់ ប៊ុនរឿន, ជូលីយ៉ូ ជីលជ្រេស, ស៊ីវហ្វាន ម៉ូរីស សមាជិកសភាមកពីគណបក្សសាធារណរដ្ឋ ទំព័រវិចារណកថារបស់ទិនានុប្បវត្តិវ៉ល ស្ទ្រីត ទាំងអស់នេះគិតថា របៀបវារៈនយោបាយរបស់ខ្លួនមានសារសំខាន់ជាងចងក្រងឯកសារស្តីពីបទឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយខ្មែរក្រហមហើយនិងការនាំឧក្រិដ្ឋជនមកជម្រះទោសពីបទអំពើប្រល័យពូជសាសន៍ ។ របៀបវារៈនេះបង្ហាញអំពីសម្ព័ន្ធភាពរវាងសហរដ្ឋអាមេរិកនិងប្រទេសចិន ប្រឆាំងនឹងសូវៀតនៅដំណាក់កាលក្រោយៗមកទៀតនៃសង្គ្រាមត្រជាក់ ។ សម្ព័ន្ធភាពនេះបានផ្សំផ្គុំអ្នកអភិរក្សនិយមប្រឆាំងនឹងជនកុម្មុយនិស្តនិយម និងម៉ៅនិយមជ្រុល ។ យើងឃើញពីការបញ្ចូលគ្នានេះ ។ អាទិភាពសម្រាប់សមាជិកទាំងឡាយនៃការរួបរួមគ្នានេះជាទូទៅមានការក្លែងបន្លំកិច្ចគាំទ្ររបស់ខ្លួនចំពោះខ្មែរក្រហមដោយកប់ចោលនូវប្រវត្តិសាស្ត្រសង្គ្រាមវៀតណាម ។ ប៉ុន្តែបែរជាមកតស៊ូសាជាថ្មីដោយនិយាយតែពីរឿងខ្មែរក្រហម ព្រមទាំងបញ្ចេះបញ្ចៀសហាន បាត់ខ្លួននៅក្នុងសង្គ្រាមឲ្យកាន់តែក្តៅគគុក ។ យុត្តិធម៌សម្រាប់ជនរងគ្រោះរបស់ខ្មែរក្រហមមិនមែនជាអត្ថិភាពរបស់អ្នកទាំងនេះឡើយ ។ អ្នកដែលបានស្វែងរកយុត្តិធម៌ ជារឿយៗតែងតែត្រូវបានវាយប្រហារពីក្រុមទាំងពីរ ។

ទាំងសមាជិកសភាពីគណបក្សសាធារណរដ្ឋនិង ទិនានុប្បវត្តិ វ៉លស្ទ្រីត បានបដិសេធថាមិនមានអំពើប្រល័យពូជសាសន៍កើតឡើងឡើយ ។ ផ្ទុយមកវិញ អ្នកទាំងនេះបានចាត់វិធានការយ៉ាងពេញទំហឹងក្នុងការទប់ស្កាត់និងបង្វែងមិនឲ្យមានការស៊ើបអង្កេតទៅលើអំពើប្រល័យពូជសាសន៍ទេ ។ យុទ្ធនាការដែលពោរពេញដោយការតាំងចិត្តរបស់អ្នកនយោបាយដ៏មានឥទ្ធិពលរបស់សហរដ្ឋអាមេរិក និងសារពត៌មានដ៏មានឥទ្ធិពលនៅលើពិភពលោក ត្រូវទទួលបរាជ័យ ។ ប៉ុន្តែយុទ្ធនាការនេះបង្កជាឧបសគ្គយ៉ាងធំដល់ការចងក្រងប្រវត្តិសាស្ត្រស្តីពីអំពើប្រល័យពូជសាសន៍ ជាងការដែលអ្នកសិក្សាជាន់ខ្ពស់ចូលចិត្តប្រើគំនិតរបស់ខ្លួនឯងនិងការពន្យល់នានាហួសពីអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ ។ អ្នកសិក្សាជាន់ខ្ពស់ភាគច្រើនស្ទើរតែទាំងអស់បានសម្តែងការស្វាគមន៍ចំពោះការខិតខំស្រាវជ្រាវនិងចងក្រងឯកសារតទៅមុខទៀត ។ ក៏ប៉ុន្តែផ្ទុយមកវិញ សម្ពាធនយោបាយគឺជាការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះដំណើរការស៊ើបអង្កេតដ៏ស្មោះត្រង់មួយ ។ ហើយការការពារដ៏ល្អបំផុតមានតែការផ្លាស់ប្តូរគំនិតកាន់តែជ្រៅទៀត ភាពចេះដឹងជ្រៅជ្រះ និងការតាំងចិត្តថែមទៀតតែប៉ុណ្ណោះ ។

ប៉ុល ពត បានស្លាប់ទៅហើយ ចំណែកឯកងទ័ពខ្មែរក្រហមត្រូវរលំរលាយដោយសារការបែកបាក់និងការបរាជ័យ ។ មេដឹកនាំខ្មែរក្រហមនៅរស់សព្វថ្ងៃបានលើកដៃចុះចូល ផ្តាច់ខ្លួន និងខ្លះទៀតត្រូវបានចាប់ខ្លួន ។ ការជំនុំជម្រះទោសជាលើកដំបូងទៅលើមេបញ្ជាការយោធារបស់ ប៉ុល ពត ឈ្មោះ ឈិត ជឿន ហៅ តាម៉ុក និងលើប្រធានសន្តិសុខខ្មែរក្រហមឈ្មោះ កាំង ហ្កិចអៀវ ហៅ ឌុច អាចនឹងចាប់ផ្តើមដំណើរការនៅពេលឆាប់ៗខាងមុខនៅក្នុងទីក្រុងភ្នំពេញ ។ បទចោទប្រកាន់ប្រឆាំងនឹង នួន ជា និង ខៀវ សំផន ក៏ត្រូវបានរៀបចំរួចស្រេចហើយដែរ ។ ទោះបីជានៅក្នុងការរៀបចំចងក្រងឯកសារមានការពាក់ព័ន្ធជាមួយនយោបាយគ្រប់ជំពូកយ៉ាងណាក៏ដោយ ក៏ការរៀបចំប្រវត្តិសាស្ត្រឲ្យបានត្រឹមត្រូវបាននិងកំពុងដំណើរការទៅមុខក្នុងក្របខ័ណ្ឌសហការគ្នាល្អក្នុងគោលបំណងស្វែងរកយុត្តិធម៌ពិតប្រាកដ ។

**វ៉េន យ៉ៀរនិន**



ថូម៉ាស់ ហាម៉ាប៊ឺក

## ◆ ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិៈ តើកិច្ចព្រមព្រៀងនៅលើការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកើតឡើងដោយរបៀបណា?





***(តពីលេខមុន) ២១ខែក្រោយមកៈ ភាពទាល់ច្រក***

ការនិយាយស្តីរបស់រដ្ឋាភិបាលចេះតែខិតទៅរកសង្គ្រាមប៉ាកកានិងកាន់តែក្តៅទៅៗ ។ ប្រវត្តិសាស្ត្ររបស់អង្គការសហប្រជាជាតិស្តីអំពីខ្មែរក្រហមត្រូវបានវាយប្រហារដូចជាជំហររបស់អង្គការសហប្រជាជាតិនិងប្រទេសចិនកាលពីពេលមុននិងពេលបច្ចុប្បន្នយ៉ាងដូច្នេះដែរ ។ ហើយរហូតដល់រដ្ឋាភិបាលថៃត្រូវបានចោទប្រកាន់ថាបានធ្វើ“ការបំផ្លិចបំផ្លាញដោយចេតនា” ទៀតផង ។ មិនតែប៉ុណ្ណោះមានទង្វើករណ៍មួយចំនួនលេចឡើងដែលមិនសូវយកជាការបាន ដូចជាថា រដ្ឋធម្មនុញ្ញកម្ពុជាមិនអនុញ្ញាតឲ្យមានកិច្ចសហប្រតិបត្តិការជាមួយនឹងតុលាការអន្តរជាតិក្រៅទឹកដីកម្ពុជាឡើយ ។ លើសពីនេះទៀតមានការលើកឡើងនូវគំនិតធូររលុងមួយ តែមិនដែលត្រូវបានវិភាគឲ្យបានហ្មត់ចត់ឡើយ ស្តីអំពីការជំនុំជម្រះក្តីតាម“គំរូនៅប្រទេសអាហ្វ្រិកខាងត្បូង”ដែលត្រូវយល់ថាជាគណៈកម្មការស្វែងរកការពិតមួយផ្អែកតាមការឆ្លើយសារភាពដោយស្ម័គ្រចិត្តនិងការមិនប្រកាន់ទោស ។ ខ្ញុំមានចំណាប់អារម្មណ៍ថា ផែនការប្តូរទីស្តីនៅក្នុងការពិភាក្សាគ្នានេះបង្ហាញពីការព្រួយបារម្ភទៅចំពោះបញ្ហាទាំងមូលជាងគោលការណ៍ជាយុទ្ធសាស្ត្រច្បាស់លាស់មួយ ។ តាមការពិតការពិភាក្សានេះបានមកដល់ស្ថានការណ៍ដែលរកផ្លូវចេញគ្មាន ។ ទោះបីជាមិនសម្តែងចេញឲ្យឃើញថាសប្តុរខ្មៅយ៉ាងណាក៏ដោយ ក៏លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លែងគាំទ្រសំបុត្រខែមិថុនា ឆ្នាំ១៩៩៧ ទៀតហើយ ។ ការផ្លាស់ប្តូរជំហរនេះហាក់លេចឡើងទន្ទឹមពេលជាមួយការចុះចូលរបស់ ខៀវ សំផន និង នួន ជា និងការជួបប្រជុំរបស់អ្នកទាំងពីរជាមួយនឹងសម្តេច ហ៊ុន សែន នៅខែធ្នូ ឆ្នាំ១៩៩៨ ។ អនុស្សាវរណៈរបស់សម្តេច ហ៊ុន សែន ធ្វើឡើងនៅថ្ងៃទី២១ ខែមករា ទោះបីជាមិនមានលក្ខណៈច្បាស់លាស់ក៏ដោយ បានបង្ហើបអំពីការទាញហេតុផលមួយចំនួនដែលក្រោយមកក្លាយជារឿងសំខាន់ ។ ការទាញហេតុផលមួយគឺគំនិតផ្ទុយគ្នារវាងសន្តិភាពនិងតុលាការ ។

ប៉ុន្តែចំណុចនេះហាក់ដូចជាមានទម្ងន់ស្រាលក្រោយពីមានការចាប់ខ្លួន តាម៉ុក រួចមក ។ ជាលទ្ធផលនៃការចាប់ខ្លួន តាម៉ុក គ្មានរបាយការណ៍ស្តីអំពីបញ្ហាសន្តិសុខឡើយ ។ ជាការលំបាកដែរក្នុងការផ្ទុគ្នារវាងជំហរដែលថាខ្មែរក្រហមឥឡូវត្រូវទទួលបរាជ័យទាំងស្រុង ជាមួយនឹងការទាញហេតុផលថាតុលាការអន្តរជាតិនឹងនាំដល់សង្គ្រាមស៊ីវិល ។ ជាផលវិបាក មានចំណុចពីរត្រូវបានផ្តោតសំខាន់ជាងនេះទៅទៀត ។ ចំណុចទីមួយគឺថា “វាហួសពេលទៅហើយ” ពោលគឺល្បែងបានចប់សព្វគ្រប់ហើយ ។ ហើយចំណុចមួយទៀត គឺទាក់ទិននឹងបញ្ហាអធិបតេយ្យភាព ។

សម្តេច ហ៊ុន សែន យល់យ៉ាងប្រត្យក្សថា តុលាការអន្តរជាតិជាឧបករណ៍សម្រាប់យកឈ្នះលើខ្មែរក្រហម ជាជាងមធ្យោបាយក្នុងការបង្កើតយុត្តិធម៌ ។ នៅពេលដែល អៀង សារី នួន ជា និង ខៀវ សំផន បានចុះចូល ហើយ តាម៉ុក ត្រូវបានចាប់ខ្លួន តុលាការក៏ប្រែជាលែងសូវសំខាន់ចំពោះសម្តេច ហ៊ុន សែន ។ ប៉ុន្តែយុត្តិធម៌មានតម្លៃនៅក្នុងខ្លួនវាផ្ទាល់ ។ ការរិះគន់របស់សម្តេច ហ៊ុន សែន ទៅលើអង្គការសហប្រជាជាតិថាមិនបានឆ្លើយតបឲ្យបានឆាប់រហ័សចំពោះសំបុត្រចុះខែមិថុនា ឆ្នាំ១៩៩៧ អាចយកមកពិចារណាជាមួយនឹងការអំពាវនាវរបស់សម្តេចដល់អង្គការសហប្រជាជាតិកុំឲ្យដំណើរការផ្សារនេះមុនការបោះឆ្នោតខែកក្កដា ឆ្នាំ១៩៩៨ ។ ការទាញ

ហេតុផលចំពោះសំណើនេះគឺថា ស្ថានការណ៍ដែលងាយប្រេះស្រាំស្រាប់ទៅហើយនេះមិនគួរត្រូវបានរំខានទៀតឡើយ ហើយថារដ្ឋាភិបាលត្រូវការសភាពការណ៍ប្រសើរជាងនេះខ្លះសម្រាប់ជំរុញឲ្យមានការចុះចូលជាបន្តទៅទៀត ។

តើអង្គការសហប្រជាជាតិមានភាពយឺតយ៉ាវដល់ថ្នាក់ណាទៅ? អ្នកជំនាញការត្រូវបានចាត់តាំងជាងមួយឆ្នាំក្រោយពីការផ្ញើសំបុត្រដើមមួយច្បាប់របស់នាយករដ្ឋមន្ត្រីទាំងពីររូបកាលពីខែកក្កដា ឆ្នាំ១៩៩៨ ។ អ្នកជំនាញការទាំងនោះហៀបនឹងធ្វើដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជាម្តងរួចមកហើយនៅក្នុងខែកញ្ញា ប៉ុន្តែត្រូវសម្រេចផ្អាកបេសកកម្មនេះទៅវិញរហូតដល់ខែវិច្ឆិកា ដោយសារមានភាពតានតឹងផ្នែកនយោបាយនៅក្នុងខែសីហា-កញ្ញា ។ របាយការណ៍ចុងក្រោយត្រូវបានចេញផ្សាយ២០ខែគត់ក្រោយពីសំណើស្នើឡើងដោយរដ្ឋាភិបាលកម្ពុជា ។

ពេលវេលាសម្រាប់មកទស្សនកិច្ចនេះមានបញ្ហាដោយសារក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិមិនដែលពិភាក្សាជាផ្លូវការទៅលើសំបុត្រនេះ ហើយមិនត្រូវបានជម្រាបអំពីបញ្ហានេះឡើយ ។ ទើបតែមានសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិនៅខែធ្នូ ឆ្នាំ១៩៩៧ទេ ដែលមានប្រតិកម្មកាន់តែមានលក្ខណៈផ្លូវការពីសំណាក់ស្ថាប័នមួយរបស់អង្គការសហប្រជាជាតិ ដែលជាការបើកផ្លូវសម្រាប់ការផ្តួចផ្តើមគំនិតរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ប្រសិនបើកិច្ចការនេះត្រូវបានឆ្លើយតបយ៉ាងឆាប់រហ័សនោះ ប្រហែលជាមានអ្នកជំនាញការមកធ្វើទស្សនកិច្ចនៅកម្ពុជាតាំងពីមុនពេលបោះឆ្នោតម៉្លេះ ដែលជាពេលមួយប្រហែលជាអាចផ្តល់ជាលទ្ធផលនិងមានប្រយោជន៍ជាងនេះផងក៏ថាបាន ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសង្កត់ធ្ងន់ទៅលើចំណុចរបស់សម្តេចស្តីអំពី“បូរណភាពទឹកដី” កាលពីខែមីនា ឆ្នាំ១៩៩៩ ។ ការទាញហេតុផលនេះតែងតែត្រូវបានលើកឡើង ហើយមកដល់ឥឡូវកាន់តែលេចចេញច្បាស់ថែមទៀត ។ ការដែលរដ្ឋាភិបាលកម្ពុជាមានភាពឯកោកាលពីទសវត្សរ៍ឆ្នាំ១៩៨០ នៅក្នុងខណៈដែលរដ្ឋាភិបាលចម្រុះដែលមានខ្មែរក្រហមលើសលប់មានអាសនៈនៅអង្គការសហប្រជាជាតិនោះ គាមតែអាចយល់បាននៅតែជាប្រភពនៃភាពជូរចត់សម្រាប់សម្តេច ហ៊ុន សែន និងមេដឹកនាំផ្សេងៗទៀតរបស់គណបក្សប្រជាជន ។ ហើយសម្តេច ហ៊ុន សែន ក៏បន្តធ្វើការរិះគន់ទៀតទៅលើបេសកកម្មរបស់អង្គការសហប្រជាជាតិ អ៊ុនតាក់ នៅឆ្នាំ១៩៩២-១៩៩៣ ។ សម្តេចមានប្រសាសន៍ថា អង្គការសហប្រជាជាតិបានរៀបចំការបោះឆ្នោតយ៉ាងប៉ិនប្រសប់បម្រើឲ្យផលប្រយោជន៍សម្រាប់គណបក្សហ៊្វុនស៊ិនប៉ិច ។

ការពន្យល់មួយទៅលើភាពមិនទៀងទាត់របស់សម្តេច ហ៊ុន សែន ចំពោះបញ្ហាតុលាការនេះ គឺប្រហែលមកពីមន្ទិលសង្ស័យដែលចាក់ឫសយ៉ាងជ្រៅរបស់សម្តេចទៅលើអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិ ដែលមន្ទិលនេះហាក់ដូចជាកើនឡើងថែមទៀតដោយមានរបាយការណ៍រិះគន់អំពីសិទ្ធិមនុស្ស ។ កត្តាមួយទៀតដែលសម្តេចបានលើកមកនិយាយដោយខ្លួនឯង គឺសម្ពាធផ្ទុយគ្នាដែលដាក់ដោយសហរដ្ឋអាមេរិកនិងប្រទេសចិន ។

ប៉ុន្តែមោទកភាពជាតិតែមួយមិនអាចដោះស្រាយបញ្ហាប្រព័ន្ធយុត្តាធិការដែលមានលក្ខណៈទ្រុឌទ្រោមនេះបានឡើយ ។ ជាការច្បាស់ណាស់ថា ប្រព័ន្ធតុលាការមិនអាចដំណើរការកិច្ចការនេះក្នុងសភាពគួរឲ្យពេញចិត្តឡើយ ដូចដែលបានសារភាពរួចមកហើយតាមរយៈសំបុត្រចុះខែមិថុនា ឆ្នាំ១៩៩៧ ។ សភាពការណ៍នៃបញ្ហានេះមានលក្ខណៈប្រសើរឡើងជាមុន ក្រោយពី២០ខែបានកន្លងផុតទៅ ។ មានបញ្ហាសំខាន់ៗពីរនៅក្នុងប្រពន្ធ័តុលាការ ។ ទីមួយគឺថា បុគ្គលិកតុលាការមានការអប់រំបានតិចតួច គ្មានបទពិសោធន៍ និងខ្វះធនធាន ។ បញ្ហានេះហើយដែលរួមចំណែកបង្កើតសកម្មភាពពុករលួយ ។ ស្ថានការណ៍នេះកាន់តែត្រូវបានធ្វើឲ្យយ៉ាប់យ៉ឺនមួយកម្រិតទៀតដោយសារបញ្ហាមួយទៀតគឺថា ឯករាជ្យភាពរបស់តុលាការកម្ពុជាមិនត្រូវបានបំផ្លាញដោយអ្នកខាងក្រៅ ។ ក្នុងការងាររបស់ខ្ញុំ ខ្ញុំបានជួបប្រទះករណីជាច្រើនដែលមានការគាបសង្កត់មិនប្រក្រតីពីសំណាក់មនុស្សមានអំណាច រួមទាំងអ្នកនយោបាយនិងមន្ត្រីយោធាផង ។ គ្រប់មេធាវីសំខាន់ៗដែលខ្ញុំបានជួបនិយាយជាមួយ សុទ្ធតែបានយល់ព្រមថា ប្រទេសកម្ពុជាមិនអាចដោះស្រាយដោយខ្លួនឯងនូវ

បញ្ហាតុលាការកាត់ទោសខ្មែរក្រហមទាក់ទងនឹងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មផ្សេងៗទៀតដែលប្រឆាំងនឹងមនុស្សជាតិបានទេ ។

មានការទទួលស្គាល់ទាំងស្រុងចំពោះបញ្ហាទីមួយ នៅក្នុងការអញ្ជើញ គ្រាន់តែជាការស្នើមើលដែលឥឡូវត្រូវបានបញ្ជូនទៅរដ្ឋាភិបាលមួយចំនួនឲ្យផ្តល់ទីប្រឹក្សាផ្នែកច្បាប់មកធ្វើការនៅក្នុងតុលាការខ្មែរក្រហម នៅពេលដែលការណ៍នេះត្រូវបានសម្តេច ហ៊ុន សែន និងរដ្ឋមន្ត្រីការបរទេសរបស់សម្តេច ថាជាផ្លូវមួយផ្សេងទៀតឆ្ពោះទៅរកតុលារអន្តរជាតិ ។ ក៏ប៉ុន្តែបញ្ហាអធិបតេយ្យភាពនិងភាពគួរទុកចិត្តបាននៃដំណើរការកាត់សេចក្តីអាចមិនត្រូវបានដោះស្រាយដោយពេញចិត្តតាមរយៈដំណោះស្រាយនេះឡើយ ។ ជាការសំខាន់ណាស់ដែលប្រជាជនទូទៅអាចជឿជាក់ថា យុត្តិធម៌ពិតជាត្រូវបានសម្រេច ។ ចំពោះបញ្ហានេះ ធាតុសំខាន់របស់អន្តរជាតិពិតត្រូវការចាំបាច់ណាស់ដូចដែលក្រុមអង្គការក្រៅរដ្ឋាភិបាលនានាបានលើកឡើងដូច្នេះដែរ ។

ប៉ុន្តែសម្តេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍នៅក្នុងកិច្ចប្រជុំខែមីនាថា សម្តេចមានអារម្មណ៍ថា តួនាទីរបស់អង្គការសហប្រជាជាតិនៅក្នុងបញ្ហានេះបានដល់ទីបញ្ចប់ហើយ ។

### *ភាគ២: ខែមីនា ឆ្នាំ១៩៩៩-មករា ឆ្នាំ២០០១ គំនិតបង្កើតតុលាការចម្រុះ*

ការណ៍ដែលសម្តេចនាយករដ្ឋមន្ត្រីបញ្ចប់កិច្ចសន្ទនាជាមួយនឹងអង្គការសហប្រជាជាតិស្តីអំពីបញ្ហាតុលាការខ្មែរក្រហម គឺជាសេចក្តីសម្រេចចិត្តដ៏ធំមួយ ។ មានប្រតិកម្មយ៉ាងខ្លាំងចំពោះសេចក្តីសម្រេចនេះ រួមទាំងបក្សនយោបាយរបស់សម្តេចផង ប្រឆាំងនឹងការជួបជាមួយនឹង នួន ជា និង ខៀវ សំផន នៅក្នុងខែធ្នូ ឆ្នាំ១៩៩៨ ។ មិនតែប៉ុណ្ណោះ កិច្ចប្រជុំរបស់ខ្ញុំនៅក្នុងខែមីនា ឆ្នាំ១៩៩៩ ជាមួយនឹងអ្នកនយោបាយផ្សេងទៀត រួមទាំងអ្នកនយោបាយពីគណបក្សប្រជាជន បានឆ្លុះបញ្ចាំងឲ្យឃើញពីកិច្ចគាំទ្រយ៉ាងទូលំទូលាយឲ្យមានតុលាការច្បាស់លាស់មួយផ្អែកលើគំរូបទដ្ឋានអន្តរជាតិ ។ អ្នកទាំងនោះបានជំរុញឲ្យខ្ញុំបន្តកិច្ចការនេះតទៅទៀត ទោះជាមានភាពទាល់ច្រកយ៉ាងណាក៏ដោយ ។

ហើយអង្គទូតបរទេសដទៃទៀតប្រចាំនៅក្នុងទីក្រុងភ្នំពេញ (និងសហការីដែលមានមូលដ្ឋាននៅទីក្រុងបាងកក) ក៏បានគាំទ្រដែរ ។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានដាក់បញ្ហានេះជូនក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនិងមហាសន្និបាតតាមរយៈសំបុត្ររបស់លោកចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ដោយមានអមរបាយការណ៍របស់ក្រុមអ្នកជំនាញការ ។ ចិនបានធ្វើការប្រឆាំងនឹងគំនិតផ្តួចផ្តើមរបស់អង្គការសហប្រជាជាតិ ។ នៅក្នុងកិច្ចប្រជុំមួយ ខ្ញុំបានជួបជាមួយឯកអគ្គរដ្ឋទូតចិនប្រចាំនៅទីក្រុងភ្នំពេញ ។ លោកឯកអគ្គរដ្ឋទូតចិនបានទាញហេតុផលថា បញ្ហាខ្មែរក្រហមគឺជាបញ្ហា "ផ្ទៃក្នុង" ហើយអង្គការសហប្រជាជាតិមិនគួរដោះស្រាយទេ ទោះបីជាមានការស្នើពីកម្ពុជាក៏ដោយចុះ ។

ប៉ុន្តែមានលេចចេញនូវប្រតិកម្មមួយពីរដ្ឋជាសមាជិក នៅចុងសម័យប្រជុំរបស់គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្សឆ្នាំ១៩៩៩ដែលយកបញ្ហាកម្ពុជាជាប្រធានបទម្តងទៀត ។ សេចក្តីសម្រេចនោះបានកត់សម្គាល់របាយការណ៍ពីក្រុមអ្នកជំនាញការដោយការសរសើរ ហើយអំពាវនាវយ៉ាងទទូចដល់រដ្ឋាភិបាលកម្ពុជាឲ្យចាត់វិធានការជាចាំបាច់ដើម្បីធានាឲ្យប្រាកដថា ជនដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សត្រូវតែបាននាំយកមកកាត់ទោសតាមគំរូបទដ្ឋានអន្តរជាតិដែលមានយុត្តិធម៌ ភាពគ្មានលម្អៀង និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ។ គណៈកម្មការសិទ្ធិមនុស្សជំរុញឲ្យរដ្ឋាភិបាលកម្ពុជានិងសហគមន៍អន្តរជាតិបន្តសហប្រតិបត្តិការជាមួយគ្នាដើម្បីសម្រេចគោលដៅនេះ ។ ម្យ៉ាងវិញទៀត ចំណាប់អារម្មណ៍របស់សហគមន៍អន្តរជាតិត្រូវបានបញ្ជាក់សាជាថ្មីទៀតហើយ ។

ក៏ប៉ុន្តែ សហគមន៍អន្តរជាតិមិនបានប្រកាន់ជំហរយកគំរូច្បាស់លាស់ដូចដែលស្នើឡើងដោយក្រុមអ្នកជំនាញការឡើយ ។ ការដែលថារដ្ឋាភិបាលកម្ពុជាបាននិយាយថាខ្លួនចង់បានតុលាការនោះ ធ្វើឲ្យរដ្ឋាភិបាលមួយចំនួនមានការពិបាកក្នុងការគាំទ្រដល់ការបង្ខំឲ្យទីក្រុងភ្នំពេញទទួលយកនូវដំណោះស្រាយណាមួយជាក់លាក់ ។ តាមការពិត អ្នកតំណាងការទូតដែលខ្ញុំបានពិគ្រោះពិភាក្សាជាមួយ បានបង្ហាញ

ពីការពេញចិត្តរបស់ខ្លួនចំពោះការបង្កើតតុលាការនៅក្នុងប្រទេសកម្ពុជា ដរាបណាសន្តិសុខនិងសុចរិតភាពត្រូវបានការពារ ។ សេចក្តីនេះហាក់បញ្ជាក់ថាៈ បេះតែបន្តការពិភាក្សាទៅ អ្នកមានសេរីភាពក្នុងការជ្រើសរើសគំរូមួយណាក៏ដោយឲ្យតែមានគំរូបទដ្ឋានជាចាំបាច់ ។

ជំហានជាផ្លូវការមួយទៀតគឺសំបុត្រមួយច្បាប់ទៀតផ្ញើមកពីសម្តេច ហ៊ុន សែន ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ ទៅកាន់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ សម្តេច ហ៊ុន សែន បានពន្យល់នៅក្នុងលិខិតនេះថា ទោះជាការជំនុំជម្រះក្តី តាម៉ុក និងប្រហែលជាករណីបុគ្គលដទៃទៀតនឹងកើតឡើងនៅក្នុងតុលាការជាតិក៏ដោយចុះ ក៏យើងសូមអញ្ជើញចៅក្រមនិងព្រះរាជអាជ្ញាបរទេសឲ្យចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការជំនុំជម្រះនេះ ដើម្បីធានាឲ្យប្រាកដថា តុលាការនេះពិតជាមាននីតិវិធីត្រឹមត្រូវតាមគំរូបទដ្ឋានអន្តរជាតិ ។ សេចក្តីព្រាងច្បាប់នឹងត្រូវដាក់ឲ្យសភាជាតិកម្ពុជាអនុម័ត ដើម្បីឲ្យមានការចូលរួមពីសំណាក់ចៅក្រមនិងព្រះរាជអាជ្ញាបរទេសនៅក្នុងដំណើរការកាត់សេចក្តីនេះ ។

ការបង្កើតឲ្យមានការចូលរួមពីសំណាក់អ្នកជំនាញច្បាប់បរទេសមិនមានលក្ខណៈច្បាស់លាស់ទេ ប៉ុន្តែហាក់ដូចជាបង្ហាញថា អ្នកជំនាញទាំងនេះអាចចូលរួមក្នុងឋានៈជាចៅក្រមនិងព្រះរាជអាជ្ញា មិនមែនបានត្រឹមតែទីប្រឹក្សាប៉ុណ្ណោះទេ ។ ការបើកចំហនេះនាំឲ្យមានគំនិតបង្កើត“តុលាការចម្រុះ”មួយ ដើម្បីជាការដោះស្រាយភាពទាល់ច្រករវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានជំរុញឲ្យមានគំនិតច្នៃប្រឌិតខ្លះតាមរយៈប្រសាសន៍របស់លោកកាលពីខែមីនាថា តុលាការគឺត្រូវតែមាន“ចរិតជាអន្តរជាតិ” ប៉ុន្តែមិនចាំបាច់យកគំរូតាមតុលាការពិសេសនៅអតីតប្រទេសយូហ្គោស្លាវីនិងរ៉ូវ៉ាន់ដានោះទេ ។

កាន់តែមានលក្ខណៈជាក់ស្តែងទៅទៀតនោះគឺថា មានការទាញហេតុផលដ៏មានទម្ងន់មួយចំនួនគាំទ្រឲ្យមានតុលាការនៅក្នុងប្រទេសកម្ពុជាផ្ទាល់តែម្តង ។ ទោះបីជាក្រុមអ្នកជំនាញការបានស្នើថាគួរតែបង្កើតតុលាការក្រៅប្រទេសកម្ពុជាប៉ុន្តែនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកក៏ដោយ តែវាមិនមែនជាពាក្យចុងក្រោយដ៏ចាំបាច់ទេ ។ ប្រសិនបើបញ្ហាសន្តិសុខនិងសុចរិតភាពរបស់តុលាការត្រូវបានដោះស្រាយនោះការបង្កើតតុលាការនៅក្នុងប្រទេសកម្ពុជានឹងផ្តល់ជាគុណសម្បត្តិច្រើនណាស់ ។ ឧទាហរណ៍ ករណីនេះអាចជួយឲ្យប្រជាជនកម្ពុជាបានសង្កេតដំណើរការកាត់សេចក្តីយ៉ាងជិតដិត ហើយមើលឃើញយ៉ាងច្បាស់ថាយុត្តិធម៌កំពុងតែត្រូវបានរកឲ្យខ្លួនហើយ ។

គំនិតបង្កើត“តុលាការចម្រុះ”នេះត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំនៅខែមេសារវាងសម្តេច ហ៊ុន សែន និងសមាជិកព្រឹទ្ធសភា ចន ឃែរី ដែលបានគាំទ្រគំនិតនេះ ។ ជ្រុងមួយនៃដំណោះស្រាយនេះគឺថា នឹងមានការចូលរួមពីសំណាក់ចៅក្រមកម្ពុជានិងអន្តរជាតិ ។ តុលាការដែលមានចរិតបែបនេះមិនដែលមានកាលពីមុនមកទេ ។ នេះជាគំនិតដែលមានលក្ខណៈពិសេស ប៉ុន្តែជាការច្បាស់ណាស់ថា តុលាការចម្រុះនឹងមានការស្មុគស្មាញយ៉ាងខ្លាំងក្នុងការអនុវត្តជាក់ស្តែង ។

នៅពេលខ្ញុំជួបសម្តេច ហ៊ុន សែន នៅថ្ងៃទី១៨ ខែឧសភា យើងបានពិភាក្សាគំនិតនេះឲ្យកាន់តែស៊ីជម្រៅថែមទៀត ។ សម្តេច ហ៊ុន សែន បានសួរខ្ញុំជាលក្ខណៈស្ទាបស្ទង់ថា តើលោកអគ្គលេខាអង្គការសហប្រជាជាតិអាចធ្វើការជ្រើសតាំងចៅក្រមអន្តរជាតិបានដែរឬយ៉ាងណា? ខ្ញុំបានឆ្លើយទៅវិញថា រាល់ការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងការភ្ជាប់ការងារនេះគឺអាស្រ័យទៅលើបញ្ហាថាតើមានការធានាឲ្យមានការគោរពយុត្តិធម៌ ភាពគ្មានលម្អៀង និងនីតិវិធីត្រឹមត្រូវតាមច្បាប់ ក្នុងគំរូបទដ្ឋានអន្តរជាតិដែរឬទេ? ការបង្កើតច្បាប់ដែលនឹងយកមកធ្វើជាសេចក្តីព្រាងនិងឈានទៅរកការអនុម័តដើម្បីសម្រេចគោលដៅនេះ គឺនឹងត្រូវដោះស្រាយការព្រួយបារម្ភរបស់លោកអគ្គលេខាអង្គការសហប្រជាជាតិ ដូចដែលបានស្តែងចេញតាមរយៈសំបុត្រចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ផ្ញើមកមហាសន្និសីទបាតអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។

គំនិតបង្កើតតុលាការ“ចម្រុះ”ដែលលេចចេញមកនេះហាក់ដូចជាបង្ហាញអំពីគោលបំណងក្នុងការផ្សំផ្គុំជំហរដែលថា ការកាត់សេចក្តីត្រូវតែធ្វើឡើងនៅលើទឹកដីកម្ពុជាខ្លួនឯងផ្ទាល់និងត្រូវបានយល់ថាមានចរិតជាកម្ពុជា ហើយម្យ៉ាងវិញទៀត ការធានាជា

ចាំបាច់ថាគំរូបទដ្ឋានអន្តរជាតិត្រូវតែបានយកមកអនុវត្តនិងពង្រឹងឲ្យបាន ។

តុលាការនេះនឹងផ្អែកយ៉ាងសំខាន់ទៅលើច្បាប់ដែលនឹងអនុម័តដោយរដ្ឋសភាជាតិកម្ពុជា ។ ខ្ញុំបានគូសបញ្ជាក់ថា របាយ-ការណ៍របស់ក្រុមជំនាញការបានផ្តល់ជាសេចក្តីណែនាំយ៉ាងសំខាន់ទាក់ទងនឹងចរិតនៃការតាក់តែងច្បាប់ដែលតម្រូវឲ្យមានពាក់ព័ន្ធនឹងច្បាប់សារធាតុនិងផ្នែកនីតិវិធី ។ គំរូបទដ្ឋានអន្តរជាតិដែលទាក់ទងនឹងត្រូវតែបានបញ្ចូល ហើយការអនុវត្តនីតិកម្មក្នុងស្រុកដែលទាក់ទងនៅពេលនោះ គួរតែបញ្ជាក់ឲ្យបានច្បាស់ ។

នៅក្នុងផ្នែកនីតិវិធីនឹងត្រូវមានការចាំបាច់ក្នុងការបញ្ជាក់ច្បាស់នូវចំណុចមួយចំនួនដូចជា វិធាននានាដើម្បីធានាឲ្យប្រាកដថានឹងមានការការពារមិនឲ្យមានការគាបសង្កត់ បំភិតបំភ័យ មានការរៀបចំឲ្យមានការចាប់ខ្លួនត្រឹមត្រូវគួរជាទីពេញចិត្តតម្រូវការវាយតម្លៃភ័ស្តុតាង ដំណើរការប្តឹងឧទ្ធរណ៍ យន្តការគួរជាទីពេញចិត្តសម្រាប់ជ្រើសតាំងចៅក្រម ព្រះរាជអាជ្ញានិងបុគ្គលិកផ្សេងទៀត ព្រមទាំងបញ្ហានានាដែលទាក់ទងនឹងការបង្កើតនិងផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុសម្រាប់តុលាការនេះ ។

សម្តេច ហ៊ុន សែន បានមានប្រសាសន៍ថា ជាការសមស្របណាស់ដែលថា អ្នកជំនាញការនឹងជួយកម្ពុជាក្នុងការធ្វើសេចក្តីព្រាងច្បាប់ដើម្បីធានាថាច្បាប់នេះនឹងត្រឹមត្រូវតាមគំរូបទដ្ឋានអន្តរជាតិ ។ ខ្ញុំបានសន្យាថានឹងនាំយកប្រសាសន៍របស់សម្តេច ហ៊ុន សែន ទៅកាន់អគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ហើយស្នើឲ្យមានការផ្តល់នូវជំនាញការបែបនេះ ។ ការចូលរួមជ្រៅជាងនេះទៀតរបស់អង្គការសហប្រជាជាតិក្រោយពីមានសេចក្តីព្រាងច្បាប់ អាស្រ័យទៅលើបញ្ហាថាតើមានការយល់ព្រមទៅលើការបញ្ចូលការធានាឲ្យមានការគោរពគំរូបទដ្ឋានអន្តរជាតិដែរឬទេ ។

ខ្ញុំបានរាយការណ៍អំពីការវិវឌ្ឍទាំងនេះនៅក្នុងអង្គប្រជុំនៅអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ មានការិយាល័យនៅទីក្រុងញូវយ៉ក នៅថ្ងៃទី២៨ ខែឧសភា និងថ្ងៃទី១០ ខែមិថុនា ហើយឲ្យយោបល់ថា សូមជួយផ្តល់ជំនាញការមករដ្ឋាភិបាលកម្ពុជាផងដើម្បីធ្វើកិច្ចការនេះ ។ ចំពោះបញ្ហាដ៏វិញករណីនេះ និងជាពិសេសប្រតិកម្មរបស់រដ្ឋាភិបាលក្នុងខែមីនា មានការសម្រេចថាយើងគួរតែរកការបញ្ជាក់ច្បាស់លាស់មួយទៀតពីសម្តេចនាយករដ្ឋមន្ត្រី អំពីគោលបំណងរបស់សម្តេចផ្ទាល់ ។

ខ្ញុំបានផ្ញើជូនសម្តេច ហ៊ុន សែន នូវកំណត់សម្គាល់មួយសង្ខេបពីការយល់ឃើញរបស់ខ្ញុំចំពោះកិច្ចប្រជុំរបស់យើងនៅក្នុងខែឧសភា រួមទាំងសំណើរបស់សម្តេចដែលស្នើឲ្យមានអ្នកជំនាញការមកជួយកម្ពុជាក្នុងការធ្វើសេចក្តីព្រាងច្បាប់ដើម្បីធានាឲ្យប្រាកដថាច្បាប់នេះនឹងត្រឹមត្រូវតាមតម្រូវការអន្តរជាតិ ។ សម្តេច ហ៊ុន សែន បានសរសេរឆ្លើយតបវិញថា សម្តេចយល់ព្រមហើយ ។ ប៉ុន្តែសម្តេចបន្ថែមទៀតថា សម្តេចចង់ឲ្យអ្នកជំនាញការទាំងនេះមកកម្ពុជាឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ។

ការិយាល័យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់បានសន្យាថានឹងមកធ្វើការវិភាគទៅលើតម្រូវការផ្នែកច្បាប់ទាក់ទងនឹងតុលាការ“ចម្រុះ” ។ ការណ៍នេះនឹងជួយបង្ហាញផ្លូវសម្រាប់ក្រុមអ្នកជំនាញការដែលនឹងធ្វើដំណើរមកដល់ភ្នំពេញ ។ ការសម្រេចនេះនឹងរួមបញ្ចូលប្រការនានាទាក់ទងនឹងមូលដ្ឋានច្បាប់តុលាការ ច្បាប់មូលដ្ឋាន បុលកុន្ទិកៈ ការជ្រើសតាំងចៅក្រមនិងព្រះរាជអាជ្ញា ការធានាចាប់ខ្លួនមេដឹកនាំខ្មែរក្រហមតាមសំណើរបស់តុលាការ និងរកឲ្យឃើញនូវតម្រូវការចាំបាច់នានាដែលជាការរួមវិភាគទានដល់ផ្នែកថវិកានិងបុគ្គលិក ។

ការវិភាគរបស់ក្រុមអ្នកជំនាញការទៅលើច្បាប់ជាតិនិងគំរូបទដ្ឋានអន្តរជាតិ បានផ្តល់ជាសេចក្តីណែនាំដ៏មានប្រយោជន៍ចំពោះចំណុចមួយចំនួនជាអាទិ៍ ដែនអាជ្ញាយុកាលច្បាប់នៅក្នុងក្រមព្រហ្មទណ្ឌច្បាស់ដែលទាក់ទងនៅក្នុងឆ្នាំ១៩៧៥ (នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច) និងការអនុវត្តអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ (ដូចជាបញ្ហាថាតើមាន“ចេតនា”ដែរឬទេ) ព្រមទាំងគំរូបទដ្ឋានទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ(ដូចជាថាតើឧក្រិដ្ឋកម្មទាំងនេះអនុវត្តបានក្នុងករណីក្រៅពីជម្លោះប្រដាប់អាវុធដែរឬទេ) ។ **(នៅមានត)**

**ថូម៉ាស់ ហាម៉ាបឺក**

# សុបិនឬការពិត?

មានពេលខ្លះខ្ញុំឃើញស្រមោលស្តុំៗ ដែលមានទ្រង់ទ្រាយជាយាយចាស់ម្នាក់ ប៉ុន្តែខ្ញុំមិនដឹងច្បាស់ថាតើយាយនោះជានរណាទេ ។ ខ្ញុំមានអារម្មណ៍ថាមានមនុស្សជាច្រើនកំពុងនៅជុំវិញខ្ញុំពេលខ្ញុំកំពុងគេង ប៉ុន្តែនៅពេលដែលខ្ញុំភ្ញាក់ឡើង ខ្ញុំគ្មានឃើញអ្វីទាំងអស់ ។ ដំណើរជីវិតទៅកាន់អនាគតមានសភាពរដាក់រដុបណាស់ ដោយអារម្មណ៍រន្ធត់ដែលបណ្តាលមកពីសកម្មភាពមួយចំនួនទៀតពីអតីតកាល ។

ខ្ញុំឈ្មោះ លាង ស៊ីដនី បច្ចុប្បន្នរស់នៅរដ្ឋម៉ាសាឈូសេត សហរដ្ឋអាមេរិក ។ ឈ្មោះកំណើតរបស់ខ្ញុំគឺ លាប ។ ឪពុកខ្ញុំឈ្មោះ លាង ម្តាយឈ្មោះ ប៉ាក់ ។ ខ្ញុំកើតនៅឆ្នាំ១៩៧០ ក្នុងគ្រួសារកសិករមួយនៅភូមិតាទក ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ គួរឲ្យសោកស្តាយណាស់ ខ្ញុំពុំបានចាំអ្វីច្បាស់សោះក្នុងអំឡុងពេលមុនឆ្នាំ១៩៧៥ ។ អ្វីៗទាំងអស់ហាក់ដូចជាមានការលាយឡំដោយភាពសោកសៅប្រៀបដូចជាដើកបន្ទោរមួយភ្លែតក្នុងពេលមានព្យុះភ្លៀង ហើយត្រូវខ្យល់កួចយកទៅបាត់ ដូចជាការជិះរទេះខ្វែកាបនៅលើជ្រលងភ្នំអ៊ីចឹងដែរ ។

ការបន្តរស់ជាមនុស្សពេញវ័យក្នុងខណៈខ្លួនកំពុងស្ថិតក្នុងវ័យ៩ឆ្នាំពិតជាពិបាកណាស់ ។ ខ្ញុំប៉ិនប្រសប់ខាងដើររកអាហារសម្រាប់គ្រួសារខ្ញុំ ។ ខ្ញុំប៉ិនរកកង្កែបណាស់នៅរដូវប្រាំង ។ ខ្ញុំនៅចាំបានថា មានពេលមួយនោះខ្ញុំចាប់បានកង្កែបមួយយ៉ាងធំនៅក្នុងបឹងមួយដែលមានម្ចាស់ ។ ឃើញដូច្នោះម្ចាស់បឹងនោះក៏ដេញចាប់ខ្ញុំ ហើយអ្នកភូមិក៏រួមគ្នាសម្រុកដេញចាប់ខ្ញុំដែរ ។ នៅពេលមកដល់ផ្ទះភ្លាមស្រាប់តែមានអ្នកជិតខាងម្នាក់មកសុំខ្ញុំថា «ប្តីខ្ញុំជិតដាច់ពោះស្លាប់ហើយ តើឲ្យខ្ញុំសុំកង្កែបមួយមកបានទេ?» ។ ខ្ញុំក៏យល់ព្រម ហើយក៏ហុចកង្កែបតូចមួយដែលខ្ញុំចាប់បាននៅថ្ងៃនោះឲ្យគាត់ ។ ពេលនោះគាត់មិនព្រមយកហើយទារយកកង្កែបធំ ។ ខ្ញុំតឹងចិត្តមែនទែន ប៉ុន្តែមិនដឹងធ្វើយ៉ាងដូចម្តេច ។ ចុងក្រោយខ្ញុំក៏យល់ព្រមឲ្យកង្កែបធំទៅគាត់ ។ គាត់និងប្តីក៏បានរស់រានមានជីវិតរហូតមក ។ សព្វថ្ងៃនេះប្តីប្រពន្ធទាំងពីរនាក់រស់នៅរដ្ឋ វីហ្សីនីញ៉ា សហរដ្ឋអាមេរិក ។

ខ្ញុំសប្បាយចិត្តណាស់ដែលនៅចាំរឿងល្អៗបែបនេះ ។ មានពេលខ្លះនៅពេលខ្ញុំបិទភ្នែក ខ្ញុំឮសូរសម្រឹបជើងជនរងគ្រោះនៅក្បែរផ្ទះដែលខ្មែរក្រហមកំពុងតែបណ្តើរ ហើយត្រូវបិទមាត់ជិត ។ ជនរងគ្រោះទាំងនោះចង់ស្រែកក៏ស្រែកមិនរួច មានតែខំបម្រះប្រាសយកតែអាយុប៉ុណ្ណោះ ។ ខ្ញុំឮសំលេង«ភូសៗ» ហើយ «អ៊ួយ៎» ហើយក៏ស្ងាត់ទៅវិញនៅក្នុងវាលស្រែងងឹតមើលអ្វីពុំយល់ ។ តើនេះជាសំលេងវាយមនុស្សឬ? ខ្ញុំពុំអាចដឹងបានទេ តែអ្នកភូមិបាត់មុខជាបន្តបន្ទាប់ពីភូមិ(រលួស) ។ ខ្ញុំភិតភ័យខ្លាំងណាស់ ។ ចចកលូពេញភូមិជារៀងរាល់យប់ ហើយក៏ស្ងាត់ទៅវិញនៅពេលទៀបភ្លឺ ។ ខ្ញុំមានអារម្មណ៍មិនស្រួលព្រោះបានឃើញមុខពុកម៉ែយូរៗម្តង ដោយសារគាត់ជាប់រវល់ធ្វើការងាររបស់គាត់ ។

កាលនោះខ្មែរក្រហមដាក់ខ្ញុំនៅកងកុមារដែលមានអាយុ ៦-៧ឆ្នាំ ហើយអនុញ្ញាតឲ្យទៅជួបមុខឪពុកម្តាយតែម្តងប៉ុណ្ណោះក្នុងមួយខែ ។ យើងមិនអាចបញ្ចេញអារម្មណ៍ផ្ទាល់ខ្លួនឲ្យអ្នកដទៃដឹងឡើយ ។ គ្មានអ្នកណាហ៊ានយំសើចឬរំភើបរីករាយឡើយនៅពេលជួបឬបែកពីឪពុកម្តាយ ។ រៀងរាល់ថ្ងៃមេក្រុមនាំកុមារទៅប្រមូលអាចម៍គោនិងជីយកទៅដាក់ស្រែ ។ ម៉ោងធ្វើការងារគឺចាប់ពីម៉ោង៦កន្លះព្រឹកដល់ម៉ោង៧យប់ទើបត្រឡប់មកវិញ ប៉ុន្តែខ្មែរក្រហមឲ្យកុមារដេករហូតដល់ម៉ោងប្រហែល៩យប់ទើបមកចូលប្រជុំជីវភាព ឬ«មកអប់រំកសាងស្មារតី» ។

ពុកម៉ែដើរបណ្តើរកាន់ដៃកូនបណ្តើរ ហើយនិយាយអប់រំកូនអំពីវិធីជីវិតដែលមនុស្សម្នាក់ៗគួរទទួលយក ។ ខ្ញុំអន់ចិត្តមែនទែនដែលមិនបានចាំមុខរបស់ឪពុកខ្ញុំ ។ តើគាត់ជាអ្នកណា? ហើយធ្វើអ្វីខ្លះ? អនុស្សាវរីយ៍ដែលខ្ញុំនៅចាំបានគឺកន្លែងដែលឃើញគាត់គ្របដណ្តប់ក្រណាត់ស ។ នេះពិតជារឿងអកុសល ប៉ុន្តែជាអ្វីដែលខ្ញុំនៅចាំបាន ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅពេលព្រឹកឡើងអាកាសធាតុត្រជាក់ណាស់ ។ ខ្ញុំឃើញផ្សែងហុយ

ចេញពីក្អក់ក្អើន និងឃើញមានចុះអ័ព្ទទៀតផង ។ ប្អូនស្រីខ្ញុំមានអាយុទើបតែប្រាំឆ្នាំប៉ុណ្ណោះ ហើយបានស្រែកយំយ៉ាងខ្លាំង ។ ឯម៉ែវិញរវល់រើរកខ្ញុំប្រវេប្រវាទាំងទឹកភ្នែកហូររហាម ។ មើលទៅគាត់អស់កម្លាំងខ្លាំងណាស់ ។ ខ្ញុំមិនយល់សោះ ហើយមានអារម្មណ៍រន្ធត់ឥតឧបមា ។ ឪពុកខ្ញុំបានដាច់ខ្យល់ស្លាប់បាត់ទៅហើយ ។ សាកសពត្រូវបានតម្កល់ទុកនៅខាងមុខផ្ទះពេញមួយថ្ងៃដើម្បីឲ្យបងប្អូននិងអ្នកជិតខាងចូលមកអុជធូបសំពះ ។ អ្នកស្រុកអ្នកភូមិដើរទៅដើរមកមិនហ៊ាននៅយូរទេ ព្រោះខ្លាចធ្វើខុសនឹងវិន័យរបស់ខ្មែរក្រហម ។

អ្នកស្រុកអ្នកភូមិក៏ត្រឡប់ទៅផ្ទះរៀងៗខ្លួន ហើយអ្វីៗក៏ស្ងប់ស្ងាត់ទៅវិញរហូតក្បាលព្រលប់ ។ នៅពេលព្រះអាទិត្យអស្តង្គត ទំព័រជីវិតគ្រួសារខ្ញុំនិងខ្ញុំផ្ទាល់ក៏បានផ្លាស់ប្តូរដែរ ។ ព្រលប់ចូលមកដល់ភ្លាម បងប្រុសខ្ញុំក៏ចាប់ផ្តើមត្រដរខ្យល់ ។ ហេតុអ្វីទៅ? នៅពេលរាត្រីឈានចូលមកដល់ក៏ផ្តាច់ជីវិតបងប្រុសខ្ញុំតែម្តង ។ គាត់រឹងដៃរឹងជើងរឹងសព្វប្រាណទាំងអស់ ។ គាត់ក៏លាចាកលោកនៅយប់នោះ ។ ខ្ញុំមិនយល់ទាល់តែសោះ ហេតុអ្វីបានជាគាត់ស្លាប់? ប៉ុន្តែអ្វីដែលខ្ញុំដឹងគឺខ្ញុំបានមើលឃើញមនុស្សពីរនាក់គ្របក្រណាត់សហើយបានបាត់មុខរហូត ។ ឪពុកខ្ញុំស្លាប់ពេលព្រឹក រីឯបងប្រុសខ្ញុំដាច់ខ្យល់ស្លាប់នៅពេលយប់ ។ ថ្ងៃដែលមានអាកាសធាតុត្រជាក់នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ បានឆក់យកជីវិតឪពុកនិងបងប្រុសខ្ញុំ ។ ចាប់ពីពេលនោះមក ខ្ញុំជាកូនប្រុសតែម្នាក់ឯងគត់ដែលត្រូវថែទាំម្តាយនិងប្អូនស្រី ។ គិតទៅជីវិតពិតជាឃោរឃៅនិងអយុត្តិធម៌ណាស់ ។

ចាប់ពីថ្ងៃនោះមកខ្ញុំលែងខ្លាចស្លាប់ទៀតហើយ ។ ខ្ញុំចាំថាមានពេលមួយ ម៉ែប្រើខ្ញុំឲ្យទៅដាស់យាយមកពិសាបាយល្ងាច ។ នៅពេលខ្ញុំទៅដល់ជិតយាយ ខ្ញុំធុំក្លិនម្យ៉ាងដែលខ្ញុំធ្លាប់ស្គាល់ ។ ខ្ញុំដាស់គាត់មិនក្រោកសោះព្រោះគាត់បានស្លាប់ក្នុងដំណេកស្ទើរតែមួយថ្ងៃទៅហើយ ។ ខ្ញុំពុំដឹងធ្វើយ៉ាងម៉េចទេ ។ ខ្ញុំក៏អង្គុយនៅក្បែរគាត់មួយស្របក់ ។

យើងជាកសិករសាមញ្ញក៏ពិតមែន តែពូនិងមីងខ្ញុំធ្លាប់បានរៀននៅវត្ត នៅប្រទេសបារាំង និងនៅប្រទេសដទៃផ្សេងទៀត ។ ពូខ្ញុំម្នាក់ឈ្មោះ ពូតុ បានរៀនសូត្រភាសាបារាំងនិងភាសាខ្មែរ ។ ថ្ងៃមួយមនុស្សជាច្រើនស្លៀកពាក់ខ្មៅដើរមកដល់ផ្ទះគាត់ ហើយប្រាប់ថាយកគាត់ទៅរៀនសូត្រនៅបរទេស ។ នៅពេលចេញដំណើរ ខ្មែរក្រហមម្នាក់ប្រាប់មីងខ្ញុំថា "មើលមុខគាត់ឲ្យហើយទៅ ...នេះគឺជាពេលចុងក្រោយហើយដែលមិត្តអាចជួបគាត់" ។ តាំងពីពេលនោះមកពូខ្ញុំមិនដែលត្រឡប់មកលេងប្រពន្ធកូនទាល់តែសោះ ។ ប្រហែលជា១ខែក្រោយមក អ្នកភូមិម្នាក់ប្រាប់មីងខ្ញុំថា គាត់ឃើញ ពូតុ ចងកនៅលើដើមឈើមួយ ។ ប៉ុន្មានខែក្រោយមកទៀតក៏មានមនុស្សមកយកមីងខ្ញុំទៅទៀត ។ រហូតមកដល់បច្ចុប្បន្នមិនទាន់មានដំណឹងកូនស្រីរបស់គាត់នៅឡើយទេ ។ នាងនៅឯកោកណ្តោចកណ្តែងម្នាក់ឯងគត់ ។

ខ្ញុំនៅចងចាំហេតុការណ៍នេះច្បាស់ណាស់ ។ ខ្ញុំមិនអាចបំភ្លេចរឿងនេះបានទេ ។ ជួនកាលនឹកឡើងគួរឲ្យឈឺចាប់ណាស់ ។ ខ្ញុំពួនយំតែម្នាក់ឯងក៏មានដែរ ។ ពេលខ្លះទៀតខ្ញុំឃើញទីកន្លែងកើតហេតុ ហេតុការណ៍ និងពេលវេលា ប៉ុន្តែមិនច្បាស់ក្នុងចិត្តសោះថានោះគឺជាអ្វី ។ តើអ្វីដែលរៀបរាប់នេះជាសុបិនឬជាការពិត? ខ្ញុំមិនដែលលើករឿងនេះមកនិយាយជាមួយម៉ែទេ ព្រោះខ្លាចធ្វើឲ្យគាត់ឈឺចាប់សាជាថ្មី ។ ឆ្នាំមុន(២០០០) តាមរយៈកិច្ចសម្ភាសន៍មួយខ្ញុំដឹងថា នៅជំនាន់ខ្មែរក្រហម ម៉ែខ្ញុំបានបាត់បង់ញាតិសន្តានអស់១៧នាក់ ។ ម៉ែខ្ញុំបាននិងកំពុងទទួលរងនូវការឈឺចាប់នៅក្នុងចិត្តតែម្នាក់ឯងអស់រយៈកាលជាង២០ឆ្នាំហើយ ។ រាល់ពេលឮសំលេងកាំជ្រួច សំឡេងផ្ទុះកង់ឡាន ឬសំឡេងរ៉ៃគ្គុងគ្គាំង ម្តាយខ្ញុំតែងតែនឹកដល់អនុស្សាវរីយ៍អតីតកាលដ៏សែនឈឺចាប់ទាំងអស់ដែលបានកើតឡើងចំពោះគាត់ ។ ម៉ែខ្ញុំនិងខ្ញុំជាពលរដ្ឋអាមេរិកកាំង ប៉ុន្តែមិនអាចប្រារព្ធទិវាឯករាជ្យថ្ងៃទី៤ខែកក្កដាដូចអ្នករាល់គ្នាទេ ។

គ្រប់ស្ត្រីទាំងអស់ដែលខ្ញុំស្គាល់ មានតែម៉ែខ្ញុំទេដែលខ្លាំងក្លា ។ គាត់ខំបីបាច់ថែរក្សាកូនទាំងពីរទោះជាលំបាកវេទនាឈឺចាប់យ៉ាងណាក៏ដោយ ។ ដោយជឿលើព្រះ យើងខ្ញុំតស៊ូដើរទាំងយប់ទាំងថ្ងៃនិងដេកតាមផ្លូវឆ្លងកាត់ប្រទេសកម្ពុជាទម្រាំតែដល់ប្រទេសថៃ ។ យើងបានឃើញផ្ទាល់នឹងភ្នែក មានអ្នកខ្លះជាន់មីនស្លាប់ អ្នកខ្លះអត់អាហារដាច់ពោះស្លាប់ ហើយអ្នកខ្លះទៀតរបិតរបៃងើបមិនរួច ។ ដោយមានការតាំងចិត្តមោះមុត

តស៊ូព្យាយាមរបស់គាត់ យើងទាំងអស់គ្នាក៏បានមកដល់ជំរំខោអ៊ីដាង ប្រទេសថៃ ។

ខ្ញុំមានអារម្មណ៍សោកសៅជង ខឹងផង ។ វ័យកុមារនិងយុវភាពរបស់ខ្ញុំត្រូវបានដកហូតអស់ ហើយជំនួសវិញដោយដំណើរមិនពិតប្រាកដមួយ ។ ខ្ញុំមិនមែនជាមនុស្សតែម្នាក់ដែលរងនូវការប្រែប្រួលក្នុងវិថីជីវិតនោះទេ ។ ខុះអ៊ី មានមនុស្សជាច្រើននាក់ទៀតដែលបានរងទទួលនូវការឈឺចាប់ដូចខ្ញុំដែរ ។ មេដឹកនាំខ្មែរក្រហមគួរតែទទួលខុសត្រូវចំពោះការបាត់បង់ជីវិតនៃញាតិសន្តានបងប្អូនជនរួមជាតិនិងភូមិកំណើតរបស់ខ្ញុំ ។ គ្មានជីវិតអ្នកណាល្អជាងអ្នកណាទេ ។ **លាង ស៊ីដនី**

*ជុំគិរី ថ្ងៃទី១៧ កក្កដា ឆ្នាំ២០០១*

## សូមគោរពចូលមកលោកនាយកនិពន្ធ ឆាំង យុ នៃទស្សនាវដ្តីស្វែងរកការពិត ដោយសេចក្តីគោរពដ៏ថ្លៃថ្លាលជ្រៅបំផុត

ខ្ញុំ តុង វ៉ា ជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ បម្រើការនៅអនុវិទ្យាល័យជុំគិរី ស្រុកជុំគិរី ខេត្តកំពត ។

បន្ទាប់ពីខ្ញុំបានឃើញនិងបានអានទស្សនាវដ្តីស្វែងរកការពិតដែលបានពណ៌នានិងរៀបរាប់យ៉ាងក្បោះក្បាយពិស្តារស្តីពីប្រវត្តិការណ៍ផ្សេងៗ ព្រមទាំងបានភ្ជាប់នូវរូបភាពដ៏សែនខ្លោចផ្សាក្នុងសម័យ ប៉ុល ពត កន្លងមកនេះ បានធ្វើឲ្យអារម្មណ៍ខ្ញុំ ចិត្តខ្ញុំសែនក្តុកក្តួលឈឺចាប់ជាអនេកប្បការរកអ្វីមកប្រៀបផ្ទឹមគ្មាន ចំពោះអំពើមនុស្សឃាតអមនុស្សធម៌យ៉ាងសាហាវព្រៃផ្សៃដែលមនុស្សជាតិពុំនឹកស្មានដល់ទាល់តែសោះ ។

ក្រោមទម្ងន់នៃអំណាចផ្តាច់ការមហាហ្វាស៊ីសនេះ ខ្ញុំបាទក៏បានបាត់បង់ពូម្នាក់និងបងម្នាក់ដែលគាត់ទាំងពីរធ្វើជាគ្រូបង្រៀន ដោយសារអំពើមនុស្សឃាតរបស់ពួកខ្មែរក្រហម យកទៅសម្លាប់ក្នុងរណ្តៅតែមួយនៅវត្តស្រែក្នុង ហៅវត្តពោធិវង្ស ។ ចំណែកពូនិងបងៗផ្សេងទៀត មិនដឹងជាពួកវាយកទៅសម្លាប់នៅកន្លែងណាមួយឡើយ ។ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះ ខ្ញុំសែនឈឺចាប់ណាស់ សោកស្តាយណាស់ ដោយសារអ្វីដែលហៅថា «វែកមុខមាត់ពិតនៃពួកឧក្រិដ្ឋជនតាមផ្លូវតុលាការយុត្តិធម៌ពិតប្រាកដនោះ» ដែលនេះហើយគឺជាបំណងប្រាថ្នាចង់បានបំផុត ទាំងអ្នកដែលបានស្លាប់ទៅ ទាំងបងប្អូនឪពុកម្តាយសាច់ញាតិ កំពុងទន្ទឹងរង់ចាំយ៉ាងអន្ទះសានិងពុំអាចបំភ្លេចបានឡើយ ទោះបីជាប្រវត្តិការណ៍ឃ្លាតឆ្ងាយយូរឆ្នាំមកហើយក្តី ឃាតករកាន់តែចាស់ជរាណាស់ហើយយ៉ាងណាក៏ដោយ ។

សព្វថ្ងៃនេះ ខ្ញុំមានអារម្មណ៍អរជងភ័យជងជក់ក្នុងចិត្តជាប់ជានិច្ច ខ្ញុំអរដោយបានស្តាប់បានឮថា រដ្ឋសភាបានអនុម័តច្បាប់សម្រាប់បង្កើតតុលាការកាត់ទោសខ្មែរក្រហមរួចរាល់អស់ហើយ ខ្ញុំភ័យ ខ្ញុំព្រួយ ព្រោះខ្លាចការកាត់ក្តីខ្មែរក្រហមចេះតែបន្តពន្យារពេលយូរតទៅទៀត មិនបានកាត់ទោសឲ្យបានឆាប់ៗនៅពេលខាងមុខនេះ ។

ក្នុងក្តីសង្ឃឹមលើយុត្តិធម៌ សូមឲ្យឯកសារស្វែងរកការពិតរបស់លោកក្លាយជាសាក្សីតឹកតាងមួយយ៉ាងសំខាន់ដើម្បីបំភ្លឺនិងលាតត្រដាងពីរឿងពិតនៃរបបវាលពិឃាតនាពេលតុលាការចាប់ផ្តើមដំណើរកាត់ក្តីពួកមេខ្មែរក្រហមធំៗនៅពេលដ៏ខ្លីខាងមុខនេះ ។ សូមមេត្តាផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ និងបញ្ចប់ការឈឺចាប់បិទមុខដ៏យូរឆ្នាំកន្លងមកនេះឲ្យបានឆាប់បំផុត ។

នៅទីបញ្ចប់នេះ ខ្ញុំសូមឲ្យលោកនិពន្ធនាយកព្រមទាំងសហការីទាំងអស់បានទទួលនូវលទ្ធផលជាផ្លែផ្កាបន្តឥតឈប់ ក្នុងបុព្វហេតុដ៏ធំធេងជាប្រវត្តិសាស្ត្រសម្រាប់ជនកម្ពុជាគ្រប់រូបនិងមាតុភូមិជាទីស្នេហានៃយើងទាំងអស់គ្នាទាំងបច្ចុប្បន្ននិងទៅអនាគត ។

សូមលោកនាយកមេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។ **តុង វ៉ា**

# ដំណឹងស្វែងរកឪពុក

នាងខ្ញុំឈ្មោះ ឃុន កុលភាវតី សព្វថ្ងៃរស់នៅខេត្តស្វាយរៀង

**សូមគោរពចូលមក**

លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលស្វែងរកការពិត ជាទីគោរព

សូមលោកប្រធានមេត្តាជួយផ្សព្វផ្សាយដំណឹងស្វែងរកលោកឪពុកឲ្យនាងខ្ញុំដោយក្តីអនុគ្រោះផង ។

ឪពុកនាងខ្ញុំឈ្មោះដើមគឺ ថោង ពឿន (ឆ្នាំកំណើតមិនចាំ) ទីកំណើតនៅភូមិពោធិ៍ (ហៅភូមិព្រៃសង្កែ) ឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។ លុះពេលចូលធ្វើបដិវត្តន៍មានឈ្មោះ ថោង ស៊ុន ហើយក្រោយថ្ងៃរំដោះ ១៧ មេសា ១៩៧៥ នាងខ្ញុំបានដឹងថាគាត់មានតួនាទីជាអនុប្រធានកងវរសេនាតូចលេខ៧៥ កងទ័ពការពារព្រំដែនខេត្តស្វាយរៀង ស្ថិតនៅក្នុងតំបន់២៣ ភូមិភាគបូព៌ា ។ បើតាមពត៌មានច្បាស់ការណ៍ ឪពុកនាងខ្ញុំត្រូវចាប់ខ្លួននៅក្នុងក្រុងស្វាយរៀងនាអំឡុងឆ្នាំ១៩៧៦ ក្នុងពេលអង្គការហៅឲ្យមកប្រជុំ ។ អាស្រ័យហេតុដូចបានជម្រាបជូននេះ សូមលោកប្រធានមេត្តាជួយស្រាវជ្រាវរកឈ្មោះឪពុករបស់នាងខ្ញុំផង និងសូមអំពាវនាវដល់អស់លោកដែលជាអតីតទាហានក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយដែលបានរស់នៅសព្វថ្ងៃនេះ បើបានស្គាល់ឈ្មោះនិងបានដឹងអំពីដំណើររឿងនេះ សូមលោកមេត្តាផ្តល់ពត៌មានឲ្យនាងខ្ញុំបានដឹងតាមរយៈទស្សនាវដ្តីស្វែងរកការពិតផង ។ សូមអរគុណ ។



វិចិត្រករៈ វ៉ាន់ ណាត
អតីតអ្នកទោសមន្ទីរស-២១

## កំណាព្យខ្មែរក្រហមៈ ប្តេជ្ញាប្រែក្លាយមាតុភូមិកម្ពុជាដ៏ឧត្តមជាសួនស្រូវនិងសួនដំណាំស្រស់បំព្រង

ឱ! កម្ពុជាដ៏ឧត្តម
ពេលមានទុក្ខធំព្រោះចក្រពត្តិ
សក្តិភូមិនាយទុននិងពួកក្បត់
សង្កត់រឹបជាន់ជាប់បន្ត ។
ប្រជាជាតិនិងប្រជាជន
វេទនាពេកពន់ច្រើនតំណ
ធ្លាក់ខ្លួនខ្ញុំគេហើយក្រីក្រ
រស់ទាំងត្រដរគ្មានខ្លឹមសារ ។
បក្សកម្ពុជាដ៏រុងរឿង
ថ្កុំថ្កើងភ្លឺស្វាងមហាអស្ចារ្យ
ដឹកនាំសង្គមកម្ពុជា
ឲ្យប្រែក្លាយជាមានសមភាព ។
សង្គមថ្មីនេះល្អបវរ
យុត្តិធម៌ស្អាតស្អំគ្មានអ្វីប្រៀប
គ្មានមានគ្មានក្រគ្មានថោកទាប
គ្មានត្បៀតគ្មានកៀបគ្មានជិះជាន់ ។
យើងខ្ញុំយុវកសិករកម្មករ
កងទ័ពអរពេកពន់
ព្រោះយើងខ្ញុំបានរួចទុក្ខធ្ងន់
មានវាសនាទាន់សង្គមថ្មី ។
យើងខ្ញុំប្តេជ្ញាប្រែមាតុភូមិ
កម្ពុជាឧត្តមឲ្យប្រិមប្រិយ
ជាស្រូវ ពោត ចេក ដំឡូង ផ្លែ
កប្បាស ក្រចៅ មនពេញពាស ។
ប្រែស្រែមានភ្លឺប្រឡាយថ្មី
ជាស្រូវពេញផ្ទៃពាសដេរដាស
ស្រូវស្រាលស្រូវធ្ងន់ស្រូវកន្ទះ
លាស់ស្រស់ស្អេកស្កះគ្រប់រដូវ ។
ប្រែដីក្បែរភូមិដីទួលខ្ពស់
ក្បែរភ្នំក្បែរជ្រោះក្បែរមាត់ផ្លូវ
ជាសួនបន្លែម្ទេស ត្រប់ ត្រាវ
ដំរ ខ្ទឹម ម្រះព្រៅ ខ្ទី ល្ង រំដេង ។
ក្តាតល្ពៅត្រសក់ឃ្លោកត្រឡាច
ជ្ជីស្ពៃសណ្តែកម្រះមមាញ
ឲ្យស្រស់បំព្រងគ្រប់កន្លែង
ពេញដីធំធេងយើងគ្រប់គ្រា ។
ចំណែកយើងយើងខាងកងទ័ព
ដៃក្តាប់អាវុធចាំការពារ
ហើយចុះរួមបង្កើនផលា
ជាមួយប្រជាជនប្រុសស្រី ។
មែនហើយ! ឥឡូវមាតុភូមិយើង
ប្រែស្រស់បំព្រងឡើងប្រិមប្រិយ
យើងសែនពេញចិត្តពេញថ្លើមក្រៃ
សម្រុកយប់ថ្ងៃកាន់ទៅឡើង ។
យើងខ្ញុំប្តេជ្ញាប្រយុទ្ធទៀត
រួមសាងសង្គមជាតិឲ្យថ្កុំថ្កើង
សំបូរសប្បាយ ហើយរុងរឿង
អត្តភាពខ្ពស់ឡើងរៀងរហូត ។

**(ដកស្រង់ចេញពីសៀវភៅ យុវជននិងយុវនារីបដិវត្តលេខ៨ ខែសីហា ១៩៧៦)**

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 20 August 2001.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance;
Canadian International Development Agency (CIDA) through the Civil Society Fund, the Swedish International Development Cooperation Agency(Sida);
the Royal Danish Government and the Royal Netherlands Government, *The Hague*.